**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស (អ.ប.ជ ៧៥)

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គបុរេជំនុំជម្រះ

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី០៦ ខែ ធ្នូ ឆ្នាំ ២០១០

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 28-Dec-2010, 13:10
CMS/CFO: Phok Chanthan

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ អង្គជំនុំជម្រះ : សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

# សារណាឆ្លើយតប ទៅនឹងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ

---

ដាក់ដោយ៖

**សហមេធាវីរបស់លោក អៀង សារី៖**

អាង ឧត្ដម

Michael G. KARNAVAS

ផ្ញើជូន៖

**ចៅក្រមអង្គបុរេជំនុំជម្រះ៖**

ចៅក្រម ប្រាក់ គឹមសាន ប្រធាន

ចៅក្រម ន័យ ផុល

ចៅក្រម ហួត វុទ្ធី

ចៅក្រម Catherine MARCHI-UHEL

ចៅក្រម Rowan DOWNING

**សហព្រះរាជអាជ្ញា៖**

ជា លាង

Andrew CAYLEY

**ក្រុមមេធាវីការពារក្ដីទាំងអស់**

លោក អៀង សារី តាមរយៈសហមេធាវីរបស់គាត់ (“មេធាវីការពារក្តី”) សូមដាក់ការឆ្លើយតបនេះទៅនឹងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ (“ចម្លើយតប”)[1]។ ការឆ្លើយតបនេះ នឹងលើកឡើងនូវបញ្ហានានា ដែលមាននៅក្នុងចម្លើយតប ដែលពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍របស់ លោក អៀង សារី[2] ទៅតាមលំដាប់លំដោយលើកឡើងដោយការិយាល័យសហព្រះរាជអាជ្ញា (ក.ស.ព)។ ក.ស.ព ខកខានមិនបានផ្តល់សំអាងហេតុច្បាស់លាស់ ឬមូលដ្ឋានសំអាងផ្លូវច្បាប់ពាក់ព័ន្ធដើម្បីគាំទ្រដល់ការអះអាងរបស់ខ្លួនឡើយ។ ដោយសារតែមានការកំណត់ចំនួនទំព័រនៃការដាក់ការឆ្លើយតប មេធាវីការពារក្តីមិនបានលើកឡើងគ្រប់ចំណុចវិការៈទាំងអស់ដែលមាននៅក្នុងចម្លើយតបនោះទេ ហើយមេធាវីការពារក្តីរក្សាសិទ្ធិរបស់ខ្លួន ដើម្បីឆ្លើយតបនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។

## I. សេចក្តីសង្ខេបនៃចម្លើយតប

១. ក.ស.ព បានលើកអំណះអំណាងដូចខាងក្រោមនេះ៖

ក. បណ្តឹងឧទ្ធរណ៍មិនអាចទទួលយកបាន ដោយសារតែបណ្តឹងឧទ្ធរណ៍លើកឡើងនូវបញ្ហាដែលមិនមែនទាក់ទងនឹងយុត្តាធិការ ផុតអាជ្ញាយុកាល និង/ឬផុតរលត់ដោយសារអាជ្ញាអស់ជំនុំ។

ខ. សហចៅក្រមស៊ើបអង្កេតអាចប្រើប្រាស់ភស្តុតាងព្រឹត្តិការណ៍ ដែលស្ថិតនៅក្រៅយុត្តាធិការពេលវេលានៃ អ.វ.ត.ក។

---

[1] រឿងក្តី អៀង សារី សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អវតក/កសចស(អ.ប.ជ៧៥) ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំដោះស្រាយ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១០ ឯកសារ D427/1/17 ERN: 00626531-00626650 ។

[2] *ករណីអៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អវតក/កសចស(អ.ប.ជ៧៥) បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០ ឯកសារD427/1/6 ERN: 00617486-00617631 (បណ្តឹងឧទ្ធរណ៍)។

គ. អ.វ.ត.ក មានយុត្តាធិការលើរូបបុគ្គលលើ លោក អៀង សារី ដែលព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោស មិនបានរារាំងនោះទេ ឬមិនបានរារាំងដោយគោលការណ៍*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ (ne bis in idem)*។

ឃ. អ.វ.ត.ក មានយុត្តាធិការលើរឿងក្តីនៃឧក្រិដ្ឋកម្មជាតិ។

ង. អ.វ.ត.ក មានយុត្តាធិការទូទៅលើបទឧក្រិដ្ឋអន្តរជាតិ និងទម្រង់នៃការទទួលខុសត្រូវអន្តរជាតិ។

ច. អ.វ.ត.ក មានយុត្តាធិការលើអំពើប្រល័យពូជសាសន៍: ការទទួលខុសត្រូវបន្ទាប់បន្សំចំពោះអំពើប្រល័យពូជសាសន៍មិនតម្រូវឲ្យមានចេតនាប្រល័យពូជសាសន៍ពិសេសនោះទេ។

ឆ. អ.វ.ត.ក មានយុត្តាធិការទៅលើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ: ទោះបីជាលក្ខខណ្ឌតម្រូវអំពីចំណងទាក់ទងមានអត្ថិភាពនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិចាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ យ៉ាងណាក៏ដោយ ក៏លក្ខខណ្ឌបែបនេះត្រូវបានបំពេញនៅក្នុងរឿងក្តីនេះ ហើយការហាមប្រាមទៅលើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិគ្របដណ្តប់លើការដាក់គុក ការធ្វើទារុណកម្ម ការរំលោភសេពសន្ថវៈ និងអំពើមនុស្សធម៌ដទៃទៀត ចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។

ជ. អ.វ.ត.ក មានយុត្តាធិការលើការបំពារបំពានយ៉ាងធ្ងន់ធ្ងរ លើអនុសញ្ញាទីក្រុងហ្សឺណែវ ("ការបំពារបំពានធ្ងន់ធ្ងរ")៖ ការវិនិច្ឆ័យទោសចំពោះការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវមិនត្រូវបានរារាំងដោយការកន្លងទៅនៃពេលវេលាទេ និង

ឈ. អ.វ.ត.ក មានយុត្តាធិការលើការទទួលខុសត្រូវរបស់ថ្នាក់លើ: ការទទួលខុសត្រូវរបស់ថ្នាក់លើជាទម្រង់នៃការទទួលខុសត្រូវមួយ ដែលអាចអនុវត្តបាន ហើយដីកាដំណោះស្រាយបានអនុវត្តយ៉ាងត្រឹមត្រូវលើទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ។

## II. បណ្តឹងឧទ្ធរណ៍អាចទទួលយកបាន

### ក. បណ្តឹងឧទ្ធរណ៍លើកឡើងពាក់ព័ន្ធនឹងបញ្ហាយុត្តាធិការ ដែលអាចនឹងប្តឹងឧទ្ធរណ៍ អនុលោមតាមវិធាន៧៤(៣)(ក) នៃវិធានផ្ទៃក្នុង

#### ១. ការបកស្រាយដីកា ឬសេចក្តីសម្រេច "ដែលបញ្ជាក់ពីយុត្តាធិការរបស់អ.វ.ត.ក"

២. នៅក្នុងកថាខណ្ឌ ១២ ដល់ ៣៤ ក.ស.ព អះអាងថា "មូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងឧទ្ធរណ៍ ត្រង់ចំណុច ២, ៥, ៦, ៧, ៨, ៩, ១០ និង ១១ មិនមែនជាបញ្ហាយុត្តាធិការ" ហើយបានអះអាងថា "ដើមបណ្តឹងឧទ្ធរណ៍អាចធ្វើបណ្តឹងឧទ្ធរណ៍អំពីបញ្ហាយុត្តាធិការ"។ អនុលោមតាមវិធាន៧៤(៣)(ក) លោក អៀង សារី អាចប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកា និងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត អំពីការបញ្ជាក់ពីយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ។ សិទ្ធិប្តឹងឧទ្ធរណ៍របស់លោក អៀង សារី ក៏អាចជាប់ទាក់ទងនឹងបញ្ហាពាក់ព័ន្ធនឹងសិទ្ធិទទួលបាននូវការជំនុំជម្រះប្រកបដោយយុត្តិធម៌ ដែលអង្គបុរេជំនុំជម្រះមានយុត្តាធិការពិចារណាអនុលោមតាមវិធាន២១[3]។

៣. នៅក្នុងកថាខណ្ឌ១៥ ក.ស.ព អះអាងថា "ដោយសារ អ.វ.ត.ក បានអនុម័តជាមូលដ្ឋាននូវនីតិវិធីខុសប្លែកពីនីតិវិធីរបស់តុលាការ ICTY ដែលអនុញ្ញាតឱ្យម្ចាស់បណ្តឹងឧទ្ធរណ៍អាចលើកឡើងនូវករណីអញ្ញត្រកម្មទូលំទូលាយមួយ នៅដំណាក់កាលបន្ទាប់នៃកិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ... វិសាលភាពនៃបណ្តឹងឧទ្ធរណ៍ផ្នែកយុត្តាធិការ ដែលអនុញ្ញាតឱ្យអង្គបុរេជំនុំជម្រះ អាចត្រូវបានបកស្រាយនៅក្នុងលក្ខណៈមួយដែលមិនទូលំទូលាយ ជាងអ្វីដែលបានរៀបរាប់រួចមកហើយ នៅក្នុងវិធាន ៧២(ឃ) របស់តុលាការ ICTY និងនៅក្នុងយុត្តាធិការ "ជាយថាហេតុ..."។

---

[3] *សូមមើលករណី អៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អវតក/កសចស(អ.ប.ជ៧១) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងទៅនឹងសេចក្តីសម្រេចរបស់ ក.ស.ច.ស បដិសេធមិនទទួលយកការដាក់ឯកសារចម្លើយតបរបស់លោក អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៦៦ និងសេចក្តីសង្កេតបន្ថែម និងសំណើសុំផ្អាកដំណើការនីតិវិធី ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១០ ឯកសារD390/1/2/4 ERN: 00601705-00601717 ("សាលដីកាលើវិធាន៦៦") កថាខណ្ឌ១០, ១៣។

មិនមានមូលហេតុដើម្បីប្រៀបធៀបសិទ្ធិរបស់មេធាវីការពារក្តី ក្នុងការលើកឡើងបណ្តឹងឧទ្ធរណ៍ទាក់ទិន នឹងយុត្តាធិការជាមួយនឹងប្រព័ន្ធនៅតុលាការ ICTY នោះទេ។ ដូចដែលក.ស.ព បានទទួលស្គាល់ អ.វ.ត.ក មិនត្រឹមតែមានប្រព័ន្ធនីតិវិធីខុសគ្នាគួរឲ្យកត់សម្គាល់នោះទេ អ.វ.ត.ក គឺជាតុលាការកម្ពុជា ដែលស្ថិតក្នុងប្រព័ន្ធតុលាការនៃព្រះរាជាណាចក្រកម្ពុជា ដូចនេះវាមិនតម្រូវឲ្យគោរព ឬផ្អែកតាម យុត្តិសាស្ត្ររបស់តុលាការ ICTY ទេ។ ទោះបីជាយ៉ាងណាក៏ដោយ ប្រសិនបើការប្រៀបធៀបជាមួយ តុលាការ ICTY គឺត្រូវបានគេមើលឃើញថាជាការចាំបាច់ចំពោះបញ្ហាមួយចំនួនដែលបញ្ជាក់ថា អ្វីជា ដីកា ឬសេចក្តីសម្រេច ដែលបញ្ជាក់អំពីយុត្តាធិការរបស់ អ.វ.ត.ក (ថាតើគេត្រូវប្រើប្រាស់អ្វីខ្លះ ដើម្បីបញ្ជាក់ថាបញ្ហាអ្វីមួយគឺជាបញ្ហាយុត្តាធិការ) មែននោះ ដូចនេះ សិទ្ធិរបស់ដើមបណ្តឹងឧទ្ធរណ៍ ក្នុងការប្តឹងលើដីកា និងសេចក្តីសម្រេចដែលបញ្ជាក់ពីយុត្តាធិការ របស់សហចៅក្រមស៊ើបអង្កេត គួរ បកស្រាយតាមរបៀបទូលំទូលាយ ជាងបទប្បញ្ញត្តិដែលចែងនៅក្នុងវិធាន ៧២(ឃ) នៃវិធាន នីតិវិធីនិងភស្តុតាង របស់តុលាការ ICTY។ ក្នុងនាមជាតុលាការដែលទើបបង្កើតឡើងថ្មីៗ អ.វ.ត.ក ទើបតែបានរឿងក្តីតែពីរប៉ុណ្ណោះ ហើយបានចេញសាលក្រមតែមួយនៅសាលាដំបូងចំពោះ ករណីដែលមានការឆ្លើយសារភាពកំហុស (guilty plea)។ ប្រសិនបើអង្គបុរេជំនុំជម្រះ ពិចារណាការប្រៀបធៀបជាមួយតុលាការ ICTY ពិតជាត្រូវបានអនុញ្ញាតលើបញ្ហានេះ គេត្រូវ ចាំទុកថា កាលៈទេសៈដែលអ.វ.ត.ក កំពុងអនុវត្តនាពេលបច្ចុប្បន្ន គឺមានលក្ខណៈស្រដៀងគ្នាលើ បញ្ហានេះ ជាមួយនឹងកាលៈទេសៈនានារបស់តុលាការ ICTY កាលជំនាន់ចេញសាលដីកាលើបណ្តឹង ឧទ្ធរណ៍បន្ទាន់បង្ខំក្នុងរឿងក្តី *Tadić*[4]។ នៅដំណាក់កាលនោះ មុនពេលមានការវិវត្តន៍បណ្តុំយុត្តិសាស្ត្រ សំខាន់ៗ ដែលបង្កើតច្បាប់ជាធរមាន និងយុត្តាធិការរបស់តុលាការ ICTY ពាក្យយុត្តាធិការ ត្រូវបាន កំណត់និយមន័យ "ក្នុងលក្ខណៈទូលំទូលាយ"[5] ជាងពាក្យយុត្តាធិការ ដែលត្រូវបានឆ្លុះបញ្ចាំងដោយ បទដ្ឋាន ដែលបង្កើតឡើងដោយវិធាន៧២(ឃ)[6]។ ក្រោយពីមានការវិវត្តន៍យុត្តិសាស្ត្រនេះ

---

[4] *រឿងក្តីរដ្ឋអាជ្ញាតទល់នឹង Tadić*, IT-94-1, សាលដីកាលើញត្តិរបស់មេធាវីការពារក្តី សំពោះបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ខំស្តីពី យុត្តាធិការ, ចុះថ្ងៃទី២ ខែតុលា ឆ្នាំ១៩៩៥ ("សាលដីកាលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ខំ ក្នុងរឿងក្តី *Tadić*")។

[5] ចម្លើយតប កថាខណ្ឌ១៤។

[6] កត់សម្គាល់ថា អង្គជំនុំជម្រះតុលាការដំបូងក្នុងរឿងក្តី *Milutinovic* រកឃើញថា "វាមិនអាចកំណត់ [សំអាងហេតុសម្រាប់អនុម័ត វិធាន៧២ (ឃ)] ពីព្រោះមិនមានមតិយោបល់ ឬការរៀបរាប់ ភ្ជាប់ជាមួយនឹងវិសោធនកម្មនៃវិធានផ្ទៃក្នុង។ យ៉ាងណាក៏ដោយ

សិទ្ធិកាន់តែស្ដួចទៅសម្រាប់ការប្ដឹងឧទ្ធរណ៍ទាក់ទងនឹងបញ្ហាយុត្តាធិការ ត្រូវបានពិចារណាសមស្រប នៅតុលាការ ICTY។ មេធាវីការពារក្ដី សូមស្នើថា ក្នុងការអនុវត្តយុត្តាធិការដែលខ្លួន *មានសមត្ថកិច្ច (kompetenz-kompetenz)*[7] អង្គបុរេជំនុំជម្រះគួរទទួលការណែនាំឱ្យបានត្រឹមត្រូវពីវិធីសាស្ត្រដំបូងៗ របស់តុលាការ ICTY (ដូចដែលបានលើកឡើងនៅក្នុងសេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍បន្ទាន់បង្ហំលើ រឿងក្ដី *Tadić*) នៅពេលពិចារណាថាតើបញ្ហានានា ដែលបានលើកឡើងនៅក្នុងបណ្ដឹងឧទ្ធរណ៍ គឺជាបញ្ហាយុត្តាធិការ៖

> ការបកស្រាយតាមន័យចង្អៀតនៃទស្សនទានយុត្តាធិការនេះ ... គឺផ្ទុយទៅនឹងទស្សនទានទំនើបនៃរដ្ឋបាលតុលាការ។ <u>បញ្ហាជាសារវ័ន្ត តួយ៉ាងដូចជាបញ្ហាយុត្តាធិការរបស់តុលាការអន្តរជាតិមិនត្រូវទុករង់ចាំដល់មានសេចក្ដីសម្រេច នៅចុងបញ្ចប់នៃការជំនុំជម្រះក្ដីដែលអាចមានរយៈពេលវែង មានការរំជួលចិត្ត និងដែលចំណាយលុយច្រើននោះទេ</u>។ <u>នៅក្នុងការវិភាគចុងក្រោយ មូលដ្ឋាននៃការប្រជែងតវ៉ាដែលបានសំអាងដោយដើមបណ្ដឹងឧទ្ធរណ៍ បង្កើតឱ្យមានការវាយតម្លៃលើលទ្ធភាពផ្លូវច្បាប់របស់តុលាការអន្តរជាតិក្នុងការជំនុំជម្រះរឿងក្ដីរបស់ដើមបណ្ដឹងឧទ្ធរណ៍នោះ</u>។ នៅទីបញ្ចប់ បើសិនវាមិនមែនជាចំណោទនៃយុត្តាធិការទេនោះ តើវាជាបញ្ហាអ្វីទៅវិញ? ... ចុះប្រសិនបើផលប្រយោជន៍នៃភាពយុត្តិធម៌មានកម្រិតខ្ពស់មួយដែលបណ្ដាលអោយមានសេចក្ដីសម្រេចមួយ ដែលបានផ្ដល់ជាប្រយោជន៍ដល់ជនជាប់ចោទទៅវិញ អញ្ចឹងការជំនុំជម្រះក្ដីដែលជនជាប់ចោទនេះបានឆ្លងកាត់កន្លងមកនោះនឹងមានឈ្មោះថាជាការជំនុំជម្រះក្ដី ដែលមិនសមរម្យឬយ៉ាងណា។ ថ្វីបើបានលើកឡើងបែបនេះក្ដី នៅតុលាការមួយ សុភវិនិច្ឆ័យគួរតែត្រូវបានឱ្យតម្លៃ មិនមែនត្រឹមតែនៅពេលដែល

---

អង្គជំនុំជម្រះយល់ឃើញថា គោលបំណងនៃការធ្វើវិសោធនកម្ម ហាក់ដូចជាមានកម្រិតកំណត់។ ក្នុងករណីគ្មានការធ្វើវិសោធនកម្ម អង្គជំនុំជម្រះត្រូវពិចារណាលើសំណើសុំ ... និងបដិសេធចោលដោយផ្អែកលើមូលដ្ឋានថាវាមិនត្រូវបានរៀបចំឱ្យបានទាន់ពេលវេលា"។ *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Milutinović*, IT-94-2-AR72, សេចក្ដីសម្រេចលើសំណើរបស់Nebojša Pavković សុំឱ្យបដិសេធចោលដីកាបញ្ជូនរឿងទៅជំនុំជម្រះលើរូបគាត់ផ្អែកលើមូលដ្ឋានថា ក្រុមប្រឹក្សាសន្តិសុខរបស់អង្គការសហប្រជាជាតិបានបង្កើតដោយខុសច្បាប់នូវតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០០៨ កថាខណ្ឌ១៥។

[7] "អំណាចនេះ ត្រូវបានគេស្គាល់ជាភាសាអាល្លឺម៉ង់ថាជាគោលការណ៍ '*Kompetenz-Kompetenz*' ឬជាភាសាបារាំងថាជា '*la compétence de la competence*' គឺជាផ្នែកមួយ និងពិតជាផ្នែកសំខាន់ នៃយុត្តាធិការដែលខ្លួនមានជាប់មកជាមួយស្រាប់ ឬអាចនឹងកើតមាន របស់តុលាការ ឬរបស់ក្រុមប្រឹក្សាយអាជ្ញាកណ្ដាល ដែលមាននូវ "យុត្តាធិការក្នុងការកំណត់យុត្តាធិការរបស់ខ្លួន"។ វាគឺជាធាតុផ្សំចាំបាច់ក្នុងការអនុវត្តតួនាទីរបស់តុលាការ និងមិនត្រូវការចែងឱ្យច្បាស់សម្រាប់ ... " សាលដីកាលើបណ្ដឹងឧទ្ធរណ៍បន្ទាន់បង្ហំ កថាខណ្ឌ១៦។

អង្គហេតុទាំងឡាយត្រូវបានយកវាយតម្លៃនោះទេ ប៉ុន្តែសុភវិនិច្ឆ័យគួរតែត្រូវបានឲ្យតម្លៃដោយស្មើគ្នា នៅពេលដែលច្បាប់ត្រូវបានស្វែងរក ហើយវិធានសមរម្យ ត្រូវបានជ្រើសរើសយកមកប្រើផងដែរ[8]។

៤. មូលដ្ឋានទាំងអស់នៃបណ្តឹងឧទ្ធរណ៍ ដែល ក.ស.ព តវ៉ាមិនមែនជាបញ្ហាយុត្តាធិការ ប៉ុន្តែយ៉ាងហោចណាស់ ពាក់ព័ន្ធនឹងការវាយតម្លៃនៃសមត្ថភាពផ្លូវច្បាប់របស់ អ.វ.ត.ក ក្នុងការជំនុំជម្រះលើរឿងក្តីលោក អៀង សារី៖

ក. មូលដ្ឋានទី២ នៃបណ្តឹងឧទ្ធរណ៍ ពាក់ព័ន្ធនឹងសេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីដែលថា "ក.ស.ច.ស ភ័ន្តច្រឡំអង្គច្បាប់ ដោយយល់ឃើញថា គោលការណ៍*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* មិនបានរារាំងការចោទប្រកាន់លោក អៀង សារី នាពេលបច្ចុប្បន្ននោះទេ"[9]។

ខ. មូលដ្ឋានទី៥ នៃបណ្តឹងឧទ្ធរណ៍ ពាក់ព័ន្ធនឹងសេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីដែលថា "ក.ស.ច.ស ភ័ន្តច្រឡំអង្គច្បាប់ ចំពោះការអនុវត្តឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ បើសិនជាយល់ឃើញថា អាចអនុវត្តបាននៅ អ.វ.ត.ក"[10]។

គ. មូលដ្ឋានទី៦ នៃបណ្តឹងឧទ្ធរណ៍ ពាក់ព័ន្ធនឹងសេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីដែលថា "ក.ស.ច.ស ភ័ន្តច្រឡំអង្គច្បាប់ ចំពោះការអនុវត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ បើសិនជាយល់ឃើញថាអាចអនុវត្តបាននៅ អ.វ.ត.ក" និងការចោទប្រកាន់មួយចំនួននៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ គឺមិនមែនជាផ្នែកនៃច្បាប់អន្តរជាតិ ក្នុងចន្លោះឆ្នាំ១៩៧៥ ដល់១៩៧៩ នោះទេ[11]។

ឃ. មូលដ្ឋានទី៧ នៃបណ្តឹងឧទ្ធរណ៍ ពាក់ព័ន្ធនឹងសេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីដែលថា "ក.ស.ច.ស ភ័ន្តច្រឡំអង្គច្បាប់ ដោយយល់ឃើញថា អ.វ.ត.ក មានយុត្តាធិការ

---

[8] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ៦។

[9] ចម្លើយតប កថាខណ្ឌ១(២)។ បណ្តឹងឧទ្ធរណ៍ លើកទី១។

[10] ចម្លើយតប កថាខណ្ឌ១(៥)។ បណ្តឹងឧទ្ធរណ៍ លើកទី៦។

[11] ចម្លើយតប កថាខណ្ឌ១(៦)។ បណ្តឹងឧទ្ធរណ៍ លើកទី៧។

អនុវត្តការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ថ្មីបើមានអាជ្ញាយុកាលនៃបទល្មើស" ហើយការអនុវត្តការរំលោភបំពានធ្ងន់ធ្ងរបែបនោះ ត្រូវបានរារាំងដោយពេលវេលា[12]។

ង. មូលដ្ឋានទី៨ នៃបណ្ដឹងឧទ្ធរណ៍ ពាក់ព័ន្ធនឹងសេចក្ដីសន្និដ្ឋានរបស់មេធាវីការពារក្ដីដែលថា "ក.ស.ច.ស ភ័ន្តច្រឡំអង្គច្បាប់ ដោយយល់ឃើញថា អ.វ.ត.ក មានយុត្តាធិការអនុវត្តការទទួលខុសត្រូវរបស់ថ្នាក់លើ និងការអនុវត្តនៅ អ.វ.ត.ក នូវការទទួលខុសត្រូវរបស់ថ្នាក់លើ បើសិនជាយល់ឃើញថា អនុវត្តបាននៅ អ.វ.ត.ក"[13]។

ច. មូលដ្ឋានទី៩ នៃបណ្ដឹងឧទ្ធរណ៍ ពាក់ព័ន្ធនឹងសេចក្ដីសន្និដ្ឋានរបស់មេធាវីការពារក្ដីដែលថា "ក.ស.ច.ស ភ័ន្តច្រឡំអង្គច្បាប់ ចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម"[14]។

ឆ. មូលដ្ឋានទី១០ នៃបណ្ដឹងឧទ្ធរណ៍ ពាក់ព័ន្ធនឹងសេចក្ដីសន្និដ្ឋានរបស់មេធាវីការពារក្ដីដែលថា "ក.ស.ច.ស ភ័ន្តច្រឡំអង្គច្បាប់ ចំពោះការអនុវត្តការធ្វើផែនការ ការញុះញង់ ការបញ្ជា ការជួយនិងជំរុញ"[15]។

៥. មូលដ្ឋានទី២ នៃបណ្ដឹងឧទ្ធរណ៍ គឺជាបញ្ហាយុត្តាធិការច្បាស់ណាស់។ *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* គឺជា "ឧបសគ្គយុត្តាធិការ [ដែល] រៀបចំដើម្បីការពារបុគ្គលនានាប្រឆាំងនឹងការរំខានពីរដ្ឋ តាមរយៈការនាំទៅកាត់សេចក្ដីជាច្រើនដង ចំពោះបទល្មើសដូចគ្នា និងដើម្បីធានាភាពត្រឹមត្រូវតាមច្បាប់ និងសច្ចភាពផ្លូវច្បាប់ នៅក្នុងប្រព័ន្ធច្បាប់"[16]។

---

[12] ចម្លើយតប កថាខណ្ឌ១(៧)។ បណ្ដឹងឧទ្ធរណ៍ លើកទី៤ និងទី៨។

[13] ចម្លើយតប កថាខណ្ឌ១(៨)។ បណ្ដឹងឧទ្ធរណ៍ លើកទី១១។

[14] ចម្លើយតប កថាខណ្ឌ១(៩)។ បណ្ដឹងឧទ្ធរណ៍ លើកទី៩។

[15] ចម្លើយតប កថាខណ្ឌ១(១០)។ បណ្ដឹងឧទ្ធរណ៍ លើកទី១០។

[16] YASMIN Q. NAQVI, IMPEDIMENTS TO EXERCISING JURISDICTION OVER INTERNATIONAL CRIMES 287 (បោះពុម្ពដោយ T.M.C. Asser Press ២០១០) ("NAQVI") (គូសបញ្ជាក់បន្ថែម)។

៦. មូលដ្ឋានទី៥, ទី៦, ទី៧, ទី៨, ទី៩ និងទី១០ នៃបណ្ដឹងឧទ្ធរណ៍ គឺជាបញ្ហាប្រឈមទៅនឹងនិយមន័យរបស់ ក.ស.ច.ស ចំពោះវិសាលភាពនៃឧក្រិដ្ឋកម្ម និងទម្រង់នៃការទទួលខុសត្រូវ។ សេចក្ដីសំអាងផ្លូវច្បាប់នានា ដែលដកស្រង់ដោយ ក.ស.ព តាមពិតទៅវាត្រូវបានចាត់ទុកថាជាបញ្ហាយុត្តាធិការនៅតុលាការ ICTY។ សេចក្ដីសំអាងផ្លូវច្បាប់របស់ ក.ស.ព បង្ហាញថា វិសាលភាព នៃមាត្រា៣ នៃលក្ខន្តិកៈរបស់តុលាការ ICTY ដែលចែងអំពីយុត្តាធិការរបស់តុលាការអន្តរជាតិលើការរំលោភបំពានច្បាប់ និងទំនៀមទម្លាប់សង្គ្រាម វិសាលភាពនៃមាត្រានោះ ត្រូវបានចាត់ទុកថាជាបញ្ហាយុត្តាធិការ[17]។ យុត្តិសាស្ត្ររបស់តុលាការ ICTY ដែល ក.ស.ព យកមកជាសំអាង ក៏បានបង្ហាញផងដែរថា វិសាលភាពនៃមាត្រា៧ នៃលក្ខន្តិកៈរបស់តុលាការ ICTY ដែលចែងអំពីយុត្តាធិការលើការទទួលខុសត្រូវរបស់បុគ្គល និងការទទួលខុសត្រូវរបស់ថ្នាក់លើ ត្រូវបានចាត់ទុកថាជាបញ្ហាយុត្តាធិការ អនុលោមតាមវិធាន ៧២(ឃ)(iv) នៃវិធាននីតិវិធី និងភស្តុតាងរបស់តុលាការ ICTY[18]។

---

[17] *សូមមើលរឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Kordić & Čerkez,* សំណុំរឿង IT-95-14-2 សេចក្ដីសម្រេចលើសំណើសុំរួមរបស់មេធាវីការពារស្នើសុំបដិសេធចោលដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានកែប្រែ ដោយសារតែមិនមានយុត្តាធិការផ្អែកលើបទប្បញ្ញត្តិកំណត់យុត្តាធិការដែលមានចែងក្នុងមាត្រា២ និង៣ ថ្ងៃទី០២ ខែមីនា ឆ្នាំ១៩៩៩កថាខណ្ឌ២៨-៣០, ៣២-៣៤ *ទាញសំអាងហេតុ*ក្នុងចម្លើយតប លេខ៤២។

[18] *សូមមើល រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Hadžihasanović* IT-01-47-PT សេចក្ដីសម្រេចលើការជំទាស់ទៅនឹងយុត្តាធិការ ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០២ កថាខណ្ឌ១, ៧។ នៅក្នុងសេចក្ដីសម្រេចនេះ អង្គជំនុំជម្រះសាលាដំបូងបានពិចារណា ក្នុងចំណោមមាត្រាផ្សេងទៀត ថាតើមាត្រា៧(៣) នៃលក្ខន្តិកៈតុលាការ ICTY "ចែងអំពីការទទួលខុសត្រូវរបស់ថ្នាក់លើចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត មុនពេលមានទំនាក់ទំនងថ្នាក់លើនិងអ្នកក្រោមបង្គាប់ រវាងចារី និងថ្នាក់លើ និង [ថាតើ] មាត្រា៧(៣) នៃលក្ខន្តិកៈ មិនបានចែងអំពីការទទួលខុសត្រូវរបស់ថ្នាក់លើចំពោះការខកខានទប់ស្កាត់ ឬដាក់ទណ្ឌកម្មលើការរៀបចំផែនការ និងការប្រព្រឹត្តបទឧក្រិដ្ឋ" (កថាខណ្ឌ១)។ អង្គជំនុំជម្រះសាលាដំបូងបានបកស្រាយការជំទាស់ទៅនឹងយុត្តាធិការ "ថាជាការជំទាស់បដិសេធយុត្តាធិការផ្អែកតាមមាត្រា ៧(៣) តាំងពីដើមដំបូង និងលើកឡើងថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានកែប្រែ មិនអាចផ្អែកលើការរំលោភបំពាននៃមាត្រា៧(៣) នៃលក្ខន្តិកៈ (វិធាន៧២(ក) និងវិធាន៧២(ឃ)(iv)" (កថាខណ្ឌ៧)។ *សូមមើលផងដែរ រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង* Hadžihasanović IT-01-47-AR72 សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍បន្ទាន់បង្ខំជំទាស់នឹងយុត្តាធិការទាក់ទិននឹងការទទួលខុសត្រូវរបស់ថ្នាក់លើ ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៣ កថាខណ្ឌ៥១ ដែលអង្គជំនុំជម្រះតុលាការកំពូលសម្រេចថា "ជនជាប់ចោទមិនអាចត្រូវបានចោទប្រកាន់ផ្អែកតាមមាត្រា ៧(៣)នៃលក្ខន្តិកៈ ចំពោះបទឧក្រិដ្ឋ ដែលត្រូវបានប្រព្រឹត្តដោយអ្នកក្រោមបង្គាប់ មុនពេលដែលជនជាប់ចោទបានចាប់ផ្ដើមបញ្ជាលើអ្នកក្រោមបង្គាប់នោះឡើយ"។ *សូមមើលផងដែរ រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Popović* IT-05-88-PT សេចក្ដីសម្រេចលើសំណើរបស់ Milorad Trbić សុំការអនុញ្ញាតឱ្យឆ្លើយតបទៅនឹង

ក.ស.ព បានទទួលស្គាល់យ៉ាងច្បាស់ថា បញ្ហា "ថាតើថ្នាក់លើអាចទទួលខុសត្រូវចំពោះការខកខានពុំបានដាក់ទណ្ឌកម្ម ទៅលើបទល្មើសដែលត្រូវបានប្រព្រឹត្តនៅមុនអត្ថិភាពនៃទំនាក់ទំនងរវាងថ្នាក់លើនិងអ្នកក្រោមបង្គាប់ ឬយ៉ាងណា"[19] និង "ថាតើថ្នាក់លើអាចទទួលខុសត្រូវចំពោះការខកខានពុំបានទប់ស្កាត់ ឬដាក់ទណ្ឌកម្ម ការរៀបចំផែនការ ឬការរៀបចំការវាយប្រហារ ឬយ៉ាងណា"[20] "ត្រូវបានសម្រេចថាមានលក្ខណៈជាយុត្តាធិការនៅតុលាការ ICTY"[21]។ យុត្តិសាស្ត្រនេះ បង្ហាញថា ធាតុផ្សំដែលបង្កើតបានជាទម្រង់នៃការទទួលខុសត្រូវ ត្រូវបានចាត់ទុកថាជាបញ្ហាយុត្តាធិការ។ ការលើកអំណះអំណាងរបស់ ក.ស.ព ដែលផ្ទុយពីនេះថា "យុត្តាធិការដែលមានសុពលភាព មិនត្រូវបានពង្រីកដើម្បីដាក់បញ្ចូល ... ដើម្បីតវ៉ាទៅនឹងនិយមន័យនៃធាតុផ្សំសំខាន់នៃបទឧក្រិដ្ឋ ឬទម្រង់នៃការទទួលខុសត្រូវណាមួយ..."[22] ត្រូវតែបដិសេធចោលនោះទេ។

៧. មូលដ្ឋានទី៦ និងទី៨ នៃបណ្តឹងឧទ្ធរណ៍ ជំទាស់ថាតើឧក្រិដ្ឋកម្មមួយចំនួន ធាតុផ្សំបទល្មើស និងទម្រង់នៃការទទួលខុសត្រូវ គឺជាផ្នែកនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ មូលដ្ឋានទាំងនេះគឺជាបញ្ហាយុត្តាធិការ និងអាចប្តឹងឧទ្ធរណ៍បាន។ ក.ស.ព កត់សម្គាល់យ៉ាងត្រឹមត្រូវថា "បញ្ហានីត្យានុកូលភាព ឬ *គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* " និង "ទម្រង់នៃការទទួលខុសត្រូវ" រួមបញ្ចូលថាតើនៅពេលដែលបទល្មើសត្រូវបានចោទប្រកាន់ ច្បាប់ទំនៀមទម្លាប់អន្តរជាតិបានទទួលស្គាល់" ការទទួលខុសត្រូវរបស់អ្នកបញ្ជា ឬសហឧក្រិដ្ឋកម្មរួម[23] ត្រូវបាន "សម្រេចថាមានលក្ខណៈជាយុត្តាធិការនៅតុលាការ ICTY"[24]។ បញ្ហាថាតើឧក្រិដ្ឋកម្មមួយចំនួន ធាតុផ្សំបទល្មើស និងទម្រង់នៃការទទួលខុសត្រូវ គឺជាផ្នែកនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ

---

ចម្លើយតបរួមរបស់រដ្ឋអាជ្ញាទៅនឹងសំណើសុំរបស់មេធាវីការពារក្តីផ្អែកតាមវិធាន៧២, ថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៦ ("សេចក្តីសម្រេចវិធាន៧២ក្នុងរឿងក្តី *Popović* ") ដែល Trbić ត្រូវបានផ្តល់ការអនុញ្ញាតឲ្យឆ្លើយតបទៅនឹងវិសាលភាពJCE។

[19] ចម្លើយតប កថាខណ្ឌ១៦(ង)។

[20] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ១៦(ច)។

[21] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ១៦។

[22] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ១៧។

[23] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ១៦(ឃ)។

[24] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ១៦។

នៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ គឺជាបញ្ហានីត្យានុកូលភាព ឬ *គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* ដោយអនុវត្តលក្ខណៈវិនិច្ឆ័យរបស់ ក.ស.ព ហើយបញ្ហានេះអាចប្តឹងឧទ្ធរណ៍បាន។

៨. ចំពោះមូលដ្ឋានទី៧ នៃបណ្តឹងឧទ្ធរណ៍ ជំទាស់ថាតើការអនុវត្តការបំពារបំពានយ៉ាងធ្ងន់ធ្ងរ ត្រូវបានផុតអាជ្ញាយុកាល។ ករណីនេះគឺជាបញ្ហាយុត្តាធិការ និងអាចប្តឹងឧទ្ធរណ៍បាន។ អាជ្ញាយុកាលជាធរមាន គឺជាការរារាំងចំពោះការកាត់សេចក្តី និងដើរតួនាទីជាឧបសគ្គចំពោះសមត្ថកិច្ចរបស់តុលាការ ឬសាលាក្តីក្នុងការអនុវត្តយុត្តាធិការរបស់ខ្លួន[២៥]។ ហេតុដូច្នេះ បញ្ហាថាតើអាជ្ញាយុកាលដែលមានចែងនៅក្នុងមាត្រា១០៩ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ អាចអនុវត្តបានចំពោះមាត្រា៦ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក គឺជាបញ្ហាយុត្តាធិការ ហើយបញ្ហានេះអាចប្តឹងឧទ្ធរណ៍បាន។

### ២. បញ្ហាយុត្តាធិការ រួមបញ្ចូលទាំងបញ្ហាចម្រុះនៃអង្គហេតុ និងអង្គច្បាប់

៩. នៅក្នុងកថាខណ្ឌ ២២ ដល់ ២៤ ក.ស.ព លើកអំណះអំណាង (ដោយត្រឹមត្រូវ)ថា "បញ្ហាអង្គហេតុ ... មិនអាចប្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះទេ"[26]។ ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងកថាខណ្ឌ ២៥ និងកថាខណ្ឌ២៦ ក.ស.ព សន្និដ្ឋានថា "នៅពេលដែលយុត្តាធិការក្នុងការកាត់ក្តីលើបទល្មើសណាមួយ ដែលត្រូវបានចោទប្រកាន់ ដោយផ្អែកលើភាពមិនច្បាស់លាស់នៃបញ្ហាខាងអង្គហេតុ ដូចជាពីពេលវេលាកំណត់ ឬពីលក្ខណៈនៃជម្លោះប្រដាប់អាវុធ ដែលបញ្ហានេះ គឺជាបញ្ហាមួយចម្រុះនៃអង្គហេតុ និងអង្គច្បាប់ ហើយមិនអាចធ្វើការដោះស្រាយ នៅមុនសវនាការលើអង្គសេចក្តីបានទេ"[27]។ បន្ថែមពីលើនេះ ក.ស.ព អះអាងថា "ដើមបណ្តឹងឧទ្ធរណ៍ទាំងឡាយ មិនអាចប្តឹងឧទ្ធរណ៍ដោយផ្អែកលើទឡ្ហីករណ៍ដូចខាងក្រោម ដោយសារទឡ្ហីករណ៍ទាំងនេះរួមបង្កើតបានយ៉ាងសំខាន់អំពីការប្រើច្បាប់ចំពោះអង្គហេតុ"[28]។ ក.ស.ព ផ្អែកលើការជំទាស់យុត្តាធិការនៅតុលាការ ICTY ដែលត្រូវបានបដិសេធចោលបណ្តឹងឧទ្ធរណ៍ ដោយផ្អែកលើមូលដ្ឋានថា ការជំទាស់នោះពាក់ព័ន្ធនឹងបញ្ហាអង្គហេតុ

---

[25] *សូមមើល* NAQVI នៅត្រង់ទំព័រ ១៨៣-២១៩។

[26] *ដូចដើងទំព័រខាងលើ* កថាខណ្ឌ២។

[27] *ដូចដើងទំព័រខាងលើ* កថាខណ្ឌ២៥។

[28] *ដូចដើងទំព័រខាងលើ* កថាខណ្ឌ២៦។

ដែលត្រូវដោះស្រាយឱ្យបានសមស្របនៅពេលជំនុំជម្រះក្ដី[29]។ ទោះបីជាយ៉ាងក៏ដោយ ការជំទាស់ទាំងនេះ គឺមានលក្ខណ:ខុសគ្នាពីបញ្ហាចម្រុះអង្គច្បាប់ និងអង្គហេតុ ដែលបង្ហាញដោយមេធាវីការពារក្ដី និងមិនអាចយកជាសំអាងដើម្បីគាំទ្រអំណះអំណាងរបស់ ក.ស.ព ដែលថាមេធាវីការពារក្ដី មិនអាចប្ដឹងឧទ្ធរណ៍ចំពោះភាពចម្រុះអង្គហេតុ និងអង្គច្បាប់នោះទេ។ ការជំទាស់ដែលតុលាការ ICTY បានបដិសេធចោល ដោយសារតែគ្រាន់តែមានលក្ខណ:ជាអង្គហេតុ គឺ*គ្រាន់តែជា* បញ្ហាអង្គហេតុ និងមិនត្រូវបានចាត់ថ្នាក់ថាជាបញ្ហាចម្រុះអង្គហេតុ និងអង្គច្បាប់នោះទេ[30]។ ដើម្បីឆ្លើយនឹងសំណួរនៃបញ្ហាចម្រុះនៃអង្គហេតុនិងអង្គច្បាប់ វាមិនតម្រូវឱ្យមានការវាយតម្លៃភស្តុតាងនោះទេ។ វាគ្រាន់តែតម្រូវឱ្យមានការវាយតម្លៃលើអង្គច្បាប់ ដោយផ្អែកលើអង្គហេតុ ដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ។ មានតែប្រាំពីរទំព័រ នៃដីកាដំណោះស្រាយចំនួន ៤០២ ទំព័រ (មិនរួមបញ្ចូលជើងទំព័រ) បានលើកឡើងអំពីបញ្ហាអង្គច្បាប់សុទ្ធសាធ[31]។ វិសាលភាពទាំងស្រុងនៃច្បាប់ដែលអនុវត្តនៅក្នុងដីកាដំណោះស្រាយ គឺអាចដឹងបាន ដោយការវិភាគអំពីរបៀបដែល ក.ស.ច.ស កំណត់ចរិតលក្ខណ:អង្គហេតុតែប៉ុណ្ណោះ[32]។ ភាពច្បាស់លាស់ ទាក់ទិននឹងវិសាលភាពនៃច្បាប់ជាធរមាន គឺជាបញ្ហាដែលត្រូវបានដោះស្រាយឱ្យបានសមស្រប នៅមុនសវនាការលើអង្គសេចក្ដី[33]។ ទាំងនេះគឺជាគោលនយោបាយសមរម្យ ជាសំអាងហេតុដែលថាហេតុអ្វីបានជាបញ្ហាចម្រុះនៃអង្គហេតុ និងអង្គច្បាប់ គួរត្រូវបានបកស្រាយថាជាបញ្ហាអង្គច្បាប់ និងអាចត្រូវបានប្ដឹងឧទ្ធរណ៍នៅដំណាក់កាលនេះ[34]។ អង្គបុរេជំនុំជម្រះ ត្រូវតែពិចារណា បញ្ហាចម្រុះនៃអង្គហេតុ និង

---

[29] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ២៤។

[30] *ដូចជើងទំព័រខាងលើ។* ការជំទាស់បីដំបូងរបស់ ក.ស.ព គឺអំពីការកំណត់អង្គហេតុនៃពេលវេលារបស់បទល្មើស ខណ:ដែលការជំទាស់ទីបួនគឺថាតើធាតុផ្សំអង្គហេតុនៃទម្រង់នៃការទទួលខុសត្រូវ អាចនាំឱ្យមានការទទួលខុសត្រូវបទឧក្រិដ្ឋ និងការជំទាស់ទីប្រាំគ្រាន់តែទាក់ទងនឹងការបញ្ជាក់អង្គហេតុនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

[31] ដីកាដំណោះស្រាយ ផ្នែក II កថាខណ្ឌ១២៩៩-១៣២៦។

[32] *ដូចជើងទំព័រខាងលើ* ផ្នែកIII កថាខណ្ឌ១៣២៧-១៥៧៦។

[33] *សូមមើលកថាខណ្ឌខាងលើ* កថាខណ្ឌ ៣, ៦។

[34] ឧទាហរណ៍ តុលាការកំពូលរបស់អង្គការសហប្រជាជាតិនាឆ្នាំថ្មីៗនេះ បានប្រើប្រាស់នូវអ្វីដែលអាចរៀបរាប់ថាជាវិធីសាស្ត្រ "គោលនយោបាយ" ក្នុងការបញ្ចូលអង្គហេតុ និងអង្គច្បាប់។ *សូមមើល Miller តទល់នឹង* Fenton, 474 U.S. 104, 104 (1985)។ "ភាពខុសគ្នានូវអង្គហេតុ/អង្គច្បាប់នាពេលនោះ បានប្រែក្លាយក្នុងការកំណត់ថា ដោយសារបញ្ហារដ្ឋបាលតុលាការត្រឹមត្រូវ តួអង្គ

អង្គច្បាប់ (ឬ"ច្បាប់ដែលត្រូវយកមកអនុវត្ត") ថាជាបញ្ហាអង្គច្បាប់[35]។ យោងតាមនិយមន័យទូលាយដែលកំណត់អំពីបញ្ហាយុត្តាធិការ[36] បញ្ហាប្រភេទទាំងនេះអាចប្តឹងឧទ្ធរណ៍ចំពោះមុខអង្គបុរេជំនុំ

---

តុលាការមួយ អាចមានលក្ខណៈល្អប្រសើរជាងអ្នកផ្សេងទៀតក្នុងការសម្រេចបញ្ហាចោទ"។ *សូមមើលផងដែរ ដូចខាងលើ* ត្រង់ចំណុច១១៤ "ឧទាហរណ៍ នៅពេល ... គោលការណ៍ច្បាប់ពាក់ព័ន្ធអាចផ្តល់អត្ថន័យត្រឹមតែតាមរយៈការអនុវត្តចំពោះកាលៈទេសៈនៃរឿងក្តីពិសេស តុលាការស្នាក់ស្ទើរក្នុងការជំនុំជម្រះសេចក្តីសន្និដ្ឋានអង្គហេតុ កម្លាំងសន្មត ហើយការធ្វើដូច្នេះ គឺជាការដកចេញពីតុលាការឧទ្ធរណ៍សហព័ន្ធ នូវតួនាទីចម្បងរបស់ខ្លួនក្នុងនាមជាអ្នកបកស្រាយច្បាប់"។ *សូមមើលផងដែរ Bausch & Lomb, Inc. v. United States*, 957 F. Supp. 281 (Ct. Int'l Trade 1997) *citing U.S. v. McConney*, 728 F.2d 1195, 1202 (9th Cir. 1984) លើគោលនយោបាយពិចារណាដែលជាមូលដ្ឋាននៃបទដ្ឋាននៃការពិនិត្យឡើងវិញដែលត្រូវបានជ្រើសរើសសម្រាប់បញ្ហាចម្រុះពិសេសនៃអង្គច្បាប់និងអង្គហេតុ។ "បទដ្ឋាននៃការពិនិត្យឡើងវិញសមស្របសម្រាប់ការអនុវត្តច្បាប់របស់តុលាការថ្នាក់ស្រុកចំពោះអង្គហេតុ អាចនឹងត្រូវបានកំណត់ តាមសំអាងហេតុនៃគោលការណ៍ត្រឹមត្រូវ ដែលជាដើមកំណើតនៃវិធានរបស់ការពិចារណារបស់សាលាឧទ្ធរណ៍ដែលទើបតែបានពិភាក្សា។ ប្រសិនបើការពាក់ព័ន្ធនៃប្រសិទ្ធិភាពរដ្ឋបាលតុលាការ ភាពត្រឹមត្រូវ និងយុត្តិសាស្ត្រ អាចថ្លឹងថ្លែងឱ្យកាន់តែសមស្របសម្រាប់តុលាការស្រុកក្នុងការកំណត់ថាតើអង្គហេតុដែលមាន ស្ថិតនៅក្នុងនិយមន័យច្បាប់ពាក់ព័ន្ធ យើងគួរតែដាក់ការសម្រេចនេះឱ្យមានការគោរព ពិនិត្យដោយភ័ន្តច្រឡំយ៉ាងច្បាស់ [តួយ៉ាងបានប្រើប្រាស់សម្រាប់បង្កើតនូវអង្គហេតុប្រវត្តិសាស្ត្រ]។ ម្យ៉ាងវិញទៀត ប្រសិនបើភាពពាក់ព័ន្ធនៃរដ្ឋបាលតុលាការគាំទ្រសាលាឧទ្ធរណ៍ យើងគួរតែដាក់ការយល់ឃើញរបស់តុលាការថ្នាក់ស្រុកទៅជាការពិនិត្យមើលឡើងវិញ*សាជាថ្មី*"។

[35] សូមមើលបណ្តឹងឧទ្ធរណ៍ លេខ៥។ ដូចបញ្ហាអង្គច្បាប់ តុលាការឧទ្ធរណ៍បានសម្រេចថា ភាពចម្រុះនៃអង្គច្បាប់ និងអង្គហេតុគួរតែត្រូវពិចារណា*សាជាថ្មី*។ "ថាតើបុគ្គលមួយមានអំណាចពិតប្រាកដក្នុងការព្រមព្រៀង គឺជាបញ្ហាចម្រុះអង្គច្បាប់ និងអង្គហេតុដែលយើងពិចារណា*សាជាថ្មី* ... [យើង] ពិចារណាថាតើការជួបគ្នារវាងជនជាប់ចោទ និងការអនុវត្តច្បាប់ គឺជាការទទួលយក*សាជាថ្មី* ដោយសារភាពចម្រុះនៃអង្គច្បាប់ និងអង្គហេតុផងដែរ។ ជាចុងក្រោយ នៅពេលចុងចោទបានបដិសេធយ៉ាងត្រឹមត្រូវ យើងនឹងពិនិត្យមើលភាពគ្រប់គ្រាន់នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ*សាជាថ្មី*"។ *United States v. Enslin,* 327 F.3d 788, 792-93, (9th Cir. 2003), *citing United States v. Reid,* 226 F.3d 1020, 1025 (9th Cir. 2000), *United States v. Cormier,* 220 F.3d 1103, 1110 (9th Cir. 2000), and *United States v. Pernillo-Fuentes,* 252 F.3d 1030, 1032 (9th Cir. 2001). "ពីព្រោះបញ្ហានេះ [ទំនាក់ទំនងរវាងសកម្មភាពលាងលុយ និងផែនការលួចបន្លំខ្សែលួស] ពាក់ព័ន្ធនឹងបញ្ហាចម្រុះនៃអង្គច្បាប់និងអង្គហេតុ យើងអាចពិចារណាការផ្តន្ទាទោសការលាងលុយរបស់ដើមបណ្តឹងឧទ្ធរណ៍ *សាជាថ្មី*"។ *United States v. Szur,* 289 F.3d 200, 213 (2d Cir. 2002), *citing United States v. Fernandez-Antonia,* 278 F.3d 150, 156 (2d Cir. 2002). បន្ថែមពីលើនេះ សាលាដំបូងនានានៅសហរដ្ឋអាមេរិក បានដោះស្រាយថា បញ្ហាចម្រុះអង្គច្បាប់ និងអង្គហេតុយកមកពិចារណាថាជាបញ្ហាអង្គច្បាប់ ដែលបានលើកឡើងដោយមិនខុសគ្នាពីការសម្រេចខាងក្រោមនោះទេ។ "បញ្ហាអាជ្ញាយុកាល ដែលជាបញ្ហាចម្រុះនៃអង្គហេតុនិងអង្គច្បាប់ ត្រូវបានពិចារណាដោយតុលាការនេះថាជាបញ្ហាអង្គច្បាប់"។ *Taylor v. City of Oklahoma City*, 782 P.2d 1363, 1365 (Okla. 1989). "ដោយសារបញ្ហានេះកើតចេញពីសេចក្តីសម្រេចភ្នាក់ងាររដ្ឋបាល យើងអាចអនុវត្តបទដ្ឋាននៃការពិនិត្យឡើងវិញ ដែលត្រូវបានចែងយ៉ាងច្បាស់ដោយតុលាការ [*Permann*]"។ នៅ *Permann* យើងសម្រេចថា បញ្ហាចម្រុះអង្គច្បាប់និងអង្គហេតុ ត្រូវបានចាត់ទុក

ជម្រះ។ ហេតុដូច្នេះ ក្នុងការអនុវត្តកាតព្វកិច្ចប្រកបដោយវិរិយភាពរបស់ខ្លួន[37] មេធាវីការពារក្តី ត្រូវតែលើកឡើងអំពីបញ្ហាយុត្តាធិការដែលអាចមានទាំងអស់ ដែលចេញមកពីដីកាដំណោះស្រាយ។

### ៣. បញ្ហាយុត្តាធិការអាចទាក់ទងនឹងនិយមន័យនៃធាតុផ្សំដែលបង្កើតបានជាឧក្រិដ្ឋកម្ម ឬបង្កើតបានជាទម្រង់ផ្សេងៗនៃការទទួលខុសត្រូវ

១០. នៅក្នុងកថាខណ្ឌ២៧ ក.ស.ព លើកអំណះអំណាងថា "បញ្ហាយុត្តាធិការ គឺមិនលាតសន្ធឹងទៅដល់ការប្តឹងជំទាស់ទៅនឹងនិយមន័យនៃធាតុផ្សំសំខាន់ៗនៃឧក្រិដ្ឋកម្មណាមួយ ឬទៅនឹងទម្រង់ផ្សេងៗនៃការទទួលខុសត្រូវនោះឡើយ...។ គោលការណ៍នេះ មានភាពសមស្រប ជាពិសេសនៅក្នុងតុលាការពិសេសដែលមានតែមួយគត់ ដែលអង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក មិនជាប់កាតព្វកិច្ច ត្រូវតែអនុវត្តតាមការកំណត់បទចោទ ដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេតនោះឡើយ"។ ដូចដែល

---

ក្នុងលក្ខណៈដូចគ្នានឹងបញ្ហាអង្គច្បាប់។ បញ្ហាបែបនេះ គឺជាប្រភេទដែលយើងអាចពិចារណាឡើងវិញដោយសេរី"។ *In re Groseth Int'l, Inc.*, 442 N.W.2d 229, 232 (S.D. 1989) *citing Permann v. Dept. of Labor, Unemp. Ins. D.*, 411 N.W. 2d 113, 119 (S.D. 1987). ការកំណត់ថាជា *"ភាគី"* ល្អបំផុតគឺជាបញ្ហាចម្រុះនៃអង្គច្បាប់ និងអង្គហេតុ ដែលត្រូវពិនិត្យមើលផ្អែកតាមបទដ្ឋានភ័ន្តច្រឡំនៃច្បាប់"។ *Sardam v. Morford*, 756 P.2d 174, 175 *citing Renton Educ. Ass'n v. PERC*, 680 P.2d 40 (1984). "បញ្ហាចម្រុះអង្គច្បាប់ និងអង្គហេតុ នឹងត្រូវពិចារណាទាំងស្រុងនៅឧទ្ធរណ៍"។ *Taylor v. Cone Mills Corp.*, 306 N.C. 314, 320, 293 S.E. 2d 189, 193 (1982), *citing Brown v. Charlotte-Mecklenburg Board of Education*, 269 N.C. 667, 153 S.E.2d 335 (1967). "ថាតើមានឬមិនមានការមិនទទួលបណ្តឹងសាជាថ្មី គឺជាបញ្ហាចម្រុះនៃអង្គច្បាប់ និងអង្គហេតុ ដែលជាកម្មវត្ថុនៃការពិនិត្យឡើងវិញសាជាថ្មី..."។ *Regents of University of Minnesota v. Medical Inc.*, 382 N.W.2d 201, 207 (Minn. Ct. App. 1986), *citing United States v. Geophysical Corp.*, 732 F.2d 693, 697 (9th Cir. 1964). "ការយល់ឃើញលើអង្គហេតុ គឺជាការពិត ដោយសារត្រូវបានបង្ហាញដោយភស្តុតាងដែលត្រូវបានញែកដាច់ពីអនុភាព ឬផលវិបាកផ្លូវច្បាប់"។ នៅពេលសេចក្តីសន្និដ្ឋានចុងក្រោយ "អាចចេញមកពីតែពីការអនុវត្តវិធានតតិយុត្តិ ដូចនេះលទ្ធផលគឺជា "សេចក្តីសន្និដ្ឋានផ្លូវច្បាប់"។ *Earth Builders, Inc. v. State*, 325 N.W.2d 258, 259 (N.D. 1982), *citing E.E.E., Inc. v. Hanson*, 318 N.W.3d 101, 104 (ND.1982)

[36] ឧទា. និយមន័យ បានអនុវត្តនៅក្នុងសាលដីកាបណ្តឹងឧទ្ធរណ៍បន្ទាន់បង្គំក្នុងរឿងក្តី *Tadić*។ សូមមើលកថាខណ្ឌ៣ *ខាងលើ*។

[37] វិធាន ២២(៤) ចែងផ្នែកក្នុងផ្នែកដែលទាក់ទងថា៖ "[មេធាវី] មានកាតព្វកិច្ចក្នុងការលើកកម្ពស់យុត្តិធម៌ និងដំណើរការនីតិវិធីប្រកបដោយប្រសិទ្ធិភាព និងត្រឹមត្រូវ"។ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ក្រមសីលធម៌ មាត្រា ៦ ចែងថា៖ "នៅគ្រប់កាលៈទេសៈទាំងអស់ មេធាវីត្រូវគោរពពាក្យសម្បថរបស់ខ្លួន និងត្រូវគោរពគោលការណ៍នៃសម្បជញ្ញៈ នៃមនុស្សធម៌ និងភាពគួរសមថ្លៃថ្នូរ។ មេធាវីមិនត្រូវចូលរួមក្នុងសកម្មភាព ដែលមានលក្ខណៈផ្ទុយពីច្បាប់និងបទបញ្ជា ផ្ទុយនិងវិធានវិជ្ជាជីវៈ និងសម្បជញ្ញៈរបស់ខ្លួនដែលតម្រូវឲ្យធ្វើ"។

បានកត់សម្គាល់នៅខាងលើ សំអាងផ្លូវច្បាប់ដែលដកស្រង់ដោយ ក.ស.ព បង្ហាញថា ធាតុផ្សំដែលបង្កើតបានជាទម្រង់នៃការទទួលខុសត្រូវ ត្រូវបានចាត់ទុកថាជាបញ្ហាយុត្តាធិការនៅតុលាការ ICTY[38]។ សំអាងផ្លូវច្បាប់ដែលដកស្រង់ដោយ ក.ស.ព នៅក្នុងកថាខណ្ឌ២៧ គឺជាការគាំទ្រជំហររបស់មេធាវីការពារក្តី ឬជាសំអាងផ្លូវច្បាប់ដែលមិនពាក់ព័ន្ធ។ ក្នុងលក្ខណៈជាបញ្ហាយុត្តាធិការ អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *Prlić* នៃតុលាការ ICTY ពិតជាបានពិចារណា*ក្នុងចំណោមបញ្ហាយុត្តាធិការទាំងនោះ* គឺថាតើ តុលាការ ICTY មាន "អំណាចបោះបង់ចោលធាតុផ្សំនៃចំណងទាក់ទងហេតុនិងផល ពីផ្នែកនៃការទទួលខុសត្រូវបទឧក្រិដ្ឋជាបុគ្គល"[39]។ សំអាងហេតុនេះ គាំទ្រទទ្បីករណ៍របស់មេធាវីការពារក្តីថា វិសាលភាពនៃឧក្រិដ្ឋកម្ម ឬទម្រង់នៃការទទួលខុសត្រូវ អាចត្រូវបានចាត់ទុកថាជាបញ្ហាយុត្តាធិការ។ សេចក្តីសំអាងទៅលើរឿងក្តី *Kvočka* នៅក្នុងកថាខណ្ឌ២៧នៃចម្លើយតប ហាក់ដូចជាមានសរសេរពាក្យខុស។ កថាខណ្ឌដែលត្រូវបានដកស្រង់ មិនទាក់ទង ឬមិនគាំទ្រសេចក្តីអះអាងដែលត្រូវបានលើកឡើងនោះទេ[40] ដូចនេះមិនត្រូវយកមកពិចារណាឡើយ។ ការទទួលស្គាល់ថា ស្ថានភាពជាក់លាក់នៃអ.វ.ត.ក គាំទ្រចំពោះការអនុវត្តនិយមន័យទូលាយនៃបញ្ហាយុត្តិសាស្ត្រ ដូចមានចែងក្នុងសាលដីកាលើបណ្តឹងឧទ្ធរណ៍ទាក់ទិននឹងយុត្តាធិការក្នុងរឿងក្តី *Tadić*[41] វាមិនមានមូលហេតុអ្វីបានជាធាតុផ្សំដែលបង្កើតបានជាឧក្រិដ្ឋកម្ម ឬបង្កើតបានជាទម្រង់នៃការទទួលខុសត្រូវ មិនត្រូវបានចាត់ទុកថាដូចបែបនោះទេ។ ជាចុងក្រោយ ប្រសិនបើមានការចោទប្រកាន់លើរូបលោក អៀង សារី គាត់ត្រូវតែដឹងអំពីធាតុផ្សំនៃឧក្រិដ្ឋកម្ម និងទម្រង់នៃការទទួលខុសត្រូវចំពោះបទល្មើសដែលចោទប្រកាន់លើរូបលោក។ ប្រសិនបើមិនមានព័ត៌មាននេះទេ លោក អៀង សារី មិនអាចរៀបចំការការពារខ្លួនគាត់គ្រប់គ្រាន់នោះទេ។ ប្រសិនបើអង្គបុរេជំនុំជម្រះ បន្តបញ្ជូនរឿងទៅ

---

38 ចម្លើយតប កថាខណ្ឌ១៦(គ)។

39 *រឿងក្តីរដ្ឋអាជ្ញាតទល់នឹង* Prlić និងអ្នកផ្សេងទៀត, សំណុំរឿង IT-04-74-PT សាលដីកាមោឃភាពអញ្ញត្រកម្មបឋមប្រឆាំងនឹងសមត្ថកិច្ចយុត្តាធិការ ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០៥ កថាខណ្ឌ៨(គ) ១៨។

40 ចម្លើយតប កថាខណ្ឌ២៧ *ទាញសំអាងហេតុ រឿងក្តីរដ្ឋអាជ្ញាត ទល់នឹង Kvočka* សំណុំរឿង IT-98-30/1-T សេចក្តីសម្រេចលើសំណើសុំបឋម ដែលដាក់ដោយ Mlado Radić និង Miroslav Kvočka តវ៉ាជំទាស់នឹងយុត្តាធិការ ចុះថ្ងៃទី១ ខែមេសា ឆ្នាំ១៩៩៩ កថាខណ្ឌ១៦។ នៅក្នុងការឆ្លើយតបរបស់ខ្លួនទៅនឹងសំណើសុំ Kvocka រដ្ឋអាជ្ញាលើកឡើងត្រង់ៗសាជាថ្មីដូចគ្នានឹងទទ្បីករណ៍ដែលខ្លួនបានឆ្លើយតបទៅនឹងសំណើសុំរបស់ Radic"។

41 *សូមមើលកថាខណ្ឌខាងលើ* កថាខណ្ឌ៣។

ជំនុំជម្រះ ដោយគ្មានការកំណត់ធាតុផ្សំនៃឧក្រិដ្ឋកម្មនីមួយៗឲ្យបានច្បាស់លាស់ទេនោះ ការធ្វើដូចនេះនឹងរំលោភលើរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា[42] កិច្ចព្រមព្រៀង[43] ច្បាប់ស្តីពីការបង្កើតអ.វ.ត.ក[44] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ (ICCPR) [45] និងសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស (UDHR)[46]។

**ខ. ទោះបីជាបណ្តឹងឧទ្ធរណ៍មិនត្រូវបានចាត់ទុកថាទាក់ទងនឹងបញ្ហាយុត្តាធិការទាំងស្រុងក៏ដោយ បញ្ហានានាដែលលើកឡើង គឺអាចទទួលយកបានផ្អែកតាមវិធាន ២១**

**១. វិធាន២១ បង្កើតឲ្យមានសិទ្ធិប្តឹងឧទ្ធរណ៍ទូលាយជាងវិធាន ៧៤(៣)(ក)**

១១. នៅក្នុងកថាខណ្ឌ១៨ ក.ស.ព អះអាងថា វិធាន២១ មិនបានបង្កើតនូវសិទ្ធិប្តឹងឧទ្ធរណ៍ដោយឯករាជ្យនោះទេ[47]។ អំណះអំណាងរបស់ ក.ស.ព គឺមិនត្រឹមត្រូវ ដោយសារតែអង្គបុរេជំនុំជម្រះបានសម្រេចថា វិធាន២១ ពិតជាបានបង្កើតនូវសិទ្ធិប្តឹងឧទ្ធរណ៍ដោយឯករាជ្យ[48]។ វិធាន ៧៤(៣) ចែងថា "ជនត្រូវចោទ ឬជនជាប់ចោទ អាចធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកា ឬ សេចក្តីសម្រេចរបស់សហ

---

[42] *សូមមើល*រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ក៏ដូចជាវិសោធនកម្មឆ្នាំ១៩៩៩ ("រដ្ឋធម្មនុញ្ញកម្ពុជា") មាត្រា៣១។

[43] *សូមមើល*កិច្ចព្រមព្រៀង មាត្រា១៣(១)។

[44] *សូមមើល* ច្បាប់ស្តីពីការបង្កើតអ.វ.ត.ក មាត្រា៣៥ថ្មី។

[45] *សូមមើល* កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ បានអនុម័ត និងបើកឲ្យចុះហត្ថលេខា ឲ្យសច្ចាប័ន និងឲ្យចូលជាសមាជិកតាមសេចក្តីសម្រេចចិត្តលេខ២២០០ A(XXI) ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ របស់មហាសន្និបាតអង្គការសហប្រជាជាតិ ចូលជាធរមាននៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧៦ (កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធនយោបាយ) មាត្រា១៤(១)។

[46] *សូមមើល* សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស អនុម័ត និងប្រកាសដោយសេចក្តីសម្រេចចិត្ត នៃមហាសន្និបាតលេខ ២១៧A(III), U.N. GAOR, 3d Sess. ត្រង់ 71, ឯកសារ អ.ស.ប លេខ A/810 (១៩៤៨), មាត្រា១១(១)។

[47] ចម្លើយតប កថាខណ្ឌ១៨។

[48] សេចក្តីសម្រេចវិធាន៦៦ កថាខណ្ឌ១០-១៣។ នៅក្នុងករណីនេះ មេធាវីការពារក្តីបានប្តឹងឧទ្ធរណ៍ផ្អែកតែតាមវិធាន២១។ *សូមមើលករណីអៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អវតក/កសចស (អ.ប.ជ៧១) បណ្តឹងឧទ្ធរណ៍ជាបន្ទាន់របស់លោក អៀង សារី ប្រឆាំងទៅនឹងសេចក្តីរបស់ ក.ស.ច.ស បដិសេធមិនទទួលយកការដាក់ឯកសារចម្លើយតបរបស់លោក អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៦៦ និងសេចក្តីសង្កេតបន្ថែម និងសំណើសុំផ្អាកដំណើរការនីតិវិធី ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១០ ឯកសារD390/1/2/1 ERN: 00598683-00598696 កថាខណ្ឌ១-២។

ចៅក្រមស៊ើបអង្កេត ដូចខាងក្រោម"។ វិធាន ៧៤(៣) មិនបានបង្ហាញថា វិធាននេះ បានចែងផ្តាច់មុខ អំពីសិទ្ធិប្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី ដូចដែល ក.ស.ព អះអាងនោះទេ[49]។

១២. នៅកថាខណ្ឌ១៩ ក.ស.ព អះអាងថា ការបកស្រាយលើវិធាន២១ របស់មេធាវីការពារក្តី មានតម្លៃស្មើនឹងសំណើសុំទៅអង្គបុរេជំនុំជម្រះឲ្យធ្វើវិសោធនកម្មវិធានផ្ទៃក្នុង[50]។ នៅក្នុងយុត្តិសាស្ត្ររបស់ខ្លួន ដែលចែងថា វិធាន២១ បង្កើតនូវសិទ្ធិប្តឹងឧទ្ធរណ៍ដោយឯករាជ្យ អង្គបុរេជំនុំជម្រះមិនបានវិសោធនកម្ម តាមទំនើងចិត្ត ឬជាឯកច្ឆន្ទលើវិធាននីតិវិធីរបស់ អ.វ.ត.ក ទេ។ វិធាន២១ ចែងអំពីគោលការណ៍ស្មើភាពគ្នាចំពោះមុខច្បាប់ និងសមភាពនៃមធ្យោបាយការពារក្តី។ អង្គបុរេជំនុំជម្រះបានអនុវត្តវិធាន ២១ នៅពេលចាំបាច់ ដើម្បីធានាថា សិទ្ធិនានាដែលមានចែងនៅក្នុងវិធាន២១ ត្រូវបានគោរព។ កិច្ចប្រជុំពេញអង្គ មិនចាំបាច់មាន ដើម្បីផ្តល់ឲ្យលោក អៀង សារី នូវសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដូច ក.ស.ព អះអាងនោះទេ ដោយសារតែវិធានវិធានផ្ទៃក្នុងបានផ្តល់នូវសិទ្ធិទាំងនោះឲ្យពួកគាត់ហើយ។

១៣. នៅក្នុង កថាខណ្ឌ២០ ក.ស.ព អះអាងថា អង្គបុរេជំនុំជម្រះមិនមែនដើរតួជាតុលាការធម្មនុញ្ញ ដែលមានយុត្តាធិការពេញលេញ ដើម្បីពិនិត្យគ្រប់សេចក្តីសម្រេចនានារបស់តុលាការជាន់ក្រោមនោះទេ។ នេះគឺជាការអះអាងមិនសមស្រប។ ដូចដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង និងអនុលោមតាមការអនុវត្តពីមុន[51] អង្គបុរេជំនុំជម្រះត្រូវតែ អនុវត្តវិធាន២១ នៅពេលសិទ្ធិទទួលនូវការជំនុំជម្រះដោយយុត្តិធម៌របស់លោក អៀង សារី ត្រូវបានប៉ះពាល់ជាមូលដ្ឋាន។ ក.ស.ព យោងទៅលើយុត្តិសាស្ត្ររបស់តុលាការ ICTY ហាក់បីដូចជាយុត្តិសាស្ត្រនោះអាចអនុវត្តបាននៅ អ.វ.ត.ក យ៉ាងដូច្នេះដែរ។ អ.វ.ត.ក គឺមិនមែនជាតុលាការ ICTY ទេ ហើយវិធាននីតិវិធីរបស់តុលាការនេះ មានលក្ខណៈខុសគ្នា[52]។ អ.វ.ត.ក គឺជាតុលាការកម្ពុជា[53] ដែលផ្អែកលើប្រព័ន្ធនីតិវិធីដឹកសួរដោយចៅក្រម ដែលវាផ្ទុយនឹងតុលាការ ICTY ដែលបានប្រើប្រាស់នីតិវិធីសួរដេញដោលចំពោះមុខ។

---

[49] ចម្លើយតប កថាខណ្ឌ១៨។

[50] *ដូចជើងទំព័រខាងលើ។*

[51] សេចក្តីសម្រេវិធាន៦៦ កថាខណ្ឌ១៣។

[52] ជាការពិត ក.ស.ព អះអាងថា អ.វ.ត.ក បានអនុម័តនីតិវិធីផ្សេងជាសារវ័ន្តជាងតុលាការ ICTY។ បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ១៥។

១៨. នៅក្នុងកថាខណ្ឌ២១ ក.ស.ព អះអាងថា ការពង្រីកវិសាលភាពនៃសិទ្ធិប្ដឹងឧទ្ធរណ៍របស់លោក អៀង សារី អនុលោមតាមវិធានផ្ទៃក្នុង គឺមិនសមស្របនៅក្នុងនីតិវិធីនៅដំណាក់កាលនេះទេ។ ដំបូង វិធាន ២១ មិនបានពង្រីកវិសាលភាពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់លោក អៀង សារី ប៉ុន្តែគ្រាន់តែបានថែងធម្មតាអំពីសិទ្ធិនេះ។ ទីពីរ ចំពោះការលើកឡើងរបស់ ក.ស.ព ដែលថា សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់លោក អៀង សារី មិនសមស្របត្រូវយកមកពិចារណានៅដំណាក់នៃដំណើរការនីតិវិធីនាពេលនេះ អំណះអំណាងបែបនេះ បង្ហាញអំពីភាពខ្វះនូវការគោរពចំពោះសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់លោក អៀង សារី។ ប្រសិនបើលោក អៀង សារី មិនត្រូវបានអនុញ្ញាតឲ្យប្ដឹងឧទ្ធរណ៍ គាត់នឹងត្រូវបានបញ្ជូនទៅជំនុំជម្រះ នៅពេលដែលគាត់មិនគួរត្រូវបានបញ្ជូនទៅជំនុំជម្រះទាល់តែសោះ។ នេះជាទង្វើដែលរំលោភបំពានលើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលបានការពារ *ដោយវិធាននានាដែលក្នុងនោះ*មានទាំងវិធាន ៦៧(៣)(គ)[54]។ ទីបី អង្គបុរេជំនុំជម្រះបានសម្រេចរួចហើយថា បណ្ដឹងឧទ្ធរណ៍អាចនឹងត្រូវធ្វើទៅបាន ដោយគ្រាន់តែផ្អែកលើវិធាន២១ តែមួយបានហើយ ប្រសិនបើសិទ្ធិជាសារវន្តក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ត្រូវបានរំលោភបំពាន[55]។

### ២. បណ្ដឹងឧទ្ធរណ៍លើវិការៈផ្នែកទម្រង់នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ត្រូវតែពិចារណានៅដំណាក់កាលនេះ

១៩. នៅក្នុងកថាខណ្ឌ២៩ ក.ស.ព អះអាងថា វិការៈផ្នែកទម្រង់នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ គឺមិនមែនជាបញ្ហាយុត្តាធិការនោះទេ ដូចនេះវាមិនអាចប្ដឹងឧទ្ធរណ៍នោះទេ។ ដោយសារតែវិធានផ្ទៃក្នុងមានលក្ខណៈមិនច្បាស់លាស់ថាតើ និងនៅពេលណាដែលវិការៈផ្នែកទម្រង់នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះអាចត្រូវបានកែតម្រូវក្នុងអំឡុងពេលជំនុំជម្រះ ដូចនេះមានលទ្ធភាពដែលថា ការជំនុំជម្រះទាំងមូលនៅក្នុងសំណុំរឿង០០២ អាចធ្វើឡើងដោយដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលមានវិការៈ។ ក្នុងគោល

---

[53] ដូចជើងទំព័រខាងលើ កថាខណ្ឌ៨-២០។

[54] វិធាន៦៧(៣)(គ) បញ្ជាក់ថា "សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាលើកលែងចោទប្រកាន់ក្នុងករណីដូចខាងក្រោម៖.....។ ពុំមានភស្តុតាងគ្រប់គ្រាន់ដើម្បីផ្តន្ទាទោសជនត្រូវចោទ។"

[55] សាលដីកាលើវិធាន៦៦ កថាខណ្ឌ១៣។

បំណងនៃប្រសិទ្ធភាពតុលាការ វាចាំបាច់ណាស់ក្នុងការកែតម្រូវដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលមានវិការៈនៅដំណាក់កាលដំបូងបំផុតតាមតែអាចធ្វើទៅបាន។ ការកែតម្រូវដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលមានវិការៈឱ្យបានឆាប់រហ័ស តាមតែអាចធ្វើបាន នឹងបំពេញនូវកាតព្វកិច្ចប្រកបដោយវីរិយភាពរបស់អង្គបុរេជំនុំជម្រះ[56]។

១៦. វិការៈផ្នែកទម្រង់នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ប៉ះពាល់ដល់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌លើលោក អៀង សារី។ អង្គបុរេជំនុំជម្រះបានកែតម្រូវពីមុនចំពោះ ក.ស.ច.ស នៅពេលដែលកិច្ចរបស់ ក.ស.ច.ស ប៉ះពាល់ដល់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌[57]។ នៅពេល ក.ស.ច.ស ខកខានមិនបានអនុវត្តនូវបទដ្ឋានអន្តរជាតិ អង្គបុរេជំនុំជម្រះបានកែតម្រូវដីកាដំណោះស្រាយនៅក្នុងសំណុំរឿង០០១[58]។ ដំណើរការនីតិវិធីរបស់ អ.វ.ត.ក ត្រូវតែយុត្តិធម៌ដើម្បីគោរពតាមបទដ្ឋានអន្តរជាតិ[59]។ វិការៈផ្នែកទម្រង់នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ នឹងធ្វើឱ្យនីតិវិធីរបស់ អ.វ.ត.ក មានលក្ខណៈអយុត្តិធម៌ចំពោះលោក អៀង សារី ឧទាហរណ៍៖

ក. ប្រសិនបើដីកាដំណោះស្រាយផ្អែកលើសក្ខីកម្ម ទទួលបានតាមរយៈការធ្វើទារុណកម្ម ក.ស.ច.ស មានចេតនាផ្អែកលើព័ត៌មាន ដែលមិនអាចទទួលយកបាននៅ អ.វ.ត.ក។ មាត្រា ៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចែងច្បាស់ថា "លើកលែងបទប្បញ្ញត្តិច្បាប់ផ្ទុយពីនេះ ភស្តុតាងក្នុងរឿងព្រហ្មទណ្ឌ អាចជូនបានដោយសេរី"។ សក្ខីកម្មទទួលបានតាមរយៈការធ្វើទារុណកម្ម ត្រូវបានចាត់ទុកតាមផ្លូវច្បាប់ថាមិនអាចទទួលយក

---

[56] ក្រមសីលធម៌ចៅក្រមរបស់ អ.វ.ត.ក មាត្រា៥។

[57] *សូមមើល ឧទាហរណ៍* សាលដីកាលើវិធាន៦៦ កថាខណ្ឌ១៣។

[58] រឿងក្តី កាំង ហ្គេកអ៊ាវ សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/កសចស (អ.ប.ជ០២), សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើករណីរបស់កាំង ហ្គេកអ៊ាវ ហៅ "ឌុច" ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨ ឯកសារ D99/3/42 ERN: 00249846-00249887 ("សាលដីកាប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើករណី *ឌុច*") កថាខណ្ឌ៥៧។

[59] *សូមមើល* កិច្ចព្រមព្រៀង មាត្រា១៣(១)។ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា៣៥ថ្មី។

បាន[60]។ ក.ស.ច.ស បានបំពេញកិច្ចរំលោភបំពានដោយផ្ទាល់លើអង្គបុរេជំនុំជម្រះ និងបានបំពេញកិច្ច *ហួសអំណាចខ្លួន*។

ខ. ការប្រើប្រាស់ធាតុផ្សំនៃបទល្មើសមិនត្រឹមត្រូវ មិនបានផ្តល់នូវភាពច្បាស់លាស់នៃការចោទប្រកាន់ប្រឆាំងនឹងលោក អៀង សារីទេ។ ភាពមិនច្បាស់លាស់នេះ មិនបានអនុញ្ញាតឱ្យលោក អៀង សារី អាចរៀបចំការការពារខ្លួនប្រកបដោយប្រសិទ្ធភាព ដែលវាជាការរំលោភបំពានលើធម្មនុញ្ញរបស់ប្រទេសកម្ពុជា[61] កិច្ចព្រមព្រៀង[62] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[63] ICCPR[64] និង UDHR[65]។

គ. នៅពេលដីកាដំណោះស្រាយខកខានមិនបានថែងអំពីអង្គហេតុ ឬកិច្ចនានា ដែលកំណត់ ចំពោះបទល្មើសនីមួយៗ ឬទម្រង់នៃការទទួលខុសត្រូវ ក.ស.ច.ស ខកខានក្នុងការលើកឡើងអំពីមូលហេតុអ្វីបានជា ក.ស.ច.ស ជឿជាក់ថាមានភស្តុតាងគ្រប់គ្រាន់ក្នុងការចោទប្រកាន់លោក អៀង សារី ចំពោះបទឧក្រិដ្ឋនានា ឬផ្នែកតាមទម្រង់នៃការទទួលខុសត្រូវទាំងនោះ។ អង្គបុរេជំនុំជម្រះបានសម្រេចថា នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ "លក្ខណៈនៃការចូលរួមរបស់ជនជាប់ចោទនៅក្នុង JCE ត្រូវមានលក្ខណៈច្បាស់លាស់ ហើយនៅពេលដែលលក្ខណៈនៃការចូលរួមត្រូវបានធ្វើឡើងតាមការពិចារណា អយ្យការត្រូវបង្ហាញអត្តសញ្ញាណអំពីអង្គហេតុ និងកាលៈទេសៈនានានៅក្នុងការចោទប្រកាន់ ដែលការពិចារណាត្រូវបានស្នើឱ្យធ្វើ

---

[60] រឿងក្តី អៀង សារី សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អវតក/កសចស (អ.ប.ជ៣១) សាលដីកាសម្រេចលើការទទួលយកបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងការបដិសេធតាមការសន្និដ្ឋរបស់ ក.ស.ច.ស លើសំណើរបស់លោក អៀង សារី ទាក់ទងនឹងការទទួលស្គាល់របស់ ក.ស.ច.ស នូវភស្តុតាង និងការសំអាងទៅលើភស្តុតាងដែលទទួលបានតាមរយៈការធ្វើទារុណកម្ម ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១០ ឯកសារD130/7/3/5 ERN: 00512912-00512924 កថាខណ្ឌ៣៨។

[61] *សូមមើល*រដ្ឋធម្មនុញ្ញកម្ពុជា មាត្រា៣១។

[62] *សូមមើល* កិច្ចព្រមព្រៀង មាត្រា១៣(១)។

[63] *សូមមើល* ច្បាប់ស្តីពីការបង្កើតអ.វ.ត.ក មាត្រា៣៥ថ្មី។

[64] *សូមមើល* កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា១៤(១)។

[65] *សូមមើល* សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស មាត្រា១១(១)។

ឡើងផ្ដើមចេញពីការបង្ហាញអត្តសញ្ញាណនេះ”[66]។ មិនមានមូលហេតុដែលការណែនាំនេះ ត្រូវកំណត់ត្រឹមតែបញ្ហា JCE នោះទេ។ ក.ស.ច.ស តម្រូវឱ្យធ្វើសេចក្ដីព្រាងដីកាដំណោះស្រាយដោយរួមមានកម្រិតនៃភាពច្បាស់លាស់នេះ និងរៀបរាប់លម្អិតអំពីឧក្រិដ្ឋកម្មនិងទម្រង់នៃការទទួលខុសត្រូវទាំងអស់។ នៅក្នុងសំណុំរឿង០០១ នៅពេលក.ស.ច.ស ខកខានមិនបានលើកឡើងអំពីមូលដ្ឋានអង្គហេតុដែលខ្លួនបានផ្អែក នៅពេលដែលខ្លួនបានលើកឡើងថា “អំពើមួយចំនួន ដែលបានបង្ហាញដោយកិច្ចស៊ើបសួរ ក៏បង្កើតជាបទល្មើសក្រោមច្បាប់ជាតិផងដែរ” អង្គបុរេជំនុំជម្រះបានវិភាគ និងបានធ្វើការកែតម្រូវដីកាដំណោះស្រាយនេះ[67]។ អង្គបុរេជំនុំជម្រះត្រូវតែអនុវត្តឱ្យបានស្មើភាពគ្នាចំពោះមុខច្បាប់[68] ដោយអនុវត្តចំពោះជនជាប់ចោទនៅក្នុងសំណុំរឿង ០០២ ឱ្យដូចគ្នានឹងជនជាប់ចោទនៅក្នុងសំណុំរឿង០០១។ អង្គបុរេជំនុំជម្រះត្រូវតែកែតម្រូវវិការៈនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬផ្នែកដែលមានមិនមានសុពលនានានៃដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានចាត់ទុកជាមោឃៈ។ តុលាការ ICTY ក៏បានរកឃើញផងដែរនូវវិការៈនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ នៅពេលដែលដីកានេះខកខានក្នុងការថែងអំពីអង្គហេតុ ឬអំពើនានា ដែលកំណត់បទល្មើសនីមួយៗ ឬទម្រង់នៃការទទួលខុសត្រូវ៖

> ដីកាបញ្ជូនរឿងទៅជំនុំជម្រះ មានវិការៈប្រសិនបើដីកាខកខានមិនបានអះអាងអំពីអង្គហេតុសម្ភារៈដែលតម្រូវ។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលគ្រាន់តែបញ្ជូលបទចោទប្រឆាំងនឹងជនជាប់ចោទ ដោយមិនបានបង្ហាញអំពីអង្គហេតុសម្ភារៈ មិនមែនជាការជូនដំណឹងគ្រប់គ្រាន់ទេ ពីព្រោះវាខ្វះនូវព័ត៏មានលម្អិតគ្រប់គ្រាន់ក្នុងការ

---

[66] *រឿងក្ដី អៀង សារី* សំណុំរឿង០០២/១៩-០៩-២០០៧-អវតក/កសចស(អ.ប.ជ៣៥) សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE) ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ ឯកសារ D97/14/15 ERN: 00486521-00486589 (“អ.ប.ជ សាលដីកាលើការអនុវត្តសហឧក្រិដ្ឋកម្មរួម”) កថាខណ្ឌ៩៤។

[67] សាលដីកាប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើករណី *ឌុច* កថាខណ្ឌ៥៦, ៩៧-១០៣។

[68] រដ្ឋធម្មនុញ្ញកម្ពុជា មាត្រា៣១ ចែងក្នុងផ្នែកពាក់ព័ន្ធ “ប្រជាពលរដ្ឋខ្មែរគ្រប់រូបមានភាពស្មើគ្នាចំពោះមុខច្បាប់”។ កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធនយោបាយ មាត្រា១៤(១) ចែងក្នុងផ្នែកពាក់ព័ន្ធ “ជនគ្រប់រូប ត្រូវមានភាពស្មើគ្នាចំពោះមុខតុលាការ និងសាលាជម្រះក្ដី”។ សេចក្ដីប្រកាសជាសកលសស្ដីពីសិទ្ធីមនុស្ស មាត្រា៧ ចែងក្នុងផ្នែកពាក់ព័ន្ធ “មនុស្សគ្រប់រូបមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ និងសិទ្ធិទទួលការការពារពីច្បាប់ស្មើៗគ្នា ដោយគ្មានការរើសអើង។”

ជូនដំណឹងចុងចោទឲ្យច្បាស់អំពីការចោទប្រកាន់ប្រឆាំងនឹងគាត់ ដូចនេះគាត់អាចរៀបចំការការពារខ្លួនគាត់[69]។

ដោយសារការខកខានមិនបានបង្ហាញអង្គហេតុ ឬអំពើដែលកំណត់បទល្មើសនីមួយៗ ឬទម្រង់នៃការទទួលខុសត្រូវ ក.ស.ច.ស មិនបានជូនដំណឹងសមស្របដល់លោក អៀង សារី ចំពោះបទចោទប្រឆាំងនឹងរូបលោក ដែលមានភាពរំលោភបំពានលើកិច្ចព្រមព្រៀង[70] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[71] និង ICCPR[72]។

១៧. នៅកថាខណ្ឌ២៩ ក.ស.ព អះអាងថា លោក អៀង សារី នឹងមានសិទ្ធិតវ៉ាចំពោះភាពអាចទទួលយកបាននៃភស្តុតាងក្នុងអំឡុងពេលដំណាក់កាលជំនុំជម្រះ។ ទោះបីជាការលើកអំណះអំណាងនេះត្រឹមត្រូវបែបនោះមែនក៏ដោយ[73] ភស្តុតាងដែលគ្រាន់តែពិនិត្យ *ជាបឋម* មិនអាចទទួលយកបាន ដូចដែលបានកត់សម្គាល់ខាងលើ និងនៅក្នុងបណ្តឹងឧទ្ធរណ៍[74] មិនគួរត្រូវបានប្រើប្រាស់នៅក្នុងដំណើរការនីតិវិធីក្នុងដំណាក់កាលណាមួយនោះទេ ដែលក្នុងនោះរួមបញ្ចូលទាំងការប្រើប្រាស់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះ ដោយសារតែវារំលោភលើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់លោក អៀង សារី។ មេធាវីការពារក្តី នឹងមិនអាចបំពេញតួនាទីប្រកបដោយវិរិយភាពទេ ប្រសិនបើមេធាវីការពារក្តីមិនបានលើកឡើងបញ្ហាទាំងនេះចំពោះមុខអង្គបុរេជំនុំជម្រះ។ ដូចគ្នានេះដែរ អង្គបុរេជំនុំជម្រះនឹងមិនអាចបំពេញតួនាទីប្រកបដោយវិរិយភាព ប្រសិនបើអង្គបុរេជំនុំជម្រះមិនបានកែតម្រូវវិការៈនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះ[75]។

---

[69] *រឿងក្តីរដ្ឋអាជ្ញាតទល់នឹង* *Kvočka et al.*, សាលក្រមIT-98-30/1-A ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៥ កថាខណ្ឌ២៧-២៨។

[70] *សូមមើល* កិច្ចព្រមព្រៀង មាត្រា១៣(១)។

[71] *សូមមើល* ច្បាប់ស្តីពីការបង្កើតអ.វ.ត.ក មាត្រា៣៥ថ្មី។

[72] *សូមមើល* កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា១៤(៣)(ក) ដែលចែងក្នុងផ្នែកពាក់ព័ន្ធ "ត្រូវបានព័ត៌មានភ្លាមៗ និងដោយលំអិតអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់មកលើខ្លួនជាភាសាដែលជន នោះចេះ"។

[73] វិធាន៨៧(២)។

[74] *សូមមើលឧទាហរណ៍* បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ៥-៧។

[75] ក្រមសីលធម៌វិជ្ជាជីវៈតុលាការអ.វ.ត.ក មាត្រា៥។

១៨. នៅក្នុងកថាខណ្ឌ៣១ ក.ស.ព អះអាងថា មិនមានសិទ្ធិប្តឹងឧទ្ធរណ៍ទាក់ទងនឹងការខកខានរបស់ ក.ស.ច.ស ក្នុងការប្រើប្រាស់យន្តការដោះស្រាយជម្លោះ ដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង។ មេធាវីការពារក្តី មិនបានលើកអំណះអំណាងថា បណ្តឹងឧទ្ធរណ៍ផ្អែកលើការខកខានរបស់ ក.ស.ច.ស ក្នុងការប្រើប្រាស់យន្តការដោះស្រាយជម្លោះ។ បណ្តឹងឧទ្ធរណ៍មានលក្ខណៈចាំបាច់ដោយផ្អែក ពីព្រោះ <u>សហចៅក្រមស៊ើបអង្កេត មិនបានឯកភាពគ្នាពាក់ព័ន្ធនឹងបញ្ហាមូលដ្ឋាន និងមិនបានឯកភាពក្នុងការបញ្ជូនបញ្ហាទៅជំនុំជម្រះ ដោយមិនបានគិតពីការរំលោភបំពានយ៉ាងច្បាស់លើសិទ្ធិជាមូលដ្ឋានរបស់លោក អៀង សារី ដែលត្រូវបានសន្មតថានិរទោស។</u> កាតព្វកិច្ចរបស់អង្គបុរេជំនុំជម្រះ គឺការពារសិទ្ធិរបស់លោក អៀង សារី ដែលជាមូលហេតុបណ្តឹងឧទ្ធរណ៍ត្រូវតែទទួលយក មិនមែនពីព្រោះតែ ក.ស.ច.ស មិនបានប្រើប្រាស់យន្តការដោះស្រាយជម្លោះ ដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង។

**គ. បញ្ហានៃ *គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* អាចប្តឹងឧទ្ធរណ៍ ទោះបីជា ក.ស.ច.ស ខកខានមិនបានសម្រេចថាតើវាត្រូវរារាំងដោយយុត្តាធិការក៏ដោយ**

១៩. នៅក្នុងកថាខណ្ឌ៣៣ ក.ស.ព អះអាងថា មេធាវីការពារក្តីមិនអាចប្តឹងឧទ្ធរណ៍លើការខកខានរបស់ ក.ស.ច.ស ក្នុងការសន្និដ្ឋានថា គោលការណ៍*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* មិនបានរារាំងការកាត់សេចក្តីនាពេលបច្ចុប្បន្នរបស់គាត់ ដោយសារតែ ក.ស.ច.ស មិនបានសម្រេចលើបញ្ហានេះ ប៉ុន្តែបានសម្រេចទុកបញ្ហានេះជូនទៅអង្គជំនុំជម្រះសាលាដំបូង។ ផ្អែកតាម ក.ស.ព ក.ស.ច.ស មិនបានបញ្ជាក់អំពីយុត្តាធិការនៅក្នុងបញ្ហានេះទេ។ ករណីនេះគឺមិនត្រឹមត្រូវទេ។ ក.ស.ច.ស <u>មិនបានបំពេញតួនាទីតុលាការរបស់ខ្លួន</u> ហើយបែរជាប៉ុនប៉ងបង្វែរបញ្ហានេះជូនទៅអង្គជំនុំជម្រះសាលាដំបូង។ ការសម្រេចរបស់ ក.ស.ច.ស ក្នុងការទុកបញ្ហានេះជូនទៅអង្គជំនុំជម្រះសាលាដំបូង គឺជាការបញ្ជាក់អំពីយុត្តាធិការរបស់ អ.វ.ត.ក នៅក្នុងករណីនេះ ដូចនេះបញ្ហានេះអាចប្តឹងឧទ្ធរណ៍ អនុលោមតាមវិធាន៧៤(៣)(ក)។ ប្រសិនបើ ក.ស.ច.ស បានពិចារណាថា អ.វ.ត.ក មិនមានយុត្តាធិការ ក.ស.ច.ស នឹងមិនទុកបញ្ហានេះជូនទៅអង្គជំនុំសាលាដំបូងនោះទេ។ ក.ស.ព មិនបានផ្តល់សំអាងផ្លូវច្បាប់ក្នុងការគាំទ្រចំពោះការបកស្រាយរបស់ខ្លួនទៅនឹងការជំទាស់នេះទេ។ បញ្ហានេះក៏អាចប្តឹងឧទ្ធរណ៍តាមរយៈមាត្រា២១ ផងដែរ។ វាជាការរំលោភបំពានលើសិទ្ធិទទួលការជំនុំ

ជម្រះជាសារវ័ន្តរបស់លោក អៀង សារី ក្នុងការបញ្ជូនរឿងក្តីរបស់គាត់ទៅជំនុំជម្រះ ដោយមិនបាន កំណត់ថាតើគោលការណ៍*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* និងរារាំងការកាត់សេចក្តី។

**ឃ. បណ្តឹងឧទ្ធរណ៍មិនត្រូវបានរារាំងដោយការកន្លងទៅនៃពេលវេលាទេ**

២០. នៅកថាខណ្ឌ ៣៥-៤៤ ក.ស.ព អះអាងថា មូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍មួយចំនួន មិនត្រូវបានរារាំង ដោយការកន្លងទៅនៃពេលវេលានោះទេ ពីព្រោះសេចក្តីសម្រេចដែលបញ្ជាក់អំពីយុត្តាធិការរបស់ អ.វ.ត.ក ត្រូវបានធ្វើឡើង ពីមុនក្នុងអំឡុងពេលការស៊ើបអង្កេតតាមផ្លូវតុលាការ។ ក.ស.ព អះអាង ថា ដីកាឃុំខ្លួនលោក អៀង សារី បណ្តោះអាសន្នពីដើម បានបញ្ជាក់យុត្តាធិការរបស់ អ.វ.ត.ក លើ រូបលោក ដែលទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការរំលោភបំពានធ្ងន់ធ្ងរ។ ក.ស.ព អះអាងបន្ថែមថា យុត្តាធិការលើលោក អៀង សារី ទាក់ទងនឹងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មជាតិ និងទម្រង់នៃការទទួលខុសត្រូវចំពោះ "ការរៀបចំផែនការ ការញុះញង់ ការបញ្ជា ការប្រព្រឹត្ត ការជួយនិងជំរុញ ការសមគំនិត ការចូលរួម ការប៉ុនប៉ង សហឧក្រិដ្ឋកម្មរួម និង ការទទួលខុសត្រូវក្នុងនាមជាមេកើយ" ត្រូវបានបញ្ជាក់នៅក្នុងខែធ្នូ ឆ្នាំ២០០៩ នៅពេលដែលគាត់ ត្រូវបានជូនដំណឹងថា គាត់ត្រូវបានគេកំពុងស៊ើបអង្កេតចំពោះឧក្រិដ្ឋកម្មបន្ថែម[76]។ ក.ស.ព ក៏បាន អះអាងថា លោក អៀង សារី មាន "ឱកាសតវ៉ាអំពីយុត្តាធិការក៏មានច្រើនដែរ"[77] ដោយមិនបាន រៀបរាប់អំពីឱកាសផ្សេងៗទៀតអាចមានអ្វីខ្លះនោះទេ។ ជំហរនេះ គឺមិនស៊ីគ្នាជាមួយនឹងទឡ្ហីករណ៍ កាលពីមុនដែលធ្វើឡើងដោយ ក.ស.ព។ ឧទាហរណ៍ ក.ស.ព បានលើកទឡ្ហីករណ៍ពីមុនថា "ភាគីមិន អាចប្តឹងឧទ្ធរណ៍នូវបញ្ហាដែលមិនបានលើកឡើងឲ្យបាន<u>ច្បាស់លាស់</u> និងសម្រេចនៅក្នុងសេចក្តីសម្រេច ដែលបានតវ៉ាឡើយ"[78]។ ដីកាឃុំខ្លួនបណ្តោះអាសន្ន មិនបានលើកឡើង ឬសម្រេចច្បាស់លាស់លើ

---

[76] ចម្លើយតប កថាខណ្ឌ៣៩។

[77] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ៣៨។

[78] ករណី អៀង សារី សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អវតក/កសចស (អ.ប.ជ៦០) ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងការអនុវត្តទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១០ ឯកសារD345/5/2, ERN: 00508582-00508608 ("ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍ចំពោះការអនុវត្តនៃការ ទទួលខុសត្រូវថ្នាក់លើ") កថាខណ្ឌ១៦ (គូសបញ្ជាក់បន្ថែម)។

បញ្ហានៃយុត្តាធិការរបស់ អ.វ.ត.ក លើលោក អៀង សារី ដែលវាផ្សេងគ្នាពីបញ្ហានៃ RPA និងគោលការណ៍*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ*។ ក.ស.ព ក៏បានលើកទឡ្ហីករណ៍ថា "បណ្តឹងឧទ្ធរណ៍អាចធ្វើឡើងប្រឆាំងនឹងដីកាប៉ុណ្ណោះ និងមិនអាចប្រឆាំងនឹងឯកសារដទៃទៀតបានទេ"[79]។ កំណត់ហេតុស្តាប់ចម្លើយជនត្រូវចោទ (ដែលលោក អៀង សារី ត្រូវបានគេជូនដំណឹងថាគាត់បានប្រឈមបទចោទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងបទឧក្រិដ្ឋជាតិ) មិនមែនជាដីកា ដូចនេះយោងតាម ក.ស.ព ករណីនេះមិនអាចប្តឹងឧទ្ធរណ៍បានទេ ហេតុដូច្នេះមិនបណ្តាលឲ្យបណ្តឹងឧទ្ធរណ៍បច្ចុប្បន្នត្រូវបានរារាំងដោយការកន្លងទៅនៃពេលវេលានោះទេ។ បន្ថែមពីលើនេះ នៅពេលមេធាវីការពារក្តី មានបំណងតវ៉ាយុត្តាធិការរបស់ អ.វ.ត.ក លើឧក្រិដ្ឋកម្មមួយចំនួន ឬទម្រង់នៃការទទួលខុសត្រូវកាលពីអតីតកាល ក.ស.ព ខកខានទាំងការឆ្លើយតប (អញ្ចឹងហើយបានខកខានជំទាស់នឹងការទទួលយកបាន) ឬបានលើកឡើងថា មេធាវីការពារក្តីបានដាក់សំណើសុំឲ្យមានការបកស្រាយច្បាប់[80]។ រហូតដល់បានឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍នេះ និងសំណើសុំបន្ថែមចំនួនទំព័រដែលពាក់ព័ន្ធ[81] ក.ស.ពមិនដែលលើកឡើងថា បញ្ហាទាំងនេះត្រូវបានរារាំងដោយការកន្លងទៅនៃពេលវេលានោះទេ។ ជាជាងការប្រកាន់ជំហរស៊ីសង្វាក់គ្នាដែលស្របនឹងច្បាប់ជាធរមាន និងនីតិវិធី ក.ស.ពតែងតែលើកឡើងនូវទឡ្ហីករណ៍អ្វីក៏ដោយ ដែលក.ស.ព ជឿជាក់ថានឹងនាំឲ្យមានការបដិសេធបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី ផ្អែកលើមូលដ្ឋាននៃការទទួលយកបាននៃបណ្តឹង។

---

[79] *ករណី អៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អវតក/កសចស (អ.ប.ជ៣៥, ៣៨& ៣៩) ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង សារី, អៀង ធីរិទ្ធ និងខៀវ សំផន ស្តីអំពីសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១០ ឯកសារ D97/14/10, ERN: 00463937-00463971 ("ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍ស្តីអំពីសហឧក្រិដ្ឋ-កម្មរួម") កថាខណ្ឌ៥។ កត់សម្គាល់ថា មេធាវីការពារក្តីមិនយល់ស្របជាមួយនឹងជំហរនេះ ហើយការកត់សម្គាល់នៅទីនេះ គឺដើម្បីបង្ហាញទឡ្ហីករណ៍មិនស៊ីសង្វាក់គ្នារបស់ក.ស.ព ជាមួយនឹងការគោរពចំពោះភាពអាចទទួលយកបាន។

[80] *សូមមើលឧទាហរណ៍ ដូចជើងទំព័រខាងលើ* កថាខណ្ឌ៥-៦, ១៣។ ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍ចំពោះការអនុវត្តនៃការទទួលខុសត្រូវថ្នាក់លើ កថាខណ្ឌ៦។

[81] *សូមមើលករណី អៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អវតក/កសចស (អ.ប.ជ៧៥) សេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញា ទៅលើសំណើរបស់ អៀង សារី សុំបន្ថែមចំនួនទំព័រចំពោះបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាដំណោះស្រាយ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៧ ឯកសារD427/1/2, ERN: 00609966-00609970 កថាខណ្ឌ៧។ ចម្លើយតប កថាខណ្ឌ៣៦-៤២។

២១. បណ្តឹងឧទ្ធរណ៍មិនត្រូវបានរារាំងដោយការកន្លងទៅនៃពេលវេលានោះទេ ពីព្រោះថា ក.ស.ច.ស ទើបតែបានបញ្ជាក់យុត្តាធិការរបស់ អ.វ.ត.ក នៅពេលដែលដីកាដំណោះស្រាយត្រូវបានចេញតែប៉ុណ្ណោះ។ មេធាវីការពារក្តីមានបំណងលើកឡើងការតវ៉ានឹងបញ្ហាយុត្តាធិការជាច្រើន ក្នុងអំឡុងពេលកិច្ចស៊ើបអង្កេតតាមផ្លូវតុលាការ[82] និងក.ស.ច.ស បានជូនដំណឹងម្តងហើយម្តងទៀត ថា ខ្លួននឹង "ធ្វើការពិនិត្យលើ" អំពីការតវ៉ា នៅពេលដែលចេញដីកាដំណោះស្រាយ[83]។ វាច្បាស់ណាស់ដែលថា

---

[82] *សូមមើលឧទាហរណ៍ ករណី អៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អវតក/កសចស សំណើរបស់លោក អៀង សារី ប្រឆាំងទៅនឹងលទ្ធភាពនៃការយកច្បាប់ស្តីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍មកអនុវត្តនៅ អ.វ.ត.ក ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៩ ឯកសារD240 ERN: 00401925-00401940។ *ករណី អៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អវតក/កសចស សំណើលោក អៀង សារី ប្រឆាំងនឹងការអនុវត្តការទទួលខុសត្រូវរបស់ថ្នាក់លើនៅ អ.វ.ត.ក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១០ ឯកសារD345/2 ERN: 00475513-00475527។ *ករណីអៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អវតក/កសចស ពាក្យសុំរបស់ លោក អៀង សារី ប្រឆាំងទៅនឹងការអនុវត្តន៍ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅ អវតក ចុះថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១០ ឯកសារD378 ERN: 00498540-00498552។ *ករណីអៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អវតក/កសចស ញត្តិផ្សេងទៀតរបស់លោក អៀង សារី ស្តីពីព្រំដែនកម្រិតលទ្ធភាពអនុវត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅអវតក ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១០ ឯកសារD378/2 ERN: 00542117-00542132។ *ករណីអៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អវតក/កសចស ញត្តិរបស់លោក អៀង សារី ប្រឆាំង នឹងការអនុវត្តឧក្រិដ្ឋកម្មនានាដែលមានចែងក្នុងមាត្រា៣ថ្មី នៃច្បាប់បង្កើត អ.វ.ត.ក (បទល្មើសនៅក្នុងច្បាប់ជាតិ) នៅអ.វ.ត.ក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០ ឯកសារD382 ERN: 00532798-00532812។ *ករណី អៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អវតក/កសចស សំណើសុំរបស់ អៀង សារី ជំទាស់ទៅនឹងការអនុវត្តអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ នៅ អវតក ចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១០ ឯកសារD379 ERN: 00511576-00511589។ *ករណី អៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អវតក/កសចស សំណើសុំជាជម្រើសរបស់លោក អៀង សារី ស្តីពីការកំណត់ព្រំដែនចំពោះការអនុវត្តអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ នៅអ.វ.ត.ក ចុះថ្ងៃ១ ខែមិថុនា ឆ្នាំ២០១០ ឯកសារD379/2 ERN: 00526277-00526292 ("សំណើសុំជាជម្រើស ស្តីពីការកំណត់ព្រំដែនចំពោះការអនុវត្តអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ")។

[83] *ករណី អៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អវតក-កសចស ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរទៅលើលទ្ធភាពនៃការយកច្បាប់ស្តីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍មកអនុវត្តនៅ អ.វ.ត.ក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០៩ ឯកសារD240/3 ERN: 00421137-00421140។ *ករណី អៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អវតក-កសចស ដីកាសម្រេចលើសំណើលោក អៀង សារី ប្រឆាំងនឹងការអនុវត្តទ្រឹស្តីនៃការទទួលខុសត្រូវរបស់មេកើយ នៅ អ.វ.ត.ក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១០ ឯកសារD345/4 ERN: 00487605-00487608។ *ករណី អៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អវតក-កសចស សំបុត្រពីក្រឡាបញ្ជី ក.ស.ច.ស ផ្ញើជូនមេធាវីការពារ : សំណើសុំប្រឆាំងនឹងការអនុវត្តឧក្រិដ្ឋកម្មប្រឆាំង

ក.ស.ច.ស មិនបានពិចារណាថា សេចក្ដីសម្រេចត្រូវបានធ្វើឡើងរួចហើយចំពោះការជំទាស់នឹងយុត្តាធិការទាំងនេះ។ រហូតមកទល់ពេលចេញដីកាដំណោះស្រាយ មេធាវីការពារក្ដីមិនមានភាពច្បាស់លាស់ថាតើវានឹងមានការជំនុំជម្រះមួយដែរឬទេ និងថាតើវានឹងមានមូលហេតុណាមួយក្នុងការជំទាស់ទៅនឹងយុត្តាធិការរបស់ អ.វ.ត.ក ដែរឬអត់។ ដីកាដំណោះស្រាយបញ្ជាក់អំពីយុត្តាធិការរបស់ អ.វ.ត.ក ក្នុងការនាំលោក អៀង សារី ទៅជំនុំជម្រះ ហេតុដូច្នេះបញ្ហាយុត្តាធិការនេះអាចប្ដឹងឧទ្ធរណ៍អនុលោមតាមវិធាន៧៤(៣)(ក)។

២២. នៅក្នុងកថាខណ្ឌ៣៦ ក.ស.ព អះអាងថា មូលដ្ឋានមួយចំនួននៃបណ្ដឹងឧទ្ធរណ៍ មិនត្រូវការពិចារណានៅដំណាក់កាលមុនអង្គសេចក្ដីទេ ដោយសារតែលោក អៀង សារី នឹងមានឱកាសតវ៉ាយុត្តាធិការរបស់ អ.វ.ត.ក ចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។ ថាតើលោក អៀង សារី អាចមានឱកាសនៅពេលជំនុំជម្រះក្នុងការតវ៉ាចំពោះយុត្តាធិការ គឺមិនមានភាពពាក់ព័ន្ធទេ។ សិទ្ធិរបស់គាត់ត្រូវតែទទួលបានការការពាររាល់គ្រប់ដំណាក់កាលទាំងអស់នៃដំណើរការនីតិវិធី។ វិធាន៧៤(៣)(ក) ចែងយ៉ាងច្បាស់អំពីសិទ្ធិរបស់លោក អៀង សារី ក្នុងការជំទាស់នឹងដីកាដែលបញ្ជាក់អំពីយុត្តាធិការនៅមុនអង្គសេចក្ដី។ ការជំនុំជម្រះមិនអាចធ្វើឡើងនោះទេ ប្រសិនបើអ.វ.ត.ក ខ្វះយុត្តាធិការនោះ។

២៣. នៅក្នុងកថាខណ្ឌ៣៦ និង៣៧ ក.ស.ព អះអាងថា ការសន្សំសំចៃរបស់តុលាការ តម្រូវឱ្យអង្គបុរេជំនុំជម្រះយល់ឃើញថាជាមូលដ្ឋានមួយចំនួននៃបណ្ដឹងឧទ្ធរណ៍ ដែលមិនត្រូវទទួលយកបាន។ ការសន្សំសំចៃតុលាការគាំទ្រសេចក្ដីសន្និដ្ឋានផ្ទុយពីក.ស.ព។ វានឹងមានប្រសិទ្ធភាពកាន់តែខ្លាំងប្រសិនបើបញ្ហានានាដែលលើកឡើងនៅក្នុងបណ្ដឹងឧទ្ធរណ៍ ត្រូវបានសម្រេចនៅដំណាក់កាលនេះ ដូចនេះបញ្ហាទាំងនេះមិនត្រូវការមានចំណាត់ការផ្លូវច្បាប់សាជាថ្មីនៅពេលជំនុំជម្រះទេ។

---

នឹងមនុស្សជាតិនៅ អ.វ.ត.ក ចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១០ ឯកសារD378/1 ERN: 00511620-00511620។ *ករណី អៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អវតក-កសចស សំបុត្រពីក្រឡាបញ្ជី ក.ស.ច.ស ផ្ញើជូនមេធាវីការពារ : ញត្តិប្រឆាំងនឹងការអនុវត្តឧក្រិដ្ឋកម្មនានា ដែលមានចែងក្នុងមាត្រា៣ថ្មី នៃច្បាប់បង្កើត អ.វ.តក (បទល្មើសនៅក្នុងច្បាប់ជាតិ) នៅ អ.វ.ត.ក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១០ ឯកសារD382/1 ERN: 00534062-00534062។ *ករណីអៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អវតក-កសចស សំបុត្រពីក្រឡាបញ្ជី ក.ស.ច.ស ផ្ញើជូនមេធាវីការពារ : សំណើសុំប្រឆាំងនឹងការអនុវត្តអំពើបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវនៅ អ.វ.ត.ក ចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១០ ឯកសារD379/1 ERN: 00511617-00511617។

### ង. បណ្តឹងឧទ្ធរណ៍មិនត្រូវបានរារាំងដោយអាជ្ញាអស់ជំនុំទេ

២៤. នៅក្នុងកថាខណ្ឌ៤៥-៥២ ក.ស.ព អះអាងថា បញ្ហានៃ RPA និងការអនុវត្តJCE ត្រូវបានរារាំងដោយ *អាជ្ញាអស់ជំនុំ*។ ករណីនេះគឺមិនត្រឹមត្រូវទេ។ ទោះបីជាបញ្ហា RPA ត្រូវបានដោះស្រាយពីមុនដោយអង្គបុរេជំនុំជម្រះក្តី សេចក្តីសម្រេចរបស់វាត្រូវបានធ្វើឡើងនៅក្នុងបរិបទនៃបណ្តឹងឧទ្ធរណ៍ទាក់ទិននឹងការឃុំខ្លួនបណ្តោះអាសន្ន។ វា*គ្រាន់តែ*កំណត់ថាតើ RPA នឹង "ដែលបានផ្តល់ភស្តុតាងយ៉ាងច្បាស់ថា ជាការរារាំងដល់ការកាត់ទោស" ដោយ អ.វ.ត.ក[84]។ នេះខុសគ្នាពីសេចក្តីសម្រេចស្តាពរថាតើ អ.វ.ត.ក មានយុត្តាធិការលើលោក អៀង សារី។ ដូចដែលបានរៀបរាប់នៅក្នុងបណ្តឹងឧទ្ធរណ៍ នៅពេលអង្គបុរេជំនុំជម្រះបានសម្រេចថា "បទល្មើសទាំងឡាយដែលមានចែងនៅក្នុងច្បាប់នេះ [ច្បាប់ឆ្នាំ១៩៩៤] មិនស្ថិតនៅក្រោមសមត្ថកិច្ចរបស់ អ.វ.ត.ក ឡើយ"[85] ដីកាដំណោះស្រាយមិនត្រូវបានចេញ ហើយបទឧក្រិដ្ឋដែលលោក អៀង សារី ជាចុងក្រោយត្រូវបានចោទប្រកាន់ គឺមិនត្រូវបានដឹងនូវភាពច្បាស់លាស់ណាមួយទេ[86]។ វាមានតែពេលនេះហើយដែលដីកាដំណោះស្រាយត្រូវបានចេញ ដូចនេះអង្គបុរេជំនុំជម្រះអាចកំណត់សម្រេចថាតើបទឧក្រិដ្ឋទាំងនេះ ត្រូវបានគ្របដណ្តប់ដោយច្បាប់ឆ្នាំ១៩៩៤ ដែរឬយ៉ាងណា។ លោក អៀង សារី ត្រូវបានចោទប្រកាន់បន្ថែមពីបទប្រល័យពូជសាសន៍ និងបទឧក្រិដ្ឋជាតិ តាំងពីពេលមានចេញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងការតវ៉ាដំបូងនានាចំពោះមុខអង្គបុរេជំនុំជម្រះស្តីពីការអនុវត្តនូវ RPA ចំពោះមុខ អ.វ.ត.ក[87]។ ការអនុវត្ត RPA ចំពោះបទចោទបន្ថែមទាំងនេះ មិនត្រូវបានពិចារណា និងសម្រេចដោយអង្គបុរេជំនុំជម្រះឲ្យបានពេញលេញទេ។ ពាក់ព័ន្ធនឹងបញ្ហានៃការអនុវត្ត JCE មេធាវីការពារក្តីបានកត់សម្គាល់ថា ករណីនេះត្រូវបានចងភ្ជាប់កាតព្វកិច្ចដោយសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ

---

[84] *ករណីអៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អវតក/កសចស (អ.ប.ជ០៣) សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនជនត្រូវចោទ អៀង សារី បណ្តោះអាសន្ន ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៨ ឯកសារC22/I/73 ERN: 00232830-00232861 ("អ.ប.ជ សាលដីកាលើការឃុំខ្លួនបណ្តោះអាសន្ន") កថាខណ្ឌ១៦។

[85] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ៦១។

[86] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ៤៤-៤៥។

[87] *រឿងក្តី អៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អវតក/កសចស កំណត់ហេតុនៃការសួរចម្លើយជនជាប់ចោទ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៩ ឯកសារD282 ERN: 00417104-00417108 កថាខណ្ឌ១២-១៣។

ពីមុន[88]។ វាគ្រាន់តែថែងអំពីជំហរចំពោះការអនុវត្ត JCE ដើម្បីដោះស្រាយបញ្ហាយុត្តាធិការដែលបាន លើកឡើងនៅក្នុងដីកាដំណោះស្រាយឲ្យបានពេញលេញ និងដើម្បីបញ្ជាក់ឲ្យច្បាស់ថា មេធាវីការពារក្ដីមិនបោះបង់ចោលជំហររបស់ខ្លួនពាក់ព័ន្ធនឹងភាពអាចអនុវត្តបាននៃ JCE នោះទេ។ មេធាវីការពារក្ដីក៏បានលើកឡើងបញ្ហាផ្សេងទៀតទាក់ទិននឹង JCE ដែលមិនទាន់បានសម្រេចជាស្ថាពរដោយ អង្គបុរេជំនុំជម្រះនោះទេ[89]។ ដោយសារតែបញ្ហាទាំងនេះមិនទាន់ត្រូវបានសម្រេចជាស្ថាពរ បញ្ហាទាំងនេះមិនមែនជាអាជ្ញាអស់ជំនុំ ហើយបញ្ហាទាំងនេះអាចលើកឡើងនៅក្នុងបណ្ដឹងឧទ្ធរណ៍។

## III. បញ្ហាបឋម៖ សហចៅក្រមស៊ើបអង្កេតប្រើប្រាស់ភស្តុតាងព្រឹត្តិការណ៍ដែលស្ថិតនៅក្រៅយុត្តាធិការក្នុងពេលវេលានៃ អ.វ.ត.ក

២៥. នៅក្នុងកថាខណ្ឌ៥៣ ក.ស.ព អះអាងថា “អៀង សារីជំទាស់ថា សហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំ ដោយយកភស្តុតាងនិងព្រឹត្តិការណ៍នានា ដែលបានកើតឡើងនៅមុនពេល និងក្រោយពេលនៃយុត្តាធិការពេលវេលារបស់ អ.វ.ត.ក មកប្រើ”។ អំណះអំណាងនេះ ជាការយល់ខុសចំពោះទឡ្ហីករណ៍របស់មេធាវីការពារក្ដីលើចំណុចនេះ[90]។ នៅក្នុងបណ្ដឹងឧទ្ធរណ៍ មេធាវីការពារក្ដីមិនបានលើកទឡ្ហីករណ៍ថា ភស្តុតាងព្រឹត្តិការណ៍មុនពេល ឬក្រោយពេលយុត្តាធិការក្នុងពេលវេលានៃ អ.វ.ត.ក ត្រូវតែមិនទទួលយកជាស្វ័យប្រវត្តិនោះទេ។ ប៉ុន្តែ មេធាវីការពារក្ដីបានអះអាងថា កិច្ចខាងក្រៅយុត្តាធិការក្នុងពេលវេលា មិនអាចទទួលយកសម្រាប់ការវាយតម្លៃថាតើធាតុផ្សំទាំងអស់តម្រូវឲ្យបង្ហាញ ដើម្បីបង្កើតឲ្យបានបទល្មើសនោះទេ[91]។ ដូច្នេះ កិច្ចខាងក្រៅយុត្តាធិការក្នុងពេលវេលារបស់ អ.វ.ត.ក មិនអាចពិចារណាដើម្បីបង្កើតជាធាតុផ្សំនៃ៖ ក. “ការវាយប្រហារ” ដែលចោទប្រកាន់ទាក់ទិននឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[92] ខ. ថាតើ “ការវាយប្រហារ” គឺ “សំដៅ

[88] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ២៤៩។

[89] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ២៦៤-៧២។

[90] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ១៩២, ១៩៥, ១៩៨។

[91] *ដូចជើងទំព័រខាងលើ* លេខ ៤២៤។

[92] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ១៩២។

ប្រឆាំងលើប្រជាជនស៊ីវិល"[93] ឬ គ. ថាតើ "ការវាយប្រហារ" ស្ថិតនៅក្នុងមូលដ្ឋានរើសអើងទេ[94]។ សេចក្តីសន្និដ្ឋាននេះ ធ្វើឡើងដោយគ្មានអន្តរាយទៅដល់បញ្ហាដែលថា ភស្តុតាងដែលបង្កើតនូវទង្វើដោយមានលក្ខណៈលំនាំ ការរៀបចំ ឬដំណើរនៃការប្រព្រឹត្តិជាប្រព័ន្ធរបស់ជនជាប់ចោទ ឬផ្តល់នូវបរិបទ ឬសាវតាបទល្មើសដែលស្ថិតនៅក្នុងយុត្តាធិការក្នុងពេលវេលានៃអ.វ.ត.ក អាចនឹងទទួលយកបាន។

## IV. អ.វ.ត.ក មិនមានយុត្តាធិការបុគ្គលលើរូបលោក អៀង សារី ទេ

### ក. ព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោស រារាំងការកាត់សេចក្តីលើលោក អៀង សារី

#### ១. ច្បាប់១៩៩៤ ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលចោទប្រកាន់នាពេលថ្មីៗនេះ

២៦. នៅក្នុងកថាខណ្ឌ៦១ ក.ស.ព អះអាងថា ច្បាប់ឆ្នាំ១៩៩៤ បានចែងជាបទល្មើសនូវសមាជិកភាពរបស់ពួកខ្មែរក្រហមរយៈពេល ៦ខែ បន្ទាប់ពីច្បាប់នេះចូលជាធរមានអនុវត្តន៍នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៤[95]។ នេះជាការយល់ឃើញមិនសមទំនងចំពោះច្បាប់ឆ្នាំ១៩៩៤។ វានឹងពិតជាផ្តល់អភ័យឯកសិទ្ធិ ចំពោះសមាជិកខ្មែរក្រហមដែលប្រព្រឹត្តបទឧក្រិដ្ឋ និងមិនត្រូវបានផ្តន្ទាទោសរយៈពេល ៦ខែ។ មាត្រា៥ នៃច្បាប់ឆ្នាំ១៩៩៤ បានចែងយ៉ាងច្បាស់ថា៖ "ច្បាប់នេះអនុគ្រោះទុកពេល ៦ ខែ ក្រោយពីចូលជាធរមានឲ្យជនជាសមាជិកអង្គការនយោបាយ ឬ ជាកម្លាំងយោធានៃក្រុម "កម្ពុជាប្រជាធិបតេយ្យ" វិលត្រឡប់មករួមរស់ក្រោមការគ្រប់គ្រងរបស់រាជរដ្ឋាភិបាល ក្នុងព្រះរាជាណាចក្រកម្ពុជា <u>ដោយមិនយកទោសពៃចំពោះបទល្មើសដែលខ្លួនប្រព្រឹត្ត</u>"[96]។ ការអានធម្មតាចំពោះមាត្រា៥ នៃច្បាប់ឆ្នាំ១៩៩៤ ចែងយ៉ាងច្បាស់ថា សមាជិកខ្មែរក្រហមបានចូលរួមជាមួយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាក្នុងរយៈពេល ៦ខែ មិនត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋនានាដែលខ្លួនធ្លាប់បាន

---

[93] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ១៩៥។

[94] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ១៩៨។

[95] ច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឲ្យនៅក្រៅច្បាប់ ព្រះរាជក្រឹត្យក្រមលេខ០១ , ន.ស ៩៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៤។

[96] ច្បាប់ឆ្នាំ១៩៩៤ មាត្រា៥ (គូសបញ្ជាក់បន្ថែម)។

ប្រព្រឹត្ត កាលនៅជាសមាជិកខ្មែរក្រហមឡើយ។ ដោយសារបុគ្គលម្នាក់អាចជាសមាជិកខ្មែរក្រហម ក្នុងអំឡុងពេលដែល អ.វ.ត.ក មានយុត្តាធិការពេលវេលានោះ បទឧក្រិដ្ឋនានាដែលអាចផ្តន្ទាទោស បានក្រោមច្បាប់ឆ្នាំ១៩៩៤ ស្ថិតក្រោមយុត្តាធិការពេលវេលារបស់ អ.វ.ត.ក[97]។

**២. ព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោស (RPA) គ្របដណ្តប់ទៅលើបទឧក្រិដ្ឋទាំងអស់ដែលលោក អៀង សារី ត្រូវបានចោទប្រកាន់នាពេលបច្ចុប្បន្ន**

២៧. នៅក្នុងកថាខណ្ឌ៦២ ក.ស.ព អះអាងថា លោក អៀង សារី មិនបានទទួលការអនុគ្រោះទោសចំពោះបទល្មើសដែលអាចត្រូវបានប្រព្រឹត្តចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ទេ។ ការអះអាងបែបនេះមិនត្រឹមត្រូវទេ ដោយសារ ក.ស.ច.ស និងអង្គបុរេជំនុំជម្រះបានសម្រេចថា៖ "សុពលភាពនៃការលើកលែងទោស<u>មិនមានភាពប្រាដកប្រជា</u>"[98]។ ដូចបានអះអាងនៅក្នុងបណ្តឹងឧទ្ធរណ៍រួចមកហើយ គឺថា ការអនុគ្រោះទោសធានាថា លោក អៀង សារី នឹងមិនអនុវត្តការផ្តន្ទាទោស ទាក់ទិននឹងការចោទប្រកាន់ ដោយផ្អែកលើអំពើនានាដែលបានលើកឡើងនៅក្នុងសវនាការឆ្នាំ១៩៧៩ ដែលជាអំពើទាំងអស់ដែលត្រូវបានលើកយកមកពិភាក្សានៅ អ.វ.ត.ក[99]។

២៨. នៅកថាខណ្ឌ៦៣ ក.ស.ព អះអាងថា ការបកស្រាយទៅលើការអនុគ្រោះទោសដែលមិនមានឥទ្ធិពលនៅ អ.វ.ត.ក នឹងគោរពដល់កាតព្វកិច្ចរបស់កម្ពុជា នៅក្រោមច្បាប់អន្តរជាតិ។ ក.ស.ព ខកខានមិនបានអះអាងថា តើកាតព្វកិច្ចបែបណាខ្លះ ដែលប្រទេសកម្ពុជាត្រូវគោរពក្រោមច្បាប់អន្តរជាតិ។ អ.វ.ត.ក គឺជាតុលាការកម្ពុជា និងត្រូវគោរពច្បាប់កម្ពុជា រួមទាំង RPA ផង។ មានតែរដ្ឋាភិបាលកម្ពុជាទេដែលមានអំណាចគោរពដល់កាតព្វកិច្ចរបស់កម្ពុជាក្រោមច្បាប់អន្តរជាតិ ទោះបីកាតព្វកិច្ចនោះជាអ្វីក៏ដោយ។ តាមពិត រដ្ឋាភិបាលកម្ពុជាពិតជាបានគោរពដល់កាតព្វកិច្ចជាអន្តរជាតិ ដោយអនុវត្តតាម

---

[97] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ៨៤-៨៥។

[98] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ១៣៣០ ទាញសំអាងហេតុ អ.ប.ជ សាលដីកាលើការឃុំខ្លួនបណ្តោះអាសន្ន កថាខណ្ឌ៥៨ (គូសបញ្ជាក់បន្ថែម)។

[99] *សូមមើល*បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ៩៦-៩៧, ៩៩។

មាត្រា៦(៥) នៃពិធីសារបន្ថែមទីII[100]។ មាត្រា៦(៥) នៃពិធីសារបន្ថែមទីII អះអាងថា "នៅពេលបញ្ចប់អរិភាព អាជ្ញាធរមានសមត្ថកិច្ចត្រូវខិតខំប្រឹងប្រែង ដើម្បីផ្តល់ជូននូវការលើកលែងទោសឱ្យមានកាន់តែទូលំទូលាយតាមតែអាចធ្វើបាន ដល់បុគ្គលដែលធ្លាប់បានចូលរួមក្នុងជម្លោះប្រដាប់អាវុធ ..."។ RPA បានចង្អុលបង្ហាញពីចំណុចនេះហើយ។ នៅពេលបញ្ចប់ជម្លោះជាមួយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ព្រះមហាក្សត្រព្រះបាទ សីហនុ បានប្រទានការលើកលែងទោសដល់លោក អៀង សារី។ RPA ត្រូវតែបានបកស្រាយឱ្យទូលំទូលាយ ដើម្បីឱ្យប្រទេសកម្ពុជាគោរពដល់កាតព្វកិច្ចរបស់ខ្លួនក្រោមច្បាប់អន្តរជាតិ ពោលគឺមាត្រា៦(៥) នៃពិធីសារបន្ថែមទីII នេះ[101]។

២៩. នៅក្នុងកថាខណ្ឌ៦៣ ក.ស.ព បានដកស្រង់សេចក្តីថ្លែងការណ៍របស់នាយករដ្ឋមន្ត្រីសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ពីខែតុលា ឆ្នាំ១៩៩៦ ដែលបានថ្លែងអះអាងពីចេតនារបស់រដ្ឋាភិបាលកម្ពុជាទាក់ទិននឹង RPA នេះ[102]។ ទីមួយ អត្ថបទដកស្រង់ពីខែតុលា ឆ្នាំ១៩៩៦ - បន្ទាប់ពី RPA ត្រូវបានឡាយព្រះហស្តលេខាប្រកាសឱ្យប្រើរួច - មិនបានបង្ហាញពីចេតនារបស់រដ្ឋាភិបាលមុន ឬក្នុងអំឡុងពេលប្រកាសឱ្យប្រើនោះទេ។ ទីពីរ នាយករដ្ឋមន្ត្រី ហ៊ុន សែន មិនបានតំណាងឱ្យរដ្ឋាភិបាលតែម្នាក់ឯងទេ នាពេលនោះ។ ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ ក៏ជាសហនាយករដ្ឋមន្ត្រីដែរ។ ទីបី មុនពេល និងក្នុងអំឡុងពេលប្រកាសឱ្យប្រើការអនុគ្រោះទោសនោះ ចេតនារបស់រដ្ឋាភិបាលកម្ពុជាមានការផ្ទុយស្រឡះទៅនឹងអ្វីដែលបានលាបពណ៌ដោយ ក.ស.ព។ រដ្ឋាភិបាលកម្ពុជា រដ្ឋសភា និងប្រជាពលរដ្ឋកម្ពុជាមានចេតនាផ្តល់ការអនុគ្រោះទោស ដើម្បីបញ្ចប់សង្គ្រាមស៊ីវិលនៅកម្ពុជា[103] លោក អៀង សារី ទទួលយកតែ RPA ប៉ុណ្ណោះ ដើម្បីដោះស្រាយបញ្ហាទាំងអស់។ ដូចបានអះអាងនៅក្នុង

---

[100] ពិធីសារបន្ថែមអនុសញ្ញាទីក្រុងហ្សឺណែវ នៃថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ និង ទាក់ទងនឹងការការពារជនរងគ្រោះ នៃទំនាស់ប្រដាប់អាវុធមិនអន្តរជាតិ ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ១៩៧៧ ("ពិធីសារបន្ថែម II")។

[101] ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នពិធីសាបន្ថែមទី២ នៅថ្ងៃទី១៤ ខែមករា ឆ្នាំ១៩៩៨។

[102] ចម្លើយតប ជើងទំព័រ១៨៧ *ដកស្រង់ពី* សៀវភៅនិពន្ធដោយTOM FAWTHROP AND HELEN JARVIS មានចំណងជើងថា GETTING AWAY WITH GENOCIDE? ELUSIVE JUSTICE AND THE KHMER ROUGE TRIBUNAL 172 (បោះពុម្ពដោយ UNIVERSITY OF NEW SOUTH WALES PRESS LTD, 2005) *យោងអត្ថបទសារព័ត៌មានមានចំណងជើងថា Hun Sen: Cambodia United at any Price*, សារព័ត៌មាន ភ្នំពេញប៉ុស្តិ៍, ចុះផ្សាយថ្ងៃទី៤-១៦ ខែតុលា ឆ្នាំ១៩៩៦។

[103] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ៥៥-៦១។

បណ្ដឹងឧទ្ធរណ៍រួចហើយគឺថា សហរដ្ឋមន្ត្រីមួយរូបនៃក្រសួងការពារជាតិកម្ពុជាគឺលោក ឧត្តមសេនីយ៍ ទៀ បាញ់ "បានកោតសសើរចំពោះលោក អៀង សារី ចំពោះការស្មោះត្រង់របស់គាត់ចំពោះការផ្សះផ្សាជាតិ ដោយនិយាយថា សេចក្ដីសម្រេចចិត្តរបស់គាត់ដើម្បីបញ្ចប់ជម្លោះប្រដាប់អាវុធដែលមានរយៈកាលជាច្រើនទសវត្សរ៍ នឹងបានបង្រួបបង្រួមប្រទេសនៅទីបំផុត"[104]។ គាត់បានអះអាងថា "សេចក្ដីសម្រេចរបស់គាត់មិនអាចកាត់ថ្លៃបាន ដោយសារវាបានជួយបញ្ចប់ការប្រយុទ្ធគ្នា សន្សំសំចៃថវិកា និងបញ្ចៀសការសម្លាប់រង្គាល" និងបានសង្កត់ធ្ងន់ថា វាគ្រាន់តែជាបញ្ហានៃពេលវេលាប៉ុណ្ណោះ លោក អៀង សារី និងអ្នកក្រោមបង្គាប់គាត់គង់នឹងបានទទួលការលើកលែងទោសមិនខាន[105]។ សភាជាតិបានគាំទ្រដល់ RPA ដែលបានស្នើដោយសហនាយករដ្ឋមន្ត្រីទាំងពីរ[106]។ សេចក្ដីថ្លែងអះអាងរបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលបានធ្វើឡើងដើម្បីទទួលការគាំទ្រជាសាធារណៈនៅខែតុលា ឆ្នាំ ១៩៩៦ ផ្ទុយពីសកម្មភាពរបស់គាត់មុនពេល និងក្នុងអំឡុងពេលប្រកាសឲ្យប្រើ។ សេចក្ដីថ្លែងការណ៍នយោបាយនានា សូម្បីតែសេចក្ដីថ្លែងការណ៍របស់នាយករដ្ឋមន្ត្រីទាំងពីរ មិនមានតម្លៃ ឬមិនមានទម្ងន់ជាអំណាចតាមផ្លូវច្បាប់ទេ។ ក.ស.ព អាចបង្គាប់ឲ្យនាយករដ្ឋមន្ត្រី ហ៊ុន សែន ផ្ដល់ភស្ដុតាងតាមការធ្វើសម្បថបាន។

### ៣. ការអនុគ្រោះទោស និងការលើកលែងទោស ពីបទឧក្រិដ្ឋ *អាជ្ញាក្រឹត្ត* (*jus cogens*) អាចត្រូវបានចាត់ទុកថាមានសុពលភាព

---

[104] *សូមមើលអត្ថបទសារព័ត៌មាន មានចំណងជើងថា Ieng Sary Bargains for Amnesty: Army Brokers Secret Talks with Ministers*, កាសែតបាងកកប៉ុស្តិ៍ ចុះផ្សាយថ្ងៃទី៧ ខែកញ្ញា ឆ្នាំ១៩៩៦។

[105] *ដូចជើងទំព័រខាងលើ*។

[106] សេចក្ដីបញ្ជាក់ពី សម្ដេច នរោត្ដម សីហនុ ព្រះរាជានៃប្រទេសកម្ពុជា ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ១៩៩៦។ *សូមមើលផងដែរ អត្ថបទសារព័ត៌មាន មានចំណងជើងថា Sihanouk Pardons Ieng Sary*, សារព័ត៌មាន បាងកកប៉ុស្តិ៍, ចុះផ្សាយថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៩៦៖ "ព្រះមហាក្សត្របានចុះហត្ថលេខាលើកលែងទោស ... ដោយមានការគាំទ្រសម្លេងពីរភាគបី (នៃសមាជិក)សភា" នាយករដ្ឋមន្ត្រីទីពីរ ហ៊ុន សែន បានប្រាប់ទៅ Reuters...។ លោក ហ៊ុន សែន បាននិយាយថា វាជាការស្រួលទេក្នុងការប្រមូលហត្ថលេខាពីសមាជិកសភាចំនួន១២០រូបនៃសភាជាតិ ដោយសារតែរូបគាត់ និងនាយករដ្ឋមន្ត្រីទីមួយ នរោត្ដម រណឫទ្ធិ គឺជាមេដឹកនាំនៃគណបក្សធំៗទាំងពីរ"។

៣០. នៅក្នុងកថាខណ្ឌ៦៤ ក.ស.ព អះអាងថា អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការបំពារបំពានធ្ងន់ធ្ងរគឺជាបទឧក្រិដ្ឋ*អាជ្ញាព្រឹត្ត* RPA ចំពោះបទឧក្រិដ្ឋទាំងនេះមិនមានសុពលភាពទេ។ បទដ្ឋាន*អាជ្ញាព្រឹត្ត* អាចត្រូវបានចាត់ទុកថាជាបទដ្ឋានមិនដាច់ខាត (peremtory norms) របស់ច្បាប់អន្តរជាតិ និងបានឆ្លុះបញ្ចាំងនៅក្នុងមាត្រា៥៣ នៃអនុសញ្ញាក្រុងវីយែន ស្តីពីច្បាប់សន្ធិសញ្ញា ចែងថា៖

> បទដ្ឋានដាច់ខាតរបស់ច្បាប់អន្តរជាតិទូទៅ គឺជាបទដ្ឋានមួយដែលត្រូវបានទទួលយក និងទទួលស្គាល់ដោយសហគមន៍អន្តរជាតិនៃបណ្តារដ្ឋនានា ជាទូទៅ ដែលមិនអនុញ្ញាតឱ្យមានបដិប្បញ្ញត្តិឡើយ និងអាចត្រូវបានកែសម្រួលដោយបទដ្ឋានមួយបន្ទាប់របស់ច្បាប់អន្តរជាតិទូទៅ ដែលមានលក្ខណៈដូចគ្នា[107]។

សហគមន៍អន្តរជាតិជារួមបានទទួលយកការបន្ធូរបន្ថយទោស និងលើកលែងទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការបំពារបំពានធ្ងន់ធ្ងរ[108]។ អនុសញ្ញាគំរូស្តីពីការធ្វើបត្យាប័នរបស់អង្គការសហប្រជាជាតិ ("អ.ស.ប") បានសំអាងថា "ពេលវេលាកន្លងទៅ ឬការលើកលែងទោស" គឺជាមូលដ្ឋានមួយក្នុងចំណោមមូលដ្ឋានដែលតម្រូវតាមផ្លូវច្បាប់ក្នុងការច្រានចោលការធ្វើបត្យាប័ននេះ[109]។ មិនមានបទដ្ឋានដាច់ខាតរបស់ច្បាប់អន្តរជាតិជាទូទៅ ដែលទទួលស្គាល់ដោយសហគមន៍អន្តរជាតិថា ការលើកលែងទោស និងការអនុគ្រោះទោស ចំពោះបទឧក្រិដ្ឋទាំងនេះមិនអាចត្រូវបានចាត់ទុកថាជា*អាជ្ញាព្រឹត្ត* ដោយសារការលើកលែងទោស និងការអនុគ្រោះទោសអនុញ្ញាតឱ្យមានបដិប្បញ្ញត្តិពីការផ្តន្ទាទោសចំពោះបទឧក្រិដ្ឋទាំងនេះ ផ្ទុយពីនិយមន័យរបស់*អាជ្ញាព្រឹត្ត* ដែលបានចែងក្នុងមាត្រា៥៣ នៃអនុសញ្ញាក្រុងវីយែន ស្តីពីច្បាប់សន្ធិសញ្ញា។ សេចក្តីសន្និដ្ឋាននេះត្រូវបានសង្ខេបយ៉ាងដូច្នេះថា៖

> ការពិតដែលថា រដ្ឋមួយមានផលប្រយោជន៍តាមផ្លូវច្បាប់ ក្នុងការធានាពីការអនុវត្តកាតព្វកិច្ចមួយ មិនចាំបាច់ត្រូវបកស្រាយជាកាតព្វកិច្ចវិជ្ជមាន ដើម្បីវិនិច្ឆ័យទោសចំពោះករណីទាំងអស់នៃបទឧក្រិដ្ឋ*អាជ្ញា*

---

[107] អនុសញ្ញាទីក្រុងវីយែន ស្តីពីច្បាប់សន្ធិសញ្ញា ឆ្នាំ១៩៦៩ មាត្រា៥៣ (គូសបញ្ជាក់បន្ថែម)។

[108] *សូមមើល*បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ៧៣-៨២។

[109] គំរូសន្ធិសញ្ញាស្តីពីការធ្វើបត្យាប័ន មាត្រា៣(ង) GA Res. 45/116 ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩០។

*ព្រឹត្ត* ឡើយ។ ជាងនេះទៀត មិនមានការអនុវត្តរបស់រដ្ឋណាសន្និដ្ឋានថា កាតព្វកិច្ចបែបនេះកើតចេញពីលក្ខណៈនៃកាតព្វកិច្ចនោះឡើយ[110]។

ក.ស.ព ក៏បានអះអាងបន្ថែមទៀតថា យុត្តិសាស្ត្រ និងការអនុវត្តសិទ្ធិមនុស្សអន្តរជាតិបានកំណត់នូវគោលជំហរថា ចំពោះការរំលោភបំពានធ្ងន់ធ្ងរចំពោះច្បាប់ព្រហ្មទណ្ឌអន្តរជាតិនោះ មិនអនុញ្ញាតឱ្យមានការអនុគ្រោះទោស ឬការលើកលែងទោសឡើយ។ សេចក្តីសំអាងហេតុដែលលើកឡើងដោយ ក.ស.ព មិនបានគាំទ្រដល់អំណះអំណាងនេះទេ[111]។ ជាងនេះទៅទៀត នៅក្នុងមូលដ្ឋានសំអាងផ្លូវច្បាប់ដែលបានលើកឡើងនោះ សាស្ត្រាចារ្យ Sadat អះអាងថា៖ "ដូចដែលតុលាការ យុត្តិធម៌អន្តរជាតិ (ICJ) បានកត់សម្គាល់នៅរឿងក្តី ប្រទេសកុងហ្គោ តទល់នឹង ប្រទេសប៊ែលហ្ស៊ិក (តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូនបានកត់សម្គាល់ផងដែរ) ការលើកលែងទោសថ្នាក់ជាតិមានសុពលភាព នៅក្នុងរដ្ឋដែលផ្តល់ការលើកលែងទោសនេះ លុះត្រាតែរដ្ឋនោះសម្រេចផ្សេងពីនេះវិញ (តាមរយៈការផ្លាស់ប្តូររបប ឬកត្តាផ្សេងទៀត)"[112]។ គួរកត់សម្គាល់ថា អត្ថបទសម្រង់ពីសាស្ត្រាចារ្យ Sadat អះអាងថា ការលើកលែងទោសណាមួយមានសុពលភាព លុះត្រាតែរដ្ឋសម្រេចផ្សេងពីនេះ មិនមែនអំណាចយុត្តាធិការរបស់រដ្ឋណាមួយទេ។ ក.ស.ព បានពឹងផ្អែកដោយមិនត្រឹមត្រូវទៅលើ "បទដ្ឋានអន្តរជាតិមួយដែលជួយបំភ្លឺផ្លូវ"[113] ដែលថា រដ្ឋមួយមិនអាចផ្តល់ការលើកលែងទោស ចំពោះការរំលោភបំពានធ្ងន់ធ្ងរទៅលើច្បាប់មនុស្សធម៌អន្តរជាតិឡើយ។ បទដ្ឋានអន្តរជាតិមួយដែលជួយបំភ្លឺផ្លូវមិនទាន់ក្លាយជាបទដ្ឋានអន្តរជាតិនៅឡើយទេ ហើយហេតុនេះ គេមិនអាចពឹងផ្អែកលើវាបានទេ។ ជាងនេះទៅទៀត ក.ស.ព បានពឹងផ្អែកលើយុត្តិសាស្ត្រពីតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន ("SCSL") និងតុលាការ ICTY ដែលយុត្តាធិការរបស់តុលាការទាំងពីរនេះអាចអនុវត្តច្បាប់អន្តរជាតិ

---

[110] NAQVI នៅត្រង់១៤០។

[111] ចម្លើយតប ជើងទំព័រ១៩២ *ទាញសំអាងហេតុ* Leila Nadya Sadat, *ធ្វើនិរទេស, លើកលែងទោស និងច្បាប់អន្តរជាតិ*, 81 NOTRE DAME L. REV. ទំព័រ955, 957 (2006) ("Sadat")។

[112] Sadat នៅត្រង់១០២៣។

[113] *រឿងក្តីរដ្ឋអាជ្ញាតទល់នឹង Kallon*, SCSL-04-15-AR72(E) និង*Kamara,* SCSL-04-16-AR72(E), សេចក្តីសម្រេចលើការជំទាស់ទៅនឹងយុត្តាធិការ៖ Lom" Accord Amnesty, ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៤ ("សេចក្តីសម្រេចក្នុងរឿងក្តី *Kallon*"), កថាខណ្ឌ៨២។

ដោយផ្ទាល់បាន។ អ.វ.ត.ក គឺជាតុលាការកម្ពុជាដែលមិនអាចអនុវត្តច្បាប់អន្តរជាតិដោយផ្ទាល់បានទេ[114]។ ក.ស.ព បានអះអាងបន្ថែមទៀតថា យន្តការសិទ្ធិមនុស្ស អ.ស.ប ជាច្រើនបានអះអាងម្តងហើយម្តងទៀតថា ការលើកលែងទោសរបស់រដ្ឋាភិបាលក្នុងស្រុកដែលបានច្រានចោលការវិនិច្ឆ័យទោស ចំពោះបទឧក្រិដ្ឋធ្ងន់ធ្ងរជាអន្តរជាតិមិនស្របនឹងកាតព្វកិច្ចរបស់ភាគីរដ្ឋឡើយ។ ការដកស្រង់ដែលបានធ្វើឡើងដោយ ក.ស.ព គ្រាន់តែយោងទៅដល់យន្តការសិទ្ធិមនុស្សអ.ស.ប មួយ ដែលអះអាងថា៖ "ការលើកលែងទោសមិនស្របគ្នាជាទូទៅជាមួយនឹងកាតព្វកិច្ចរបស់រដ្ឋក្នុងការស៊ើបអង្កេត [អំពើទារុណកម្ម]"[115]។ ការដកស្រង់បែបនេះមិនបានគាំទ្រដល់ការអះអាងរបស់ ក.ស.ព ទេ។ ការដកស្រង់នេះគ្រាន់តែអះអាងថា <u>ជាទូទៅ</u>ការលើកលែងទោសមិនបានរារាំងរដ្ឋមិនឱ្យ<u>ស៊ើបអង្កេត</u>ពីអំពើទារុណកម្មទេ តែមិនមែនថា រដ្ឋមិនអាចចេញការលើកលែងទោសចំពោះឧក្រិដ្ឋកម្មជាអន្តរជាតិណាបាននោះដែរ។ សុពលភាពនៃការលើកលែងទោសរបស់រដ្ឋាភិបាលក្នុងស្រុក នៅក្នុងតុលាការក្នុងស្រុក ត្រូវតែទុកឱ្យរដ្ឋសាម៉ីនោះជាអ្នកសម្រេច ក្រោមគោលការណ៍អធិបតេយ្យរបស់រដ្ឋនោះ[116]។ អ.វ.ត.ក មិនមានកាតព្វកិច្ច ចំពោះអ្វីដែលកើតឡើងនៅក្នុងតុលាការក្នុងស្រុកដទៃទៀតឡើយ។

៣១. នៅក្នុងកថាខណ្ឌ៦៥ ក.ស.ព អះអាងថា ការអនុគ្រោះទោស នៅពេលដែលទណ្ឌិតមិនបានទទួលរងទណ្ឌកម្ម គឺរំលោភដល់កាតព្វកិច្ចជាអន្តរជាតិរបស់ប្រទេសកម្ពុជា ដើម្បីផ្តន្ទាទោសចំពោះបទឧក្រិដ្ឋក្រោមអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍។ ដូចបានពន្យល់នៅក្នុងបណ្តឹងឧទ្ធរណ៍[117] រួចមកហើយគឺថា នេះជាកាតព្វកិច្ចសម្រាប់រដ្ឋាភិបាលកម្ពុជា ហើយវាមិនពាក់ព័ន្ធនឹងអំណាចតុលាការទេ។ អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍តម្រូវឱ្យរដ្ឋត្រូវបង្កើតច្បាប់ ដើម្បីផ្តល់សុពលភាពចំពោះបទ

[114] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ១១១-៣៥។

[115] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ យោបល់ទូទៅលេខ ២០ – មាត្រា៧: ការហាមឃាត់ការធ្វើទារុណកម្ម និងការប្រព្រឹត្តិមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប, ឯកសារ អ.ស.ប លេខ RI/GEN/1/Rev.1, ចុះថ្ងៃទី៣ ខែតុលា ឆ្នាំ១៩៩២ កថាខណ្ឌ១៥។

[116] *សូមមើល* ធម្មនុញ្ញអង្គការសហប្រជាជាតិ មាត្រា២(៧)។ សេចក្តីសម្រេច*Kallon* កថាខណ្ឌ៦៧។ Sadat នៅត្រង់ទំព័រ ១០២៣។

[117] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ៩៦-៩៩។

ប្បញ្ញត្តិនានានៅក្នុងអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍នោះ[118]។ ប្រទេសកម្ពុជាមិនបានបង្កើតច្បាប់បែបនេះទេរហូតដល់ឆ្នាំ២០០៩[119]។ មិនមានបទប្បញ្ញត្តិណាមួយនៅក្នុងច្បាប់កម្ពុជាបានរារាំងមិនសម្រេចឱ្យមាន RPA និងមិនមានអ្វីត្រូវរារាំងឱ្យអនុវត្ត RPA ដើម្បីរារាំងយុត្តាធិការរបស់ អ.វ.ត.ក ទៅលើលោក អៀង សារី ឡើយ។ ជាងនេះទៀត មិនមានវិធានណាមួយដែលចែងថា ការអនុគ្រោះទោសចំពោះអំពើប្រល័យពូជសាសន៍មិនមានសុពលភាព ក្រោមច្បាប់អន្តរជាតិទូទៅ[120] ទេ។ ការអនុវត្តរបស់រដ្ឋដែលបង្ហាញពីការអត់ឱនចំពោះបុគ្គលដែលត្រូវបានចោទប្រកាន់ពីអំពើប្រល័យពូជសាសន៍ ដូចជាករណី កម្មវិធីមេត្តាករុណារបស់អាមេរិក នៅក្នុងប្រទេសអាល្លឺម៉ង់ក្រោយសង្គ្រាមលោកលើកទី២ បង្ហាញថា រដ្ឋនានាមិនបានយល់ថា ការអនុគ្រោះទោសមិនស្របនឹងអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ទេ[121]។

## ៤. អ.វ.ត.ក ជាប់កាតព្វកិច្ចទៅនឹងព្រះរាជក្រឹត្យអនុគ្រោះទោស និងលើកលែងទោស

៣២. នៅក្នុងកថាខណ្ឌ៦៧ ក.ស.ព អះអាងថា អ.វ.ត.ក គឺជាតុលាការពិសេសដែលមានលក្ខណៈជាអន្តរជាតិ ជាប់កាតព្វកិច្ចទៅនឹងច្បាប់អន្តរជាតិ ហើយអាស្រ័យហេតុនេះ ការអនុគ្រោះទោសថ្នាក់ជាតិមិនត្រូវយកមកអនុវត្តទាក់ទិននឹងឧក្រិដ្ឋកម្ម*អាជ្ញាព្រឹត្តិ* ជាអន្តរជាតិនៅ អ.វ.ត.ក ទេ។ ក.ស.ព អះអាងថា ចំណុចនេះស្របទៅនឹងសេចក្តីរបស់តុលាការ SCSL ក្នុង*រឿងក្តី Kallon*[122]។ ទីមួយ អ.វ.ត.ក មិនមែនជាតុលាការពិសេសអន្តរជាតិទេ តែជាតុលាការកម្ពុជាប៉ុណ្ណោះ។ ក.ស.ព មិនបានបង្ហាញថា RPA នឹងមិនមានសុពលភាពនៅក្នុងតុលាការកម្ពុជាឡើយ។ ទីពីរ ក្នុងនាមជា

---

[118] អនុសញ្ញាស្តីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ មាត្រា៥។

[119] ក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០០៩ ផ្នែកទី២ គន្ថីទី១ មាតិកាទី១: ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ មាត្រា១៨៣។

[120] NAQVI នៅត្រង់១៧១។

[121] *ដូចជើងទំព័រខាងលើ* នៅត្រង់១៧១ លេខ១៤៣។

[122] អ្វីក៏ដោយដែលប៉ះពាល់ការលើកលែងទោសដែលផ្តល់ឱ្យតាមកិច្ចព្រមព្រៀង Lomé អាចចោទប្រកាន់ចំពោះបទឧក្រិដ្ឋបែបនោះដោយសារវាមានចែងនៅក្នុងមាត្រា២ ដល់មាត្រា៤ នៅក្នុងតុលាការជាតិរបស់ប្រទេសសេរ៉ាឡេអូន។ វាមិនមានអនុភាពក្នុងការដកចេញនូវយុត្តាធិការសកលក្នុងការកាត់សេចក្តីបុគ្គលនានាដែលត្រូវបានចោទប្រកាន់ចំពោះបទល្មើសបែបនោះ ដែលរដ្ឋផ្សេងទៀតផ្អែកលើមូលហេតុនៃប្រភេទបទឧក្រិដ្ឋ។ វាក៏មិនមានអនុភាពក្នុងការដកចេញតុលាការអន្តរជាតិមួយដូចជាយុត្តាធិការរបស់តុលាការពិសេសនោះទេ”។ សេចក្តីសម្រេច *Kallon*, កថាខណ្ឌ៨៨។

តុលាការកម្ពុជា អ.វ.ត.ក ជាប់កាតព្វកិច្ចទៅនឹងច្បាប់កម្ពុជាតែមួយគត់។ យុត្តិសាស្ត្ររបស់តុលាការ SCSL មិនជាប់កាតព្វកិច្ចឡើយ។ ទីបី ក្នុងនាមជាតុលាការកម្ពុជា អ.វ.ត.ក ត្រូវតែមានចំណងជាមួយ RPA ដោយសារវាជាការឡាយព្រះហស្ថលេខាប្រទានដោយព្រះមហាក្សត្រ។ ទីបួន អសុពលភាពរបស់ការអនុគ្រោះទោសចំពោះអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការបំពារបំពានធ្ងន់ធ្ងរមិនមែនជា *អាជ្ញាព្រឹត្តិ* ទេ។

**ខ. គោលការណ៍*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ (ne bis in idem)* រារាំងមិនឱ្យមានការវិនិច្ឆ័យទោសចំពោះលោក អៀង សារី**

**១. គោលការណ៍*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* អនុវត្តចំពោះករណីលោក អៀង សារី**

៣៣. នៅក្នុងកថាខណ្ឌ៧០ ក.ស.ព អះអាងថា ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាមិនយកមកអនុវត្ត ដើម្បីរារាំងយុត្តាធិការលើលោក អៀង សារី ទេ ពីព្រោះមាត្រា១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាចែងថា៖ "ជនណាដែលត្រូវបានតុលាការសម្រេចឱ្យរួចខ្លួនស្ពាពរហើយ ជននោះមិនអាចត្រូវចោទប្រកាន់ទៀតទេចំពោះអំពីដដែល ទោះបីជាក្រោមការកំណត់ឈ្មោះបទល្មើសថ្មីផ្សេងក៏ដោយ" ហើយលោក អៀង សារី មិនត្រូវបានលើកលែងការចោទប្រកាន់ដោយសាលក្រមឆ្នាំ១៩៧៩ ទេ។ ទោះបីក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាអាចចែងថា មាត្រា១២ អនុវត្តនៅពេលបុគ្គលម្នាក់ត្រូវបានលើកលែងការចោទប្រកាន់ ក៏ពិតមែន តែវាជាការមិនសមហេតុផលទេក្នុងការកំណត់ពីការការពារចំពោះអ្នកដែលត្រូវបានលើកលែងការចោទប្រកាន់ និងមិនបានការពារដល់អ្នកដែលត្រូវបានកាត់ទោសពីមុនមកនោះ។ ការបកស្រាយបែបនេះ មិនបានស្របទៅនឹងបទដ្ឋាននៃការជំនុំជម្រះប្រកបដោយយុត្តិធម៌ជាអន្តរជាតិ[123] ដែល ក.ស.ព ទំនងជាបានទទួលស្គាល់ដែរនោះ[124]។

[123] មាត្រា១៤(៧) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចែងថា "គ្មានជនណាម្នាក់ ត្រូវយកមកចោទប្រកាន់ ឬយកមកផ្តន្ទាទោសសារជាថ្មីឡើយ ចំពោះបទល្មើសដែលបានផ្តន្ទាទោសជាស្ថាពរ ឬបានលើកលែងទោសស្របតាមច្បាប់ និងនីតិវិធីព្រហ្មទណ្ឌរបស់រដ្ឋនីមួយៗរួចហើយ។" (គូសបញ្ជាក់បន្ថែម)។

[124] នៅក្នុងកថាខណ្ឌ៧១ នៃចម្លើយតប ក.ស.ព លើកឡើងថា គោលបំណងនៃគោលការគ្មានការកាត់សេចក្តីពីរដងចំពោះបទល្មើសតែមួយ នៅក្នុងច្បាប់អន្តរជាតិ គឺដើម្បីជួយដល់បុគ្គលមិនឱ្យទទួលរងនូវការកាត់សេចក្តីពីរដង។

៣៤. នៅក្នុងកថាខណ្ឌ៧១ ក.ស.ព អះអាងថា៖ “គោលបំណងនៃគោលការណ៍នេះ គឺដើម្បីជួយបុគ្គលឲ្យរួចផុតពីការគាបសង្កត់ផ្នែកចិត្តសាស្ត្រ សតិអារម្មណ៍ រូបរាងកាយ និងថិរកា ដែលពាក់ព័ន្ធនឹងការកាត់សេចក្តីពីរដងលើបទល្មើសតែមួយ”។ គោលបំណងនេះមិនត្រឹមតែលេចចេញជារូបរាងនៅពេលជនជាប់ចោទមានវត្តមាននៅពេលសវនាការទេ តែវាថែមទាំងអាចអនុវត្តបាននៅពេលជននោះត្រូវបានកាត់ទោសកំបាំងមុខផងដែរ។ ភាពអន្ទះសារ និងការធុញថប់ក្នុងចិត្តដែលបណ្តាលមកពីការវិនិច្ឆ័យទោសម្តងហើយម្តងទៀតបានប៉ះពាល់ដល់ក្រុមគ្រួសារ សាក្សី និងសូម្បីតែជនរងគ្រោះខ្លួនឯង និងទំនងជាលេចឡើងជាថ្មីដោយសារការចាប់អារម្មណ៍ពីបណ្តាញសារព័ត៌មាន[125]។ ជាងនេះទៅទៀត នេះមិនមែនជាគោលបំណងតែមួយគត់របស់គោលការណ៍នេះទេ។ គោលការណ៍*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* “ត្រូវបានកំណត់ថាជាលទ្ធផលដោយផ្ទាល់ពីការទទួលស្គាល់ឥទ្ធិពលនៃ *អាជ្ញាអស់ជំនុំ* ក្នុងគោលបំណងការពារភាពស្ថាពរនៃសាលក្រម/ដីកា។ គំនិតដែលថា នៅពេលរឿងក្តីមួយត្រូវបានដោះស្រាយរួចហើយ គេមិនគួរបើករឿងក្តីនេះមកដោះស្រាយម្តងទៀតទេ *(factum praeteritum)* ដោយសារវានឹងធ្វើឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ការគោរពកិច្ចដំណើរការនីតិវិធី និងអំណាចតុលាការជាទូទៅ”[126]។ ចំណុចនេះត្រូវបានគេហៅថា “ការប៉ះពាល់ផ្នែកនីតិវិធី” របស់គោលការណ៍*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ*[127]។ តម្រូវការឲ្យ អ.វ.ត.ក ធ្វើសកម្មភាពក្នុងនាមជាតុលាការគំរូសម្រាប់កម្ពុជា[128] និងដើម្បីបង្កើនការគោរពដល់អំណាចតុលាការ និងកិច្ចដំណើរការនីតិវិធីតុលាការគួរនាំ អ.វ.ត.ក ឲ្យគោរព និងអនុវត្តគោលការណ៍*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ*។ ការអនុវត្តបែបជម្រើសចំពោះគោលការណ៍នេះនៅក្នុងច្បាប់កម្ពុជា និងបទដ្ឋានយុត្តិធម៌អន្តរជាតិនឹងនាំឲ្យសាធារណជនជឿថា ច្បាប់អាចត្រូវបានគេប្រើ

---

[125] NAQVI, *យោង* The Law Commission Consultative Paper No. 156. *Double Jeopardy: A Consultative Paper* (1999) (UK), នៅត្រង់៣១ កថាខណ្ឌ៤.៦។

[126] *ដូចជើងទំព័រខាងលើ* នៅត្រង់៣០៧-០៨។

[127] *ដូចជើងទំព័រខាងលើ* នៅត្រង់២៩២-៩៣។

[128] “អ.វ.ត.ក រៀបចំជាគំរូមួយសម្រាប់កំណែទម្រង់ច្បាប់ និងតុលាការរបស់ប្រទេសកម្ពុជា”។ អនុសាសន៍ទាក់ទិននឹងតម្លាភាពបន្ថែមនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (...) បានដាក់ជូនដោយសមាជិករបស់សង្គមស៊ីវិល និងសមាជិករបស់សារព័ត៌មានកម្ពុជា ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៨ *មាននៅ* http://www.cambodiatribunal.org/CTM/Recommendations%20Regarding%20Additional%20Transparency.pdf?phpMyAdmin=8319ad34ce0db941ff04d8c 788f6365e ។

ជាការបញ្ឆោត ឬអាចត្រូវគេមិនយកចិត្តទុកដាក់ទាល់តែសោះ ដើម្បីសម្រេចបានទៅតាមលទ្ធផលដែលគេចង់បាន។

៣៥. នៅក្នុងកថាខណ្ឌ៧២-៧៣ ក.ស.ព អះអាងថា សាលក្រមឆ្នាំ១៩៧៩ មិនទាន់ក្លាយជាស្ថាពរទេ ដោយសារលោក អៀង សារី ត្រូវបានកាត់ទោសកំបាំងមុខ ហើយបើតាមច្បាប់កម្ពុជា សាលក្រមបែបនេះមិនត្រូវបានចាត់ទុកជាសាលក្រមស្ថាពរទេ ហើយហេតុនេះមិនអាចយកគោលការណ៍ *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* មកអនុវត្តបានទេ។ ក.ស.ព បានដកស្រង់ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាដោយភ័ន្តច្រឡំ ដើម្បីជាសំណើដែលថា មិនតាមច្បាប់កម្ពុជា សាលក្រមដែលកើតចេញពីសវនាការកំបាំងមុខមិនត្រូវបានចាត់ទុកជាសាលក្រមស្ថាពរឡើយ។ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាបានចូលជាធរមាននៅឆ្នាំ២០០៧។ នៅឆ្នាំ១៩៧៩ មិនទាន់មានតុលាការទេ (តុលាការកំពូលបង្កើតនៅឆ្នាំ១៩៨៥) ហើយហេតុនេះសាលក្រមដែលកើតចេញពីតុលាការប្រជាជនបដិវត្តន៍ត្រូវបានចាត់ទុកថាជាសាលក្រមស្ថាពរ។ ការពិត នៅពេលនេះ សាលក្រមឆ្នាំ១៩៧៩ ត្រូវបានចាត់ទុកជាសាលក្រមស្ថាពរ ទោះបីសាលក្រមនេះមិនទាន់ត្រូវបានចាត់ទុកជាសាលក្រមស្ថាពរនាពេលនោះក៏ដោយ។ លោក អៀង សារី មិនមានលទ្ធភាពត្រូវគេកាត់ទោសជាថ្មីដោយតុលាការប្រជាជនបដិវត្តន៍ទេ។ កិច្ចដំណើរការនីតិវិធីនៅ អ.វ.ត.ក មិនត្រូវបានចាត់ទុកជា "សវនាការជាថ្មី"- លោក អៀង សារី កំពុងត្រូវបានជំនុំជម្រះដោយតុលាការកម្ពុជាមួយផ្សេង និងក្រោមច្បាប់ផ្សេង ទោះបីការប្រព្រឹត្តដូចគ្នានោះត្រូវបានពិភាក្សាក្នុងឆ្នាំ១៩៧៩ រួចមកហើយក្តី។ ទោះបីបទប្បញ្ញត្តិរបស់ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាអាចត្រូវបានយកមកពិចារណាយ៉ាងសមរម្យក៏ដោយ ក៏បទប្បញ្ញត្តិទាំងនេះមិនអាចជួយដល់ ក.ស.ព ទេ។ សវនាការ និងការកាត់ទោសកំបាំងមុខ ត្រូវបានអនុញ្ញាតតាមមាត្រា ៣៣៣ ហើយមាត្រា៣៥៣ ទណ្ឌិតដែលត្រូវបានចាប់ខ្លួន ឬទណ្ឌិតដែលចូលប្រគល់ខ្លួន អាចជំទាស់នឹងសាលក្រមកំបាំងមុខ ដើម្បីស្នើសុំឲ្យមានសវនាការសារជាថ្មី។ មាត្រា៣៥៣ មិនបានចែងថា សវនាការសារជាថ្មី ជាលក្ខណ្ឌតម្រូវតាមច្បាប់ទេ។ វាជាសិទ្ធិរបស់ជនជាប់ចោទ ក្នុងការសម្រេចថា តើគួរឲ្យមានសវនាការថ្មីមួយ ឬយ៉ាងណា។ មាត្រា៤១០ និង៤១២ ដែល ក.ស.ព បានដកស្រង់ គឺយោងត្រឹមតែទៅដល់សាលដីកាកំបាំងមុខរបស់សាលាឧទ្ធរណ៍តែប៉ុណ្ណោះ។ ការយោងដ៏ត្រឹមត្រូវចំពោះសាលក្រមកំបាំងមុខរបស់សាលាដំបូង គួរតែនៅក្នុងមាត្រា៣៦៥ និង៣៦៨។ ពីមាត្រា៤៨៩ ដល់មាត្រា៤៩៣ ដែល ក.ស.ព លើកយកមកសំអាងនោះ គឺទាក់ទិនតែនឹងរបៀបជូនដំណឹងពីសាល

ក្រម/ដីការបស់តុលាការតែប៉ុណ្ណោះ។ ប្រការដែលគួរឱ្យកត់សម្គាល់នោះគឺថា មាត្រា៤៩០ ចែងថា៖ "ប្រសិនបើភាគីពាក់ព័ន្ធគ្មានលំនៅដ្ឋាន ឬទីសំណាក់ទេ ឬប្រសិនបើភាគីពាក់ព័ន្ធនេះរស់នៅក្រៅដែនដីជាតិ សេចក្តីសម្រេចរបស់តុលាការក៏អាចជូនដំណឹងដល់សាម៉ីខ្លួនបានដែរ។ ក្នុងករណីនេះ កាលបរិច្ឆេទនៃសេចក្តីសម្រេចតុលាការត្រូវចាត់ទុកថា ជាកាលបរិច្ឆេទនៃការជូនដំណឹង"។ មាត្រានេះយោងទៅដល់ទណ្ឌិតដែលគេមិនស្គាល់អាសយដ្ឋាន ហើយមធ្យោបាយក្នុងការជូនដំណឹងពីសាលក្រម/ដីការបស់តុលាការមិនអាចធ្វើបាន។ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាសន្និដ្ឋានថា កាលបរិច្ឆេទនៃការជូនដំណឹង គឺជាកាលបរិច្ឆេទនៃការចេញសាលក្រម/ដីកាកាត់ទោសកំបាំងមុខនោះតែម្តង។ ហេតុនេះ បន្ទាប់ពីពេលវេលាដែលអនុញ្ញាតឱ្យមានការប្តឹងជំទាស់ចំពោះសាលក្រម/ដីកាកំបាំងមុខនោះ ហើយបន្ទាប់ពេលផុតកំណត់នៃការប្តឹងជំទាស់នេះ សាលក្រម/ដីកានឹងចូលជាស្ថាពរ។

៣៦. នៅក្នុងកថាខណ្ឌ៧៤ ក.ស.ព អះអាងថា សវនាការឆ្នាំ១៩៧៩ មិនត្រូវបានប្រព្រឹត្តឡើង "ស្របទៅនឹងច្បាប់របស់ប្រទេសទេ"។ ក.ស.ព មិនបានផ្តល់សំអាងដើម្បីគាំទ្រដល់អំណះអំណាងនេះទេដែលថា សវនាការឆ្នាំ១៩៧៩ មិនបានស្របនឹងច្បាប់កម្ពុជានោះ។ ផ្ទុយទៅវិញ ក.ស.ព បានដកស្រង់មាត្រា១៤ នៃ ICCPR ដែលតម្រូវឱ្យតុលាការត្រូវឯករាជ្យ មានជំហរអនាគតិ និងបង្កើតឡើងដោយច្បាប់។ នៅឆ្នាំ១៩៧៩ ICCPR មិនទាន់មានសុពលភាព ឬជាច្បាប់ដែលជាប់កាតព្វកិច្ចនៅប្រទេសកម្ពុជាឡើយ។ ប្រទេសកម្ពុជាមិនបានចូលជាភាគី ICCPR នោះទេ រហូតដល់ឆ្នាំ១៩៩២[129]។ ជាងនេះទៀត លក្ខខណ្ឌតម្រូវរបស់មាត្រា១៤ មានចេតនាការពារជនជាប់ចោទ មិនមែនត្រូវយកមកប្រើដើម្បីធ្វើយុត្តិកម្ម សម្រាប់ច្រានចោលការការពារដែលមានចែងក្នុង ICCPR ឡើយ។

**២. សវនាការកាត់ទោសលោក អៀង សារី នៅចំពោះមុខ អ.វ.ត.ក មិនបានបង្កើតជាករណីលើកលែងចំពោះគោលការណ៍*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* ទេ**

---

[129] ប្រទេសកម្ពុជាចុះហត្ថលេខាលើកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៨០ និងត្រូវបានយល់ព្រមនៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៩២។
*សូមមើល* http://treaties.un.org/Pages/ViewDetails.aspx?src=TREATY&mtdsg_no=IV-4&chapter=4&lang=en.

៣៧. នៅក្នុងកថាខណ្ឌ៧៦ ក.ស.ព អះអាងថា វិការៈនានានៅក្នុងសវនាការឆ្នាំ១៩៧៩ នឹងធ្វើយុត្តិកម្មដល់សវនាការថ្មីមួយ ដោយមិនគិតដល់ចំណុចដែលថា តើវិការៈទាំងនេះបានប៉ះពាល់ដល់លទ្ធផលដែលបានជាប្រយោជន៍លោក អៀង សារី ឬការខូចខាតរបស់គាត់។ ក.ស.ព បានដកស្រង់របាយការណ៍មួយរបស់ក្រុមប្រឹក្សាទ្វីបអឺរ៉ុប ដែលចែងជាថ្មីនៅក្នុងមាត្រា៤ នៃវិធីសារទី៧ នៃអនុសញ្ញាទ្វីបអឺរ៉ុបស្តីពីសិទ្ធិមនុស្ស ("ECHR") ដែល ក.ស.ព ក៏បានដកស្រង់ផងដែរ។ មាត្រានេះចែងថា បញ្ញត្តិនៃគោលការណ៍ *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* នៅក្នុង ECHR "មិនបានរារាំងមិនឱ្យបើកជាថ្មីឡើងវិញនូវករណី ដែលអនុលោមតាមច្បាប់ និងនីតិវិធីព្រហ្មទណ្ឌ របស់រដ្ឋសាម៉ី ប្រសិនបើមានភស្តុតាងនៃអង្គហេតុថ្មី ឬដែលទើបរកឃើញថ្មី ឬប្រសិនបើមានវិការៈជាមូលដ្ឋាននៅក្នុងកិច្ចដំណើរការនីតិវិធីពីមុន ដែលអាចប៉ះពាល់ដល់លទ្ធផលនៃករណីនេះ"។ ECHR មិនមែនជាច្បាប់ដែលជាប់កាតព្វកិច្ចនៅប្រទេសកម្ពុជាទេ។ ជាងនេះទៀត បញ្ញត្តិនេះចែងថា ការបើករឿងក្តីឡើងវិញត្រូវតែធ្វើឡើងស្របទៅតាមច្បាប់ និងនីតិវិធីព្រហ្មទណ្ឌរបស់រដ្ឋសាម៉ី ដែលក្នុងករណីនេះគឺប្រទេសកម្ពុជា។ ក.ស.ព មិនបានបង្ហាញពីរបៀបដែលច្បាប់ និងនីតិវិធីព្រហ្មទណ្ឌរបស់កម្ពុជាអនុញ្ញាតឱ្យមានការបើករឿងក្តីនេះឡើងវិញក្នុងស្ថានភាពនេះទេ។ ក.ស.ព មិនកំពុងស្វែងរកការបើករឿងក្តីនៅក្នុងសវនាការឆ្នាំ១៩៧៩ ទេ តែគឺជាសវនាការថ្មីមួយសុទ្ធសាធនៅ អ.វ.ត.ក។ ក.ស.ព ក៏បានអះអាងបន្ថែមទៀតថា គោលការណ៍*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* "មិនអាចយកមកអនុវត្តបាននោះទេ នៅពេលដែលតុលាការអន្តរជាតិ ដំណើរការកាត់សេចក្តីជាលើកទីពីរ បន្ទាប់ពីការកាត់សេចក្តីថ្នាក់ជាតិលើកទីមួយ មិនត្រូវបានប្រព្រឹត្តឡើងដោយឯករាជ្យ ឬមិនលំអៀងដោយផ្អែកតាមបទដ្ឋាននីតិវិធីត្រឹមត្រូវ ដែលទទួលស្គាល់ជាលក្ខណៈអន្តរជាតិ ឬត្រូវបានធ្វើឡើងនៅក្នុងរបៀបមួយដែលផ្ទុយទៅនឹងចេតនានាំជនជាប់ចោទមកកាត់សេចក្តីដោយយុត្តិធម៌"[130]។ ក.ស.ព ដកស្រង់លក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិ ("ICC") លក្ខន្តិកៈតុលាការ ICTY និងលក្ខន្តិកៈតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា ("ICTR") ដើម្បីធ្វើជាសំអាងហេតុ។ ការពិត លក្ខន្តិកៈតុលាការ ICC ចែងថាគោលការណ៍ *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* មិនបានអនុវត្តនៅពេលកិច្ចដំណើរការនីតិវិធី "មិនត្រូវបានប្រព្រឹត្តឡើងដោយឯករាជ្យ ឬដោយប្រកាន់ជំហរអនាគតិស្របទៅតាមបទដ្ឋាននៃដំណើរការតាមផ្លូវច្បាប់ដែលទទួលស្គាល់ដោយច្បាប់អន្តរជាតិ និង ត្រូវបាន

---

[130] គូសបញ្ជាក់បន្ថែម។

ប្រព្រឹត្តឡើងក្នុងលក្ខណៈ ក្នុងកាលៈទេសៈ ដែលមិនស៊ីសង្វាក់ទៅនឹងចេតនាក្នុងការនាំខ្លួនសាម៉ីជនទៅតាមយុត្តិធម៌"[131]។ ពាក្យពេចន៍នៅក្នុងលក្ខន្តិកៈតុលាការ ICTY និងតុលាការ ICTR មានភាពស្រដៀងគ្នាជាខ្លាំងទៅនឹងសម្រង់របស់ ក.ស.ព តែភាពខុសគ្នាទៅនឹងលក្ខន្តិកៈតុលាការ ICC បង្ហាញថា ករណីលើកលែងចំពោះគោលការណ៍នេះ មិនត្រូវបានបំភ្លឺផ្លូវនៅក្នុងច្បាប់អន្តរជាតិ ដូចដែល ក.ស.ព បានលើកឡើងផងទេ។ ក.ស.ព បានយោងទៅដល់សិទ្ធិមួយចំនួនដែលមានចែងក្នុងមាត្រា ១៤ នៃ ICCPR ដោយមិនបានពន្យល់ពីរបៀបដែលសិទ្ធិទាំងនេះគាំទ្រដល់អំណះអំណាងរបស់ខ្លួន ដែលវិការៈនៅក្នុងសវនាការឆ្នាំ១៩៧៩ តម្រូវឱ្យមានការសវនាការថ្មីមួយនៅ អ.វ.ត.ក។ សិទ្ធិនានាដែលមានចែងក្នុងមាត្រា១៤នៃ ICCPR សំដៅដល់ការការពារសិទ្ធិរបស់ជនជាប់ចោទ និងមិនតម្រូវឱ្យយកជននោះទៅជំនុំជម្រះសាជាថ្មីឡើយ ប្រសិនបើគាត់មិនបានស្វែងរកឱ្យមានសវនាការថ្មី។

៣៨. នៅក្នុងកថាខណ្ឌ៧៧ ដល់៧៩ ក.ស.ព អះអាងថា សវនាការឆ្នាំ១៩៧៩ មិនបានស្របតាមបទដ្ឋានសវនាការប្រកបដោយយុត្តិធម៌អន្តរជាតិទេ។ សហមេធាវីការពារក្តីមិនចាំបាច់ធ្វើយុត្តិកម្ម ឬការពារសវនាការឆ្នាំ១៩៧៩ ទេ។ វិការៈនៅក្នុងសវនាការឆ្នាំ១៩៧៩ មិនបានបណ្តាលឱ្យគោលការណ៍ *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* មិនត្រូវបានយកទៅអនុវត្តទេ ដោយសារសវនាការនេះមិនមែនជាសវនាការប្រឌិតដែលធ្វើឡើង ដើម្បីឱ្យលោក អៀង សារី គេចផុតពីយុត្តិធម៌នោះទេ។ ទទ្បីករណ៍របស់ ក.ស.ព មិនចាំបាច់បង្ហាញពីកំហុសឆ្គងនៅក្នុងសវនាការឆ្នាំ១៩៧៩ ទេ។ ឧទាហរណ៍ នៅក្នុងកថាខណ្ឌ៧៧ ក.ស.ព អះអាងថា សវនាការឆ្នាំ១៩៧៩ ធ្វើឡើងត្រឹម ៥ ថ្ងៃប៉ុណ្ណោះ។ រយៈពេលនេះទំនងជាមិនពេញលេញគ្រប់គ្រាន់ទេ។ សវនាការមិនចាំបាច់ចំណាយទេយូរទើបមានយុត្តិធម៌នោះទេ។ បើយើងប្រៀបធៀបទៅនឹងសវនាការនាពេលថ្មីរបស់សហរដ្ឋអាមេរិកចំពោះ Ahmed Khalfan Ghailani ដែលត្រូវបានចោទប្រកាន់ចំនួនជាង ២៨០ បទចោទប្រកាន់ចំពោះការសមគំនិត និងមនុស្សឃាតទាក់ទិននឹងការដាក់គ្រាប់បែកភេរវកម្មឆ្នាំ១៩៩៨ ទៅលើស្ថានទូតសហរដ្ឋអាមេរិកនៅប្រទេសកេនយ៉ា និងតង់ហ្សានី ដែលសវនាការនេះមានរយៈពេលត្រឹមតែ ៤

---

[131] លក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិ មាត្រា២០(៣)(ខ) (គូសបញ្ជាក់បន្ថែម)។

សប្តាហ៍ប៉ុណ្ណោះ[132]។ នៅក្នុងកថាខណ្ឌ៧៨ ក.ស.ព អះអាងថាសវនាការឆ្នាំ១៩៧៩ បានកើតឡើងដោយគ្មានវត្តមានរបស់លោក អៀង សារី ទេ តែវាមិនចាំបាច់ថាផ្ទុយនឹងបទដ្ឋានអន្តរជាតិឡើយ។ អង្គការសហប្រជាជាតិបានបង្កើតតុលាការពិសេសសម្រាប់ប្រទេសលីបង់ បានគាំទ្រជាសាធារណៈឱ្យមានសវនាការកំបាំងមុខ[133]។

៣៩. នៅក្នុងកថាខណ្ឌ៨០ ក.ស.ព អះអាងថាការរាំងមិនឱ្យមានការវិនិច្ឆ័យចំពោះលោក អៀង សារី នឹងមិនបម្រើដល់គោលបំណងនៃគោលការណ៍ *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* ទេ។ ផ្ទុយទៅវិញ គោលបំណងនៃគោលការណ៍ *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* ពិតជាបានគាំទ្រដល់ការអនុវត្តនូវគោលការណ៍នេះនៅក្នុងករណីបច្ចុប្បន្ននេះ។ ក.ស.ព អះអាងបន្ថែមទៀតថា "តម្រូវការសម្រាប់ អ.វ.ត.ក ក្នុងការដោះស្រាយដំណើរការនីតិវិធីដំបូងដែលមានវិការៈត្រូវមានសារៈសំខាន់ជាងសិទ្ធិទទួលបានស្ថាពរនៃការផ្តន្ទាទោសរបស់ អៀង សារី នៅតុលាការ PRT"។ វាមិនមែនជាយុត្តាធិការរបស់ អ.វ.ត.ក ក្នុងការដោះស្រាយចំពោះកំហុសឆ្គងនៅក្នុងកិច្ចដំណើរការនីតិវិធីកាលពីអតីតកាលនោះទេ។ គោលបំណងបែបនេះមិនអាចបន្ថែមទម្ងន់ដល់សិទ្ធិរបស់លោក អៀង សារី ក្នុងការទទួលបាននូវភាពស្ថាពរនៃការកាត់ទោសចំពោះគាត់កាលពីអតីតកាលនោះទេ។ អ.វ.ត.ក មានភារកិច្ចគោរពតាម និងតម្កល់សិទ្ធិរបស់លោក អៀង សារី ដោយឥតលក្ខខណ្ឌ។

### ៣. អង្គបុរេជំនុំជម្រះត្រូវតែប្រៀបធៀបអំពើ និងបទឧក្រិដ្ឋដែលកាត់សេចក្តី ដោយតុលាការ PRT និង អ.វ.ត.ក ដើម្បីសន្និដ្ឋានថាតើ អៀង សារី គួរតែកាត់សេចក្តីនៅចំពោះ មុខ អ.វ.ត.ក ដែរឬទេ

៤០. ក្នុងកថាខណ្ឌ ៨១ ក.ស.ព អះអាងថា អង្គបុរេជំនុំជម្រះមិនចាំបាច់ពិនិត្យមើលដំណើរការ នីតិវិធីឆ្នាំ១៩៧៩ ឡើយ ដើម្បីកំណត់ថាតើ លោក អៀង សារី ត្រូវបានចោទប្រកាន់កាលពីលើកមុនចំពោះអំពើ ឬឧក្រិដ្ឋកម្មដូចគ្នា ឬយ៉ាងណានោះ។ ក.ស.ព អះអាងថា ការផ្តន្ទាទោសច្រើនបទចំពោះអំពើ

[132] Benjamin Weizer, *US Court Clears Detainee on Most Terror Charges*, កាសែត CAMBODIA DAILY ចុះផ្សាយថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១០។

[133] លក្ខន្តិកៈតុលាការពិសេសសម្រាប់ Lebanon មាត្រា២២។

ឧក្រិដ្ឋដូចគ្នា មិនរំលោភលើគោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយនោះទេ ដរាបណាភាពមិនត្រឹមត្រូវដែលកើតចេញពីការកាត់ទោសពីរដង ត្រូវបានគេគិតគូរសម្រាប់ការកាត់ទោស។ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ហាមឃាត់មិនឱ្យមានការចោទប្រកាន់ជាថ្មីម្តងទៀតដែលកើតចេញមកពី*អំពើដដែល*ដូចដែលមាននៅក្នុងការជំនុំជម្រះក្តីមុនៗ[134]។ នេះគឺជាគោលជំហររួមនៅក្នុងបណ្តារដ្ឋនៃទ្វីបភាគច្រើន (ដែលប្រើប្រព័ន្ធច្បាប់ស៊ីវិលឡ)[135]។ ប្រសិនបើអង្គបុរេជំនុំជម្រះ មិនច្បាស់ ថាតើគួរអនុវត្តការបកស្រាយក្នុងន័យចង្អៀត ដែលបានអះអាងដោយ ក.ស.ព ឬការបកស្រាយក្នុងន័យទូលាយ ដែលគាំទ្រដោយក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា និងជាទូទៅនៅក្នុងបណ្តារដ្ឋដែលប្រើប្រព័ន្ធច្បាប់ស៊ីវិលឡនោះ ការបកស្រាយក្នុងន័យទូលាយជាងត្រូវតែអនុវត្ត ស្របតាម *គោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ*

---

[134] *សូមមើល* NAQVI, ត្រង់ទំព័រ 324 (គូសបញ្ជាក់បន្ថែម) ដែលលោកស្រីបញ្ជាក់ថា "David Boyle បានលើកទឡ្ហីករណ៍ថានឹងមិនមានការហាមឃាត់ការកាត់ទោសពីរដងចំពោះបទល្មើសតែមួយឡើយលើ អៀង សារី ដែលកំពុងត្រូវបានជំនុំជម្រះទោសដោយអង្គជំនុំជម្រះវិសាមញ្ញរបស់កម្ពុជា ចំពោះអំពើប្រល័យពូជសាសន៍ ទោះបីជា សារី ត្រូវបានរកឃើញថាមានពិរុទ្ធភាពពី "បទប្រល័យពូជសាសន៍" ក្នុងការជំនុំជម្រះទោសកំបាំងមុខឆ្នាំ១៩៧៩ យ៉ាងណាក៏ដោយ (ហើយក្រោយមកត្រូវបានលើកលែងទោសក្នុងឆ្នាំ១៩៩៦) ពីព្រោះនិយមន័យនៃបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់នៅពេលជំនុំជម្រះទោសលើកដំបូង 'ដែលត្រូវបានកែសម្រួលភាសាដើម្បីធានាឱ្យមានការផ្តន្ទាទោស' ខុស ពីអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ឆ្នាំ១៩៤៨ ក្នុងវិសាលភាពដែលវាអាចគេមើលឃើញថាជា ការអនុវត្តច្បាប់ ក្នុងប្រទេសសុទ្ធសាធ។ <u>ទម្ងន់នៃទឡ្ហីករណ៍នេះគឺអាចជជែកពិភាក្សាបាន។ វាហាក់បីដូចជាថា បទល្មើសដែល ត្រូវ បានចោទប្រកាន់នៅក្នុងការជំនុំជម្រះទោសឆ្នាំ១៩៧៩ គឺដូចគ្នាមែនទែនទៅនឹងនិយមន័យនៃ អំពើប្រល័យពូជសាសន៍ ដែលមានចែងនៅក្នុងច្បាប់ឆ្នាំ២០០១ ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ</u>។ ទោះបីជាអត្ថន័យនៃនិយមន័យនៃអំពើ ប្រល័យពូជសាសន៍នៅក្នុងក្រិត្យស្តីពីការបង្កើតអង្គជំនុំជម្រះ ខុសគ្នាបន្តិចពីនិយមន័យក្នុងច្បាប់ឆ្នាំ២០០១ ក៏ដោយ ក្នុងអំឡុងដំណើរការនីតិវិធី John Quigley ជាមេធាវីអន្តរជាតិមកពីសហរដ្ឋអាមេរិក ត្រូវបានស្នើឱ្យផ្តល់ នូវសេចក្តី បញ្ជាក់ស្តីពីថាតើគាត់ពិចារណាថា អំពើប្រល័យពូជសាសន៍ដែលមានចែងនៅក្នុង អនុសញ្ញា ស្តីពីអំពើ ប្រល័យពូជសាសន៍ឆ្នាំ១៩៤៨ ត្រូវបានប្រព្រឹត្តឡើងក្នុងប្រទេសកម្ពុជា ឬយ៉ាងណា ក្នុងអំឡុងការជំនុំជម្រះក្តីឆ្នាំ១៩៧៩ ហើយបានសន្និដ្ឋានថា អំពើប្រល័យពូជសាសន៍នោះត្រូវបានប្រព្រឹត្តឡើង។ នេះបង្ហាញឱ្យឃើញថា ក្រិត្យមាន គោលបំណងដើម្បីឆ្លុះបញ្ចាំងអំពីនិយមន័យនៅក្នុងអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ ដូចច្បាប់ឆ្នាំ២០០១ ដែរ។ ដូច្នេះ វាមានការពិបាកក្នុងការជំទាស់ថា អៀង សារី ត្រូវបានផ្តន្ទាទោសក្នុងឆ្នាំ១៩៧៩ ចំពោះ 'បទឧក្រិដ្ឋធម្មតា' ហើយឥឡូវនេះអាចត្រូវបានផ្តន្ទាទោសម្តងទៀតចំពោះ 'បទឧក្រិដ្ឋអន្តរជាតិ'"។

[135] *ដូចជើងទំព័រខាងលើ* ត្រង់ទំព័រ 296។

ដោយសារតែវាជាប្រយោជន៍ដល់ជនជាប់ចោទ[136]។ លើសពីនេះទៀត បញ្ហានៃពិរុទ្ធភាពត្រួត មិនអាចអនុវត្តបានទេនៅទីនេះ[១៣៧]។ ការជំនុំជម្រះក្តីត្រូវបានបំបែកចេញអស់រយៈពេលជិត ៣០ឆ្នាំ ហើយ។ មេធាវីការពារក្តីមិនបានព្យាយាមប្តឹងឧទ្ធរណ៍ ចំពោះភាពអប្រក្រតីនៃនីតិវិធីនៅក្នុងការស៊ើបអង្កេត ដូចដែល ក.ស.ព បានអះអាងឡើយ[138]។

## V. អ.វ.ត.ក មិនមានយុត្តាធិការលើរឿងក្តីនេះលើឧក្រិដ្ឋកម្មជាតិឡើយ

### ក. ការពន្យារអាជ្ញាយុកាលចំពោះបទឧក្រិដ្ឋនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ រំលោភទៅលើគោលការណ៍នីត្យានុកូលភាព

៤១. នៅក្នុងកថាខណ្ឌ ៩០ ក.ស.ព អះអាងថា គោលការណ៍នីត្យានុកូលភាពដែលមានចែងនៅ ក្នុងមាត្រា ១៥.១ នៃកតិកាសញ្ញា ICCPR បានតម្រូវថា បទល្មើសត្រូវតែមានចែងនៅក្នុងច្បាប់ ដោយមានភាពអាចដឹងថាមានច្បាប់ចែង និងភាពអាចប្រមើលដឹងថាមានច្បាប់ចែងយ៉ាងគ្រប់គ្រាន់។ ក.ស.ព អះអាងថា ឧក្រិដ្ឋកម្មជាតិក្រោមយុត្តាធិការរបស់ អ.វ.ត.ក ត្រូវទៅតាមលក្ខខណ្ឌតម្រូវទាំងនោះ

---

[136] រដ្ឋធម្មនុញ្ញកម្ពុជាតម្រូវថា វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ។ សូមមើលរដ្ឋធម្មនុញ្ញកម្ពុជា មាត្រា៣៨។ គោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* (*in dubio pro reo*) ត្រូវបានចាត់ទុកថាជាបទដ្ឋាន យុត្តិធម៌អន្តរជាតិ។ នៅតុលាការ ICTY គោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* ត្រូវបានទទួលស្គាល់ យ៉ាងទូលំទូលាយ ដែលជាលទ្ធផលនៃសច្ចធារណ៍នៃនិរទោស និង បន្ទុកក្នុងការស្វែងរកភស្តុតាងដោយគ្មានវិមតិសង្ស័យ។ *សូមមើល រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Delalić *និងអ្នកផ្សេងទៀត*, IT-96-21-T, សាលក្រម, ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៨ (“សាលក្រមក្នុងរឿងក្តី *Čelebići*”), កថាខណ្ឌ 601។

[137] *សូមមើល* Hong S. Wills, *Cumulative Convictions and the Double Jeopardy Rule: Pursuing Justice at the ICTY and the ICTR*, 17 EMORY INT'L L. REV. ទំព័រ 341, 376 (២០០៣) “ការផ្តោត [នៃការរារាំងមិនឱ្យមានការផ្តន្ទាទោសពីរដងចំពោះបទល្មើសតែមួយ] គឺស្តីអំពីភាពអាចអនុញ្ញាតបាននៃការចោទប្រកាន់លើកក្រោយចំពោះបទល្មើសដដែលជាជាងពិរុទ្ធភាពត្រួតគ្នានៅក្នុងដំណើរការនីតិវិធីតែមួយ”។ *សូមមើលផងដែរ* Anne Bowen Poulin, *Double Jeopardy and Multiple Punishment: Cutting the Gordian Knot*, 77 U. COLO. L. REV. ទំព័រ 595 (២០០៦) ដែលពិភាក្សា (ក្នុងយុត្តិសាស្ត្រសហរដ្ឋអាមេរិក) អំពីបញ្ហានៃការភ័ន្តច្រឡំអំពីគោលការណ៍ការផ្តន្ទាទោសពីរដងចំពោះបទល្មើសតែមួយ ជាមួយនឹងពិរុទ្ធភាពត្រួតគ្នា។

[138] *សូមមើល* Response, កថាខណ្ឌ៣២។

ហើយថា ដូច្នេះការពន្យារអាជ្ញាយុកាល គឺត្រូវជាមួយនឹងអាជ្ញាយុកាលស្តីពីនីត្យានុកូលភាព។ ទោះបីជាយ៉ាងណាក៏ដោយ ដូចដែលចៅក្រមអន្តរជាតិនៃអង្គជំនុំជម្រះសាលាដំបូងលើរឿងក្តីឌុច បានពន្យល់ "ទាំងមាត្រា១៤ និងមាត្រា១៥ នៃ ICCPR មិនបានសំដៅដោយផ្ទាល់ចំពោះថិរវេលានៃអាជ្ញាយុកាលទេ។ ដូច្នេះ ប្រភពទាំងនេះពុំបានបកស្រាយច្បាស់លាស់អំពីដែនកំណត់នៃគោលការណ៍ជំនុំជម្រះប្រកបដោយយុត្តិធម៌ជាអន្តរជាតិ ដែលទាក់ទងនឹងការពិចារណាអំពីប្រតិសកម្មនៃច្បាប់ ឬការលុបចោលអាជ្ញាយុកាលនោះទេ"[139]។ កតិកាសញ្ញា ICCPR មានលក្ខណៈមិនច្បាស់អំពីដែនកំណត់នៃគោលការណ៍ជំនុំជម្រះ ប្រកបដោយយុត្តិធម៌ជាអន្តរជាតិ ដែលទាក់ទងនឹងការពិចារណាអំពីប្រតិសកម្មនៃច្បាប់ ឬការលុបចោលអាជ្ញាយុកាល។ ដែនកំណត់ នៃគោលការណ៍ជំនុំជម្រះទោសប្រកបដោយយុត្តិធម៌ជាអន្តរជាតិ គឺទូលំទូលាយជាងអ្វី ដែលមានបញ្ជាក់យ៉ាងច្បាស់នៅក្នុង ICCPR។ "សិទ្ធិក្នុងការទទួលបានសច្ចភាពផ្លូវច្បាប់ គឺជាធាតុផ្សំមួយក្នុងចំណោមធាតុផ្សំជាច្រើនទៀតនៃគោលការណ៍នីត្យានុកូលភាព ឬ *គ្មានបទល្មើស បើគ្មានច្បាប់ចែង* (*nullum crimen sine leg)* ដែលបានបង្កើតឡើងយ៉ាងត្រឹមត្រូវ ដែលរួមបញ្ចូលនូវការហាមឃាត់នូវច្បាប់ប្រតិសកម្ម... ក្នុងគោលការណ៍នៃនិយ័តភាពគតិយុត្តិ បញ្ជាក់ថា សិទ្ធិស្របច្បាប់មិនអាចត្រូវបានធ្វើវិសោធនកម្ម ដោយប្រតិសកម្ម ដែលធ្វើឱ្យប៉ះពាល់ដល់ចុងចោទ ដែលបានទទួលសិទ្ធិស្របច្បាប់នេះឡើយ"[140] គោលការណ៍នីត្យានុកូលភាពមានទិដ្ឋភាព ចំនួនបួន ៖ ច្បាប់ជាលាយលក្ខណ៍អក្សរ *lex scripta* (ការដាក់ទោសទណ្ឌត្រូវតែផ្អែកទៅលើច្បាប់ដែលមានចែងជាលាយលក្ខណ៍អក្សរ) ច្បាប់ត្រូវតែមានលក្ខណៈច្បាស់លាស់ *lex certa* (ទម្រង់ និងភាពធ្ងន់ធ្ងរនៃទោសទណ្ឌ ត្រូវតែកំណត់ឱ្យបានច្បាស់ និងអាចកំណត់លក្ខណៈខុសគ្នាបាន) គោលការណ៍នៃអានុភាពអប្រតិសកម្ម *lex praevia* (ការហាមឃាត់ប្រឆាំងនឹងការអនុវត្តប្រតិសកម្ម) និងច្បាប់ត្រូវតែតឹងរ៉ឹង *lex stricta* (ការហាមឃាត់ ប្រឆាំងនឹងការអនុវត្តទោសទណ្ឌតាម

---

[139] *រឿងក្តី កាំង ហ្គេកអ៊ាវ ហៅ "ឌុច"* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ, សេចក្តីសម្រេចស្តីពីអញ្ញត្រកម្មទាក់ទងនឹងថិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិ ដែលលើកឡើងដោយមេធាវីការពារក្តី យោបល់របស់ចៅក្រម Silvia Cartwright និង Jean-Marc Lavergne ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E187 ("សេចក្តីសម្រេចទាក់ទងនឹងបទល្មើសថ្នាក់ជាតិ"), កថាខណ្ឌ៤២ (គូសបញ្ជាក់បន្ថែម)។

[140] សៀវភៅនិពន្ធដោយ RUTH A. KOK មានចំណងជើងថា STATUTORY LIMITATIONS IN INTERNATIONAL CRIMINAL LAW ទំព័រ290, 308 (2007) ("KOK")។

សទិសភាព)[141]។ "ស្ទើរតែគ្មានករណីលើកលែងឡើយ បណ្តារដ្ឋដែលមានទស្សនៈថា គោលការណ៍នៃអានុភាពអប្រតិសកម្ម (lex praevia) គឺជាលក្ខណៈពិសេសជាមូលដ្ឋាននៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌណាមួយ រួមទាំងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ"[142]។ ទោះបីជាក្រុមប្រឹក្សាធម្មនុញ្ញបានរកឃើញថាគោលការណ៍នោះមិនមែនជាគោលការណ៍ធម្មនុញ្ញក៏ដោយ ក្រុមប្រឹក្សា ធម្មនុញ្ញបានអះអាងថា វាគឺជាគោលការណ៍ជាមូលដ្ឋាន" ដែលត្រូវបានទទួលស្គាល់ដោយ ប្រទេសកម្ពុជា[143]។

**១. បញ្ហាមិនមែនថាតើ ឧក្រិដ្ឋកម្មជាតិមានចែងក្នុងច្បាប់ដែលមានលក្ខណៈ គ្រប់គ្រាន់ស្តីពីភាពអាចដឹងថាមានច្បាប់ចែង និងមិនមែនថាតើ ទណ្ឌកម្មព្រហ្មទណ្ឌអាចប្រមើលដឹងថាជាបទឧក្រិដ្ឋយ៉ាងគ្រប់គ្រាន់រវាងឆ្នាំ១៩៧៥-១៩៧៩ ឬយ៉ាងណានោះទេ**

៤២. នៅក្នុងកថាខណ្ឌ ៩១ ក.ស.ព អះអាងថា ការពន្យារអាជ្ញាយុកាលសម្រាប់ឧក្រិដ្ឋកម្មជាតិ មិនបំពានលើលក្ខខណ្ឌដែលថា ឧក្រិដ្ឋកម្មនានាត្រូវតែច្បាប់កំណត់និយមន័យ ពីព្រោះវាមិនត្រូវបានផ្លាស់ប្តូរធាតុផ្សំចាំបាច់នៃបទល្មើសដែលត្រូវបានចោទប្រកាន់ឡើយ។ ក.ស.ព អះអាងថា មាត្រា៥១.១ នៃកតិកាសញ្ញា ICCPR គ្រាន់តែហាមឃាត់នូវការឱ្យបុគ្គលម្នាក់មានពិរុទ្ធភាពពីឧក្រិដ្ឋកម្មមួយដែលមិនមែនជាបទល្មើស នៅពេលដែលត្រូវបានប្រព្រឹត្ត ហើយថាឧក្រិដ្ឋកម្មទាំងឡាយដែលមានរៀបរាប់នៅក្នុងមាត្រានៅក្នុងមាត្រា៣(ថ្មី) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះ ត្រូវបានចែងផ្តន្ទាទោសព្រហ្មទណ្ឌដោយក្រម ព្រហ្មទណ្ឌឆ្នាំ១៩៥៦។ ក.ស.ព យល់ខុសលើបញ្ហានេះ ដែលមិនមែនគ្រាន់តែថាតើឧក្រិដ្ឋកម្មទាំងឡាយដែលមានរៀបរាប់នៅក្នុងមាត្រា៣ថ្មី ត្រូវបានចែងផ្តន្ទាទោសព្រហ្មទណ្ឌនៅពេលវេលាដែលពាក់ព័ន្ធ ឬយ៉ាងណានោះទេ។ មេធាវីការពារក្តីមិនបានជំទាស់ថា ឧក្រិដ្ឋកម្មជាតិមិនមានអត្ថិភាពក្នុងឆ្នាំ១៩៧៥-៧៩ ឡើយ។

---

[141] *សូមមើល* SUPRANATIONAL CRIMINAL LAW: A SYSTEM *SUI GENERIS* 40 (Roelof Haveman និងអ្នកផ្សេងទៀត ប្រែសម្រួល Intersentia ២០០៣)។

[142] សៀវភៅនិពន្ធដោយ Shahram Dana មានចំណងជើងថា *Beyond Retroactivity to Realizing Justice: A Theory on the Principle of Legality in International Criminal Law Sentencing*, 99 J. Crim. L. & Criminology ទំព័រ857, 878 (២០០៩)។

[143] សេចក្តីសម្រេចក្រុមប្រឹក្សាធម្មនុញ្ញលេខ ០៤០/០០២/២០០១, ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០១, ទំព័រ២ (បកប្រែក្រៅផ្លូវការគូសបញ្ជាក់បន្ថែម)។

៤៣. ក្នុងកថាខណ្ឌ ៩២ ក.ស.ព បញ្ជាក់ថា ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ អាចរកបានចំពោះលោក អៀង សារី ហើយថា ការពន្យារអាជ្ញាយុកាលមិនអាចផ្លាស់ប្តូរចំណុចនេះបានឡើយ។ មេធាវីការពារក្តីមិនបានជំទាស់ថា ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ មិនអាចរកបាននោះឡើយ ហើយនេះមិនមែនជាបញ្ហាទេ។ ក.ស.ព អះអាងថា គោលបំណងនៃនីត្យានុកូលភាពគឺដើម្បីច្រានចោលជាមុន នូវការដាក់ទណ្ឌកម្មចំពោះអំពើទាំងឡាយដែលគេមិនបានជឿជាក់ថា ជាអំពីព្រហ្មទណ្ឌនៅពេលដែលត្រូវបានប្រព្រឹត្ត។ នេះអាចជាគោលបំណងមួយនៃគោលការណ៍នីត្យានុកូលភាព ប៉ុន្តែវាមិនមែនជាគោលបំណងតែមួយគត់ប៉ុណ្ណោះនោះទេ។ គោលបំណងនៅពីក្រោយគោលការណ៍នៃអានុភាពអប្រតិសកម្មនៃច្បាប់គឺដើម្បី "ធានា រក្សាការអនុវត្តនូវគោលការណ៍អនាគតិ និងសត្យានុម័តរបស់នីតិរដ្ឋ"[144] និងដើម្បីផ្តល់នូវការធានាប្រឆាំងនឹងច្បាប់ប្រតិសកម្ម ដែលអាចផ្លាស់ប្តូរបាន និងតាមតែអំពើចិត្ត ដែលនឹងធ្វើឲ្យជនជាប់ចោទមិនទទួលបាននូវការក្រើនរំឭកដ៏ត្រឹមត្រូវជាមុន ដែលអាចនាំឲ្យគាត់រក្សាបាននូវភស្តុតាងដោះបន្ទុក[145]។ អាជ្ញាយុកាល ការពារបុគ្គលទាំងឡាយពីការ ត្រូវតែការពារខ្លួនពួកគេនៅពេលសវនាការ ដែលផ្អែកទៅលើភស្តុតាងដែលមិនមានសុពលភាព និងដើម្បីបង្កើតនូវស្ថេរភាព និងសច្ចភាពនៅក្នុងច្បាប់[146]។ បញ្ហាថាតើ លោក អៀង សារី អាចប្រមើលដឹងជាមុន បានថាមានទោសទណ្ឌអស់រយៈពេលជាង៣០ឆ្នាំ បន្ទាប់ពីឧក្រិដ្ឋកម្ម ត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តឡើង ឬយ៉ាងណា និងថាតើច្បាប់នេះដែលអនុញ្ញាត ឲ្យមានការដាក់ទោសទណ្ឌ នៅពេលអនាគតដ៏យូរអង្វែង អាចឲ្យគេរកបាន ឬយ៉ាងណានោះ គឺជាបញ្ហាពាក់ព័ន្ធ។

៤៤. នៅក្នុងកថាខណ្ឌ ៩៣ ក.ស.ព អះអាងថា ប្រភពច្បាប់ផ្សេងៗ ដែលបានដកស្រង់ដោយ មេធាវីការពារក្តី បានគាំទ្រនូវគោលជំហរថា អាជ្ញាយុកាលអាចត្រូវបានពន្យារនៅក្នុងកាលៈទេសៈមួយចំនួននៅមុនពេលដែលបទល្មើសបានក្លាយទៅជាការរារាំងមួយដោយអាជ្ញាយុកាល។ ក.ស.ព អះអាងថា ដោយសារអាជ្ញាយុកាលដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ អាចត្រូវបានពន្យារនៅមុនពេលផុតកំណត់អាជ្ញាយុកាលនោះ ការពន្យារបែបនោះមិនអាចថាមិនបានប្រមើលដឹងជាមុនបាន

[144]សេចក្តីសម្រេចទាក់ទងនឹងបទល្មើសថ្នាក់ជាតិ យោបល់របស់ចៅក្រម Silvia Cartwright និង Jean-Marc Lavergne, កថាខណ្ឌ៥៣។

[145] *សូមមើលផងដែរ រឿងក្តី Stogner តទល់នឹង California*, 539 U.S. ទំព័រ 607, 611 (២០០៣) (យោងខាងក្នុងត្រូវបានលុប)។

[146] NAQVI, ទំព័រ 183។

ចំពោះលោក អៀង សារី ឡើយ។ ក្នុងខណៈដែលជាការពិតណាស់ដែលថា តុលាការជាតិខ្លះបានយល់ឃើញថា ការពន្យារអាជ្ញាយុកាលអាចអនុញ្ញាតបាន នៅពេលដែលអាជ្ញាយុកាលមិនទាន់បានផុតកំណត់នោះ នេះមិនមែនជាគោលជំហរជាសកលឡើយ ហើយគោលជំហររបស់ប្រទេសកម្ពុជាលើបញ្ហានេះគឺមិនច្បាស់លាស់ ពីព្រោះច្បាប់មិនបានចែងអំពីបញ្ហានេះ។ លទ្ធភាពដែលតុលាការកម្ពុជាកំណត់ថា ការពន្យារអាជ្ញាយុកាល (នៅមុនការផុត) កំណត់នៃអាជ្ញាយុកាលនោះ មិនរំលោភលើគោលការណ៍នៃអានុភាពអប្រតិសកម្ម នឹងមិនអាចប្រមើលដឹងជាមុន និងអាចរកបានចំពោះលោក អៀង សារី ឡើយ។ វាមិនមានចែងនៅក្នុងច្បាប់កម្ពុជាឡើយ។ តុលាការកម្ពុជាមិនដែលបានធ្វើការកំណត់បែបនេះឡើយកាលពីអតីតកាល។

៤៥. នៅក្នុងកថាខណ្ឌ ៩៤ ក.ស.ព អះអាងថា ចៅក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី ឌុច ចំនួនពីររូបដែលជំទាស់ "មិនបានរកឃើញនូវការខ្វែងយោបល់គ្នាច្បាស់លាស់ រវាងបទដ្ឋានអន្តរជាតិនៃការជំនុំជម្រះក្តីដោយយុត្តិធម៌ ដែលអាចអនុវត្តនៅចំពោះមុខ អ.វ.ត.ក និងវិសោធនកម្មដោយមានប្រតិសកម្ម ដោយអង្គនីតិប្បញ្ញត្តិជាតិ ទៅលើថិរវេលានៃអាជ្ញាយុកាលនោះទេ"[147]។ សេចក្តីបញ្ជាក់របស់ចៅក្រមអន្តរជាតិ គួរត្រូវបានដាក់បញ្ចូលនៅក្នុងបរិបទ។ ពួកគាត់បញ្ជាក់ថា "ទាំងមាត្រា ១៤ និងមាត្រា១៥ នៃ ICCPR មិនបានសំដៅដោយផ្ទាល់ចំពោះថិរវេលានៃអាជ្ញាយុកាលទេ។ <u>ដូច្នេះប្រភពទាំងនេះពុំបានបកស្រាយច្បាស់លាស់អំពីដែនកំណត់នៃគោលការណ៍ជំនុំជម្រះ ប្រកបដោយយុត្តិធម៌ជាអន្តរជាតិ ដែលទាក់ទងនឹងការពិចារណាអំពីប្រតិសកម្មនៃច្បាប់ ឬលុបចោលអាជ្ញាយុកាលនោះទេ</u>"។ ដូច្នេះ ចៅក្រមអន្តរជាតិ មិនបានរកឃើញនូវការខ្វែងយោបល់គ្នា<u>ច្បាស់លាស់</u>រវាងបទដ្ឋានអន្តរជាតិនៃការជំនុំជម្រះក្តីដោយយុត្តិធម៌ ដែលអាចអនុវត្តនៅចំពោះមុខ អ.វ.ត.ក និងវិសោធនកម្មដោយមានប្រតិសកម្ម ដោយអង្គនីតិប្បញ្ញត្តិជាតិ ទៅលើថិរវេលានៃអាជ្ញាយុកាលនោះទេ"[148]។ ចៅក្រមអន្តរជាតិបានយល់ឃើញទៀតថា អង្គនីតិប្បញ្ញត្តិជាតិមិនបានបង្កើតនូវបទប្បញ្ញត្តិច្បាប់ ដែលមានលក្ខណៈច្បាស់លាស់ និងផ្ចិតផ្ចង់ដើម្បីធ្វើវិសោធនកម្ម ដោយប្រតិសកម្មលើអាជ្ញាយុកាល

---

[147]ចម្លើយតប កថាខណ្ឌ៩៤, *ដកស្រង់ចេញពី* សេចក្តីសម្រេចទាក់ទងនឹងបទល្មើសថ្នាក់ជាតិ យោបល់របស់ចៅក្រម Silvia Cartwright និង Jean-Marc Lavergne កថាខណ្ឌ៤៣។

[148]សេចក្តីសម្រេចទាក់ទងនឹងបទល្មើសថ្នាក់ជាតិ យោបល់របស់ចៅក្រម Silvia Cartwright និង Jean-Marc Lavergne កថាខណ្ឌ៤២-៤៣។

ឡើយ[149]។

២. មាត្រា១៥(២) នៃកតិកាសញ្ញា ICCPR មិនបានចែងអំពីករណីលើកលែងដែលនឹងអនុញ្ញាត ឲ្យមានយុត្តាធិការលើឧក្រិដ្ឋកម្មជាតិឡើយ

៤៦. នៅក្នុងកថាខណ្ឌ ៩៥ និង ៩៦ ក.ស.ព អះអាងថា ឧក្រិដ្ឋកម្មជាតិស្តីពីមនុស្សឃាត ទារុណកម្ម និងការវាយប្រហារលើសាសនា គឺស្ថិតនៅក្រោមមាត្រា ១៥(២) នៃកតិកាសញ្ញា ICCPR ពីព្រោះ ការកំណត់ថាជាបទល្មើសព្រហ្មទណ្ឌលើអំពើមនុស្សឃាត អំពើទារុណកម្ម និងការវាយប្រហារលើ សាសនា គឺជាគោលការណ៍ទូទៅនៃច្បាប់។ នៅក្នុងកថាខណ្ឌ ៩៧ ក.ស.ព បញ្ជាក់ថា ដោយសារ ឧក្រិដ្ឋកម្មទាំងនេះគឺពិតជាផ្ទុយទៅនឹងច្បាប់ លោក អៀង សារី មិនអាចជំទាស់បានឡើយថា ការទទួលខុសត្រូវព្រហ្មទណ្ឌមិនអាចប្រមើលដឹងជាមុនបាននោះ។ មេធាវីការពារក្តី មិនបានតវ៉ាថា ឧក្រិដ្ឋកម្មទាំងនោះមិនមានអត្ថិភាព នៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ មុនឆ្នាំ១៩៧៥ នោះទេ។ បញ្ហាគឺ មិនមែនថា អ.វ.ត.ក កំពុងអនុវត្តឧក្រិដ្ឋកម្មទាំងឡាយដែលមិនមានអត្ថិភាពនៅក្នុងច្បាប់ជាធរមានក្នុង ឆ្នាំ១៩៧៥-៧៩ នោះទេ ប្រសិនបើតុលាការអនុវត្តមាត្រា៣ថ្មី ។ បញ្ហាគឺថា អាជ្ញាយុកាលសម្រាប់ ឧក្រិដ្ឋកម្មទាំងនេះ បានផុតកំណត់អស់រយៈពេលជាច្រើនឆ្នាំមកហើយ មុនពេលមានការបង្កើត អ.វ.ត.ក ហើយការយកក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ មកអនុវត្តចំពោះឧក្រិដ្ឋកម្មទាំងនោះនាពេលនេះ នឹងរំលោភលើ គោលការណ៍នៃអានុភាពអប្រតិសកម្មនៃច្បាប់។

៣. ការធ្វើឲ្យដំណើរការឡើងវិញនូវអាជ្ញាយុកាល បន្ទាប់ពីការផុតកំណត់នៃអាជ្ញាយុកាលនោះ មិនមែនជាបញ្ហានីតិវិធីតែប៉ុណ្ណោះនោះទេ

៤៧. កថាខណ្ឌ ៩៨ ក.ស.ព អះអាងថា អាជ្ញាយុកាលគឺជានីតិវិធី ហើយការពន្យារអាជ្ញាយុកាលគឺជា បញ្ហានីតិវិធី។ ក្នុងកថាខណ្ឌ ៩៩ ក.ស.ព អះអាងថា ការកំណត់ចំពោះថាតើ ការពន្យារអាជ្ញាយុកាល គឺជាបញ្ហានីតិវិធី ឬបញ្ហាសារធាតុនោះ គឺមិនពាក់ព័ន្ធឡើយ ក្នុងការសម្រេច ថាតើការពន្យារ អាជ្ញាយុកាលនេះ ស្របនឹងគោលការណ៍នីត្យានុកូលភាព ដូចដែលមានចែងក្នុងមាត្រា១៥.១ នៃ កតិកាសញ្ញា ICCPR ដែរឬអត់។ មេធាវីការពារក្តី បានចង្អុលបង្ហាញនៅក្នុងបណ្តឹងឧទ្ធរណ៍ថា បណ្តា

[149] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ៤៧-៤៩។

រដ្ឋជាច្រើនមានទស្សនៈថា ច្បាប់ពន្យារអាជ្ញាយុកាលនៃបទល្មើសមានផ្ទុកនូវការចោទប្រកាន់ និង ការផ្តន្ទាទោស ដែលចែងដាច់ដោយឡែកពីច្បាប់នីតិវិធីផ្សេងទៀត[150]។

**៤. សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ទាក់ទិននឹងមាត្រា៣ថ្មី មិនមាន ន័យថា មាត្រា៣ ថ្មី ត្រូវតែយកមកអនុវត្តនៅ អ.វ.ត.ក នោះទេ**

៤៨. នៅក្នុងកថាខណ្ឌ ១០០ ក.ស.ព អះអាងថា ក្រុមប្រឹក្សាធម្មនុញ្ញបានពិចារណាអំពីបញ្ហា ថាតើ ការពន្យារអាជ្ញាយុកាលមានធម្មនុញ្ញភាពដែរឬយ៉ាងណា ហើយបានសម្រេចថា វាស្របនឹងរដ្ឋធម្មនុញ្ញ ហើយ។ នេះមិនមានន័យថា អ.វ.ត.ក មានយុត្តាធិការដើម្បីអនុវត្ត មាត្រា៣ថ្មី ឡើយ។ អង្គបុរេជំនុំ ជម្រះត្រូវតែពិចារណាថាតើ ការអនុវត្តមាត្រា៣ថ្មី នឹងរំលោភលើរដ្ឋធម្មនុញ្ញកម្ពុជា ច្បាប់កម្ពុជា ឬ អនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជា ជាភាគីហត្ថលេខីមួយ ដែរឬទេ[151]។ ការអនុវត្តមាត្រា៣ថ្មី នឹង រំលោភលើរដ្ឋធម្មនុញ្ញកម្ពុជា ឬច្បាប់កម្ពុជា ឬអនុសញ្ញាអន្តរជាតិ ដូចដែលបានពន្យល់នៅក្នុងបណ្តឹង ឧទ្ធរណ៍។ ក្នុងសំណុំរឿង ០០១ អង្គជំនុំជម្រះសាលាដំបូងលើរឿងក្តី ឌុច យល់ឃើញថា ការអនុវត្ត ប្រតិសកម្មនៃច្បាប់ គឺជាការរំលោភលើសិទ្ធិរបស់ជនជាប់ចោទ តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់អន្តរជាតិ[152]។

៤៩. នៅក្នុងកថាខណ្ឌ ១០១ ក.ស.ព អះអាងថា សិទ្ធិទទួលបានការប្រព្រឹត្តដូចៗគ្នា ត្រូវបានចែងនៅក្នុង រដ្ឋធម្មនុញ្ញកម្ពុជា ហើយក្រុមប្រឹក្សាធម្មនុញ្ញយល់ឃើញយ៉ាងជាក់លាក់ថា មាត្រា៣ថ្មី មិនបានរំលោភ លើរដ្ឋធម្មនុញ្ញ ឡើយ។ ក.ស.ព អះអាងថា សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញមានលក្ខណៈ ជាប់កាតព្វកិច្ច និងជាស្ថាពរ ហើយថា អ.វ.ត.ក ពុំមានសមត្ថកិច្ចពិនិត្យសេចក្តីសម្រេចនានារបស់ ក្រុមប្រឹក្សាធម្មនុញ្ញទេ។ ក្រុមប្រឹក្សាធម្មនុញ្ញមិនបានពិចារណា ឬលើកឡើងជាក់លាក់អំពីបញ្ហានៃ មាត្រា៣ថ្មី ដែលរំលោភលើ សិទ្ធិទទួលបានការប្រព្រឹត្តដូចៗគ្នារបស់លោក អៀង សារី ឡើយ។ បញ្ហា

---

[150] *សូមមើល* បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ១៦០-៦៣។

[151] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ១៥១-៥៣, ១៥៧, ១៦៧។

[152] *សូមមើល រឿងក្តី កាំង ហ្កេកអ៊ាវ ហៅ ឌុច* ០០១/១៨-០៧-២០០៧/អ.វ.ត.ក/អ.ជ.ស.ដ, សេចក្តីសម្រេចលើ សំណើសុំដោះលែងជនជាប់ចោទឲ្យនៅក្រៅឃុំ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ ឯកសារ E39/5, ERN: 00338832-00338846, កថាខណ្ឌ២១។

នេះនឹងត្រូវបានពិភាក្សាលម្អិតថែមទៀតនៅក្នុងផ្នែក*ខាងក្រោម* ទាក់ទិននឹងការប្រព្រឹត្តដូចៗគ្នា។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញចងកាតព្វកិច្ច អ.វ.ត.ក ដែល អ.វ.ត.ក មិនមានអំណាចដើម្បីច្រានចោលសេចក្តីសម្រេច ឬប្រកាសថា មាត្រា៣ថ្មី ត្រូវតែធ្វើវិសោធនកម្ម ឬត្រូវតែដកចេញពីច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះឡើយ។ នេះមិនមានន័យថា អ.វ.ត.ក ត្រូវតែកំណត់ថា ខ្លួនមានយុត្តាធិការ ដើម្បីអនុវត្តមាត្រា៣ថ្មី ឡើយ។ អ.វ.ត.ក មានកាតព្វកិច្ចមួយដើម្បីអនុវត្តយុត្តាធិការរបស់ខ្លួន និងអនុវត្តតែច្បាប់ណាដែលមិនរំលោភលើរដ្ឋធម្មនុញ្ញកម្ពុជា ច្បាប់កម្ពុជា (រួមទាំងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះផង) ឬអនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាក៏ជាភាគីហត្ថលេខីផងដែរ។ ការអនុវត្ត មាត្រា៣ថ្មី នឹងរំលោភលើរដ្ឋធម្មនុញ្ញកម្ពុជា ឬច្បាប់កម្ពុជា ឬអនុសញ្ញាអន្តរជាតិ។ ទឡ្ហីករណ៍ទាំងនេះរបស់ ក.ស.ព ជួយគាំទ្របន្ថែមទៀត ចំពោះទស្សនៈដែលថា អ.វ.ត.ក គឺជាតុលាការកម្ពុជាក្នុងស្រុក។

៥០. នៅក្នុងកថាខណ្ឌ ១០២ ក.ស.ព អះអាងថា មានការសន្និដ្ឋានយ៉ាងមុតមាំថា ក្រុមប្រឹក្សាធម្មនុញ្ញបានជឿថា ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក រួមទាំងការពន្យារអាជ្ញាយុកាលផង គឺស្របតាមកាតព្វកិច្ចអន្តរជាតិរបស់កម្ពុជា។ ពុំមានការសន្និដ្ឋានយ៉ាងមុតមាំឡើយថា ក្រុមប្រឹក្សាធម្មនុញ្ញបានពិចារណាថាតើ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ស្របតាមកាតព្វកិច្ចអន្តរជាតិរបស់កម្ពុជា រួមទាំងកាតព្វកិច្ចនៃការប្រព្រឹត្តដូចៗគ្នា ដែរឬយ៉ាងណា។ តាមពិត ការសន្និដ្ឋានប្រាកដជាផ្ទុយគ្នាស្រឡះ ៖ ក្រុមប្រឹក្សាធម្មនុញ្ញបានពិចារណាត្រឹមតែ ថាតើ ការពន្យារអាជ្ញាយុកាលនឹងរំលោភលើគោលការណ៍នៃអានុភាពអប្រតិសកម្ម ដែរឬយ៉ាងណាប៉ុណ្ណោះ។ ចំណុចនេះមានលក្ខណៈច្បាស់លាស់ចេញពីអត្ថបទនៃសេចក្តីសម្រេច ដែលបញ្ជាក់ថា "មាត្រា១៖ ផ្អែកលើអត្ថបទខាងលើ ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ... ត្រូវបានសម្រេចថាអនុលោមតាមរដ្ឋធម្មនុញ្ញ..."[153]។ ក្រុមប្រឹក្សាធម្មនុញ្ញមិនបានយោងទៅលើមាត្រា៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជាឡើយ ហើយក៏មិនបានយោងទៅលើកាតព្វកិច្ចអន្តរជាតិរបស់កម្ពុជាដែរ។ មិនមានការបញ្ជាក់អំពីការប្រព្រឹត្តដូចៗគ្នាឡើយ។

---

[153] សេចក្តីសម្រេចក្រុមប្រឹក្សាធម្មនុញ្ញ លេខ ០៤០/00២/២០០១, ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០១ មាត្រា ១ (បកប្រែក្រៅផ្លូវការ គូសបញ្ជាក់បន្ថែម)។

៥១. នៅក្នុងកថាខណ្ឌ ១០៣ និង ១០៤ ក.ស.ព ពិភាក្សាអំពីសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ឆ្នាំ ២០០៧ ដែលត្រូវបានយោងនៅក្នុងបណ្ដឹងឧទ្ធរណ៍[154]។ ក.ស.ព អះអាងថា សេចក្ដីសម្រេចនេះមិនបានបញ្ជាក់ឱ្យបានច្បាស់ អំពីការអនុវត្តការពិនិត្យឡើងវិញតាមផ្លូវ តុលាការដោយចៅក្រមជំនុំជម្រះឡើយ ផ្ទុយទៅវិញសេចក្ដីសម្រេចនេះគ្រាន់តែ "ណែនាំចៅក្រមឱ្យបកស្រាយបទប្បញ្ញត្តិច្បាប់ពាក់ព័ន្ធឱ្យមានសុខដុមនីយកម្មជាមួយរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតុបករណ៍អន្តរជាតិពាក់ព័ន្ធដទៃទៀតតែប៉ុណ្ណោះ។ ដូច្នេះ ប្រសិនបើមានការកម្រិតណាមួយដ៏ខ្លាំងនោះ សេចក្ដីសម្រេចនេះគឺពាក់ព័ន្ធសម្រាប់ករណីបច្ចុប្បន្ននេះ"។ នេះមិនបានធ្វើការសម្រេចអំពីតម្លៃនៃ "ការកម្រិតដ៏ខ្លាំង" ឡើយ។ ក្រុមប្រឹក្សាធម្មនុញ្ញបានបញ្ជាក់យ៉ាងជាក់លាក់ថា ចៅក្រមគួរតែពិចារណាទៅលើរដ្ឋធម្មនុញ្ញកម្ពុជា ច្បាប់ជាធរមានដទៃៗទៀត និងអនុសញ្ញានានា ដែលប្រទេសកម្ពុជាបានទទួលស្គាល់[155]។ មេធាវីការពារក្ដីពុំ បានស្នើដល់អង្គបុរេជំនុំជម្រះឱ្យបដិសេធសេចក្ដីសម្រេច របស់ក្រុមប្រឹក្សាធម្មនុញ្ញឡើយ ប៉ុន្តែស្នើឱ្យពិនិត្យឡើងវិញនូវប្រភពដែលអាចអនុវត្តបានទាំងអស់ ក្នុងការសម្រេចថាតើ ខ្លួនអាចអនុវត្តយុត្តាធិការទៅលើលោក អៀង សារី ឬយ៉ាងណា។ ចំណុចនេះនឹងស្របជាមួយនឹងសេចក្ដីសម្រេចឆ្នាំ២០០៧ របស់ក្រុមប្រឹក្សាធម្មនុញ្ញ។

### ៥. "ការលើកលែងនៃការផ្តន្ទាទោសស្រាលជាង"

៥២. នៅក្នុងកថាខណ្ឌ ១០៥ និង ១០៦ ក.ស.ព អះអាងថា មាត្រា៣ថ្មី មិនបានរំលោភលើការលើកលែងនៃការផ្តន្ទាទោសស្រាលជាង ដែលមានចែងនៅក្នុងមាត្រា១៥.១ នៃកតិកាសញ្ញា ICCPR (ដែលចែងថា មិនត្រូវដាក់ទណ្ឌកម្មឱ្យធ្ងន់ជាងទណ្ឌកម្មដែលបានអនុវត្ត នៅពេលដែលបានប្រព្រឹត្តបទល្មើសនោះឡើយ) ពីព្រោះកាលបរិច្ឆេទពាក់ព័ន្ធសម្រាប់ការប្រៀបធៀប គឺចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ មិនមែនកាលបរិច្ឆេទនៃការផុតរលត់អាជ្ញាយុកាលនោះទេ។ ក.ស.ព អះអាងថា មាត្រា១៥.១ មិនត្រូវបានរំលោភឡើយ ពីព្រោះកម្រិតទោសអតិបរមាចំពោះការប្រព្រឹត្តបទឧក្រិដ្ឋទាំងនោះ ដែលបានកំណត់នៅក្នុងមាត្រា៣ថ្មី គឺត្រឹមដាក់ពន្ធនាគារអស់មួយជីវិត មិនមែនទោសប្រហារជីវិតឡើយ។ ការលើកលែង

---

[154] *សូមមើល* បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ១៥១-៥៣, ១៥៧, ១៦៧។

[155] សេចក្ដីសម្រេចក្រុមប្រឹក្សាធម្មនុញ្ញ លេខ ០៩២/០០៣/២០០៧ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧ (បកប្រែក្រៅផ្លូវការជាភាសាអង់គ្លេសដោយ OHCHR Cambodia)។

នៃការផ្តន្ទាទោសស្រាលជាង គឺមិនអាចអនុវត្តបានទេនៅទីនេះ។ រយៈពេល ពាក់ព័ន្ធនៅក្នុងឧទាហរណ៍នេះ គឺមិនមែននៅក្នុងចន្លោះឆ្នាំ១៩៧៥-៧៩ ឡើយ ប៉ុន្តែនៅពេលដែលអាជ្ញាយុកាលបានផុតរលត់។ ដូចដែលចៅក្រមអន្តរជាតិនៃអង្គជំនុំជម្រះសាលា ដំបូងលើរឿងក្តី ឌុច បានពន្យល់ មាត្រា១៥ នៃកតិកាសញ្ញា ICCPR មាត្រា១៥ មិនបាន សំដៅដោយផ្ទាល់ចំពោះថិរវេលា នៃអាជ្ញាយុកាលទេ។ ដូច្នេះប្រភពទាំងឡាយពុំបានបកស្រាយច្បាស់លាស់អំពីដែនកំណត់នៃគោលការណ៍ជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ជាអន្តរជាតិ ដែលទាក់ទងនឹងការពិចារណាអំពីប្រតិសកម្មនៃច្បាប់ ឬលុបចោលអាជ្ញាយុកាលនោះទេ”[156]។ នេះគឺជាផ្នែកមួយដែលការបកស្រាយដ៏តឹងរ៉ឹងនៃមាត្រា១៥.១ មិនបានបញ្ជាក់អំពីបញ្ហាជាមូលដ្ឋាន នៅក្នុងការពន្យារអាជ្ញាយុកាលជាប្រតិសកម្ម។ ដូច្នេះ ការប្រព្រឹត្តចំពោះបញ្ហានេះ នៅក្នុងយុត្តាធិការដទៃទៀត អាចមានប្រយោជន៍។ បញ្ហាស្រដៀងគ្នាមួយត្រូវបានដោះស្រាយដោយតុលាការកំពូលសហរដ្ឋអាមេរិក។ តុលាការនេះបានពន្យល់ថា “បន្ទាប់ពី (ប៉ុន្តែ មិនមែនមុនពេលឡើយ) អាជ្ញាយុកាលដើមបានផុតរលត់ [ជនជាប់ចោទ] មិនត្រូវ “ទទួលទោសទណ្ឌអ្វីឡើយ”។ ដូច្នេះ លក្ខន្តិកៈថ្មីរបស់រដ្ឋ California ‘បានបន្ថែមទម្ងន់’ ទៅលើឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់របស់ [ជនជាប់ចោទ] ឬក៏បានធ្វើឱ្យឧក្រិដ្ឋកម្មនោះ ‘កាន់តែធ្ងន់ធ្ងរជាងកាលដែលឧក្រិដ្ឋកម្មនោះ ត្រូវបានប្រព្រឹត្តឡើង’ នៅក្នុងន័យ និងវិសាលភាពថា លក្ខន្តិកៈនេះ ‘បានដាក់ទោសទណ្ឌ’ ចំពោះអំពើកាលពីអតីតកាល ដែល [នៅពេលច្បាប់ពន្យារអាជ្ញាយុកាលត្រូវបានអនុម័ត] មិនបាននាំឱ្យមាននូវការទទួលខុសត្រូវណាមួយឡើយ”[157]។ ស្រដៀងគ្នានេះដែរ “ភាគច្រើននៃយុត្តិសាស្ត្រប្រទេសកូរ៉េបញ្ជាក់ថា ការអនុវត្តប្រតិសកម្ម នៃរយៈពេលកំណត់ដែលបានធ្វើវិសោធនកម្ម ចំពោះការចោទប្រកាន់ដែលថិរវេលានៃអាជ្ញាយុកាលបានផុតរលត់ទៅហើយនោះ រំលោភលើគោលការណ៍អង្គហេតុកើតមុនច្បាប់ (Ex Post Facto) ពីព្រោះវាអាចធ្វើឱ្យមានការអនុវត្តដែលមានលក្ខណៈគាបសង្កត់ និងតាមអំពើចិត្តរបស់អាជ្ញាធររដ្ឋក្នុងការដាក់ទណ្ឌកម្ម និងអាចរំលោភលើសេចក្តីសង្ឃឹមរបស់ប្រជាពលរដ្ឋក្នុងការរួចផុតពីការដាក់ទោសទណ្ឌ ដោយឡែក ការពន្យាររយៈពេលកំណត់នៅមុនពេល

---

[156] សេចក្តីសម្រេចទាក់ទងនឹងបទល្មើសថ្នាក់ជាតិ យោបល់របស់ចៅក្រម Silvia Cartwright និង Jean-Marc Lavergne កថាខណ្ឌ ៤២ (គូសបញ្ជាក់បន្ថែម)។

[157] *រឿងក្តី Stogner តទល់នឹង California*, 539 U.S. ទំព័រ 607, 613 (2003)។

ការចោទប្រកាន់ត្រូវបានហាមឃាត់ មិនរំលោភលើគោលការណ៍នេះទេ”[158]។

## ៦. អាជ្ញាយុកាលក្រោមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ មិនត្រូវបានពន្យារឡើយ មុនពេលអាជ្ញាយុកាលនេះផុតរលត់

៥៣. នៅក្នុងកថាខណ្ឌ ១០៧ ក.ស.ព អះអាងថា ការពន្យារអាជ្ញាយុកាលក្នុងក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៦ មិនរំលោភលើគោលការណ៍នីត្យានុកូលភាព ដូចមានចែងក្នុងមាត្រា១៥.១ នៃកតិកាសញ្ញាអន្តរជាតិ ICCPR នោះទេ ពីព្រោះធាតុផ្សំនៃបទល្មើសមិនត្រូវបានផ្លាស់ប្តូរ ឡើយ ហើយថា ដូច្នេះវាមិនមានការពាក់ព័ន្ធថាតើអាជ្ញាយុកាលបានផុតរលត់មុននឹងត្រូវបានពន្យារ ឬយ៉ាងណានោះទេ។ មេធាវីការពារក្តីមិនបានលើកទឡ្ហីករណ៍ថា ធាតុផ្សំនៃបទល្មើសដែលមាននៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ បានផ្លាស់ប្តូរនោះទេ។ វាមិនមែនមិនមានការពាក់ព័ន្ធថាតើ អាជ្ញាយុកាលបានផុតរលត់មុននឹងត្រូវបានពន្យារ ឬយ៉ាងណានោះឡើយ។ បញ្ហានេះគឺមានសារៈសំខាន់យ៉ាងខ្លាំងចំពោះសេចក្តីសម្រេចរបស់អង្គជំនុំ ជម្រះសាលាដំបូងលើរឿងក្តី ឌុច ចំពោះថាតើឧក្រិដ្ឋកម្មជាតិអាចត្រូវបានអនុវត្ត នៅក្នុងសំណុំរឿង ០០១ ឬយ៉ាងណា[159]។ នេះក៏ជាបញ្ហាដ៏សំខាន់ផងដែរ នៅចំពោះមុខតុលាការជាតិ ក្នុងការសម្រេចថាតើការពន្យារអាជ្ញាយុកាល នឹងរំលោភលើគោលការណ៍នៃអានុភាពអប្រតិសកម្ម ឬយ៉ាងណា[160]។

៥៤. នៅក្នុងកថាខណ្ឌ ១០៨ ក.ស.ព អះអាងថា អាជ្ញាយុកាលនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ មិនបានរលត់ឡើយ ពីព្រោះអាជ្ញាយុកាលនេះត្រូវបានពន្យារចាប់តាំងពីឆ្នាំ១៩៧៥-៧៩ រហូតដល់យ៉ាងហោចណាស់ឆ្នាំ១៩៩៣។ ក្នុងកថាខណ្ឌ ១០៩ ក.ស.ព ផ្តល់ឧទាហរណ៍នៅក្នុងបណ្តារដ្ឋដទៃទៀតដែលគាំទ្រដល់ការអះអាងនេះថា អាជ្ញាយុកាលអាចត្រូវបានពន្យារនៅក្នុងស្ថានភាពមួយចំនួន។ ក្នុងខណៈពេលដែលវាជាការពិតដែលរដ្ឋខ្លះ អនុញ្ញាតឲ្យពន្យារអាជ្ញាយុកាលនៅក្នុងស្ថានភាពមួយចំនួននោះ

---

[158] អត្ថបទរបស់ Kuk Cho មានចំណងជើងថា Nullum Crimen, Nulla Poena Sine Lege *នៅក្នុង* *Korean Criminal Law*, 6 J. KOREAN L. 147, 152 (2006)។

[159]សេចក្តីសម្រេចទាក់ទងនឹងបទល្មើសថ្នាក់ជាតិ កថាខណ្ឌ១៤។

[160]*សូមមើល* បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១៦១-៦២, ១៦៩។

ក៏មានរដ្ឋដទៃទៀតយល់ឃើញថា ការពន្យារនេះគឺផ្ទុយពីរដ្ឋធម្មនុញ្ញ[161]។ អង្គនីតិប្បញ្ញត្តិកម្ពុជា មិនបាន អនុម័តច្បាប់ណាមួយដែលប្រកាសថារយៈពេលកំណត់ត្រូវបានពន្យារនោះឡើយ[162]។ នៅក្នុងកថាខណ្ឌ ១១០ ក.ស.ព អះអាងថា អាជ្ញាយុកាលត្រូវបានពន្យារចាប់ពីឆ្នាំ១៩៧៥-៧៩។ នៅក្នុងកថាខណ្ឌ ១១១ ដល់ ១១៤ ក.ស.ព អះអាងថា ការកសាងប្រព័ន្ធតុលាការឡើងវិញដែលនឹងអាចធ្វើការចោទប្រកាន់ ចំពោះមេដឹកនាំខ្មែរក្រហម មិនបានកើតឡើងឡើយ រហូតដល់ឆ្នាំ១៩៩៣។ ក.ស.ព យល់ខុសអំពី ប្រព័ន្ធតុលាការដ៏ល្អបំផុត ជាមួយនឹងដំណើរការនៃប្រព័ន្ធតុលាការ។ ប្រព័ន្ធតុលាការកម្ពុជាចាប់ផ្តើម ដំណើរការតាំងពីឆ្នាំ១៩៧៩[163]។ ដូចដែលចៅក្រមអន្តរជាតិរបស់អង្គជំនុំជម្រះសាលាដំបូងលើរឿងក្តី *ឌុច* យល់ឃើញ ចាប់ពីឆ្នាំ១៩៧៩ មក ច្បាប់ និងក្រឹត្យ-ច្បាប់នានាត្រូវបានអនុម័តជាបន្តបន្ទាប់ ហើយ ការចោទប្រកាន់មិនត្រូវបានបង្អាក់គ្រប់កន្លែងនៅក្នុងប្រទេសនោះទេ ទោះបីជា សង្គ្រាមស៊ីវិល និង ការគ្រប់គ្រងរបស់ខ្មែរក្រហម ទៅលើតំបន់មួយចំនួនក្នុងប្រទេសក៏ដោយ[164]។

### ៧. ចៅក្រមអន្តរជាតិរបស់អង្គជំនុំជម្រះសាលាដំបូងលើរឿងក្តី ឌុច មិនបានផ្អែកសេចក្តីសម្រេច របស់ខ្លួនទៅលើតែអត្ថន័យនៃពាក្យប៉ុណ្ណោះទេ

៩៥. នៅក្នុងកថាខណ្ឌ ១១៥ និង ១១៦ ក.ស.ព អះអាងថា ចៅក្រមអន្តរជាតិពីររូបរបស់អង្គជំនុំជម្រះ សាលាដំបូងលើរឿងក្តី ឌុច បានសម្រេចថា អាជ្ញាយុកាលបានផុតរលត់ទៅ ហើយ "ហើយអង្គ នីតិប្បញ្ញត្តិកម្ពុជា ឬក្រុមប្រឹក្សាធម្មនុញ្ញមិនបានពន្យារចិរវេលានៃអាជ្ញាយុកាលដោយមានប្រតិសកម្ម ឬបន្តឡើងវិញនូវសិទ្ធិធ្វើការចោទប្រកាន់តាមរយៈអំពើ មួយដែលសម្តែងយ៉ាងច្បាស់លាស់នោះទេ" ដោយផ្អែកលើមូលដ្ឋានថា អង្គនីតិប្បញ្ញត្តិកម្ពុជាបានប្រើពាក្យ "បានពន្យារ" គឺមិនមែនប្រើពាក្យ "បាន បន្តឡើងវិញ" នោះទេ។ ក.ស.ព អះអាងថា ការញែកពីគ្នារវាងពាក្យថា "ការពន្យារ" និង "ការបន្ត

---

[161] ឧទាហរណ៍, Hungary។ *សូមមើល* KOK, ត្រង់ទំព័រ 202-03។

[162] សេចក្តីសម្រេចទាក់ទងនឹងបទល្មើសថ្នាក់ជាតិ យោបល់របស់ចៅក្រម Silvia Cartwright និង Jean-Marc Lavergne, កថាខណ្ឌ២៩។

[163] *សូមមើល* បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ១៧០-៧២។

[164] សេចក្តីសម្រេចទាក់ទងនឹងបទល្មើសថ្នាក់ជាតិ យោបល់របស់ចៅក្រម Silvia Cartwright និង Jean-Marc Lavergne, កថាខណ្ឌ៣២-៣៣។

ឡើងវិញ” គឺជា ពាក្យមួយដែលមានអត្ថន័យផ្នែកភាសា ហើយពាក្យពេចន៍ទាំងពីរនេះអាចត្រូវបានប្រើប្រាស់ដោយផ្លាស់ប្តូរគ្នាបាន។ ការអះអាងនេះមិនត្រឹមត្រូវឡើយ។ ចៅក្រមអន្តរជាតិ របស់អង្គជំនុំជម្រះសាលាដំបូងលើរឿងក្តី ឌុច បានបញ្ជាក់ថា ៖ ក. ចៅក្រមអន្តរជាតិមិនអាចសន្និដ្ឋានបានថាអាជ្ញាយុកាលត្រូវបានពន្យារនៅចន្លោះឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩៣ នោះឡើយ[165]។ និង ខ. ចៅក្រមអន្តរជាតិអាចយល់ឃើញថា មិនមានច្បាប់ដែលរៀបចំឡើងដើម្បីអាចធ្វើការចោទប្រកាន់ចំពោះបទល្មើសនានា ដែលថិរវេលានៃអាជ្ញាយុកាល ត្រូវបានផុតរលត់ឡើយ ឬក៏ពុំមានយុត្តិសាស្ត្រកម្ពុជាដែលបង្ហាញអំពីថិរវេលានៃអាជ្ញាយុកាល ដែលត្រូវបានព្យួរនោះឡើយ[166]។ បន្ទាប់ពីធ្វើសំអាងហេតុទាំងនេះរួចហើយ ចៅក្រមអន្តរជាតិបានបញ្ជាក់ថា “ចៅក្រមអន្តរជាតិនឹងពិចារណាបន្ថែមចំពោះសញ្ញាណនៃ “ការពន្យារ” ថិរវេលានៃអាជ្ញាយុកាល ដូចមានចែងនៅក្នុងមាត្រា៣ថ្មី” នៃច្បាប់ អ.វ.ត.ក[167]។ ក.ស.ព អះអាងថា ចៅក្រមអន្តរជាតិបានកំណត់លក្ខណៈខុសគ្នារវាង “ការពន្យារ” និង “ការបន្តឡើងវិញ”។ ទោះបីជាយ៉ាងណាក៏ដោយ ចៅក្រមអន្តរជាតិបាន បញ្ជាក់ថា ចៅក្រមអន្តរជាតិមិនអាចសន្និដ្ឋានបានថា អង្គនីតិប្បញ្ញត្តិកម្ពុជាធ្លាប់បានបង្ហាញច្បាស់លាស់ពីចេតនាដើម្បីព្យួរថិរវេលានៃអាជ្ញាយុកាល ឬប្រតិសកម្មសិទ្ធិដើម្បីចោទប្រកាន់បទល្មើសជាតិក្រោយពេលផុតរលត់អាជ្ញាយុកាលឡើយ”[168]។ ចៅក្រមអន្តរជាតិមិនបានផ្អែកសេចក្តីសម្រេចរបស់ខ្លួនលើតែអត្ថន័យនៃពាក្យប៉ុណ្ណោះនោះទេ។

៥៦. ក្នុងកថាខណ្ឌ ១១៧ ក.ស.ព អះអាងថា អង្គនីតិប្បញ្ញត្តិកម្ពុជាបានពន្យារអាជ្ញាយុកាល មុនពេលដែលសេចក្តីសម្រេចតាមផ្លូវតុលាការត្រូវបានធ្វើឡើង ទៅលើចំណោទបញ្ហាថាតើអាជ្ញាយុកាលត្រូវបានព្យួរឬយ៉ាងណានោះ។ ក.ស.ព អះអាងថា ដោយសារបញ្ហានេះ គឺជាការស្វែងយល់ដ៏ត្រឹមត្រូវតាមផ្លូវតុលាការ ពាក់ព័ន្ធទៅនឹងការស្វែងរកការពិត ហើយអង្គនីតិប្បញ្ញត្តិមិនបានឆ្លើយទៅនឹងបញ្ហានេះទើបអង្គជំនុំជម្រះសាលាដំបូងមិនអាចសម្រេចនៅដំណាក់កាលនេះបានថាតើ អាជ្ញាយុកាលគួរតែត្រូវ “បានពន្យារ” និង “បានបន្តឡើងវិញ” យ៉ាងណានោះទេ។ មិនមានអ្វីហាមឃាត់អង្គនីតិប្បញ្ញត្តិ

---

[165] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ២៧។

[166] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ២៩។

[167] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ៤៣ (គូសបញ្ជាក់បន្ថែម)។

[168] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ៤៥ (គូសបញ្ជាក់បន្ថែម)។

មិនឲ្យអនុម័តច្បាប់ ដែលប្រកាសថាចិរវេលានៃអាជ្ញាយុកាលបានពន្យារឡើយ។ មិនមានរបកគំហើញនៃអង្គហេតុ នឹងត្រូវបានតម្រូវឲ្យមានសម្រាប់អង្គនីតិប្បញ្ញត្តិ ដើម្បីអនុម័តច្បាប់បែបនេះឡើយ។

៥៧. នៅក្នុងកថាខណ្ឌ ១១៨ ក.ស.ព អះអាងថា អង្គនីតិប្បញ្ញត្តិបានបន្តពិភាក្សា "ដោយផ្អែកទៅលើមូលដ្ឋានដែលថា មាត្រា៣ មិនបានរំលោភគោលការណ៍អប្រតិសកម្មនោះទេ ដោយសារមាត្រា៣ គឺមានចរិតលក្ខណៈជានីតិវិធី ហើយមានតែការកែប្រែច្បាប់សារធាតុទេ ទើបពាក់ព័ន្ធនឹងគោលការណ៍អប្រតិសកម្ម។ ហេតុដូច្នេះ សំអាងហេតុនេះមិនត្រូវបានជំទាស់ដោយចៅក្រមដែលមានយោបល់ផ្ទុយ ដែលបានទទួលស្គាល់ថា សិទ្ធិទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ ដែលមានចែងនៅក្នុងកតិកាសញ្ញាអន្តរជាតិ ICCPR មិនត្រូវបានប៉ះពាល់ដោយការពន្យារអាជ្ញាយុកាលនេះទេ"។ ចៅក្រមដែលមានយោបល់ ផ្ទុយ មិនបាន "ទទួលស្គាល់" ថា សិទ្ធិទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ ដែលមានចែងនៅក្នុងកតិកាសញ្ញាអន្តរជាតិ ICCPR មិនត្រូវបានប៉ះពាល់ដោយការពន្យារនោះឡើយ ប៉ុន្តែគ្រាន់តែបានពន្យល់ថា កតិកាសញ្ញាអន្តរជាតិ ICCPR មិនបានសំដៅ ឲ្យបានច្បាស់លាស់ទៅលើបញ្ហានៃចិរវេលានៃអាជ្ញាយុកាល ហើយដូច្នេះ មិនមានភាព ផ្ទុយគ្នាច្បាស់លាស់ឡើយ[169]។

## ៨. ច្បាប់អន្តរជាតិមិនតម្រូវឲ្យមានការផ្តន្ទាទោសបទល្មើសជាតិដែលឈាន ដល់កម្រិតបទល្មើសអន្តរជាតិ សូម្បីតែអាជ្ញាយុកាលរារាំងដល់ការផ្តន្ទាទោស ទាំងនោះក៏ដោយ

៥៨. នៅក្នុងកថាខណ្ឌ ១១៩ ក.ស.ព អះអាងថា កាតព្វកិច្ចអន្តរជាតិរបស់កម្ពុជា ហាមឃាត់ ចំពោះការអនុវត្តអាជ្ញាយុកាលទៅលើបទល្មើសជាតិ ហើយថា តុលាការជាន់ខ្ពស់របស់ "ប្រទេសជាច្រើន" បានសម្រេចថា ក្នុងករណីដែលបទល្មើសជាតិមានធាតុបទល្មើស អន្តរជាតិដែរ ឧបសគ្គនៃច្បាប់ជាតិក្នុងការចោទប្រកាន់ ដូចជា អាជ្ញាយុកាល មិនត្រូវបាន យកចិត្តទុកដាក់ទេ។ ក.ស.ព ផ្តល់សំអាងផ្លូវច្បាប់មិនគ្រប់គ្រាន់ឡើយក្នុងការគាំទ្រដល់ការអះអាងនេះ។ ក.ស.ព ផ្តល់តែឧទាហរណ៍ដែលមាននៅក្នុងប្រទេសឈីលី និងអាហ្សង់ទីនប៉ុណ្ណោះ។ ក.ស.ព អះអាងថា ដោយការផ្តល់សច្ចាប័នទៅលើ

---

[169]សេចក្តីសម្រេចទាក់ទងនឹងបទល្មើសថ្នាក់ជាតិ យោបល់របស់ចៅក្រម Silvia Cartwright និង Jean-Marc Lavergne, កថាខណ្ឌ៤២-៤៣។

អនុសញ្ញា ប្រឆាំងនឹងការធ្វើទារុណកម្ម ប្រទេសកម្ពុជាមានកាតព្វកិច្ចដើម្បីផ្តន្ទាទោសចំពោះអំពើទារុណកម្ម។ ពុំមានកាតព្វកិច្ចទំនៀមទម្លាប់អន្តរជាតិ មិនទទួលស្គាល់អាជ្ញាយុកាលឡើយ[170]។ ករណីនេះអាចត្រូវបានមើលឃើញពីអង្គហេតុដែលថា អនុសញ្ញាឆ្នាំ១៩៦៨ ស្តីពីការមិនអនុវត្តអាជ្ញាយុកាលចំពោះឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មិនត្រូវបានផ្តល់សច្ចាប័នទូលំទូលាយឡើយ[171] ដោយសារការព្រួយបារម្ភថា អនុសញ្ញានេះនឹងរំលោភលើគោលការណ៍នៃអានុភាពអប្រតិសកម្ម ពីព្រោះអនុសញ្ញានេះ អនុវត្តចំពោះឧក្រិដ្ឋកម្មទាំងនេះ "ដោយមិនគិតពីកាលបរិច្ឆេទនៃការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ"[172]។ កាតព្វកិច្ចអន្តរជាតិរបស់កម្ពុជាគឺជាបញ្ហាសម្រាប់អង្គនីតិប្បញ្ញត្តិ មិនមែនតុលាការទេ[173]។ ដូចដែលចៅក្រមជាតិនៃអង្គជំនុំជម្រះសាលាដំបូងលើរឿងក្តី ឌុច បានពន្យល់

---

[170] *សូមមើល* NAQVI, ត្រង់ទំព័រ 192-93។ "ទទ្បីករណីដែលថា មានវិធានទំនៀមទម្លាប់ចែងថា អាជ្ញាយុកាលមិនអាចអនុវត្តចំពោះឧក្រិដ្ឋកម្មអន្តរជាតិ គឺភាគច្រើនជាលទ្ធផលនៃសកម្មភាពរបស់តុលាការ ជាជាងការអនុវត្តរបស់រដ្ឋដ៏ច្រើនលើសលប់ និង*ទស្សនច្បាប់* (*opinio juris*) ស្តីអំពីបញ្ហានេះ ទោះបីជាប៉ុន្មានឆ្នាំថ្មីៗនេះឃើញមានការកើនឡើងក្នុងផ្នែកទាំងពីរនេះក៏ដោយ។ ការអនុវត្តរបស់រដ្ឋទាក់ទិននឹងអាជ្ញាយុកាល ដែលពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មអន្តរជាតិ គឺពុំមានសង្គតិភាព ឬស៊ីសង្វាក់គ្នាទាល់តែ សោះ"។ *សូមមើលផងដែរ* ទំព័រ195-97។

[171] *សូមមើល* អត្ថបទរបស់ Christine Van den Wyngaert & John Dugard មានចំណងជើងថា *Non-Applicability of Statute of Limitations*, *នៅក្នុង* THE ROME STATUTE OF THE INTERNATIONAL CRIMINAL COURT: A COMMENTARY VOL. 1 ទំព័រ 874-75 (បោះពុម្ពដោយ Oxford University Press, ២០០២)។

[172] អនុសញ្ញាស្តីពីការមិនអនុវត្តអាជ្ញាយុកាលចំពោះឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ G.A. Res. 2391 (XXIII), Annex, 23 U.N. GAOR Supp. (No. 18) at 40, U.N. Doc. A/7218 (1968) មាត្រា១។

[173] *សូមមើល* បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ១២៦-២៩។ *សូមមើលផងដែរ* WARD N. FERDINANDUSSE, DIRECT APPLICATION OF INTERNATIONAL CRIMINAL LAW IN NATIONAL COURTS 142 (បោះពុម្ពដោយ T.M.C. Asser Press ឆ្នាំ២០០៦)។ "នៅពេលដែលអង្គនីតិបញ្ញត្តិ និងអង្គនីតិប្រតិបត្តិ ខកខានពុំបានចាត់វិធានការណ៍អនុវត្តឱ្យបានគ្រប់គ្រាន់ តុលាការជាតិតែងតែ ចៀសវាងមិនប្រតិបត្តិតាមច្បាប់អន្តរជាតិ តាមរយៈការអនុវត្តដោយផ្ទាល់ ដោយយល់ឃើញថា តុលាការជាតិមិនអាចជំនួសឱ្យស្ថាប័ននយោបាយក្នុងការជ្រើសរើសទម្រង់នៃការប្រតិបត្តិតាមកាតព្វកិច្ចអន្តរជាតិឡើយ"។ *សូមមើលផងដែរ* សៀវភៅនិពន្ធដោយ Rosemary Pattenden មានចំណងជើងថា *Admissibility in Criminal Proceedings of Third Party and Real Evidence Obtained by Methods Prohibited by UNCAT*, 10 INT'L J. EVIDENCE & PROOF 1, 29 (២០០៦) "កាតព្វកិច្ច... ដែលតម្រូវឱ្យមានដោយការផ្តល់សច្ចាប័នលើអនុសញ្ញា ប្រឆាំងនឹងការធ្វើទារុណកម្មរបស់អង្គការសហប្រជាជាតិ (UNCAT) គឺមិនអាចអនុវត្តបានដោយផ្ទាល់នៅក្នុងតុលាការអង់គ្លេសឡើយ ពីព្រោះ 'សន្ធិសញ្ញាអន្តរជាតិពុំបានបង្កើតជាផ្នែកនៃច្បាប់អង់គ្លេសឡើយ ហើយតុលាការអង់គ្លេសពុំមានយុត្តាធិការក្នុងការបកស្រាយ ឬអនុវត្តសន្ធិសញ្ញាអន្តរជាតិទាំងនោះឡើយ'"។ សូមមើល ផងដែរ

"ចៅក្រមមិនមែនជាអ្នកបង្កើតច្បាប់ទេ។ ចៅក្រមគ្រាន់តែជាអ្នកអាចវិនិច្ឆ័យ សេចក្តីទៅលើស្ថានភាពនៃបុគ្គលម្នាក់ៗ នៅក្នុងរឿងក្តីដែលមានចំពោះមុខខ្លួន តាមនីតិវិធី តែប៉ុណ្ណោះ"[174]។ ដោយសារតែលោក អៀង សារី ត្រូវបានចោទប្រកាន់រួចហើយអំពី ឧក្រិដ្ឋកម្មអន្តរជាតិ ដែលច្បាស់ណាស់ពុំមានអាជ្ញាយុកាល (ឧទាហរណ៍ អំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ) ក្នុងករណីនេះ ពុំមានហេតុផលក្នុងការ សន្និដ្ឋានថា អាជ្ញាយុកាលមិនអាចរារាំងការចោទប្រកាន់គាត់ចំពោះឧក្រិដ្ឋកម្មជាតិបាន ឡើយ។

៥៩. នៅក្នុងកថាខណ្ឌ ១២០ ក.ស.ព អះអាងថា អ.វ.ត.ក គួរតែបដិសេធចោលអាជ្ញាយុកាល ពីព្រោះឧក្រិដ្ឋកម្មដែលមានបញ្ជាក់នៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ក៏មានធាតុឧក្រិដ្ឋកម្ម អន្តរជាតិដែរ។ ក្នុងកថាខណ្ឌ ១២១ ក.ស.ព អះអាងថា អង្គជំនុំជម្រះសាលាដំបូងលើ រឿងក្តី ឌុច មិនបានពិចារណាលើបញ្ហានេះឡើយ ហើយបញ្ហានេះនៅតែមិនទាន់បានដោះស្រាយនៅឡើយ។ ការអះអាងនេះមិនត្រឹមត្រូវឡើយ។ ក.ស.ព បានលើកទឡ្ហីករណ៍ដូចគ្នានេះនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងលើរឿងក្តីឌុច[175]។ ការពិតដែលទឡ្ហីករណ៍ ទាំងនេះមិនត្រូវបានទទួលយកដោយអង្គជំនុំជម្រះសាលាដំបូង

---

SUPRANATIONAL CRIMINAL LAW: A SYSTEM *SUI GENERIS* 51-52 (Roelof Haveman et al. eds. Intersentia 2003) "តួនាទីការពារនៃគោលការណ៍នីត្យានុកូលភាព មានលក្ខណៈច្បាស់លាស់ ជាពិសេសនៅពេលដែលបញ្ចូលជាមួយទ្រឹស្តីរបស់ Montesquieu អំពីការបែងចែកអំណាច *Trias Politica* ដូចដែលពិពណ៌នានៅក្នុង សៀវភៅ *De l' esprit des lois* (1748) របស់គាត់ ៖ ទាំងនេះគឺជាអំណាចបីនៅក្នុងរដ្ឋ ដែលត្រូវបានកំណត់លក្ខណៈផ្សេងៗគ្នា។ ទីមួយ គឺអំណាចក្នុងការតាក់តែងច្បាប់ ដែលត្រូវប្រគល់ទៅឱ្យសភា ដែលជាតំណាងប្រជាជន៖ អង្គនីតិបញ្ញត្តិ។ បន្ទាប់មកគឺ អំណាចប្រតិបត្តិ ដែលទទួលបន្ទុកក្នុងការប្រតិបត្តិច្បាប់៖ អង្គនីតិប្រតិបត្តិ។ ទីបី ចុងក្រោយគឺ អំណាចក្នុងការកាត់សេចក្តី ដែលទទួលបន្ទុកក្នុងការដោះស្រាយជម្លោះ។ ទាក់ទិនទៅនឹងបញ្ហានេះ ចៅក្រមគឺជាពាក្យសុភាសិតដ៏ល្បីល្បាញមួយដែលថា គាត់ "គឺជាមាត់ដែលថាតាមច្បាប់"៖ "*La juge est la bouche qui pronounce les paroles de la loi*" ៖ តុលាការ....។ ក្នុងទំនៀមទម្លាប់ច្បាប់ស៊ីវិលឡូ អ្នកតាក់តែងច្បាប់ – រដ្ឋាភិបាល សភា – ដែលជាទូទៅជាអ្នកកំណត់និយមន័យបទឧក្រិដ្ឋ ដែលនៅក្នុងករណីជាក់ស្តែង ចៅក្រមអាចកំណត់លក្ខណៈគ្រប់គ្រាន់នៃអំពើជាក់លាក់របស់បុគ្គលជាក់លាក់ណាម្នាក់ថាជាអំពើឧក្រិដ្ឋ។ នៅក្នុងប្រទេសដែលអនុវត្តច្បាប់ស៊ីវិលឡូ ការបែងចែកអំណាចនេះត្រូវបានគេយល់ឃើញយ៉ាងច្បាស់ ដែលខុសពីប្រទេសអង់គ្លេសដែលអនុវត្តច្បាប់កំមិនឡូ ដែលតុលាការមានអំណាច "នីតិបញ្ញត្តិ" មួយចំនួន ទោះបីជាគេតែងតែនិយាយថាជា "ផ្នែកដែលនៅសេសសល់" ក៏ដោយ...."។

[174] សេចក្តីសម្រេចទាក់ទងនឹងបទល្មើសថ្នាក់ជាតិ យោបល់របស់ចៅក្រម និល ណុន, យ៉ា សុខន និង ធូ មណី កថាខណ្ឌ២៦។

[175] *សូមមើល រឿងក្តី កាំង ហ្កេកអ៊ាវ ហៅ "ឌុច"* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ, សេចក្តីសន្និដ្ឋានឆ្លើយតបជាលាយលក្ខណ៍អក្សររបស់សហព្រះរាជអាជ្ញា ទៅនឹងអញ្ញត្រកម្មជាបឋមរបស់សហមេធាវីការពារក្តីចំពោះ

លើរឿងក្តី ឌុច មិនមែន មានន័យថា ទឡ្ហីករណ៍ទាំងនេះមិនត្រូវបានគេពិចារណានោះឡើយ។ តាមពិត ទឡ្ហីករណ៍ ទាំងនេះ ត្រូវបានពិចារណា ប៉ុន្តែទំនងជាមិនត្រូវបានយល់ឃើញថាគួរឲ្យជឿជាក់បាន។ ចៅក្រមអន្តរជាតិនៃអង្គជំនុំជម្រះសាលាដំបូងលើរឿងក្តី ឌុច "ពិចារណាថា បញ្ហាដែល កើតឡើង នៅក្នុងបរិបទបច្ចុប្បន្ន គឺមិនត្រឹមត្រូវតាមច្បាប់ ក្នុងការចោទប្រកាន់អំពីបទ មនុស្សឃាត និង បទទារុណកម្មទេ (ដែលបទល្មើសទាំងពីរនេះត្រូវបានផ្តន្ទាទោសជាសកលនៅជាឧក្រិដ្ឋកម្មអន្តរជាតិ) ប៉ុន្តែបញ្ហាគឺថាតើ មានយុត្តាធិការដើម្បីជំនុំជម្រះបទ ល្មើសប្រហាក់ប្រហែលទៅនឹងឧក្រិដ្ឋកម្មជាតិ ដោយផ្អែកលើមូលដ្ឋាននៃក្របខ័ណ្ឌច្បាប់ ជាតិ ដែរឬទេ។ ដំបូងបង្អស់ គឺជាបញ្ហានៃការបង្កើតច្បាប់ ជាតិដែលពាក់ព័ន្ធ"[176]។

### ៩. ការកាត់សេចក្តីលោក អៀង សារី ពីការរំលោភលើក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ជាការកាត់សេចក្តីមួយមិនត្រឹមត្រូវ មិនថាគាត់បានធ្វើសកម្មភាព ឬមិនបានធ្វើសកម្មភាព នៅពេលផុតរលត់អាជ្ញាយុកាលនោះ

៦០. នៅក្នុងកថាខណ្ឌ ១២២ ក.ស.ព អះអាងថា ទោះបីជាមាត្រា៣ថ្មី រំលោភលើគោលការណ៍នីត្យានុកូលភាពក៏ដោយ ក៏ការរំលោភបែបនេះមិនបានប៉ះពាល់ដល់លោក អៀង សារី នោះទេ ពីព្រោះគាត់មិនបានធ្វើសកម្មភាព ដោយអនុលោមតាមការរលត់ អាជ្ញាយុកាល។ ក្នុងកថាខណ្ឌ ១២៣ និង ១២៤ ក.ស.ព ព្យាយាមលើកបង្ហាញអំពីចំណុចនេះ។ ចំណុចនេះគឺមិនពាក់ព័ន្ធឡើយ។ មិនមានលក្ខខណ្ឌតម្រូវថា ជនជាប់ចោទត្រូវតែធ្វើសកម្មភាពដោយអនុលោមតាមការរលត់អាជ្ញាយុកាល នៅមុនពេលការពន្យារដោយប្រតិសកម្មអាចត្រូវបានហាមឃាត់នោះឡើយ។ ក.ស.ព មានលើកទឡ្ហីករណ៍ដូចគ្នា នៅក្នុងសំណុំរឿង ០០១[177]។ អង្គជំនុំជម្រះសាលាដំបូងលើរឿងក្តី ឌុច យល់ឃើញថា ទឡ្ហីករណ៍នេះមិនគួរឲ្យជឿជាក់បាន។

---

ការអនុវត្តក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៩ ឯកសារ D288/6.9/7, ERN: 00332733-00332751, កថាខណ្ឌ២០-២៣។

[176]ចក្តីសម្រេចទាក់ទងនឹងបទល្មើសថ្នាក់ជាតិ យោបល់របស់ចៅក្រម Silvia Cartwright និង Jean-Marc Lavergne, កថាខណ្ឌ៥៤។

[177] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ៣៧។

ខ. សិទ្ធិរបស់លោក អៀង សារី ស្តីពីសមភាពនៅចំពោះមុខច្បាប់នឹងត្រូវបានរំលោភ តាមរយៈការអនុវត្តមាត្រា៣ថ្មី

៦១. ក្នុងកថាខណ្ឌ ១២៥ និង ១២៦ ក.ស.ព បញ្ជាក់ថា សេចក្តីអះអាងរបស់មេធាវីការពារក្តី ថាមាត្រា៣ថ្មី រំលោភសិទ្ធិមានសមភាពនៅចំពោះមុខច្បាប់ ត្រូវបានអះអាងដោយមិនត្រឹមត្រូវ និងគួរតែត្រូវបដិសេធចោល។ ក្នុងកថាខណ្ឌ ១២៦ ក.ស.ព អះអាងថា ៖

> ការកាត់សេចក្តីជនសង្ស័យនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ដែលអនុវត្តនីតិវិធី វិសាមញ្ញ គឺមិនត្រូវបានហាមឃាត់ដោយច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងមិនរំលោភមាត្រា១៤.១ នៃកតិកាសញ្ញាអន្តរជាតិ ICCPR។ គណៈកម្មាធិការសិទ្ធិមនុស្សបាន អះអាងដដែលៗថា គោលការណ៍នៃការកាត់សេចក្តីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ដែលអនុវត្តនីតិវិធីផ្សេងៗគ្នាពីតុលាការសាមញ្ញ គឺមិនមែនជាការរំលោភទៅលើសិទ្ធិ ដែលមានចែងក្នុងកតិកាសញ្ញាអន្តរជាតិ ICCPR។ លើកលែងតែក្នុងករណី ដែលការជ្រើសរើសជនណាម្នាក់មកធ្វើការកាត់សេចក្តី នៅចំពោះមុខនីតិវិធីពិសេសមួយ មិនត្រូវបានសំអាងទៅលើលក្ខណៈវិនិច្ឆ័យប្រកបដោយហេតុផល និងជាសត្យានុម័តដែលថា ការជំទាស់ដែលយោងទៅលើការរំលោភមាត្រា១៤ ឬមាត្រា២៦ អាចធ្វើទៅបាន។ ដូច្នេះ វា គឺជាការជ្រើសរើសជនសង្ស័យមកកាត់សេចក្តីនៅចំពោះមុខ អ.វ.ត.ក គឺមិនមែនការ បង្កើត អ.វ.ត.ក ឬបទប្បញ្ញត្តិស្តីពីនីតិវិធី ឬខ្លឹមសារដែលអនុវត្តនៅចំពោះមុខតុលាការនេះ ដែលថាជាការរំលោភទៅលើសិទ្ធិទទួលបានសមភាពនៅចំពោះមុខច្បាប់.....។

៦២. នៅក្នុងកថាខណ្ឌ ១២៧ ដល់ ១៣០ ក.ស.ព ផ្តល់នូវទឡ្ហីករណ៍បន្ថែមទៀត ដើម្បីគាំទ្រ ការអះអាងរបស់ខ្លួនថា ការកាត់សេចក្តីមេដឹកនាំជាន់ខ្ពស់នៅ អ.វ.ត.ក មិនរំលោភលើ លក្ខខណ្ឌនៃសមភាពនៅចំពោះមុខច្បាប់ឡើយ។ ក.ស.ព ព្យាយាមប្តូរការផ្តោតការចាប់ អារម្មណ៍ពីថាតើ សិទ្ធិទទួលបានសមភាពនៅចំពោះមុខច្បាប់ ត្រូវបានរំលោភដោយការ ពន្យារអាជ្ញាយុកាលនៅ អ.វ.ត.ក ឬយ៉ាងណាទៅជាថាតើ សិទ្ធិត្រូវបានរំលោភ ដែរឬទេ ដែលផ្អែកទៅលើ តើនរណាអាចត្រូវបានយកមកជំនុំជម្រះទោសនៅ អ.វ.ត.ក។ ការរំលោភសិទ្ធិជាមូលដ្ឋានក្នុងការទទួលបានសមភាពនៅចំពោះមុខច្បាប់របស់ លោក អៀង សារី កើតមានឡើង ពីព្រោះប្រសិនបើមាត្រា៣ថ្មី ត្រូវបានអនុវត្ត លោក អៀង សារី នឹងត្រូវបានជំនុំជម្រះទោសចំពោះឧក្រិដ្ឋកម្មជាតិ ដែលមាននៅក្នុងក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៦ នៅពេលដែលមិនមានជនណាផ្សេងទៀតត្រូវបានចោទប្រកាន់អំពីឧក្រិដ្ឋកម្ម បែបនេះនៅចំពោះមុខ

តុលាការកម្ពុជាណាផ្សេងទៀតនោះ។ អ.វ.ត.ក មិនត្រឹមតែអនុវត្ត នីតិវិធីផ្សេងគ្នាពីតុលាការកម្ពុជាផ្សេងទៀតឡើយ។ អ.វ.ត.ក កំពុងតែអនុវត្តច្បាប់ ដែលមិនស្ថិតនៅជាធរមានតទៅទៀតឡើយនៅតុលាការកម្ពុជាផ្សេងទៀត។

៦៣. នៅក្នុងកថាខណ្ឌ ១២៩ ក.ស.ព អះអាងថា គោលការណ៍ជាមូលដ្ឋាន ដែលកំណត់ដោយច្បាប់ព្រហ្មទណ្ឌអន្តរជាតិគឺថា អ្នកដែលទទួលខុសត្រូវចំពោះការរំលោភធ្ងន់ធ្ងរទៅលើសិទ្ធិរបស់បុគ្គលទាំងឡាយ និងច្បាប់សង្គ្រាម គួរតែត្រូវបាននាំខ្លួនមកផ្ដន្ទាទោស ហើយថា ការកម្រិតយុត្តាធិការរបស់ "តុលាការពិសេសដែលមានចរិតអន្តរជាតិ" ចំពោះមេដឹកនាំ ជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតគឺផ្ទុះបញ្ច្រាំងពីគោលការណ៍ជាមូលដ្ឋាននៃយុត្តិធម៌ និងមិនផ្ទុយនឹងច្បាប់នោះឡើយ។ បញ្ហាគឺមិនមែនស្ថិតលើ <u>តើនរណា</u>អាចត្រូវ បាននាំយកមកជំនុំជម្រះទោសឡើយ ប៉ុន្តែបញ្ហាគឺស្ថិតលើ <u>តើច្បាប់អ្វី</u>អាចត្រូវបានយកមកអនុវត្ត។ វាគឺជាគោលការណ៍យុត្តិធម៌អន្តរជាតិ និងស្របតាមរដ្ឋធម្មនុញ្ញ ក្នុងការប្រព្រឹត្ត ស្មើភាពគ្នាចំពោះជនជាប់ចោទទាំងអស់។ គោលការណ៍នេះ មិនអាចត្រូវបានបោះបង់ចោលបានឡើយ។

## VI. អ.វ.ត.ក ពុំមានយុត្តាធិការលើបទឧក្រិដ្ឋអន្តរជាតិ និងទម្រង់នៃការទទួលខុសត្រូវឡើយ

### ក. ច្បាប់ស្ដីពីការបង្កើតអ.វ.ត.ក មិនអាចផ្ដល់ឲ្យតុលាការនេះនូវយុត្តាធិការ លើបទឧក្រិដ្ឋអន្តរជាតិបានឡើយ

៦៤. នៅក្នុងកថាខណ្ឌ ១៣៤ ក.ស.ព អះអាងថា ច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក គឺជាលក្ខន្តិកៈមួយ ដែលផ្ដល់អំណាចទៅឲ្យ អ.វ.ត.ក ដើម្បីអនុវត្តបទល្មើសព្រហ្មទណ្ឌ ដែលអាចអនុវត្តបាននៅក្នុងច្បាប់ជាតិ ឬច្បាប់អន្តរជាតិក្នុងអំឡុងពេលពាក់ព័ន្ធនោះ។ ទោះបីជាច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក អាចត្រូវបានចាត់ទុកថាជាលក្ខន្តិកៈផ្ដល់អំណាចក៏ដោយ ក៏វាមិនផ្លាស់ប្ដូរការពិតដែលថា អ.វ.ត.ក មិនអាចអនុវត្តច្បាប់ដែលមិនមានជាធរមាន ក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ១៩៧៥-៧៩ ឡើយ ដូចជា អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្ម ប្រឆាំងមនុស្សជាតិ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរ និងទម្រង់នៃការទទួលខុសត្រូវជាអន្តរជាតិ ដែលមិនមានអត្ថិភាពក្នុងច្បាប់ជាតិ។ ដូចដែល ក.ស.ព បានទទួលស្គាល់លក្ខន្តិកៈផ្ដល់អំណាចឲ្យតុលាការនូវយុត្តាធិការលើឧក្រិដ្ឋកម្ម "ដែលអាចអនុវត្តបាន ក្នុងអំឡុងរយៈពេលនៃ

យុត្តាធិការលើអាជ្ញាយុកាលរបស់តុលាការ”។ ឧក្រិដ្ឋកម្ម និងការ ទទួលខុសត្រូវទាំងនេះ មិនផ្តល់ទេ។

៦៥. នៅក្នុងកថាខណ្ឌ ១៣៥ ក.ស.ព អះអាងថា ពាក្យពេចន៍នៅក្នុងមាត្រា៤ មាត្រា៥ និង មាត្រា៦ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក នៅពេលដែលគេអានជាមួយមាត្រា១ និង មាត្រា២ “មិនបន្សល់ឲ្យមានចម្ងល់អ្វីពីគោលបំណងរបស់ស្ថាប័នបញ្ញត្តិ ដែលផ្តល់អំណាចឲ្យ អ.វ.ត.ក ក្នុងការអនុវត្តយុត្តាធិការរបស់ខ្លួនទៅលើបទល្មើសអន្តរជាតិជាក់ លាក់ទាំងនោះទេ ហើយថា មិនមានបុរេលក្ខខណ្ឌអ្វីបន្ថែមដែលត្រូវទាមទារឲ្យមានក្នុង ការអនុវត្តច្បាប់ទាំងនោះដែរ ក្រៅពីការធានាយ៉ាងណាឲ្យមានការជំនុំជម្រះក្តីដោយយុត្តិធម៌”។ ពាក្យពេចន៍របស់ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មិនអាចផ្លាស់ប្តូរការពិតដែលថា អ.វ.ត.ក មិនអាចអនុវត្តច្បាប់ដែលមិនមានអត្ថិភាពនៅក្នុងប្រទេសកម្ពុជានៅពេលវេលាដែលពាក់ព័ន្ធ ដោយមិនរំលោភលើគោលការណ៍នីត្យានុកូលភាពបានឡើយ។ ការធានាយ៉ាងណាឲ្យមានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ ដែល ក.ស.ព ទទួលស្គាល់ថាសំខាន់បំផុតនោះ ត្រូវតែត្រូវបានគោរព។ ការជំនុំជម្រះក្តីមិនអាចមានយុត្តិធម៌បានឡើយ ប្រសិនបើគោលការណ៍នីត្យានុកូលភាពត្រូវបានរំលោភ។

៦៦. នៅក្នុងកថាខណ្ឌ ១៣៦ ក.ស.ព អះអាងថា ការប្រើពាក្យពេចន៍នៅក្នុងមាត្រា២ នៃច្បាប់ អ.វ.ត.ក នាំឲ្យអង្គបុរេជំនុំជម្រះសន្និដ្ឋានថា អ.វ.ត.ក មានយុត្តាធិការលើការ អនុវត្តទម្រង់នៃការទទួលខុសត្រូវដែលមានអត្ថិភាពនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនាអំឡុងពេលនោះ។ ក.ស.ព ក៏បានអះអាងដែរថា អង្គជំនុំជម្រះសាលាដំបូង លើរឿងក្តី ឌុច សម្រេចថា អង្គជំនុំជម្រះអាចអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងអនុសញ្ញាអន្តរជាតិ រួមទាំងគោលការណ៍ទូទៅនៃច្បាប់។ អង្គបុរេជំនុំជម្រះភ័ន្តច្រឡំ ក្នុងការសម្រេចថា អ.វ.ត.ក មានយុត្តាធិការលើសហឧក្រិដ្ឋកម្មរួមជាទម្រង់ទំនៀមទម្លាប់អន្តរជាតិនៃការទទួលខុសត្រូវ[178]។ អង្គជំនុំជម្រះសាលាដំបូងលើរឿងក្តី ឌុច មិន ដែលត្រូវបានស្នើឲ្យពិចារណាថាតើ អង្គជំនុំជម្រះមាន ឬពុំមានយុត្តាធិការដើម្បីអនុវត្តឧក្រិដ្ឋកម្មអន្តរជាតិ ឬទម្រង់អន្តរជាតិនៃការទទួលខុសត្រូវ (ក្រៅពី JCE) ឡើយ។ ដូច្នេះ សេចក្តីសម្រេចរបស់ខ្លួនក្នុងការអនុវត្តច្បាប់អន្តរជាតិ និងទម្រង់នៃការទទួលខុសត្រូវ មិនអាចត្រូវបានពិចារណាថាផ្តល់នូវការគាំទ្រច្រើនដល់គោលជំហររបស់ ក.ស.ព ឡើយ ប្រសិនបើមាន។ ដូចដែលអង្គបុរេជំនុំជម្រះបានបញ្ជាក់នៅក្នុង

---

[178] *សូមមើល* បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ១០៣-១៤, ១២១-២៥។

សាលដីកាស្តីពី JCE "សំអាងហេតុរបស់អង្គបុរេជំនុំជម្រះស្តីពីការអនុវត្តទម្រង់ JCE នៅក្នុងសំណុំរឿង លេខ ០០១ មិនមានការជាប់ទាក់ទងនឹងការអនុវត្តទម្រង់ JCE នៅក្នុងសំណុំរឿងលេខ ០០២ ឡើយ"[179]។ វាគួរតែមានសុពលភាពដូចគ្នាដែរចំពោះទម្រង់អន្តរជាតិនៃការទទួល ខុសត្រូវដទៃទៀត ព្រមទាំងឧក្រិដ្ឋកម្មអន្តរជាតិ។ ការដែលគ្រាន់តែលើកឡើងថា ច្បាប់ អ.វ.ត.ក ចែងថា អ.វ.ត.ក មានយុត្តាធិការក្នុងការអនុវត្តច្បាប់មួយចំនួន ឬទម្រង់នៃការទទួលខុសត្រូវ តែប៉ុណ្ណោះ មិនអាចធ្វើឱ្យការអនុវត្តនោះត្រូវតែទទួលយកបាននោះឡើយ។ សូមពិចារណា ថាតើ ច្បាប់ អ.វ.ត.ក បានចែងថា អ.វ.ត.ក មានយុត្តាធិការក្នុងការអនុវត្តច្បាប់មួយចំនួនរបស់ប្រទេសថៃ ប្រទេសវៀតណាម ឬប្រទេសចិន ដែលមានអត្ថិភាពក្នុងឆ្នាំ១៩៧៥-៧៩។ សេចក្តីសន្និដ្ឋានភ្លាមៗ គឺថា អ.វ.ត.ក មិនអាចអនុវត្តបែបនេះបានឡើយ ទោះបីជាអ្វីត្រូវបាន ចែងនៅក្នុងច្បាប់ អ.វ.ត.ក ក៏ដោយ ពីព្រោះច្បាប់ទាំងនេះមិនមានអត្ថិភាពនៅក្នុងប្រទេសកម្ពុជាក្នុងអំឡុងពេលពាក់ព័ន្ធ និងមិនអាចត្រូវបានអនុវត្តដោយតុលាការកម្ពុជាបានឡើយ។ ការវិភាគមិនផ្លាស់ប្តូរឡើយ នៅពេលដែលច្បាប់ដែលត្រូវបានយោង ត្រូវបានអះអាងថាជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ ពុំមែនច្បាប់របស់ប្រទេសថៃ ប្រទេសវៀតណាម ឬប្រទេសចិនឡើយ ពីព្រោះច្បាប់ទាំងនេះមិនអាចអនុវត្តបានឡើយ នៅក្នុងប្រទេសកម្ពុជានៅពេលនោះ។ វាមិនមានបញ្ហាឡើយដែលថាច្បាប់ អ.វ.ត.ក អាចបញ្ជាក់អំពីច្បាប់ទាំងនេះ។ មានតែច្បាប់ ដែលមានអត្ថិភាព និងអាចអនុវត្តបានក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ១៩៧៥-៧៩ ប៉ុណ្ណោះ អាចត្រូវបានអនុវត្តដោយមិនរំលោភលើគោលការណ៍ជាមូលដ្ឋាននៃនីត្យានុកូលភាព។ ក្នុងកថាខណ្ឌ ១៤៣ ក.ស.ព អះអាងថា ពាក្យពេចន៍នៃមាត្រា២ នៃច្បាប់ អ.វ.ត.ក ផ្តល់ឱ្យ អ.វ.ត.ក នូវយុត្តាធិការលើបទល្មើសក្រោមច្បាប់អន្តរជាតិ ហើយថា ដូច្នេះ វាមិនមានបញ្ហាឡើយចំពោះថាតើប្រព័ន្ធគតិយុត្តិកម្ពុជា គឺជាប្រព័ន្ធទ្វិកនិយម ឬឯកទ្វិកនិយម និងថាតើ ច្បាប់អន្តរជាតិអាចត្រូវបានអនុវត្តដោយផ្ទាល់នៅក្នុងប្រព័ន្ធគតិយុត្តិកម្ពុជា ឬយ៉ាងណានោះ។ ការអះអាងនេះ មិនត្រឹមត្រូវឡើយ ចំពោះហេតុផលដែលទើបត្រូវបានពន្យល់។

---

[179] សេចក្តីសម្រេចរបស់ អ.ប.ជ ស្តីពី JCE កថាខណ្ឌ៨៦។

ខ. អ.វ.ត.ក គឺជាតុលាការកម្ពុជាក្នុងស្រុក ហើយចរិតលក្ខណៈណាដែលកំណត់តុលាការនេះខុសពីតុលាការកម្ពុជាដទៃទៀត ដោយសារតែ អ.វ.ត.ក ទទួលជំនួយអន្តរជាតិ មិនអាចផ្លាស់ប្តូរការពិតបានឡើយ

៦៧. នៅក្នុងកថាខណ្ឌ ១៣៧ ក.ស.ព អះអាងថា ឋានៈជាតិរបស់ អ.វ.ត.ក និងការពិត ដែលឋានៈនេះពុំអនុញ្ញាតឱ្យ អ.វ.ត.ក អនុវត្តឧក្រិដ្ឋកម្មអន្តរជាតិ និងទម្រង់នៃការទទួលខុសត្រូវ គឺផ្ទុយទៅនឹងមាត្រា១ និងមាត្រា២ នៃច្បាប់ អ.វ.ត.ក។ ក.ស.ព អះអាងថា អង្គបុរេជំនុំជម្រះបានទទួលស្គាល់ចំណុចនេះ នៅពេលដែលអង្គបុរេជំនុំជម្រះបានសម្រេចថា ឋានៈរបស់ អ.វ.ត.ក ជាតុលាការជាតិ ឬតុលាការអន្តរជាតិ ពុំមានការជាប់ទាក់ទងឡើយទៅនឹងថាតើ អ.វ.ត.ក មានយុត្តាធិការអនុវត្ត JCE ឬយ៉ាងណានោះ។ ផ្នែកនៃច្បាប់ជាតិ ដូចជាច្បាប់ អ.វ.ត.ក មិនអាចបង្កើតតុលាការអន្តរជាតិ ដែលអាចអនុវត្តច្បាប់អន្តរជាតិបានទេ។ ការយោងរបស់ច្បាប់ អ.វ.ត.ក ទៅលើ "ទំនៀមទម្លាប់អន្តរជាតិ" មិនអាចអនុញ្ញាតឱ្យមានការអនុវត្តច្បាប់អន្តរជាតិ ដែលមិនត្រូវបានទទួលស្គាល់ក្នុងប្រទេសកម្ពុជាបានឡើយ ដូចដែលបានពន្យល់ខាងលើ។

៦៨. ក្នុងកថាខណ្ឌ ១៣៨ ដល់ ១៤០ ក.ស.ព ផ្តល់ឧទាហរណ៍មួយចំនួន ដែលអះអាងថា អ.វ.ត.ក គឺជាតុលាការកូនកាត់ដែលមានលក្ខណៈអន្តរជាតិ។ ពុំមានឧទាហរណ៍ណា មួយបង្ហាញថា អ.វ.ត.ក គឺជាតុលាការអន្តរជាតិឡើយ[180]។ អ.វ.ត.ក ត្រូវបានបង្កើត ឡើងជាតុលាការកម្ពុជាក្នុងស្រុក ហើយ

180 ក្នុងកថាខណ្ឌ ១៣៨ ក.ស.ព អះអាងថា អ.វ.ត.ក "ត្រូវបានពិពណ៌នាដោយអង្គជំនុំជម្រះសាលាដំបូងថាជា 'តុលាការឯករាជ្យដែលមានលក្ខណៈអន្តរជាតិ និងមានធម្មនុញ្ញភាពដាច់ដោយឡែកមួយ'"។ នេះមិនមែនមានន័យថា អ.វ.ត.ក គឺជាតុលាការអន្តរជាតិដែលអនុវត្តច្បាប់អន្តរជាតិឡើយ ប៉ុន្តែគ្រាន់តែឆ្លុះបញ្ចាំងថា តុលាការនេះគឺជាតុលាការវិសាមញ្ញ *ស្ថិតក្នុង*ប្រព័ន្ធច្បាប់កម្ពុជា។ ក្នុងកថាខណ្ឌ ១៣៩(២) ក.ស.ព អះអាងថា អ.វ.ត.ក អាចដោះស្រាយតែចំពោះបទល្មើសជាក់លាក់ទាំងឡាយណា ដែលត្រូវបានប្រព្រឹត្តក្នុងអំឡុងពេលកំណត់មួយដោយ 'ជនជាប់ចោទមួយក្រុមដែលត្រូវបានកំណត់និយមន័យយ៉ាងចង្អៀត'"។ ចំណុចនេះមិនពាក់ព័ន្ធឡើយ។ តុលាការជាតិជាច្រើន ដោះស្រាយចំពោះបញ្ហាផ្នែកច្បាប់ជាក់លាក់។ ឧទាហរណ៍ ក្នុងប្រទេសអង់គ្លេស តុលាការព្រហ្មទណ្ឌ (Crown Court) ដោះស្រាយតែចំពោះបទឧក្រិដ្ឋប៉ុណ្ណោះ ដោយឡែកតុលាការរដ្ឋប្បវេណី (County Court) ដោះស្រាយតែចំពោះបញ្ហារដ្ឋប្បវេណីប៉ុណ្ណោះ។ ការពិពណ៌នាអំពីយុត្តាធិការនៃតុលាការព្រហ្មទណ្ឌ គឺអាចរកមើលបាននៅគេហទំព័រHer Majesty's Court Services : http://www.hmcourts-service.gov.uk/infoabout/crown/index.htm ហើយការ

---

ពិពណ៌នាអំពីយុត្តាធិការនៃតុលាការរដ្ឋប្បវេណី គឺអាចរកមើលបាននៅគេហទំព័រ Her Majesty's Court Services : http://www.hmcourts-service.gov.uk/infoabout/county/index.htm។

ក្នុងកថាខណ្ឌ ១៣៩(៣) ក.ស.ព អះអាងថា ច្បាប់ អ.វ.ត.ក រួមបញ្ចូលនូវបទល្មើសអន្តរជាតិ និងគោលការណ៍អន្តរជាតិផ្សេងៗ។ ច្បាប់ អ.វ.ត.ក គឺជាច្បាប់កម្ពុជា និងមិនអាចផ្តល់ឲ្យតុលាការនូវឋានៈអន្តរជាតិឡើយ និងមិនអាចអនុញ្ញាតឲ្យមានការអនុវត្តប្រតិសកម្មនៃច្បាប់ ដែលមិនអាចអនុវត្តបានក្នុងប្រទេសកម្ពុជានៅអំឡុងពេលដែលពាក់ព័ន្ធឡើយ។

ក្នុងកថាខណ្ឌ ១៣៩(៤) ក.ស.ព អះអាងថា អ.វ.ត.ក ត្រូវកែសម្រួលនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដើម្បីធានាឲ្យមានភាពស្របគ្នាទៅនឹងបទដ្ឋានអន្តរជាតិនានា។ រដ្ឋធម្មនុញ្ញកម្ពុជា អនុញ្ញាតឲ្យតុលាការកម្ពុជាប្រតិបត្តិតាមបទដ្ឋានអន្តរជាតិ។ សូមមើលរដ្ឋធម្មនុញ្ញកម្ពុជា មាត្រា៣១។ ការងាកចេញពីនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដើម្បីឲ្យសមស្របចំពោះភាពស្មុគស្មាញ វិសាលភាព និងបទល្មើសនៅក្នុងកិច្ចដំណើរការនីតិវិធី គឺមិនមែនជាហេតុផលក្នុងការពិចារណាថា អ.វ.ត.ក ជាតុលាការអន្តរជាតិនោះឡើយ។ ឧទាហរណ៍នៃការចូលរួមរបស់ជនរងគ្រោះគឺមាននៅក្នុងតុលាការព្រហ្មទណ្ឌកម្ពុជាដទៃទៀត ហើយត្រូវបានចែងយ៉ាងច្បាស់នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា (CPC)។ សូមមើល (CPC) មាត្រា ៣១៣។

ក្នុងកថាខណ្ឌ ១៣៩(៥) ក.ស.ព អះអាងថា "សមាសភាពរបស់ អ.វ.ត.ក និងសមាសភាពចៅក្រមជាតិ និងចៅក្រមអន្តរជាតិចម្រុះដែលជាអ្នកសម្រេចសេចក្តីដោយផ្អែកលើប្រព័ន្ធបោះឆ្នោតពិសេសមួយ" ធ្វើឲ្យ អ.វ.ត.ក ជាតុលាការមួយដែលមានលក្ខណៈអន្តរជាតិ។ ស្រដៀងគ្នានេះដែរ ក្នុងកថាខណ្ឌ ១៣៩(៨) ក.ស.ព អះអាងថា រចនាសម្ព័ន្ធ និងដំណើរការរបស់ការិយាល័យសហព្រះរាជអាជ្ញា មិនប្រព្រឹត្តទៅតាមរចនាសម្ព័ន្ធនៅក្នុងតុលាការជាតិកម្ពុជាដទៃទៀតឡើយ ហើយនៅក្នុងកថាខណ្ឌ ១៣៩(១១) បញ្ជាក់ថា មានការចូលរួមពីបុគ្គលិកអន្តរជាតិនៅក្នុងរាល់កិច្ចដំណើរការនីតិវិធី និងរាល់ការិយាល័យរដ្ឋបាលរបស់ អ.វ.ត.ក។ ភាពខុសគ្នានីមួយៗក្នុងចំណោមភាពខុសគ្នាទាំងនេះ គឺដោយសារតែជំនួយផ្នែកបច្ចេកទេស ដែលផ្តល់ឲ្យតាមរយៈកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ។ ពុំមានការបង្ហាញថា អ.វ.ត.ក ជាតុលាការអន្តរជាតិឡើយ។

ក្នុងកថាខណ្ឌ ១៣៩(៦) ក.ស.ព អះអាងថា ចៅក្រមអន្តរជាតិមិនបានទទួលការហ្វឹកហ្វឺនស្តីពីច្បាប់កម្ពុជាទេ។ ចំណុចនេះមិនមានការពាក់ព័ន្ធឡើយ ដោយសារចៅក្រមអន្តរជាតិទាំងនោះបំពេញការងារជាមួយចៅក្រមកម្ពុជា ដែលបានទទួលការហ្វឹកហ្វឺនស្តីពីច្បាប់កម្ពុជា។ លើសពីនេះទៀត ការផ្តល់នូវបុព្វសិទ្ធិដល់ចៅក្រមជាតិ ពុំបានធ្វើឲ្យ អ.វ.ត.ក ក្លាយជាតុលាការអន្តរជាតិឡើយ។

ក្នុងកថាខណ្ឌ ១៣៩(៩) នៅក្នុងការកាត់ទោសនៅ អ.វ.ត.ក អនុវត្ត "គោលការណ៍ និងកត្តាកំណត់ទោសជាតិផង និងអន្តរជាតិដែលពាក់ព័ន្ធផង"។ ដោយសារតែការកាត់ទោសចំពោះអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ បានកើតឡើងភាគច្រើននៅក្នុងតុលាការអន្តរជាតិ សេចក្តីណែនាំអាចត្រូវបានយកមកពីតុលាការអន្តរជាតិទាំងនេះសម្រាប់គោលបំណងក្នុងការកំណត់ទោស។ ប្រការនេះមិនផ្លាស់ប្តូរឋានៈរបស់ អ.វ.ត.ក ជាតុលាការកម្ពុជាឡើយ។

ក្នុងកថាខណ្ឌ ១៣៩(១០) ក.ស.ព អះអាងថា អ.វ.ត.ក ត្រូវបានផ្គត់ផ្គង់ផ្នែកហិរញ្ញវត្ថុពីខាងជាតិ និងខាងអន្តរជាតិ។ គេសង្ឃឹមថា ជំនួយផ្នែកបច្ចេកទេស ដែលត្រូវបានផ្តល់ដោយអង្គការសហប្រជាជាតិ តម្រូវឲ្យមានការផ្តល់ថវិកា។ ការផ្តល់ថវិកាបែបនេះពុំបានផ្លាស់ប្តូរឋានៈរបស់អ.វ.ត.ក ដែលជាតុលាការកម្ពុជាឡើយ។

ភាពខុសគ្នាណាមួយដែលអាចមានរវាង តុលាការនេះ និងតុលាការកម្ពុជាដទៃទៀត កើតចេញមកពីកិច្ចព្រមព្រៀងរវាងកម្ពុជា និងអង្គការសហប្រជាជាតិដើម្បីទទួលបាននូវជំនួយផ្នែកបច្ចេកទេស។ ជំនួយផ្នែកបច្ចេកទេសនេះ មិនបាន និងមិនអាចប្រែក្លាយតុលាការកម្ពុជាមួយឱ្យទៅជាតុលាការអន្តរជាតិមួយបានឡើយ។

៦៩. ក្នុងកថាខណ្ឌ ១៤១ ក.ស.ព អះអាងថា លក្ខណៈខុសប្លែកពីគេ *(sui generic)* របស់ អ.វ.ត.ក បដិសេធចំពោះការប្រៀបធៀបគ្នាដោយផ្ទាល់ជាមួយតុលាការជាតិ ហើយនៅក្នុងកថាខណ្ឌ ១៤២ ក.ស.ព ប្រៀបធៀប អ.វ.ត.ក ទៅនឹង "តុលាការកូនកាត់ដទៃ ទៀត"។ ការអះអាង និងការប្រៀបធៀប គឺមិនត្រឹមត្រូវឡើយ។ ភាពខុសគ្នារវាង អ.វ.ត.ក និងតុលាការកម្ពុជាដទៃទៀត ដូចដែលទើបបានពន្យល់រួចហើយ គឺគ្រាន់តែកើតចេញមកពីកិច្ចព្រមព្រមព្រៀងជាមួយអង្គការសហប្រជាជាតិ ដើម្បីផ្តល់នូវជំនួយផ្នែកបច្ចេកទេសប៉ុណ្ណោះ។ ប្រវត្តិនៃការចរចាដើម្បីបង្កើត អ.វ.ត.ក បង្ហាញថា គោលបំណងរបស់ប្រទេសកម្ពុជាគឺដើម្បីបង្កើតតុលាការ<u>ជាតិ</u>មួយ មិនមែនតុលាការ "កូនកាត់ដែលមានលក្ខណៈអន្តរជាតិ" ឬតុលាការអន្តរជាតិមួយឡើយ ដែលមិនមែនជាផ្នែកមួយដ៏រឹងមាំនៃរចនាសម្ព័ន្ធតុលាការកម្ពុជា[181]។ អាណត្តិរបស់ អ.វ.ត.ក គឺដើម្បី វិនិច្ឆ័យទោសមេដឹកនាំជាន់ខ្ពស់ និងអ្នកទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តក្នុងអំឡុងឆ្នាំ១៩៧៥-៧៩។ អ.វ.ត.ក ត្រូវតែបំពេញនូវអាណត្តិនេះជាតុលាការកម្ពុជាមួយ ដែលអនុវត្តច្បាប់កម្ពុជា[182]។

---

ក្នុងកថាខណ្ឌ ១៣៩(១២) ក.ស.ព អះអាងថា អ.វ.ត.ក នឹងត្រូវរលាយបន្ទាប់ពីបញ្ចប់អាណត្តិរបស់ខ្លួនសព្វគ្រប់ហើយ។ ប្រការនេះពុំបានប៉ះពាល់ដល់ឋានៈរបស់ អ.វ.ត.ក ឡើយ។ មិនមានអ្វីរារាំងតុលាការជាតិមិនឱ្យរលាយនៅពេលបញ្ចប់អាណត្តិរបស់ខ្លួននោះឡើយ។

ក្នុងកថាខណ្ឌ ១៣៩(១៣) ក.ស.ព អះអាងថា ពាក្យ "វិសាមញ្ញ" នៅក្នុងឈ្មោះរបស់ អ.វ.ត.ក បង្ហាញពីលក្ខណៈ ពិសេស របស់ អ.វ.ត.ក។ ការពិតដែល អ.វ.ត.ក មានលក្ខណៈពិសេស ពុំបានធ្វើឱ្យ អ.វ.ត.ក ក្លាយជាតុលាការអន្តរជាតិឡើយ។

ក្នុងកថាខណ្ឌ ១៤០ ក.ស.ព ផ្តល់នូវ "ការបង្ហាញជាក់ស្តែង" មួយ ពីភាពខុសគ្នារវាង អ.វ.ត.ក និងតុលាការជាតិកម្ពុជា។ ការបង្ហាញនេះពុំមានអ្វីបង្ហាញថា អ.វ.ត.ក មិនមែនជាតុលាការកម្ពុជាឡើយ។

[181] *សូមមើល* បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ៩-១២។

[182] *សូមមើល* ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ២ថ្មី ដែលចែងថា អ.វ.ត.ក "ត្រូវបង្កើតឡើងនៅក្នុង<u>រចនាសម្ព័ន្ធតុលាការដែលមានស្រាប់</u> ..." (គូសបញ្ជាក់បន្ថែម)។

### គ. បញ្ហាមិនមែនថាតើ យុត្តាធិការរបស់ អ.វ.ត.ក លើឧក្រិដ្ឋកម្មអន្តរជាតិនិងទម្រង់នៃការទទួលខុសត្រូវ នឹងរំលោភលើគោលការណ៍នីត្យានុកូល ភាពដែលមានចែងក្នុងច្បាប់អន្តរជាតិ ឬយ៉ាងណានោះឡើយ

៧០. នៅក្នុងកថាខណ្ឌ ១៤៥ ក.ស.ព បញ្ជាក់អំពីគោលការណ៍នីត្យានុកូលភាព ដែលមាន ចែងនៅក្នុងមាត្រា១៥.១ នៃកតិកាសញ្ញាអន្តរជាតិ ICCPR។ ក្នុងកថាខណ្ឌ ១៤៦ ក.ស.ព អះអាងថា គោលការណ៍នីត្យានុកូលភាព ដែលមានចែងនៅក្នុងកតិកាសញ្ញា អន្តរជាតិ ICCPR អាចអនុវត្តបាននៅចំពោះមុខ អ.វ.ត.ក។ ទោះបីជាគោលការណ៍ នីត្យានុកូល-ភាពដែលមានចែងនៅក្នុងមាត្រា១៥.១ នៃកតិកាសញ្ញាអន្តរជាតិ អាចអនុវត្ត បាននៅចំពោះមុខ អ.វ.ត.ក យ៉ាងណាក៏ដោយ គោលការណ៍នីត្យានុកូលភាពជាតិក៏អាច អនុវត្តបានដោយស្មើគ្នាដែរ។ មាត្រា៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ តម្រូវថា បទល្មើសទាំងនោះត្រូវតែមានចែងទុកជាមុននៅក្នុងច្បាប់កម្ពុជា ដើម្បីអាចយកបទល្មើសទាំងនោះមកអនុវត្តបាន ដូចដែលបានពន្យល់នៅក្នុងបណ្តឹងឧទ្ធរណ៍[183]។ ក.ស.ព អះអាងទៀតថា គ្មានអ្វីមួយជាការគាំទ្រដល់អំណះអំណាងរបស់មេធាវីការពារក្តីឡើយ ដែលថា គោលការណ៍នីត្យានុកូលភាព គឺសមស្របតែជាមួយនឹងច្បាប់ជាលាយលក្ខណ៍អក្សរប៉ុណ្ណោះ។ ការអះអាងនេះមិនត្រឹមត្រូវឡើយ។ ការពិភាក្សាអំពីច្បាប់ជាលាយលក្ខណ៍អក្សរ (*lex scripta)* ជាទិដ្ឋភាពមួយនៃគោលការណ៍នីត្យានុកូលភាព លោក Roelof Haveman សរសេរថា "ក្នុងច្បាប់ស៊ីវិលឡ (civil law) ទិដ្ឋភាពទីមួយ ភាពអាចដាក់ទោសទណ្ឌបាន ដោយផ្អែក លើច្បាប់ '*lege*' ត្រូវបានបកស្រាយថា៖ ផ្អែកលើ 'ច្បាប់ជាលាយលក្ខណ៍អក្សរ'។ ប្រការនេះបង្ហាញអំពីការហាមឃាត់ទៅលើទំនៀមទម្លាប់ដែលជាប្រភពផ្ទាល់នៃភាពអាចដាក់ទោសទណ្ឌបាន។ វាគឺជាលក្ខន្តិកៈ ដែលជាច្បាប់ជាលាយលក្ខណ៍អក្សរដែលអាចដាក់ទោសទណ្ឌបានចំពោះឥរិយាបថមួយចំនួន។ ប្រសិនបើគ្មាននិយមន័យលក្ខន្តិកៈ នៃឥរិយាបថមួយចំនួនជាបទឧក្រិដ្ឋទេ ការប្រព្រឹត្តនេះមិនអាចដាក់ទោសទណ្ឌបានឡើយ"[184]។ គាត់ពន្យល់ថា គោលការណ៍ ខុសគ្នានៅក្នុងច្បាប់កុំមិនឡ (common law)[185]។ ប្រហែលជាប្រការនេះ

---

[183] *សូមមើល* បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ១០៦-១០។

[184] សៀវភៅ SUPRANATIONAL CRIMINAL LAW: A SYSTEM *SUI GENERIS* 41 (Roelof Haveman និងអ្នកផ្សេងទៀតប្រែសម្រួល Intersentia ២០០៣)។

[185] *ដូចជើងទំព័រខាងលើ*។

រួមជាមួយនឹងការពិតដែលថា តុលាការ ICTY ត្រូវបានផ្តល់អាណត្តិយ៉ាងជាក់លាក់ដើម្បីអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ[186] ពន្យល់ថា ហេតុអ្វីបានជាតុលាការ ICTY ដែលអនុវត្តតាមវិធីសាស្ត្រច្បាប់ខំមិនឡូ និងច្បាប់ស៊ីវិលឡូ មិនត្រូវបានចងកាតព្វកិច្ចដោយគោលការណ៍នេះ។ អ.វ.ត.ក ជាតុលាការកម្ពុជាដែលមានមូលដ្ឋាននៅក្នុងទំនៀមទម្លាប់ច្បាប់ស៊ីវិលឡូ មិនអាចអនុវត្តច្បាប់ជាលាយលក្ខណ៍អក្សរឡើយ។

៧១. ក្នុងកថាខណ្ឌ ១៤៧ ក.ស.ព អះអាងថា គោលការណ៍នីត្យានុកូលភាព ពុំបានហាមឃាត់ មិនឱ្យតុលាការកំណត់សម្រេចបញ្ហាណាមួយ តាមរយៈការបកស្រាយ និងការបញ្ជាក់បំភ្លឺឡើយ ហើយថា យុត្តិសាស្ត្ររបស់តុលាការមិនអចិន្ត្រៃយ៍ គឺអាចអនុវត្តបាន ដោយសារ មិនមានការវិវឌ្ឍន៍ដ៏គួរឱ្យកត់សម្គាល់នៅក្នុងច្បាប់អន្តរជាតិក្នុងអំឡុងឆ្នាំ១៩៧៥ និងឆ្នាំ១៩៩១។ យុត្តិសាស្ត្ររបស់តុលាការមិនអចិន្ត្រៃយ៍ <u>មិនអាច</u>ត្រូវបានទទួលយកដោយ អ.វ.ត.ក ឡើយ ដោយគ្មានការវិភាគឯករាជ្យអំពីថាតើ ឧក្រិដ្ឋកម្មដែលពាក់ព័ន្ធ ឬទម្រង់ នៃការទទួលខុសត្រូវពិតជាមានអត្ថិភាពនៅក្នុងអំឡុងពេលដែលពាក់ព័ន្ធ ឬយ៉ាងណា និងថាតើ ការផ្លាស់ប្តូរណាមួយបានកើតឡើងក្នុងអំឡុងឆ្នាំ១៩៧៥ និងឆ្នាំ១៩៩១ ដែលអាចមានអានុភាពទៅលើរបៀបដែលយុត្តិសាស្ត្រនេះត្រូវបានអនុវត្ត និងត្រូវបានបកស្រាយ ឬយ៉ាងណា។ ប្រការនេះស៊ីសង្វាក់គ្នាជាមួយនឹងវិធីសាស្ត្ររបស់អង្គបុរេជំនុំជម្រះក្នុងការសម្រេចដោយឯករាជ្យថាតើ JCE មាន ឬមិនមានអត្ថិភាពនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងឆ្នាំ១៩៧៥ ជាជាងគ្រាន់តែសន្មតថា JCE មានអត្ថិភាព ពីព្រោះ JCE ត្រូវបានរកឃើញថាមានអត្ថិភាពនៅក្នុងទសវត្សរ៍ឆ្នាំ១៩៩០ ដោយតុលាការ ICTY[187]។ លើសពីនេះទៀត មានការវិវឌ្ឍន៍ដ៏គួរឱ្យកត់សម្គាល់នៅក្នុងច្បាប់អន្តរជាតិក្នុងអំឡុងឆ្នាំ១៩៧៥ និងឆ្នាំ១៩៩១។ ការកម្រិតវិសាលភាព និងពេលវេលា មិនអាចឱ្យមេធាវីការពារក្តី ពង្រីកចំណុចនេះឱ្យកាន់តែធំនៅក្នុងសារណាតបនេះបានឡើយ ក្រៅតែពីឧទាហរណ៍មួយ គឺពិចារណាទៅលើអនុសញ្ញាប្រឆាំងនឹងអំពើទារុណកម្មឆ្នាំ១៩៨៤ (“CAT”)។

---

[186]របាយការណ៍របស់អគ្គលេខាធិការ អនុលោមតាមកថាខណ្ឌ២ នៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខ លេខ ៨០៨ (១៩៩៣) និង ឧបសម្ព័ន្ធ ខាងមុខ ឯកសារ អ.ស.ប S/25704, កថាខណ្ឌ៣៤។

[187] *សូមមើល* សេចក្តីសម្រេចរបស់ អ.ប.ជ ស្តីពី JCE កថាខណ្ឌ៤៥។

៧២. នៅក្នុងកថាខណ្ឌ ១៤៨ ក.ស.ព អះអាងថា គោលការណ៍នីត្យានុកូលភាពត្រូវបានទទួលការគាំពារដោយសារឧក្រិដ្ឋកម្មក្នុងក្របខ័ណ្ឌយុត្តាធិការ អ.វ.ត.ក មានចែងក្នុងច្បាប់ ពីចន្លោះឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩ ហើយលក្ខខណ្ឌតម្រូវនៃភាពអាចប្រមើលមើលដឹងថា ជាបទឧក្រិដ្ឋ និងភាពអាចដឹងថាមានច្បាប់ចែង ត្រូវបានបំពេញ។ ក្នុងកថាខណ្ឌ ១៤៩ ក.ស.ព ជាថ្មីម្តងទៀតបានផ្អែកដោយភ័ន្តច្រឡំទៅលើគោលការណ៍នីត្យានុកូលភាព ដែលមានចែងនៅក្នុងកតិកាសញ្ញាអន្តរជាតិ ICCPR ដោយមិនបានពិចារណាលើគោល-ការណ៍ ដែលមានអត្ថិភាពក្នុងច្បាប់កម្ពុជាទេ។ ការយោងទៅលើយុត្តិសាស្ត្រតុលាការ ICTY គឺមិនមានប្រយោជន៍ឡើយនៅក្នុងករណីនេះ ពីព្រោះតុលាការ ICTY គឺជាតុលាការអន្តរជាតិ និងមិនចាំបាច់ត្រូវពាក់ព័ន្ធជាមួយនឹងគោលការណ៍នីត្យានុកូលភាពក្នុងច្បាប់ជាតិឡើយ។ ក្នុងកថាខណ្ឌ ១៥០ ក.ស.ព ដកស្រង់រឿងក្តី *Eichmann* នៅក្នុងតុលាកាកំពូលប្រទេសអ៊ីស្រាអែល។ ករណីមួយមកពីយុត្តាធិការជាតិមួយ មិនអាចគាំទ្រដល់ការអះអាងដែលថា គោលការណ៍នីត្យានុកូលភាព នឹងមិនត្រូវបានរំលោភដោយការអនុវត្តប្រតិសកម្មនៃច្បាប់ឡើយ។

៧៣. ក្នុងកថាខណ្ឌ ១៥១ ក.ស.ព អះអាងថា អង្គបុរេជំនុំជម្រះសម្រេចថា បញ្ហាចោទដែលថា តើទម្រង់នៃការទទួលខុសត្រូវមួយ ត្រូវបានទទួលស្គាល់នៅក្នុងច្បាប់ជាតិអាចមានសារៈសំខាន់ ដែរឬទេ នៅពេលដែលសម្រេចថាតើទម្រង់នៃការទទួលខុសត្រូវនោះអាចប្រមើល មើលដឹងថាជាបទឧក្រិដ្ឋ ឬយ៉ាងណា ប៉ុន្តែបញ្ជាក់ថា វាមិនចាំបាច់ទេដែលទម្រង់នៃការទទួលខុសត្រូវដែលអាចអនុវត្តបាននៅក្នុងច្បាប់ជាតិ អាចអនុវត្តបាននៅ អ.វ.ត.ក នោះ។ អង្គបុរេជំនុំជម្រះភ័ន្តច្រឡំក្នុងការសម្រេចថា ទម្រង់នៃការទទួលខុសត្រូវ មិនចាំបាច់ត្រូវមានអត្ថិភាពក្នុងច្បាប់កម្ពុជាឡើយ ដើម្បីអាចអនុវត្តបាននៅ អ.វ.ត.ក។ អង្គបុរេជំនុំជម្រះ មិនគួរពង្រីកការសម្រេចនេះដល់ឧក្រិដ្ឋកម្មអន្តរជាតិឡើយ។ ការធ្វើបែបនេះ នឹងរំលោភ លើមាត្រា៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦។ វាក៏មិនស្របគ្នាផងដែរជាមួយនឹងឋានៈ តុលាការជាតិនៃ អ.វ.ត.ក។

៧៤. នៅក្នុងកថាខណ្ឌ ១៥២ ក.ស.ព អះអាងថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងអំពើ ប្រល័យពូជសាសន៍ ត្រូវបានកំណត់ថាជាបទល្មើសព្រហ្មទណ្ឌក្នុងច្បាប់អន្តរជាតិក្នុងឆ្នាំ១៩៧៥-៧៩។ ក្នុងកថាខណ្ឌ ១៥៣ ក.ស.ព អះអាងថា អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរ លើអនុសញ្ញាទីក្រុងហ្សឺណែវមានចែងនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងឆ្នាំ១៩៧៥-៧៩។ កថាខណ្ឌ ១៥៤ ក.ស.ព

អះអាងថា ការកំណត់ពីលក្ខណៈឧក្រិដ្ឋក្នុងច្បាប់ជាតិ បានផ្តល់នូវការជូនដំណឹងគ្រប់គ្រាន់ពីភាពខុសឆ្គងនៃអំពើនោះ ទោះបីជាច្បាប់អន្តរជាតិ តម្រូវឱ្យមានធាតុផ្សំបន្ថែមក៏ដោយ។ ក.ស.ព អះអាងថា អំពើសកម្ម ឬអំពើអកម្ម ដែល ត្រូវបានចោទប្រកាន់ចំពោះលោក អៀង សារី ត្រូវបានកំណត់ថាជាបទល្មើសព្រហ្មទណ្ឌ ក្រោមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦។ ក.ស.ព អះអាងថា ចំណុចនេះគាំទ្រដល់*[ការ]*សន្និដ្ឋានថា បទល្មើសទាំងនេះមានចែងក្នុងច្បាប់ក្នុងអំឡុងពេលពាក់ព័ន្ធ។ ក.ស.ព មិនបានពន្យល់ថា តើការពិតដែលបទល្មើសមួយចំនួនមានចែងនៅក្នុងច្បាប់ជាតិ អាចគាំទ្រទឡ្ហីករណ៍របស់ ខ្លួនយ៉ាងដូចម្តេច ដែលបទល្មើសខុសគ្នាស្រឡះមានអត្ថិភាពនៅក្នុងផ្នែកខុសគ្នានៃច្បាប់នៅទន្ទឹមពេលគ្នានោះ។ សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងលើរឿងក្តី *Čelebići* របស់តុលាការ ICTY ដែលក.ស.ព បានដកស្រង់នោះ <u>មិនបាន</u>ផ្តល់នូវការគាំទ្រចំពោះ ការអះអាងរបស់ ក.ស.ព ឡើយ[188]។ អង្គជំនុំជម្រះសាលាដំបូងលើរឿងក្តី *Čelebići* មិនបានពិភាក្សាអំពីការដាក់បន្ថែមធាតុផ្សំបន្ថែមទៅនឹងច្បាប់ជាតិ និងអំពីបញ្ហាថាតើ ប្រការនេះនឹងនាំឱ្យមានការរំលោភលើគោលការណ៍នីត្យានុកូលភាព ឬយ៉ាងណានោះឡើយ។ លទ្ធភាពដែល លោក អៀង សារី អាចប្រឈមនឹងការចោទប្រកាន់ពីបទមនុស្សឃាត អំពើទារុណកម្ម ឬការធ្វើទុក្ខបុកម្នេញលើសាសនា ក្រោមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ប្រសិនបើគាត់ជាប់ពាក់ព័ន្ធក្នុងអំពើមួយចំនួន មិនមានន័យថា គាត់អាចបានប្រមើលមើល ដឹងអំពីការដាក់ឱ្យទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្ម

---

[188]កថាខណ្ឌដែលត្រូវបានដកស្រង់បញ្ជាក់ថា "បន្ថែមទៅលើអ្វីដែលត្រូវបានបញ្ជាក់ពីខាងលើ ទាក់ទិននឹងលក្ខណៈទំនៀមទម្លាប់នៃការហាមឃាត់ ដែលមានចែងនៅក្នុងមាត្រាពរួម នៃអនុសញ្ញាទីក្រុងហ្សឺណែវ និងការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល ដែលការរំលោភបំពាននោះកើតមាន អង្គជំនុំជម្រះសាលាដំបូងនេះដាក់ការសង្កត់ធ្ងន់ជាពិសេសទៅលើបទប្បញ្ញត្តិ នៃក្រមព្រហ្មទណ្ឌរបស់សាធារណរដ្ឋសហព័ន្ធសង្គមនិយមយូហ្គោស្លាវី ដែលត្រូវបានអនុម័តដោយបូស្នី និង ហឺសេហ្គោវីន ក្នុងខែមេសា ឆ្នាំ១៩៩២។ ច្បាប់នេះកំណត់នូវយុត្តាធិការនៃតុលាការបូស្នីលើឧក្រិដ្ឋកម្មសង្គ្រាម ដែលត្រូវបានប្រព្រឹត្ត 'នៅពេល មានសង្គ្រាម ជម្លោះប្រដាប់អាវុធ ឬការកាន់កាប់ត្រួតត្រា' ដែលពុំបានបង្ហាញនូវភាពខុសគ្នារវាងជម្លោះប្រដាប់អាវុធជាតិ និងជម្លោះប្រដាប់អាវុធអន្តរជាតិឡើយ។ ដូច្នេះ ជនជាប់ចោទនីមួយៗនៅក្នុងរឿងក្តីនេះ អាចត្រូវបានដាក់ឱ្យស្ថិតក្រោមការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គលក្រោមច្បាប់ជាតិរបស់ពួកគេចំពោះឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់នៅក្នុងដីកា បញ្ជូន រឿងទៅជំនុំជម្រះ។ ដូច្នេះ ផ្អែកលើមូលដ្ឋាននេះ ផងដែរក៏មិនមានទម្ងន់ចំពោះទឡ្ហីករណ៍ដែលថា ការអនុវត្តបទប្បញ្ញត្តិនៃ មាត្រាពរួមនៃអនុសញ្ញាទីក្រុងហ្សឺណែវ ក្រោមមាត្រា៣ នៃលក្ខន្តិកៈ រំលោភលើគោលការណ៍គ្មានបទល្មើស បើគ្មានច្បាប់ចែង (*nullum crimen sine lege*)" សាលក្រមរឿងក្តី *Čelebići* កថាខណ្ឌ ៣១២។

ប្រឆាំងមនុស្សជាតិ ឬការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវនោះឡើយ។

**ឃ. ច្បាប់ដែលចែងឱ្យមានការទទួលខុសត្រូវ មិនអាចមានភាពដឹងថាមានគ្រប់គ្រាន់ ហើយការដាក់ទោសឧក្រិដ្ឋមិនអាចប្រមើលមើលដឹងមុនគ្រប់គ្រាន់ឡើយ ក្នុងចន្លោះឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩**

៧៥. ក្នុងកថាខណ្ឌ ១៥៥ ក.ស.ព អះអាងថា គោលបំណងនៃគោលការណ៍នីត្យានុកូលភាព គឺដើម្បីរារាំងការដាក់ទណ្ឌកម្មទៅលើអំពើណាដែលគេពុំជឿថាជាអំពើឧក្រិដ្ឋ នៅពេល ដែលអំពើនោះត្រូវបានប្រព្រឹត្ត។ មេធាវីការពារក្តីយល់ស្របថា នេះអាចជាគោលបំណង <u>មួយ</u>នៃគោលការណ៍នេះ ហើយថាតុលាការ ICTY អាចបានទទួលស្គាល់ថា នេះគឺជា គោលបំណងមួយនៃគោលការណ៍នេះ ដូចដែល ក.ស.ព បានអះអាងផងដែរ។ គោលបំណងមួយទៀតនៃគោលការណ៍នេះគឺ "ដើម្បីការពារពលរដ្ឋឱ្យបានរឹងមាំតាមលទ្ធភាពធ្វើទៅបាន ប្រឆាំងនឹងអំណាចតាមទំនើងចិត្តរបស់រដ្ឋាភិបាល និងឆន្ទានុសិទ្ធិហួសហេតុរបស់តុលាការ។ ជារួម មូលដ្ឋានគ្រឹះនៃទស្សនៈនេះស្ថិតនៅលើការសន្មត *ការលម្អៀងមកខាងជនជាប់ចោទ favor rei* (ដែលមានទំនោរទៅរកជនជាប់ចោទ) (ផ្ទុយពី *ការលម្អៀងមកខាងសង្គម favor societatis* ឬដែលមានទំនោរទៅរកសង្គម"[189]។ ដូចដែលបានបញ្ជាក់ដោយចៅក្រម Robertson នៃតុលាការ SCSL វាអាច មាន "លក្ខណៈមិនងាយស្រួល [ប៉ុន្តែ] វាមាន<u>លក្ខណៈច្បាស់លាស់ នៅពេលដែលមានអំពើ ដែលគួរឱ្យស្អប់ខ្ពើម និងដែលគួរឱ្យរន្ធត់កើតឡើង</u> ដែលគោលការណ៍នីត្យានុកូលភាព ត្រូវតែយកមកអនុវត្តឱ្យបានតឹងរ៉ឹងបំផុត ដើម្បីធានាថា ចុងចោទមិនត្រូវបានជំនុំជម្រះក្តីឱ្យមានទោស ដោយមូលហេតុនៃភាពស្អប់ខ្ពើម ជាជាងការផ្អែកទៅលើភស្តុតាង ឬដោយផ្អែកទៅលើឧក្រិដ្ឋកម្មដែលមិនមានអត្ថិភាពនោះ"[190]។ គាត់បញ្ជាក់បន្ថែមទៀតថា គោលការណ៍នេះ "តម្រូវឱ្យរដ្ឋាភិបាល (ក្នុងករណីនៃច្បាប់ជាតិ) និងសហគមន៍អន្តរជាតិ (ក្នុងករណីច្បាប់

---

[189] សៀវភៅនិពន្ធដោយ ANTONIO CASSESE, មានចំណងជើងថា INTERNATIONAL CRIMINAL LAW ទំព័រ142 (ប្រែសម្រួលលើកទី១ បោះពុម្ពដោយ Oxford University Press ២០០៣)។

[190] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Fofana & Kondewa*, SCSL-2004-14-AR72(E), សេចក្តីសម្រេចលើ ញត្តិបឋមដោយមូលហេតុកង្វះខាតយុត្តាធិការ យោបល់ដោយឡែករបស់ចៅក្រម Robertson, ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០៤ កថាខណ្ឌ២ (គូសបញ្ជាក់បន្ថែម)។

ព្រហ្មទណ្ឌអន្តរជាតិ) ចាត់វិធានការជាវិជ្ជមានប្រឆាំងនឹងការប្រព្រឹត្តដែលគួរឲ្យស្អប់ខ្ពើម បើពុំដូច្នោះទេ ការប្រព្រឹត្តនោះនឹងមិនត្រូវបានផ្តន្ទាទោសឡើយ។ ហេតុដូច្នេះ គោលការណ៍នេះផ្តល់ជាយុត្តកម្មសម្រាប់ការកាត់តែងច្បាប់ សន្ធិសញ្ញា និងអនុសញ្ញានានា...។ នេះជាមូលហេតុដែលថា យើងទាំងអស់គ្នាត្រូវបានគ្រប់គ្រងដោយ ច្បាប់ និងមិនមែនដោយនគរបាលទេ"[191]។ វាច្បាស់ណាស់ដែលថា ចៅក្រម Robertson កំពុងសំដៅទៅលើអំពើដែលចារីនឹងជឿជាក់ថាជាឧក្រិដ្ឋជន នៅពេលដែលអំពើនោះត្រូវបានប្រព្រឹត្ត។

៧៦. នៅក្នុងកថាខណ្ឌ ១៥៦ ក.ស.ព អះអាងថា តុលាការ ICTY បានអនុវត្តជាប់ជាហូរហែ នូវការពិសោធន៍ "ភាពអាចប្រមើលមើលដឹងថាជាបទឧក្រិដ្ឋ និងភាពអាចដឹងថាមាន ច្បាប់ចែង" ដើម្បីកំណត់ថាតើគោលការណ៍នីត្យានុកូលភាព ត្រូវបានរំលោភដែរឬយ៉ាង ណា ហើយថា អង្គជំនុំជម្រះសាលាដំបូងលើរឿងក្តី ឌុច អនុវត្តតាមវិធីសាស្ត្រនេះ។ យុត្តិសាស្ត្រតុលាការ ICTY មិនត្រូវបានអនុម័តដោយអង្គបុរេជំនុំជម្រះឡើយ ដោយគ្មានការវិភាគឯករាជ្យថាតើយុត្តិសាស្ត្រនេះត្រឹមត្រូវដែរឬយ៉ាងណា។ សាលក្រម ឌុច មានទម្ងន់តិចតួច ទាក់ទិនទៅនឹងច្បាប់ដែលអាចអនុវត្តបាន ដោយសារតែបញ្ហានេះ ដូចគ្នាជាមួយនឹងបញ្ហាគតិយុត្តិផ្នែកយុត្តាធិការស្ទើរតែទាំងអស់ដទៃទៀត មិនត្រូវបានជំទាស់ដោយមេធាវីការពារក្តី។

៧៧. ក្នុងកថាខណ្ឌ ១៥៧ ក.ស.ព អះអាងថា ការពិចារណាពាក់ព័ន្ធនឹងការវាយតម្លៃលើលក្ខខណ្ឌតម្រូវនៃភាពអាចប្រមើលមើលដឹងថាជាបទឧក្រិដ្ឋ និងភាពអាចដឹងថាមានច្បាប់ចែង រួមមាន៖ ភាពគួរឲ្យរន្ធត់ និងភាពអសីលធម៌នៃអំពើមួយ និងការដែលថាឧក្រិដ្ឋកម្ម ណាមួយ ឬទម្រង់នៃការទទួលខុសត្រូវមានអត្ថិភាពនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ ក.ស.ព អះអាងថា ការអនុវត្តរបស់រដ្ឋដែលយោគយល់ ឬជំរុញដល់អំពើមួយ នឹងមិនរារាំងដល់ការកាត់សេចក្តី និងផ្តន្ទាទោសដល់ចារីបានទេ នៅពេលដែលអំពើទាំងនោះ គឺជាបទឧក្រិដ្ឋនៅក្រោមច្បាប់ជាតិ ឬអន្តរជាតិ។ ទាក់ទិនទៅនឹងភាពគួរឲ្យរន្ធត់ ឬភាព អសីលធម៌នៃអំពើមួយ វាអាចដូច្នេះមែន ប្រសិនបើជនជាប់ចោទប្រព្រឹត្តអំពើមួយដោយខ្លួនឯង ដែលជាអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឬការបំពារបំពានយ៉ាងធ្ងន់ធ្ងរ ដែលរូបគាត់អាចប្រមើលដឹងជាមុនបានថាអំពើនោះគឺជាបទឧក្រិដ្ឋ។ ទោះបីជាយ៉ាងណា

---

[191] *ដូចដើងទំព័រខាងលើ* កថាខណ្ឌ១៤។

ក៏ដោយ នៅពេលដែលមានការជាប់ពាក់ព័ន្ធជាមួយនឹងទម្រង់នៃការទទួលខុសត្រូវ ដូចជា JCE និងការទទួលខុសត្រូវក្នុងការចេញបញ្ជា នោះវាកាន់តែមានការពិបាកថែមទៀតក្នុងការសន្និដ្ឋានថា ឧក្រិដ្ឋភាពអាចប្រមើលមើលដឹងជាមុនបាននោះ។

> ប្រហែលជាមិនមានទស្សនទានពង្រីកសញ្ញាណទំនៀមទម្លាប់ នៃការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គល ឱ្យលើសពីការទទួលខុសត្រូវរបស់ថ្នាក់លើនោះទេ ចំពោះអំពើឧក្រិដ្ឋរបស់អ្នកនៅក្រោមបង្គាប់នោះឡើយ។ ការទទួលខុសត្រូវរបស់ថ្នាក់លើគឺជាការទទួលខុសត្រូវនៃការខកខាន ដែលជនល្មើសត្រូវផ្តន្ទាទោសចំពោះការ *មិនបាន*ប្រព្រឹត្ត។ ប៉ុន្តែវាមានន័យច្រើនជាងនេះទៀត។ ថ្នាក់លើត្រូវទទួលខុសត្រូវចំពោះបទឧក្រិដ្ឋជាក់លាក់ មិនមែនដោយសារអំពើរបស់គាត់ស្ថិតនៅក្នុងនិយមន័យរបស់បទឧក្រិដ្ឋនោះទេ ប៉ុន្តែដោយសារគាត់ ខកខានមិនបានទប់ស្កាត់ការប្រព្រឹត្តបទឧក្រិដ្ឋនោះពីសំណាក់អ្នកដទៃ។ អ្វីដែលសំខាន់នោះគឺថា ថ្នាក់លើត្រូវទទួលខុសត្រូវចំពោះ*បទឧក្រិដ្ឋជាក់ស្តែង* របស់អ្នកនៅក្រោមបង្គាប់ មិនមែនចំពោះបទល្មើសដាច់ដោយឡែក ដែលត្រូវបានផ្តោតទៅលើ សេចក្តីធ្វេសប្រហែសក្នុងករណីកិច្ចរបស់អ្នកចេញបញ្ជានោះទេ[192]។

ដូច្នេះ វាមិនគ្រប់គ្រាន់ទេក្នុងការបញ្ជាក់ថា ការទទួលខុសត្រូវព្រហ្មទណ្ឌ នឹងអាចត្រូវបានប្រមើលមើលដឹងជាមុនបាន ដោយផ្អែកលើលក្ខណៈនៃបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់នោះ។ អង្គបុរេជំនុំជម្រះគួរតែបន្តការអនុវត្តពីមុនៗរបស់ខ្លួន នៃការសម្រេចថាតើ ជនជាប់ចោទពិតជាអាចប្រមើលមើលដឹងជាមុនអំពីការទទួលខុសត្រូវ ឬយ៉ាងណា ជាជាងគ្រាន់តែស្វះស្វែងរកថាតើ ការទទួលខុសត្រូវមានអត្ថិភាពក្នុងច្បាប់ទំនៀមទម្លាប់ អន្តរជាតិ ដែរឬយ៉ាងណានោះ[193]។

៧៨. ក្នុងកថាខណ្ឌ ១៥៨ ក.ស.ព អះអាងថា អង្គជំនុំជម្រះសាលាដំបូងលើរឿងក្តី ឌុច សម្រេចថា គេអាចប្រមើលមើលដឹងថាជាបទឧក្រិដ្ឋនៅក្នុងអំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ដែល ឌុច អាចត្រូវបានដាក់ឱ្យទទួលខុសត្រូវព្រហ្មទណ្ឌចំពោះបទល្មើសដែលខ្លួន ត្រូវបានចោទប្រកាន់។ អង្គបុរេជំនុំ

---

[192] សៀវភៅនិពន្ធដោយ David L. Nersessian មានចំណងជើងថា *Whoops, I Committed Genocide! The Anomaly of Constructive Liability for Serious International Crimes*, 30 FLETCHER F. WORLD AFF. ទំព័រ81, 88-89 (2006)។

[193] *សូមមើល* សេចក្តីសម្រេចរបស់ អ.ប.ជ ស្តីពី JCE កថាខណ្ឌ៤៥។

ជម្រះគួរតែមានការប្រុងប្រយ័ត្នក្នុងការផ្អែកទៅលើ សាលក្រម ឌុច ទាក់ទិននឹងបញ្ហានេះ។ បញ្ហាទាំងនេះ មិនត្រូវបានជំទាស់ដោយមេធាវី ការពារក្តីឡើយ។ អង្គបុរេជំនុំជម្រះត្រូវតែកំណត់ថាតើ បទឧក្រិដ្ឋ និងទម្រង់នៃការទទួលខុសត្រូវដែលត្រូវបានអនុវត្តនោះ គឺពិតជាអាចប្រមើលមើលដឹងជាមុនចំពោះលោក អៀង សារី ដែរឬទេ។

៧៩. ក្នុងកថាខណ្ឌ ១៥៩ ក.ស.ព អះអាងថា លោក អៀង សារី អាចដឹងមុនថាខ្លួនអាច ត្រូវបានដាក់ឲ្យទទួលខុសត្រូវចំពោះអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ សូម្បីតែមិនស្ថិតក្នុង ជម្លោះប្រដាប់អាវុធក្តី។ ក.ស.ព អះអាងថា ក្នុងនាមជាសមាជិកមួយរូប*[នៃ]*អង្គមហាសន្និបាតអង្គការសហប្រជាជាតិ របបកម្ពុជាប្រជាធិបតេយ្យបានកត់សម្គាល់អំពីលិខិតុបករណ៍ពាក់ព័ន្ធមួយចំនួន ដែលទាក់ទិនទៅនឹងឧក្រិដ្ឋកម្មអន្តរជាតិទាំងនេះ។ ការអះអាង ដែលថាការចោទប្រកាន់ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងតុលាការកម្ពុជា ចំពោះអំពើ ដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តឡើងក្នុងឆ្នាំ១៩៧៥-៧៩ ដោយមិនមានទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធ ប្រាកដជាអាចប្រមើលមើលដឹងជាមុនបាន ដោយផ្អែកលើឯកសាររបស់មហាសន្និបាតអង្គការសហប្រជាជាតិ ត្រូវតែបដិសេធចោល។ ការចោទប្រកាន់ដោយផ្អែកលើទម្រង់នៃការទទួលខុសត្រូវ ដូចជា ការទទួលខុសត្រូវក្នុងការចេញបញ្ជា ឬ JCE មិនអាចប្រមើលមើលដឹងជាមុនបានឡើយ។ ទម្រង់ នៃការទទួលខុសត្រូវទាំងនេះ <u>មិនត្រូវបាន</u>ចងក្រងជាច្បាប់ឡើយនៅពេលនោះ[194]។ ការចោទប្រកាន់នៅក្នុងប្រទេសកម្ពុជាចំពោះបទឧក្រិដ្ឋទាំងនេះ មិនអាចប្រមើលមើលដឹងជាមុនបានឡើយ ដោយសារតែពុំមានច្បាប់ជាតិដែលអាចអនុវត្តបាននៅពេលនោះ។ ក.ស.ព អះអាងថា ភាពគួរឲ្យរន្ធត់នៃបទឧក្រិដ្ឋទាំងនេះ បានធ្វើឲ្យពួកគាត់អាចប្រមើលមើលដឹងជាមុនបាន។ ទោះបីជាចំណុចនេះទំនងជាអាចប្រមើលមើលដឹងជាមុនបានថា <u>ការប្រព្រឹត្ត</u>ជាក់ស្តែងនៃបទឧក្រិដ្ឋទាំងនោះ នឹងនាំឲ្យមានការទទួលខុសត្រូវក៏ដោយ ក៏វា មិនធ្វើឲ្យការទទួលខុសត្រូវអាចប្រមើលមើលដឹងជាមុនបាន ទាក់ទិនទៅនឹងទម្រង់នៃការទទួលខុសត្រូវដទៃទៀតឡើយ ដូចជា

---

[194]ការទទួលខុសត្រូវក្នុងការចេញបញ្ជាត្រូវបានចងក្រងជាច្បាប់ដោយពិធីសារបន្ថែម I ក្នុងឆ្នាំ១៩៧៧ ប៉ុន្តែនេះនឹងមិនធ្វើឲ្យមានការទទួលខុសត្រូវ អនុលោមតាមការប្រមើលមើលដឹងជាមុននៃការទទួលខុសត្រូវនេះនៅពេលនោះឡើយ។ សូមមើល ការទទួលខុសត្រូវក្នុងការចេញបញ្ជានៅផ្នែក*ខាងក្រោម*សម្រាប់សេចក្តីពន្យល់បន្ថែម។

JCE និងការទទួលខុសត្រូវក្នុងការចេញបញ្ជា។

### ង. មាត្រា១៥(១) នៃកតិកាសញ្ញាអន្តរជាតិ ICCPR

៨០. ក្នុងកថាខណ្ឌ ១៦០ ក.ស.ព ដកស្រង់មាត្រា១៥(២) នៃកតិកាសញ្ញាអន្តរជាតិ ICCPR។ ក្នុងកថាខណ្ឌ ១៦១ ក.ស.ព អះអាងថា សេចក្តីយោងនៅក្នុងមាត្រា១៥(២) ទៅលើ “គោលការណ៍ទូទៅនៃច្បាប់” គឺជាសេចក្តីយោងមួយទៅលើប្រភពទីបីនៃច្បាប់អន្តរជាតិ ដែលមានចែងនៅក្នុងលក្ខន្តិកៈតុលាការយុត្តិធម៌អន្តរជាតិ។ ក្នុងកថាខណ្ឌ ១៦២ ក.ស.ព អះអាងថា មាត្រា១៥(២) សំដៅទៅលើថាតើ “អំពើ” ជាអំពើឧក្រិដ្ឋ ឬយ៉ាងណា ហើយថា គេមិនទាមទារឲ្យមានការចង្អុលបង្ហាញពីបទល្មើសជាក់លាក់ណាមួយនោះទេ។ ក.ស.ព អះអាងថា ដូច្នេះ មាត្រា១៥(២) នឹងអនុញ្ញាតឲ្យរដ្ឋអាចអនុម័តនូវច្បាប់ដែល កំណត់ពីលក្ខណៈឧក្រិដ្ឋរបស់អំពើ ដែលអាចមិនមែនជាបទល្មើសជាក់លាក់នៅពេលដែល អំពើនោះត្រូវបានប្រព្រឹត្ត នៅក្រោមច្បាប់ជាតិ ច្បាប់ទំនៀមទម្លាប់អន្តរជាតិ ឬច្បាប់អនុសញ្ញាអន្តរជាតិ។ មាត្រា១៥(២) មិនមានបំណងដើម្បីអាចឲ្យរដ្ឋកំណត់ពីលក្ខណៈឧក្រិដ្ឋ របស់អំពើដោយប្រតិសកម្មឡើយ។ មាត្រានេះគ្រាន់តែមានបំណងដើម្បីកម្រិតវិសាលភាពនៃមាត្រា១៥(១) ប៉ុណ្ណោះ។ លើសពីនេះទៀត វាគួរឲ្យមានមន្ទិលថាតើ គោលការណ៍ទូទៅនៃច្បាប់អាចមានអត្ថិភាពដែរឬទេ នៅពេលដែលគោលការណ៍ទាំងនេះមិនផ្អែកទៅលើច្បាប់ជាតិ[195]។

៨១. ក្នុងមាត្រា ១៦៣ ក.ស.ព រៀបរាប់អំពីរឿងក្តីមួយចំនួន ដែលយោងទៅលើគោលការណ៍ទូទៅនៃច្បាប់។ ក្នុងកថាខណ្ឌ ១៦៤ ក.ស.ព លើកឡើងថា បទឧក្រិដ្ឋដែលរៀបរាប់នៅក្នុងមាត្រា៤ មាត្រា៥ និងមាត្រា៦ នៃច្បាប់អ.វ.ត.ក គឺជាអំពើឧក្រិដ្ឋ អនុលោមតាម គោលការណ៍ទូទៅនៃច្បាប់ក្នុងឆ្នាំ១៩៧៥។ គោលការណ៍នីត្យានុកូលភាពដែលមានចែង នៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ពុំមានករណីលើកលែងឡើយ ស្រដៀងគ្នាទៅនឹងមាត្រា១៥(២) នៃកតិកាសញ្ញាអន្តរជាតិ ICCPR។ ទោះបីជាយ៉ាងណាក៏ដោយ ប្រសិនបើអង្គបុរេជំនុំជម្រះយល់ឃើញថា មាត្រា៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ មិនអាចអនុវត្តបាន អង្គបុរេជំនុំជម្រះត្រូវតែសម្រេចថាតើ បទឧក្រិដ្ឋនីមួយៗក្នុងចំណោមបទឧក្រិដ្ឋ

---

[195] សៀវភៅរបស់ Cherif Bassiouni មានចំណងជើងថា៖ *A Functional Approach to ‘General Principles of International Law’*, 11 MICH. J. INT’L L. ទំព័រ 768, 773-74 (ឆ្នាំ១៩៩០)។

ទាំងនេះ មានអត្ថិភាពជាគោលការណ៍ទូទៅនៃច្បាប់ក្នុងឆ្នាំ១៩៧៥ ដែរឬយ៉ាងណា។

### ច. គោលការណ៍នីត្យានុកូលភាពក្នុងច្បាប់កម្ពុជា

៨២. ក្នុងមាត្រា ១៦៥ ក.ស.ព ឆ្លើយតបជាសំខាន់ទៅនឹងទឡ្ហីករណ៍របស់ជនជាប់ចោទដទៃ ទៀត។ ការអះអាងរបស់ ក.ស.ព ដែលថា ក្រុមប្រឹក្សាធម្មនុញ្ញបានសម្រេចថា "ច្បាប់រដ្ឋធម្មនុញ្ញមិនរារាំងដល់អង្គនីតិប្បញ្ញត្តិក្នុងការអនុម័តច្បាប់ ដែលមានការអនុវត្តពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍នានា ដែលមានពីពេលមុនវា" គឺមានលក្ខណៈទូទៅហួសហេតុ។ ក្រុមប្រឹក្សាធម្មនុញ្ញពិភាក្សាតែបញ្ហាជាក់លាក់នៅចំពោះមុខខ្លួនប៉ុណ្ណោះ និងមិនបានសម្រេចថា អង្គនីតិប្បញ្ញត្តិអាចអនុម័តច្បាប់ប្រតិសកម្មនៅក្នុងករណីផ្សេងទៀតឡើយ។ ក្រុមប្រឹក្សាធម្មនុញ្ញសំដៅទៅលើគោលការណ៍នៃភាពអប្រតិសកម្មនៃច្បាប់ ជាគោលការណ៍មូលដ្ឋាននៃច្បាប់។ ក្រុមប្រឹក្សាធម្មនុញ្ញយល់ឃើញថា "ប្រទេសកម្ពុជា ដូចបណ្តាប្រទេសដែលមានអារ្យធម៌ខ្ពង់ខ្ពស់ដទៃទៀតដែរ ទទួលស្គាល់ [គោលការណ៍នេះ] នៅមុន ឆ្នាំ១៩៧៥ និងក្រោយឆ្នាំ១៩៧៨ រួមទាំងរយៈកាលអន្តរកាលនៃក្រុមប្រឹក្សាជាតិជាន់ខ្ពស់"[196]។

៨៣. ក្នុងកថាខណ្ឌ ១៦៦ ក.ស.ព អះអាងថា មាត្រា៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ពុំបានរារាំងដល់ការអនុវត្តច្បាប់អ.វ.ត.ក ឡើយ ដោយសារតែច្បាប់ច្បាប់អ.វ.ត.ក មិនមាន អានុភាពប្រតិសកម្មទេ និងគ្រាន់តែផ្តល់ឲ្យ អ.វ.ត.ក នូវយុត្តាធិការពាក់ព័ន្ធទៅនឹងការ ប្រព្រឹត្តដែលមានលក្ខណៈជាព្រហ្មទណ្ឌ ហើយដែលអាចផ្តន្ទាទោសបាននៅពេលវេលា ដែលពាក់ព័ន្ធប៉ុណ្ណោះ។ ទោះបីជាយ៉ាងណាក៏ដោយ ក.ស.ព មានបំណងឲ្យច្បាប់អ.វ.ត.ក មានអានុភាពប្រតិសកម្ម ពីព្រោះប្រការនេះនឹងធ្វើឲ្យមានយុត្តាធិការលើអំពើ ដែលមិនត្រូវបានកំណត់ថាជាអំពើព្រហ្មទណ្ឌក្នុងច្បាប់ជាតិក្នុងឆ្នាំ១៩៧៥-៧៩ ហើយ បើមិនធ្វើដូច្នេះទេនោះ នឹងមិនមានអ្វីអាចផ្តន្ទាទោសបានឡើយក្នុងប្រទេសកម្ពុជា[197]។

៨៤. ក្នុងកថាខណ្ឌ ១៦៧ ក.ស.ព អះអាងថា មាត្រា៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ គ្រាន់តែ កម្រិតទៅ

---

[196] សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ លេខ ០៤០/00២/២00១, ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២00១ ទំព័រ២ (បកប្រែក្រៅផ្លូវការ គូសបញ្ជាក់បន្ថែម)។

[197] *សូមមើល* ចម្លើយតប កថាខណ្ឌ១៣៥។

លើការអនុវត្តក្រមព្រហ្មទណ្ឌនេះប៉ុណ្ណោះ ប៉ុន្តែមិនបានកម្រិតទៅលើការអនុវត្តច្បាប់ដទៃទៀតឡើយ។ ក.ស.ព អះអាងថា ជាងនេះទៅទៀតនោះ ច្បាប់អ.វ.ត.ក "បានបង្ហាញពី *ច្បាប់ពិសេសមួយ* នៅពេលក្រោយមកទៀត (later-in-time *lex specialis)* ដែលមានអានុភាពជាគុណសម្បត្តិក្នុងមាត្រា៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦"។ ក.ស.ព មិនបានផ្តល់នូវការគាំទ្រចំពោះការអះអាងទាំងនេះទេ។ នៅក្នុងក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៦ ឬច្បាប់អ.វ.ត.ក មិនមានចំណុចណាគាំទ្រដល់ការបកស្រាយបែបនេះឡើយ។

## VII. អ.វ.ត.ក ពុំមានយុត្តាធិការដើម្បីអនុវត្តអំពើប្រល័យពូជសាសន៍ឡើយ តើអាចមានការអនុវត្តអំពើប្រល័យពូជសាសន៍បានទេ ប្រសិនបើគ្មានការចោទប្រកាន់អំពីចេតនាប្រល័យពូជសាសន៍ជាក់លាក់ ទៅលើជនជាប់ចោទ

៨៥. ក្នុងកថាខណ្ឌ ១៧០ ដល់ ១៧១ ក.ស.ព អះអាងថា ភស្តុតាងបញ្ជាក់អំពី "ចេតនាប្រល័យពូជសាសន៍ពិសេស" មិនតម្រូវឱ្យមានសម្រាប់គ្រប់ប្រភេទនៃការទទួលខុសត្រូវលើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទាំងអស់នោះទេ ហើយថា ក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ *ចេតនាឧក្រិដ្ឋ* ជាក់លាក់ដែលតម្រូវឱ្យមានសម្រាប់អំពើប្រល័យពូជសាសន៍ គឺអាស្រ័យ លើប្រភេទនៃការទទួលខុសត្រូវដែលជនជាប់ចោទរងការចោទប្រកាន់។ ក.ស.ព យោងទៅលើតុលាការ ICTY និងតុលាការ ICTR ដែលបានអនុវត្តអំពើប្រល័យពូជសាសន៍ សូម្បីតែគ្មានសំអាងហេតុនៃចេតនាជាក់លាក់តាមរយៈទម្រង់នៃការទទួលខុសត្រូវកម្រិត មធ្យមក៏ដោយ ហើយទទូចឱ្យ អ.វ.ត.ក ទទួលយកយុត្តិសាស្ត្រនេះ ទោះបីជាវាត្រូវបានធ្វើឡើងនៅក្រោយអំឡុងពេលដែលចោទជាបញ្ហានេះក៏ដោយ។ អង្គបុរេជំនុំជម្រះមិនគួរអនុវត្តតាមវិធីសាស្ត្រ ដែលមានវិការៈរបស់តុលាការមិនអចិន្ត្រៃយ៍ទាំងនោះឡើយ។ កតិកាសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ មិនបានចែងអំពី *ចេតនាឧក្រិដ្ឋ* ដែលមានកម្រិតទាប នៅពេលដែលជនជាប់ចោទត្រូវបានចោទប្រកាន់ពីអំពើប្រល័យពូជសាសន៍តាមរយៈ ទម្រង់នៃការទទួលខុសត្រូវកម្រិតមធ្យមឡើយ។ ពិតណាស់នេះមិនមែនជាគោលបំណង របស់អ្នកតាក់តែងឡើយ។ ក្នុងឆ្នាំ១៩៨៥ លោក Benjamin Whitaker ដែលជាអ្នកធ្វើ របាយការណ៍ពិសេសអំពីអំពើប្រល័យពូជសាសន៍បានដាក់របាយការណ៍មួយ "ស្តីពីបញ្ហា នៃការការពារ និងការដាក់ទោសទណ្ឌឧក្រិដ្ឋកម្មប្រល័យពូជសាសន៍" ដែលមាន

ចំណងជើងថា *របាយការណ៍ដែលបានធ្វើបច្ចុប្បន្នភាព និងកែសម្រួល ស្តីពីបញ្ហានៃការការពារ និងការដាក់ទោសទណ្ឌឧក្រិដ្ឋកម្មប្រល័យពូជសាសន៍*[198] ដែលបានលើកឡើងនូវសំណើ និង អនុសាសន៍ជាច្រើន។ របាយការណ៍នេះផ្តល់នូវអនុសាសន៍ថា "មានការផ្តល់នូវ យោបល់ថា តុលាការគួរតែអាចធ្វើសេចក្តីសន្និដ្ឋានអំពីចេតនាចាំបាច់ ចេញពីភស្តុតាងគ្រប់គ្រាន់ ហើយថា នៅក្នុងករណីមួយចំនួន នេះនឹងរួមបញ្ចូលនូវសកម្មភាព ឬការខកខាននៃកម្រិតនៃភាពធ្វេសប្រហែស ឬភាពមិនអើពើដែលមានលក្ខណៈឧក្រិដ្ឋ ដែលចុងចោទត្រូវបានសន្មតដោយសមហេតុផលថា បានដឹងអំពីផលវិបាកនៃអំពើរបស់គាត់"[199]។ សេចក្តីបញ្ជាក់នេះនឹងមិនមានលក្ខណៈចាំបាច់ទេ ប្រសិនបើចេតនាជាក់លាក់មិនតម្រូវ ឲ្យមានក្រោមទម្រង់នៃការទទួលខុសត្រូវទាំងអស់នៅពេលនោះ។ របាយការណ៍ឆ្នាំ១៩៧៨ កាលពីលើកមុននេះ មិនមានអនុសាសន៍នេះទេ។ របាយការណ៍នេះបានបញ្ជាក់ថា៖

> ក្នុងអំឡុងកិច្ចពិភាក្សានៅក្នុងគណៈកម្មាធិការទី៦ មានការចង្អុលបង្ហាញថា *ក្នុងចំណោមប្រការផ្សេងទៀត* អ្វីដែលបានកំណត់ថាអំពើប្រល័យពូជសាសន៍មានលក្ខណៈខុសពីឧក្រិដ្ឋកម្មទូទៅនៃអំពើមនុស្សឃាត គឺចេតនាក្នុងការបំផ្លាញក្រុមមួយ។ អំពើប្រល័យពូជសាសន៍ ត្រូវបានកំណត់លក្ខណៈតាមរយៈកត្តានៃចេតនាពិសេស (dolus specialis) ក្នុងការបំផ្លាញក្រុមមួយ។ ប្រសិនបើពុំមានកត្តានោះទេ ទោះបីជាភាពឃោរឃៅមានកម្រិតបែបណាក៏ដោយ ហើយទោះបីជាវាមានលក្ខណៈស្រដៀងគ្នាទៅនឹងអំពើដែលបានរៀបរាប់នៅអនុសញ្ញាយ៉ាងណាក៏ដោយ ក៏អំពើនោះនៅតែមិនអាចហៅថាជាអំពើប្រល័យពូជសាសន៍បានឡើយ...។ វាគួរតែត្រូវបានបញ្ជាក់នៅក្នុងបរិបទនេះថា សំណើ សុំដាក់ជំនួសពាក្យ 'បានប្រព្រឹត្តដោយមានចេតនាបំផ្លាញ' ដោយពាក្យ 'សំដៅបំផ្លិចបំផ្លាញរូបរាងកាយនៃ' ក្រុមមនុស្ស (a/C.6/223) មិនត្រូវបានទទួលយកឡើយ.... តាមទស្សនៈរបស់អ្នកធ្វើរបាយការណ៍ពិសេស ការបំបាត់ចោលនូវធាតុផ្សំនៃចេតនា នឹងលុបចោលនូវភាពខុសគ្នារវាងអំពើប្រល័យពូជសាសន៍ និង

---

[198]សេចក្តីរាយការណ៍របស់ អ្នករាយការណ៍ពិសេស Benjamin Whitaker មានចំណងជើងថា *Review Of Further Developments In Fields With Which The Sub-Commission Has Been Concerned, Revised and Updated Report on the Question of the Prevention and Punishment of the Crime of Genocide Prepared by Mr. Whitaker*, U.N. ESCOR, អនុគណៈកម្មការសិទ្ធិមនុស្សស្តីពីការទប់ស្កាត់ការរើសអើង និងការការពារជនជាតិភាគតិច, សម័យប្រជុំលើកទី៣៨, លេខ 37, ឯកសារ អ.ស.បប E/CN.4/Sub.2/1985/6 (ឆ្នាំ1985)។

[199] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ៣៩។

<u>អំពើមនុស្សឃាតធម្មតានិងផងដែរ... រវាងអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មសង្គ្រាម</u>[200]

## VIII. អ.ទ.ត.ក គ្មានយុត្តាធិការលើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដូចមានចែង ក្នុងដីកាដំណោះស្រាយឡើយ

### ក. ការហាមឃាត់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ តម្រូវឱ្យមានចំណងពាក់ព័ន្ធមួយទៅនឹងជម្លោះប្រដាប់អាវុធ នៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩

៨៦. ត្រង់កថាខណ្ឌ ១៧២ ក.ស.ព អះអាងថាសេចក្ដីសន្និដ្ឋានរបស់មេធាវីការពារក្ដីដែលថាច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ បានតម្រូវឱ្យមានចំណងពាក់ព័ន្ធមួយរវាងអំពើជាមូលដ្ឋានទាំងនោះ និងជម្លោះប្រដាប់អាវុធអន្តរជាតិ គឺធ្វើឡើង "ដោយផ្អែកតាមទស្សនៈភ័ន្តច្រឡំថាមានតែនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិតាមលក្ខន្តិកៈតុលាការ IMT មួយប៉ុណ្ណោះ ដែលត្រូវបានយកមកអនុវត្តនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ"។ នេះជាការលើកឡើងពុំត្រឹមត្រូវនូវទស្សនៈរបស់មេធាវីការពារក្ដី។ ដូចបានគូសបញ្ជាក់ក្នុងបណ្ដឹងឧទ្ធរណ៍ គោលការណ៍តុលាការ Nuremberg ក៏បានឆ្លុះបញ្ចាំងឱ្យឃើញថា និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ បានតម្រូវឱ្យមានចំណងពាក់ព័ន្ធមួយរវាងជម្លោះប្រដាប់អាវុធអន្តរជាតិក្នុងចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩[201]។

៨៧. ត្រង់កថាខណ្ឌ ១៧៦ ក.ស.ព អះអាងថា "នៅមិនទាន់ច្បាស់លាស់ទេថា ទំនាក់ទំនងរវាងជម្លោះប្រដាប់អាវុធ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ធ្លាប់ជាទំនាក់ទំនងចាំបាច់ ក្នុងលក្ខណៈជាបញ្ហា

---

[200]សេចក្ដីរាយការណ៍របស់ អ្នករាយការណ៍ពិសេស Nicodeme Ruhashyankiko, មានចំណងជើងថា *Study of the Question of the Prevention and Punishment of the Crime of Genocide*, U.N. ESCOR, សម័យប្រជុំលើកទី៣១, លេខ 120, ឯកសារ អ.ស.ប E/CN.4/Sub.2/416 (ឆ្នាំ1978), កថាខណ្ឌ 96, 98, 100។

[201] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ១៨៩។ *សូមមើលផងដែរ* គោលការណ៍ច្បាប់អន្តរជាតិដែលបានការទទួលស្គាល់ក្នុងធម្មនុញ្ញតុលាការ Nuremburg និងក្នុងសាលក្រមរបស់តុលាការនេះ, ឯកសារ អ.ស.ប A/1316 (ឆ្នាំ១៩៥0) ("គោលការណ៍ Nuremberg"), គោលការណ៍លេខ VI (គ)។ សេចក្ដីបញ្ជាក់នៃគោលការណ៍របស់ច្បាប់អន្តរជាតិដែលត្រូវបានទទួលស្គាល់ដោយតុលាការ Nuremburg *ត្រូវបានអនុម័តនៅថ្ងៃទី* ១១ ខែធ្នូ ឆ្នាំ១៩៤៦, G.A. Res. 95(1), U.N. G.A.O.R. សម័យប្រជុំលើកទី១, កិច្ចប្រជុំពេញអង្គលើកទី៥៥, ឯកសារ អ.ស.ប A/64/Add.1 (ឆ្នាំ១៩៤៦) ត្រង់ទំព័រ ១៨៨។

មួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ”[202]។ ការសន្និដ្ឋានបែបនេះពុំត្រឹមត្រូវទេ។ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិបានកើតចេញមកពីច្បាប់សង្គ្រាម[203]។ បើគ្មានលក្ខខណ្ឌតម្រូវឱ្យមានចំណងពាក់ព័ន្ធ ដែលបង្កើតបានជាធាតុផ្សំមួយនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ គេពុំទាន់ប្រាកដថាតើគេអាចមានមូលដ្ឋានគតិយុត្តិគ្រប់គ្រាន់ដែរ ឬទេ ក្នុងការកាត់សេចក្តីឧក្រិដ្ឋកម្ម ទាំងអស់នោះភ្លាមៗ ក្រោយសង្គ្រាមលោកលើកទី២[204]។ ការកំណត់លក្ខខណ្ឌតម្រូវឱ្យមានចំណងពាក់ព័ន្ធក្នុងធម្មនុញ្ញតុលាការ IMT ថាជាលក្ខខណ្ឌតម្រូវខាងយុត្តាធិការ ជាជាងជាធាតុផ្សំមួយនៃបទល្មើស គឺជាការយល់ខុសអំពីឫសគល់ឧក្រិដ្ឋកម្ម[205]។

---

202 ចម្លើយតប កថាខណ្ឌ១៧៦។

203 *សូមមើល* ឧទាហរណ៍ សៀវភៅនិពន្ធដោយ M. CHERIF BASSIOUNI មានចំណងជើងថា CRIMES AGAINST HUMANITY IN INTERNATIONAL CRIMINAL LAW 77 (បោះពុម្ពដោយ Kluwer ឆ្នាំ១៩៩៩) (“BASSIOUNI”)៖ “សេចក្តីសន្និដ្ឋានមានភាពច្បាស់លាស់គឺថា “ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ” គឺស្រដៀងនឹងឧក្រិដ្ឋកម្មសង្គ្រាម និងជាមែកធាងនៃឧក្រិដ្ឋកម្មសង្គ្រាម ហើយឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិមានមូលដ្ឋានឈរលើគតិយុត្តិ និងសីលធម៌តែមួយដូចគ្នា ដែលបានមានអត្ថិភាពជាយូរលង់មកហើយ និងជាឫសគល់នៃគោលការណ៍, និយាម, និងវិធាននៃការកំណត់ភាពជាមនុស្ស និងបញ្ញត្តិស្តីពីជម្លោះប្រដាប់អាវុធ” *សូមមើលផងដែរ* សៀវភៅនិពន្ធដោយ Egon Schwelb មានចំណងជើងថា *Crimes Against Humanity* 23 B. Y.B. INT’L L. 178, 206 (ឆ្នាំ១៩៤៦) (“Schwelb”)៖ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដូចគេបានបកស្រាយក្នុងសាលក្រមតុលាការ IMT គឺជាឧក្រិដ្ឋកម្ម “អម” ឬ “បន្ទាប់បន្សំ” លើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឬការរំលោភច្បាប់ និងទំនៀមទម្លាប់សង្គ្រាម”។

204 *សូមមើល* សៀវភៅនិពន្ធដោយ BASSIOUNI នៅត្រង់២៥៥-៥៦:ឧក្រិដ្ឋកម្មអន្តរជាតិខុសពីឧក្រិដ្ឋកម្មជាតិ ដោយសារអត្ថិភាពនៃធាតុផ្សំគតិយុត្តិអន្តរជាតិបន្ថែមនៃឧក្រិដ្ឋកម្មទាំងនោះ។ ធាតុផ្សំមួយនៃធាតុផ្សំអន្តរជាតិដែលមានចែងក្នុងនិយមន័យនៃ “ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ” នៃធម្មនុញ្ញតុលាការ Nuremberg គឺការជាប់ពាក់ព័ន្ធនឹងសង្គ្រាម។ *សូមមើលផងដែរ* ទំព័រ២៦៥៖ “ធាតុផ្សំពាក់ព័ន្ធនឹងសង្គ្រាមនេះ” ជាធាតុផ្សំចាំបាច់ដើម្បីភ្ជាប់ “ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ” ទៅនឹងអនុសញ្ញា និងច្បាប់ទំនៀមទម្លាប់អន្តរជាតិនានាពីមុន ដែលបានហាមឃាត់ទង្វើនេះក្នុងពេលសង្គ្រាម។

205 *សូមមើល* សៀវភៅនិពន្ធដោយ Schwelb នៅត្រង់ទំព័រ ២០៦។ “[ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ] គឺជាផ្លែផ្កានៃសង្គ្រាម ដែលគេអាចយកមកអនុវត្តបានក្នុងពេលសង្គ្រាម ឬពាក់ព័ន្ធនឹងសង្គ្រាម និងមានទិសដៅជាចម្បងដើម្បីការពារប្រជាជនរដ្ឋបរទេសឱ្យជៀសផុតពីឧក្រិដ្ឋកម្មដែលគេបានប្រព្រឹត្តពាក់ព័ន្ធនឹងសង្គ្រាមឈ្លានពានពីសំណាក់រដ្ឋអំណាច និងស្ថាប័នរដ្ឋឈ្លានពាន”។ ចំពោះគោលជំហររបស់ ក.ស.ព *សូមមើល* ចម្លើយតប កថាខណ្ឌ ១៨១ *ទាញហេតុសំអាង រឿងក្តី តទល់នឹង Tadić*, IT-94-I-T សាលដីកាលើញត្តិរបស់មេធាវីការពារក្តី ស្តីពីយុត្តាធិការ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៥ កថាខណ្ឌ ៧៨។ សាលដីកាលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ខំក្នុងរឿងក្តី*Tadić* កថាខណ្ឌ១៤០។

៨៨. ត្រង់កថាខណ្ឌ១៨០ ក.ស.ព អះអាងថា "ការដែលថាអនុសញ្ញាអន្តរជាតិចំនួន២ [អនុសញ្ញាស្ដីពីអំពើប្រល័យពូជសាសន៍ និងអនុសញ្ញាស្ដីពីការប្រកាន់រើសអើងពូជសាសន៍ Apatheid ដែលបានអនុម័តនៅមុនឆ្នាំ១៩៧៥ ដែលបានកំណត់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដោយគ្មានចំណងពាក់ព័ន្ធទៅនឹងជម្លោះប្រដាប់អាវុធ គឺជាសញ្ញាបញ្ជាក់យ៉ាងច្បាស់ថានេះគឺជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងអំឡុងរយៈកាលពីចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩"។ ពីទសវត្សរ៍ឆ្នាំ១៩៥០ ដល់ឆ្នាំ១៩៧៩ មានភស្តុតាងតិចតួចស្ដួចស្ដើងណាស់ដែលបញ្ជាក់អំពីទម្លាប់អនុវត្តទូទៅរបស់រដ្ឋ និង *ទស្សនៈច្បាប់* ដែលថាចំណងពាក់ព័ន្ធនេះ លែងជាធាតុផ្សំមួយចាំបាច់នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិទៀតហើយ[206]។ ក្នុងអនុសញ្ញាប្រល័យពូជសាសន៍[207] អវត្តមានលក្ខខណ្ឌតម្រូវឱ្យមានចំណងពាក់ព័ន្ធពុំមានសារសំខាន់ឡើយ។ ត្រង់កថាខណ្ឌ១៨០ ក.ស.ព អះអាងថា "ការដែលថាអនុសញ្ញាអន្តរជាតិចំនួន២ [អនុសញ្ញាស្ដីពីអំពើប្រល័យពូជសាសន៍ និងអនុសញ្ញាស្ដីពីការប្រកាន់រើសអើងពូជសាសន៍ Apatheid ដែលបានអនុម័តនៅមុនឆ្នាំ១៩៧៥ ដែលបានកំណត់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដោយគ្មានចំណងពាក់ព័ន្ធទៅនឹងជម្លោះប្រដាប់អាវុធ គឺជាសញ្ញាបញ្ជាក់ច្បាស់ថានេះគឺជាច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងអំឡុងរយៈកាលពីចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩"។ តាមទិដ្ឋភាពច្បាប់ អំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិមិនដូចគ្នាទេ។ ទីមួយ ឧក្រិដ្ឋកម្មនីមួយៗមាន *ចេតនាឧក្រិដ្ឋ* ខុសៗគ្នា។ ទីពីរ ក្នុងបណ្ដាបទល្មើសប្រល័យពូជសាសន៍ជាមូលដ្ឋានត្រូវមានបទល្មើសមួយដែលអាចកើតឡើង ឬបទល្មើសតូចតាច ដែលរួមចំណែកដល់ការបំផ្លិចបំផ្លាញទាំងស្រុង ឬមួយផ្នែកនៃក្រុមជនរងគ្រោះ។ ទីបី និយមន័យនៃអំពើប្រល័យពូជសាសន៍ពុំតម្រូវ ថាអំពើរបស់ជនជាប់ចោទត្រូវតែបានកើតឡើងក្នុងក្របខ័ណ្ឌនៃ "ការវាយប្រហារជាទូទៅ ឬជាប្រព័ន្ធមកលើប្រជាជនស៊ីវិល"[208] ឡើយ។ អនុសញ្ញា

[206] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ១៨៩។

[207] សេចក្ដីសម្រេចរបស់អង្គមហាសន្និបាតអង្គការសហប្រជាជាតិលេខ 260(III) (ថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៤៨)។

[208] សេចក្ដីព្រាងក្រមស្ដីពីបទល្មើសប្រឆាំងនឹងសន្តិភាព និងសន្តិសុខរបស់មនុស្សជាតិ របាយការណ៍របស់ J. Spiropoulos, ចៅក្រមរបាយការណ៍, ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៥០ ("សេចក្ដីព្រាងច្បាប់ស្ដីពីបទល្មើស") *មានទៅក្នុង* 2 Y.B. INT'L COMM'N ទំព័រ២៥៣, ២៥៥, កថាខណ្ឌ២ (ឆ្នាំ១៩៥០) បានកត់សម្គាល់ឃើញថាអវត្តមាននៃលក្ខខណ្ឌតម្រូវឱ្យមានចំណងពាក់ព័ន្ធ ដោយអនុសញ្ញាប្រល័យពូជសាសន៍ ត្រូវបានចាត់ទុកថាជាលក្ខណៈមួយខុសប្លែកនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ *សូមមើល* សេចក្ដីព្រាងច្បាប់ ស្ដីពីបទល្មើស ត្រង់ទំព័រ២៦៣, កថាខណ្ឌ៦៥។ *សូមមើលផងដែរ* Ford, ត្រង់ទំព័រ១៥២-៥៣។

អន្តរជាតិស្តីពីការបង្រ្កាប និងការផ្តន្ទាទោសប្រកាន់រើសអើងពូជសាសន៍ Apatheid ("អនុសញ្ញាស្តីពីការប្រកាន់រើសអើងពូជសាសន៍ Apatheid") ពុំគាំទ្រអំណះអំណាងដែលថាចំណងពាក់ព័ន្ធលែងជាលក្ខខណ្ឌតម្រូវទៀតហើយ នៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ នៅពេលអនុសញ្ញាស្តីពីការប្រកាន់រើសអើងពូជសាសន៍ Apatheid បានចូលជាធរមាននៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ១៩៧៦ គ្មានប្រទេសលោកខាងលិចណាមួយបានចុះហត្ថលេខាលើអនុសញ្ញានេះឡើយ។ ជាការពិតមួយ បណ្តាប្រទេសធំៗមួយចំនួននៅលោកខាងលិចដូចជា សហរដ្ឋអាមេរិក, ចក្រភពអង់គ្លេស, បារាំង, កាណាដា, អូស្ត្រាលី, អ៊ីតាលី, និងអេស្ប៉ាញជាដើម ពុំធ្លាប់ជាសមាជិកហត្ថលេខីលើអនុសញ្ញាអាផាថេតឡើយ[209]។ គេពុំអាចនិយាយថានិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្នុងអនុសញ្ញា Apatheid ឆ្លុះបញ្ចាំងអំពីច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ឡើយ។

៨៩. ត្រង់កថាខណ្ឌ១៨២ ក.ស.ព អះអាងថា "ដូចដែលអង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ក្នុងសំណុំរឿង ០០១ "ករណី ឌុច" ការពិនិត្យមើលទម្លាប់អនុវត្តរបស់រដ្ឋ និង *ទស្សនៈច្បាប់* ក្នុងអំឡុងពេលប៉ុន្មានឆ្នាំក្រោយពេលមានធម្មនុញ្ញតុលាការយោធាអន្តរជាតិ IMT បង្ហាញថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិបានមានអត្ថិភាព ក្នុងលក្ខណៈជាទស្សនទានមួយខុសប្លែកពីជម្លោះប្រដាប់អាវុធក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ"។ ការសន្និដ្ឋានបែបនេះពុំមានភាពគួរឱ្យជឿជាក់បានឡើយ។ ទោះបីគេបានដកលក្ខខណ្ឌតម្រូវឱ្យមានជម្លោះប្រដាប់អាវុធចេញពីមាត្រាII នៃច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ១០ មែនក៏ប៉ុន្តែតុលាការអាល្លឺម៉ង់ និងសម្ព័ន្ធមិត្តដែលយកច្បាប់នេះមកអនុវត្តគឺជា "តុលាការក្នុងស្រុក ដែល

[209] នៅពេលអនុសញ្ញាចូលជាធរមាន នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ១៩៧៦ គឺមានរដ្ឋភាគីលើសពី៣០៖ ប្រទេសអាល់ហ្សេរី, អាហ្វហ្កានីស្ថាន, បេឡារុស, បេណាំង, ប៊ុលហ្គារី, បួគីណាហ្វាសូ, ឆាដ, អេក្វាទ័រ, ហ្គីណេ, ហុងគ្រី, អ៊ីរ៉ាក់, ហ្សាម៉ាអ៊ីក, ហ្សកដានី, កេនយ៉ា, ម៉ុងហ្គោលី, នីហ្សេរីយ៉ា, អូម៉ង់, ប៉ាណាម៉ា, ហ្វីលីពីន, ប៉ូឡូញ, កាតា, រូម៉ានី, សហភាពសូវៀត, រវ៉ាន់ដា, សូម៉ាលី, ស៊ូដង់, ស៊ីរី, ទ្រីនីដាដ និងតូបាហ្គោ, អ៊ុយហ្គាន់ដា, អ៊ុយក្រែន, អេមីរ៉ាតអារ៉ាប់រួម។ មកដល់ថ្ងៃទី១ ខែមករា ឆ្នាំ១៩៨០ អនុសញ្ញានេះមានប្រទេសសមាជិកចំនួន២៧ថែមទៀតដូចជា៖ ប្រទេសបាបាដុស, ប៊ូរុនឌី, កាមេរូន, កាប់វែរ, សាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ, អេហ្ស៊ីប, អែលសាល់វ៉ាឌ័រ, អេត្យូពី, ហ្គំប៊ី, ហ្គាណា, ហ្គីយ៉ាន, ហៃទី, ឥណ្ឌា, គូវ៉ែត, លីបេរីយ៉ា, លីប៊ី, ម៉ាដាហ្គាស្កា, ម៉ាលី, ណេប៉ាល់, នីហ្សេ, ប៉េរូ, សៅតូម៉េ និងប្រាំងស៊ីប, សេណេហ្គាល់, ស៊ីស្ហែល, ទុយនីស៊ី, និងតង់សានី បញ្ជីរាយនាមភាគីជាន់គ្នាជាមួយនឹងបញ្ជីភាគីហត្ថលេខីអនុសញ្ញាស្តីពីអាជ្ញាយុកាលឆ្នាំ១៩៦៨។ *សូមមើល* Ford, ត្រង់ទំព័រលេខ២៣២។

អនុវត្តជាចម្បងនូវច្បាប់ (ក្រុង) ក្នុងស្រុក”[210] ប៉ុណ្ណោះ ហើយ “ភ្លាមៗក្រោយសង្គ្រាមលោកលើកទី២ និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិរបស់តុលាការ IMT ត្រូវបានគេចាត់ទុកថាជាការពន្យល់ដ៏សមស្របបំផុតអំពីច្បាប់អន្តរជាតិ រួមទាំងលក្ខខណ្ឌតម្រូវឱ្យមានចំណងពាក់ព័ន្ធជាមួយជម្លោះប្រដាប់អាវុធផង”[211]។ គោលការណ៍តុលាការ Nuremberg ឆ្លុះបញ្ចាំងនូវការយល់ដឹងចំណុចទាំងអស់នេះ[212]។

៩០. ត្រង់កថាខណ្ឌ ១៨៣ ក.ស.ព អះអាងថា “ភស្តុតាងផ្សេងៗទៀតស្តីពីទម្លាប់អនុវត្តរបស់រដ្ឋ ព្រមទាំង *ទស្សនៈនៃច្បាប់* កាន់តែពុំស្របមួយកម្រិតទៀតទៅនឹងអំណះអំណាងរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ដែលថា និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិរបស់ធម្មនុញ្ញតុលាការ IMT មានចែងក្នុងច្បាប់ទំនៀម ទម្លាប់អន្តរជាតិនៅចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩”។ ដើម្បីជាការគាំទ្រអំណះអំណាងនេះដំបូង ក.ស.ព បានលើកយកសេចក្តីព្រាងក្រម ស្តីពីបទល្មើសប្រឆាំងនឹងសន្តិភាព និងសន្តិសុខមនុស្សជាតិរបស់គណៈកម្មាធិការច្បាប់អន្តរជាតិ ILC ឆ្នាំ១៩៥៤ មកធ្វើជាសំអាង។ ជាការសំខាន់ដែលត្រូវបញ្ជាក់ថា គណៈកម្មាធិការច្បាប់អន្តរជាតិមានមុខងារចំនួន២ គឺ ក. ការងារប្រមូលចងក្រងច្បាប់

---

[210] សៀវភៅនិពន្ធដោយ Schwelb, ត្រង់ទំព័រ ២១៨-១៩។

[211] *សូមមើល* សៀវភៅនិពន្ធដោយ Stuart Ford មានចំណងជើងថា *Crimes Against Humanity at The Extraordinary Chambers in the Courts of Cambodia: Is a Connection with Armed Conflict Required?*, 24 UCLA PAC. BASIN L.J. ទំព័រ ១២៥, ១៤៨, ១៥១ (ឆ្នាំ ២០០៦-២០០៧) (“សៀវភៅនិពន្ធដោយ Ford”), *ទាញសំអាងហេតុ* សេចក្តីសង្ខេបនៃកិច្ចប្រជុំ លើកទី៤៨ របស់ ILC, ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៥០, ទំព័រ៣៦៤, ៣៧៧ *មាននៅ* http://untreaty.un.org/ilc/documentation/english/a_cn4_sr48.pdf ។ នៅឆ្នាំ១៩៥០ គណៈកម្មការច្បាប់អន្តរជាតិ (“ILC”) បានសម្រេចតម្កល់លក្ខខណ្ឌតម្រូវឱ្យមានចំណងពាក់ព័ន្ធនៅក្នុងនិយមន័យឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងលុបជើងទំព័ររបស់ចៅក្រមរបាយការណ៍ ដែលនេះបង្ហាញថាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិអាចពុំចាំបាច់តម្រូវឱ្យមានចំណងពាក់ព័ន្ធណាមួយឡើយ។ ការពិភាក្សាដេញដោលរវាងសមាជិកតុលាការ ILC និងរដ្ឋសមាជិកអង្គការសហប្រជាជាតិស្តីពីគោលការណ៍ Nuremberg បង្ហាញថាគេបានទទួលស្គាល់ជាទូទៅថាទំនាក់ទំនងជាមួយសង្គ្រាម គឺជាធាតុផ្សំចាំបាច់មួយនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្នុងទសវត្សរ៍ឆ្នាំ១៩៥០។ “និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្នុងគោលការណ៍ Nuremberg ហាក់ដូចជាបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវអំពីស្ថានភាពច្បាប់ទំនៀមទម្លាប់កាលពីឆ្នាំ១៩៥១ និងរយៈពេលក្រោយមកទៀត”។

[212] គោលការណ៍ Nuremberg, គោលការណ៍ទី VI(គ)។

អន្តរជាតិដែលមានស្រាប់ និង **ខ.** ការអភិវឌ្ឍជាបន្តបន្ទាប់នៃច្បាប់អន្តរជាតិ[213]។ ការធ្វើសេចក្តីព្រាងក្រមថ្មីស្តីពីបទល្មើសនេះ គឺជាគំរូមួយនៃការចូលរួមចំណែករបស់គណៈកម្មាធិការ ILC ដល់*ការបង្កើតច្បាប់អន្តរជាតិជាបន្តបន្ទាប់*[214]។ *ឯកសារការងារត្រៀមរៀបចំ* (travaux preparotires) នៃសេចក្តីព្រាងក្រមឆ្នាំ១៩៥៤ បង្ហាញថាភាគីទាំងសងខាង នៅក្នុងការជជែកដេញដោលថា តើត្រូវរក្សាទុកចំណងពាក់ព័ន្ធជាមួយជម្លោះប្រដាប់អាវុធ ក្នុងនិយមន័យឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ បានទទួលស្គាល់ថានិយមន័យចុងក្រោយដែលបានដាក់ជូនអង្គមហាសន្និបាតក្នុងរបាយការណ៍ របស់គណៈកម្មាធិការ ILC ឆ្នាំ១៩៥៤ គឺ "មានន័យទូលំទូលាយខ្លាំងជាងនិយមន័យក្នុងច្បាប់អន្តរជាតិ ដែលមានស្រាប់"[215]។ ក.ស.ព ក៏បានលើកយកអវត្តមាននៃ លក្ខខណ្ឌតម្រូវឱ្យមានចំណងពាក់ព័ន្ធពីអនុសញ្ញាឆ្នាំ១៩៦៨ ស្តីពីការពុំអាចយកមកអនុវត្តបាននូវយុត្តាធិការលើឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ មកធ្វើជាភស្តុតាងបញ្ជាក់បន្ថែមថាអំណះអំណាងរបស់ មេធាវីការពារក្តី មានការខុសឆ្គងត្រង់ចំណុចដែលថានិយមន័យរបស់ធម្មនុញ្ញតុលាការ IMT មានចែងក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ ជាមូលដ្ឋាន អនុសញ្ញានេះ **ក.** គឺជាឯកសារនយោបាយមួយ ដែលទទួលបានការគាំទ្រតិចជាងពាក់កណ្តាលពីសំណាក់បណ្តារដ្ឋ ដែលជាសមាជិកអង្គការសហប្រជាជាតិ"[216] **ខ.** ធ្វើឱ្យមនុស្សទូទៅយល់ថាចាំបាច់ត្រូវមានចំណងពាក់ព័ន្ធទៅនឹងជម្លោះប្រដាប់អាវុធ លើកលែងតែក្នុងករណីដែលឧក្រិដ្ឋកម្មមួយចំនួនដូចជា ឧក្រិដ្ឋកម្មប្រកាន់រើសអើងពូជសាសន៍ Apatheid, ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ បានកើតឡើងដោយពុំពាក់ព័ន្ធទៅនឹងជម្លោះ

---

[213] *សូមមើល* លក្ខន្តិកៈគណៈកម្មការច្បាប់អន្តរជាតិ, មាត្រា១៥។

[214] *សូមមើល* សេចក្តីព្រាងច្បាប់ស្តីពីបទល្មើស, ត្រង់ទំព័រ ២៥៥ កថាខណ្ឌ ២, ដែលបានកត់សម្គាល់ថាចៅក្រមរបាយការណ៍ពុំបានចងក្រងច្បាប់អន្តរជាតិដែលមានស្រាប់ ប៉ុន្តែបែរជាធ្វើកិច្ចការដែលមាន "លក្ខណៈច្បាស់លាស់" ទៅវិញ។ *សូមមើលផងដែរ* ទំព័រ ២៥៧, កថាខណ្ឌ ២០, ដែលបានកត់សម្គាល់ថាតុលាការ ILC បានពិភាក្សាអំពីបញ្ហានេះ និងបានសន្និដ្ឋានថាសេចក្តីព្រាងក្រមស្តីពីបទល្មើសគឺតំណាងឱ្យ "ដំណើរវិវឌ្ឍន៍ជាហូរហែរនៃច្បាប់អន្តរជាតិ"។ *សូមមើលផងដែរ* សៀវភៅនិពន្ធដោយ Ford, ត្រង់ទំព័រ ១៥៣។

[215] សៀវភៅនិពន្ធដោយ Ford, ត្រង់ទំព័រ១៥៨។ ជាការពិត អ្នកគាំទ្រនិយមន័យនេះបានចាត់ទុកការនេះថាជា "ការបោះជំហានធំមួយក្នុងដំណើរវិវឌ្ឍន៍នៃច្បាប់អន្តរជាតិ"។ *សូមមើល* កំណត់ហេតុសង្ខេបស្តីពីកិច្ចប្រជុំលើកទី២៦៩ *ដែលមាននៅលើគេហទំព័រ* http://untreaty.un.org/ilc/documentation/english/a_cn4_sr269.pdf ទំព័រ ១៤០-៤៦, កថាខណ្ឌ ៤០។ អ្នកជំទាស់បានចាត់ទុកវាថាជា "ដំណើរវិវឌ្ឍន៍លឿនជ្រុលក្នុងស្ថានភាពបច្ចុប្បន្ននៃច្បាប់អន្តរជាតិ"។ *ដូចដើងទំព័រខាងលើ* កថាខណ្ឌ ៤២។

[216] *ដូចដើងទំព័រខាងលើ* នៅត្រង់១៦១-៦២។

ប្រដាប់អាវុធ[217] និង គ. បង្ហាញថាពុំមានទម្លាប់អនុវត្តទូទៅរបស់រដ្ឋណាមួយបានមានអត្ថិភាពកាលពីពេលនោះឡើយ[218]។ អំណះអំណាងខាងលើរបស់ ក.ស.ព ពុំមែនជាភស្តុតាងរឹងមាំដើម្បីបញ្ជាក់ថានៅឆ្នាំ ១៩៦៨ មានលក្ខខណ្ឌតម្រូវឱ្យមានចំណងពាក់ព័ន្ធឡើយ។ ក.ស.ព ក៏បានលើកយក "ច្បាប់ក្នុងស្រុកដូចជាលក្ខន្តិកៈនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិរបស់អ៊ីស្រាអែលឆ្នាំ១៩៥០"[219] មកធ្វើជាភស្តុតាងបញ្ជាក់ថា "ការអះអាងថានិយមន័យតាមធម្មនុញ្ញតុលាការ IMT ... មានចែងក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩" គឺជាការខុសឆ្គង[220]។ គេពុំអាចចាត់ទុកសេចក្តីសម្រេចថ្នាក់ជាតិ ថាជាសេចក្តីប្រកាសនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិបានឡើយ ក្នុងពេលឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្ត។ ក្នុងករណីមានការប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅចន្លោះឆ្នាំ១៩៣៩ ដល់ឆ្នាំ១៩៤៥ មានតែនិយមន័យឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្នុងធម្មនុញ្ញតុលាការ IMT និងក្នុងសាលក្រមរបស់តុលាការនេះមួយប៉ុណ្ណោះ ដែលមានអាជ្ញាព្រឹត្តិ[221]។

៩១. ត្រង់កថាខណ្ឌ ១៨៥ ក.ស.ព "សន្និដ្ឋានថាទម្លាប់អនុវត្តទៀងទាត់របស់តុលាការអន្តរ ជាតិទាមទារឱ្យអង្គបុរេជំនុំជម្រះគោរពតាមយុត្តិសាស្ត្រពីមុនរបស់ អ.វ.ត.ក ពាក់ព័ន្ធនឹងបញ្ហាអង្គច្បាប់ ដូចបញ្ហាដែលយើងកំពុងប្រឈម" ហើយ អង្គបុរេជំនុំជម្រះគួរអនុវត្តតាម សេចក្តីសម្រេចក្នុងសំណុំរឿង *ឌុច* ដែលថា "នៅមុនឆ្នាំ១៩៧៥ សញ្ញាណនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ បានមានអត្ថិភាពដាច់ដោយឡែកពីជម្លោះប្រដាប់អាវុធ"[222]។ ក.ស.ព អះអាងដោយភ្លាំភ្លងថា ការដែលថា "មេធាវីការពារក្តីក្នុងសំណុំរឿង *ឌុច* ពុំបានជំទាស់ទៅនឹងវិសាលភាពនៃយុត្តាធិការ អ.វ.ត.ក លើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ គឺពុំពាក់ព័ន្ធទៅនឹងបញ្ហា ថាតើអង្គបុរេជំនុំជម្រះគួរអនុវត្តតាមសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីបញ្ហានេះដែរ ឬទេឡើយ"[223]។ ដូចដែលអង្គបុរេជំនុំជម្រះបានកត់សម្គាល់

---

[217] *ដូចជើងទំព័រខាងលើ* លេខ១៦០។

[218] *ដូចជើងទំព័រខាងលើ* លេខ១៦៧-៨៣។

[219] គួរកត់សម្គាល់ថាចំណងជើងពិតនៃច្បាប់នេះគឺ "ច្បាប់ (ផ្តន្ទាទោស) ពួកណាស៊ី និងអ្នកចូលដៃជាមួយពួកណាស៊ីឆ្នាំ១៩៥០"។

[220] ចម្លើយតប កថាខណ្ឌ១៨៣។

[221] *សូមមើល* សៀវភៅនិពន្ធដោយ Ford នៅត្រង់១៤៨។

[222] ចម្លើយតប កថាខណ្ឌ១៨៤។

[223] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ១៨៥។

"ក្នុងករណីមានកិច្ចដំណើរការនីតិវិធីមួយចំនួនកំពុងរង់ចាំដំណោះស្រាយ វាជាទម្លាប់របស់តុលាការ ដែលថាការសម្រេចលើអង្គច្បាប់នៅក្នុងរឿងក្ដីមួយ នឹងជួយបង្ហាញផ្លូវដល់តុលាការដើម្បីសម្រេច រឿងក្ដីក្រោយៗ ដែលស្រដៀងគ្នាទៅនឹងរឿងក្ដីមុន ក្នុងករណីពុំមានការលើកឡើងនូវអំណះអំណាង ឬ កាលៈទេសៈថ្មីណាមួយ"[224]។ បណ្ដឹងឧទ្ធរណ៍នោះលើកឡើងនូវទឡ្ហីករណ៍ថ្មីៗ ស្ដីពីបញ្ហាទាំងប៉ុន្មាន ដែលពុំទាន់ត្រូវបានលើកឡើងក្នុងសំណុំរឿង *ឌុច* ហើយដែលជាបញ្ហាសក្ដិសមនឹងឲ្យតុលាការយកទៅ ពិនិត្យពិចារណា។ លើសពីនេះ ក្នុងឋានៈជាតុលាការកម្ពុជាដែលដំណើរការក្នុងប្រព័ន្ធច្បាប់ស៊ីវិល អង្គ បុរេជំនុំជម្រះពុំជាប់ចំណងកាតព្វកិច្ចតាម *គោលការណ៍ប្រកាន់តាមសេចក្ដីសម្រេចកន្លងមក* (*stare decicis)* ឡើយ។ អង្គបុរេជំនុំជម្រះមានសិទ្ធិពេញលេញក្នុងការយកបញ្ហានេះមកពិចារណាម្ដងទៀត ទោះបីអង្គជំនុំជម្រះសាលាដំបូងក្នុងករណី *ឌុច* ធ្លាប់បានសម្រេចរួចម្ដងហើយក្ដី។

៩២. ត្រង់កថាខណ្ឌ ១៨៦ ក.ស.ព អះអាងថា "បញ្ហាថាតើមានទំនាក់ទំនងផ្ទាល់រវាងអំពើជាមូលដ្ឋាន និង ជម្លោះប្រដាប់អាវុធអន្តរជាតិជាមួយប្រទេសរៀតណាម ឬទេ គឺពុំមែនជាបញ្ហាពាក់ព័ន្ធឡើយ"។ សាលក្រមតុលាការ IMT មានលក្ខណៈច្បាស់លាស់៖ "ដើម្បីបង្កើតបានជាឧក្រិដ្ឋកម្មប្រ ឆាំងនឹង មនុស្សជាតិ អំពើទាំងប៉ុន្មាន ដែលគេបានលើកយកមកជាសំអាងនៅមុនពេលមានសង្គ្រាម ត្រូវ តែជាការអនុវត្ត ឬពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មណាមួយក្រោមយុត្តាធិការតុលាការ"[225]។ ឯកសារសំអាងផ្លូវ ច្បាប់របស់តុលាការ ICTY ដែល ក.ស.ព បានលើកយកមកសំអាងគឺពុំមែនជាឯកសារពាក់ព័ន្ធឡើយ។ ក.ស.ព បានចាត់ទុកលក្ខខណ្ឌតម្រូវឲ្យមានជម្លោះប្រដាប់អាវុធ ក្នុងមាត្រា៥ នៃលក្ខន្តិកៈតុលាការ ICTY ថាជាលក្ខខណ្ឌតម្រូវផ្នែកយុត្តាធិការ ពោលគឺពុំមែនជាធាតុផ្សំណាមួយនៃបទល្មើសដូចមានចែង ក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិឡើយ។

---

[224] *រឿងក្ដី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ០០១/១៨-០៧-២០០៧-អវតក/កសចស (អ.ប.ជ០២) សេចក្ដីសម្រេចលើសំណើរបស់លោក អៀង សារី សុំដាក់អំណះអំណាងស្ដីពីការអនុវត្តន៍ទ្រឹស្ដីសហកម្មឧក្រិដ្ឋកម្មរួម នៅក្នុងបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ជំទាស់ទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើករណីរបស់ កាំង ហ្គេកអ៊ាវ ហៅ "ឌុច" ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨ ឯកសារD99/3/19 ERN: 00226067-00226070 កថាខណ្ឌ១៤។

[225] សាលក្រមតុលាការ IMT *មាននៅលើគេហទំព័រ* http://avalon.law.yale.edu/imt/judlawre.asp (គូសបញ្ជាក់ បន្ថែម)។

៩៣. ត្រង់កថាខណ្ឌ១៨៦ ក.ស.ព អះអាងថា "អង្គហេតុនៃសំណុំរឿង" នឹងបំពេញតាមលក្ខខណ្ឌតម្រូវនៃ "ទំនាក់ទំនងរវាងអំពើជាមូលដ្ឋាន និងជម្លោះប្រដាប់អាវុធ"។ នេះជាបញ្ហាអង្គហេតុសុទ្ធសាធ និងពុំស្ថិតក្នុងវិសាលភាពនៃបណ្តឹងឧទ្ធរណ៍ឡើយ[226]។ មេធាវីការពារក្តីសូមរក្សាសិទ្ធិក្នុងការធ្វើសេចក្តីសន្និដ្ឋានលើបញ្ហានេះ នៅពេលចាំបាច់។

**ខ. ការហាមឃាត់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិពុំរាប់បញ្ចូលការចាប់ដាក់មន្ទីរឃុំឃាំង, ការធ្វើទារុណកម្ម, អំពើរំលោភសេពសន្ថវៈ, ឬអំពើអមនុស្សធម៌ដទៃទៀត នៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ឡើយ**

៩៤. ត្រង់កថាខណ្ឌ១៨៧ ក.ស.ព អះអាងថា "ការចាប់ដាក់មន្ទីរឃុំឃាំង, ការធ្វើទារុណកម្ម, ការរំលោភសេពសន្ថវៈ និងអំពើមនុស្សធម៌ដទៃទៀតរួមមាន ការរៀបការដោយបង្ខំ ការជម្លៀសដោយបង្ខំ អំពើហិង្សាផ្លូវភេទ និងការបាត់ខ្លួនដោយបង្ខំ គឺជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងក្រម ព្រហ្មទណ្ឌឆ្នាំ១៩៥៦ អំឡុងពេលពាក់ព័ន្ធ"។ ប៉ុន្តែ ទាំង ក.ស.ព (និង ក.ស.ច.ស ក្នុងដីកាដំណោះស្រាយ) សុទ្ធតែពុំបានធ្វើការយោងណាមួយទៅលើក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ដើម្បីគាំទ្រអំណះអំណាងដែលថា ការរៀបការដោយបង្ខំ, ការជម្លៀសដោយបង្ខំ, និងការបាត់ខ្លួនដោយបង្ខំ គឺជាឧក្រិដ្ឋកម្ម ឡើយ។ ដូច្នេះ ត្រង់ប្រការនេះ តុលាការពុំអាចផ្តល់ទម្ងន់ដល់ការសន្និដ្ឋានរបស់ ក.ស.ព បានឡើយ។

៩៥. ត្រង់កថាខណ្ឌ ១៨៨ ក.ស.ព លើកឡើងនូវអ្វីដែលខ្លួនយល់ថាជាមូលដ្ឋាននៃច្បាប់ទំនៀមទម្លាប់អន្តរជាតិចំពោះការចាប់ដាក់មន្ទីរឃុំឃាំង ក្នុងលក្ខណៈជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និង*ធាតុផ្សំសត្យានុម័ត* នៃឧក្រិដ្ឋកម្មនេះ។ ការចាប់ដាក់មន្ទីរឃុំឃាំងពុំមែនជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ*ដែលគេបានរៀបរាប់* នៅចន្លោះឆ្នាំ១៩៧៥ ដល់១៩៧៩ ឡើយ ហើយការចាប់ដាក់មន្ទីរឃុំឃាំងអាចត្រឹមតែជាអំពើរំលោភលើមាត្រា៥នៃច្បាប់ អ.វ.ត.ក ប៉ុណ្ណោះ ប្រសិនបើ៖ ក. ប្រភេទ "អំពើអមនុស្សធម៌ដទៃទៀត" អាចយកមកអនុវត្តបាន និង ខ. ការចាប់ដាក់មន្ទីរឃុំឃាំងបង្កើតបានជាប្រភេទ "អំពើ

[226] ចម្លើយតប កថាខណ្ឌ ១៨៦។

អមនុស្សធម៌ដទៃទៀត” នៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩[227]។

៩៦. ត្រង់កថាខណ្ឌ១៨៩ *ក្នុងចំណោមប្រការផ្សេងៗ* ក.ស.ព លើកឡើងនូវអ្វីដែលខ្លួនយល់ថាជាមូលដ្ឋាននៃច្បាប់ ទំនៀមទម្លាប់អន្តរជាតិចំពោះការធ្វើទារុណកម្ម ក្នុងលក្ខណៈជាបទល្មើសជាមូលដ្ឋានមួយ ដែលបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងប្រភព នៃនិយមន័យរបស់ឧក្រិដ្ឋកម្មនេះតាមការសន្និត។ អំពើទារុណកម្មពុំមែនជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ *ដែលគេបានរៀបរាប់* នៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ឡើយ ហើយអំពើទារុណកម្មអាចត្រឹមតែរំលោភមាត្រា៥ នៃច្បាប់ អ.វ.ត.ក មួយប៉ុណ្ណោះ ប្រសិនបើ៖ ក. ប្រភេទ “អំពើអមនុស្សធម៌ដទៃទៀត” អាចយកមកអនុវត្តបាន និង **ខ.** ការធ្វើទារុណកម្មបង្កើតបានជា “អមនុស្សធម៌ដទៃទៀត” នៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩[228]។

៩៧. ត្រង់កថាខណ្ឌ ១៨៩ ក.ស.ព កត់សម្គាល់ឃើញថានិយមន័យនៃអំពើទារុណកម្មក្នុងសេចក្តីប្រកាសរបស់អង្គមហាសន្និបាតស្តីពីអំពើទារុណកម្ម (“ការប្រកាសស្តីពីអំពើទារុណកម្ម”) “ឆ្លុះបញ្ចាំងស្រដៀងគ្នា” នូវនិយមន័យក្នុង CAT។ សេចក្តីប្រកាសស្តីពីអំពើទារុណកម្ម ពុំមែនជាសេចក្តីប្រកាសនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ឡើយ[229] ហើយនៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ CAT ពុំមានអត្ថិភាពឡើយ[230]។ ការយកនិយមន័យការធ្វើទារុណកម្មរបស់ CAT មក

---

[227] *សូមមើល* បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ២០៥។

[228] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ២០៨។

[229] *សូមមើល* សៀវភៅនិពន្ធដោយ Hans Danelius មានចំណងជើងថា *Convention Against Torture and Other Cruel, Inhuman or Degrading Treatment or Punishment*, UNITED NATIONS AUDIOVISUAL LIBRARY OF INTERNATIONAL LAW 1 (អង្គការសហប្រជាជាតិ), ឆ្នាំ២០០៨។ “សេចក្តីប្រកាសស្តីពីការធ្វើទារុណកម្មត្រូវបានបង្កើតឡើង ដើម្បីជាចំណុចចាប់ផ្តើមសម្រាប់ការបំពេញកិច្ចការងារបន្ថែមទៀតប្រឆាំងនឹងការធ្វើទារុណកម្ម... និយមន័យនៃអំពើទារុណកម្មដែលមានក្នុងសេចក្តីប្រកាសស្តីពីការធ្វើទារុណកម្ម ពុំត្រូវបានចាត់ទុកថាមានលក្ខណៈជាក់លាក់គ្រប់គ្រាន់ និងបានរងការរិះគន់ត្រង់ចំណុចជាច្រើន”។ *សូមមើលផងដែរ* សៀវភៅរបស់ J. HERMAN BURGERS និង HANS DANELIUS មានចំណងជើងថា THE UNITED NATIONS CONVENTION AGAINST TORTURE: A HANDBOOK ON THE CONVENTION AGAINST TORTURE AND OTHER CRUEL, INHUMAN OR DEGRADING TREATMENT OR PUNISHMENT 16 (ឆ្នាំ1988, បោះពុម្ពដោយ Kluwer Academic Publishers)។ អ្នកតាក់តែងសេចក្តីព្រាងនេះគិតឃើញថា “ពុំមែនជាការចាំបាច់ដែលសេចក្តីប្រកាសនេះត្រូវតែជាលិខិតុបករណ៍ដែលដាក់បញ្ចូលអ្វីៗ គ្រប់យ៉ាងដោយលម្អិតឡើយ។ សេចក្តីប្រកាសនេះគឺជាឯកសារផ្លូវការដែលពុំចងកាតព្វកិច្ចផ្លូវច្បាប់ឡើយ...”។

[230] សូមមើល *សារណាពាក់ព័ន្ធនឹងអំពើបំពារបំពានធ្ងន់ធ្ងរដែលជាជម្រើសមួយទៀត កថាខណ្ឌ ៣៥*។

អនុវត្ត អាចជាការរំលោភគោលការណ៍ *គ្មានបទល្មើស បើគ្មានច្បាប់ចែង*[231]។

៩៨. ត្រង់កថាខណ្ឌ ១៩០ *ក្នុងចំណោមប្រការផ្សេងៗ* ក.ស.ព លើកឡើងនូវអ្វីដែលខ្លួនយល់ថាជាមូលដ្ឋានច្បាប់ទំនៀមទម្លាប់អន្តរជាតិនៃអំពើរំលោភសេពសន្ថវៈ ក្នុងលក្ខណៈជាបទល្មើសជាមូលដ្ឋានមួយដែលបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងប្រភពនៃនិយមន័យឧក្រិដ្ឋកម្មនេះតាមការសន្មត។ អំពើរំលោភសេពសន្ថវៈពុំមែនជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិមួយ *ដែលគេបានរៀបរាប់* នៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ឡើយ ហើយអំពើរំលោភសេពសន្ថវៈអាចត្រឹមតែរំលោភមាត្រា៥ នៃច្បាប់ អ.វ.ត.ក មួយប៉ុណ្ណោះ ប្រសិនបើ៖ ក. ប្រភេទ "អំពើអមនុស្សធម៌ដទៃទៀត" អាចយកមកអនុវត្តបាន និង **ខ.** អំពើរំលោភសេពសន្ថវៈបង្កើតបានជា "អំពើអមនុស្សធម៌ដទៃទៀត" នៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩[232]។

៩៩. ត្រង់កថាខណ្ឌ ១៩១ ក.ស.ព អះអាងថា "ការជម្លៀសដោយបង្ខំក្នុងប្រភេទជា "អំពើ អមនុស្សធម៌ដទៃទៀត" គឺជាឧក្រិដ្ឋកម្មដែលច្បាប់អន្តរជាតិបានទទួលស្គាល់អំឡុងរបបកម្ពុជាប្រជាធិបតេយ្យ"។ ដើម្បីគាំទ្រអំណះអំណាងនេះ ក.ស.ព បានយកឧក្រិដ្ឋកម្ម ២ ផ្សេងគ្នាគឺឧក្រិដ្ឋកម្មនៃការនិរទេសនិងការជម្លៀសដោយបង្ខំមកបូកបញ្ចូលគ្នា។ ក.ស.ព សន្និដ្ឋានថា "ការនិរទេស និងការជម្លៀសដោយបង្ខំ គឺសំដៅទៅលើឧក្រិដ្ឋកម្មតែមួយ ដូចគ្នា"។ ត្រង់កថាខណ្ឌ ១៩២ ក.ស.ព កត់សម្គាល់ឃើញថា លក្ខន្តិកៈ តុលាការ ICC "ចាត់ទុកការនិរទេស និងការជម្លៀសដោយបង្ខំ ថាជាឧក្រិដ្ឋកម្មតែមួយ ក្រោមឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ"។ ក.ស.ព ទាញសន្និដ្ឋានថា "ឧក្រិដ្ឋកម្មនៃការជម្លៀសដោយបង្ខំត្រូវបានដាក់បញ្ចូលថាជាឧក្រិដ្ឋកម្មមួយ នៅក្នុងធម្មនុញ្ញតុលាការ Nuremberg, ធម្មនុញ្ញនៃតុលាការ IMTFE និងច្បាប់ នៃក្រុមប្រឹក្សាត្រួតពិនិត្យ លេខ ១០"។ ការនិរទេស និងការជម្លៀសដោយបង្ខំ គឺជា<u>ឧក្រិដ្ឋកម្មដាច់ដោយឡែកពីគ្នា</u>។ ទោះបីឧក្រិដ្ឋកម្មទាំង២នេះមានធាតុផ្សំដូចគ្នាយ៉ាងណាក្តី ក៏ការផ្លាស់ប្តូរទីកន្លែងក្នុងរង្វង់ព្រំដែននៃរដ្ឋមួយបង្កើតបានត្រឹមតែជាការជម្លៀសដោយបង្ខំប៉ុណ្ណោះ ពុំមែនជាការនិរទេសទេ។ ប្រសិនបើការជម្លៀសដោយបង្ខំជាអំពើដែលអាចផ្តន្ទាទោសបាន អំពើនេះត្រូវតែស្ថិត

[231] ICCPR, មាត្រា ១៥(១)។

[232] *សូមមើល* បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២១៨។

នៅក្នុងប្រភេទជា "អំពើអមនុស្សធម៌ដទៃទៀត"[233]។

១០០. ត្រង់កថាខណ្ឌ ១៩៣ ក.ស.ព "សន្និដ្ឋានថាអំពើហិង្សាផ្លូវភេទគឺជាអំពើអមនុស្សធម៌មួយផ្សេងទៀត [sic] ក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ អំពើហិង្សាផ្លូវភេទស្រដៀងគ្នាទៅនឹងអំពើរំលោភសេពសន្ថវៈ ដែលគេបានទទួលស្គាល់ជាយូរមកហើយថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ"។ អំណះអំណាងរបស់ ក.ស.ព ដែលថា "អំពើហិង្សាផ្លូវភេទស្រដៀងគ្នាទៅនឹងអំពើរំលោភសេពសន្ថវៈ" គឺជាការរំលោភលើការហាមឃាត់សទិសភាពទាំងក្នុងច្បាប់ស៊ីវិល និងច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិ[234]។ ធម្មនុញ្ញតុលាការ IMT ពុំចាត់ទុកអំពើហិង្សាផ្លូវភេទ (ឬឧក្រិដ្ឋកម្មផ្លូវភេទណាមួយផ្សេងទៀត) ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិឡើយ ហើយក៏មិនដែលមានការកាត់សេចក្តីណាមួយនៅតុលាការ Nuremberg ឬ តូក្យូ ពីបទឧក្រិដ្ឋកម្មហិង្សាផ្លូវភេទដែរ[235]។

[233] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Brdanin, IT-99-36-T, បណ្តឹងឧទ្ធរណ៍, ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០០៤ កថាខណ្ឌ ៥៤៤។ ពាក់ព័ន្ធនឹងមូលហេតុដែលការជម្លៀសដោយបង្ខំ ពុំមែនជាបទល្មើសដែលអាចផ្តន្ទាទោសបាន ក្នុងប្រភេទជា "អំពើអមនុស្សធម៌ដទៃទៀត" *សូមមើល* បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ២២៦។

[234] *សូមមើល* លក្ខន្តិកៈតុលាការ ICC, មាត្រា២២(២), ដែលចែងក្នុងផ្នែកដែលទាក់ទងថា៖ "គេត្រូវបកស្រាយនិយមន័យនៃឧក្រិដ្ឋកម្មណាមួយឱ្យបានល្អិតល្អន់ និងពុំត្រូវពង្រីកឧក្រិដ្ឋកម្មនោះតាមរយៈគោលការណ៍សទិសភាពឡើយ"។ លើសពីនេះ តុលាការជាតិ (ពិសេសក្នុងប្រទេសប្រកាន់ច្បាប់ស៊ីវិល) ព្រមទាំងតុលាការអន្តរជាតិ ជាទូទៅពុំយក [ច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិ] មកអនុវត្តតាមគោលការណ៍សទិសភាពឡើយ។ នៅក្នុងច្បាប់ជាតិ ការហាមឃាត់មិនឱ្យអនុវត្តវិធានចែងពីឧក្រិដ្ឋកម្មតាមរយៈសទិសភាព...មានឫសគល់ក្នុងភាពចាំបាច់ក្នុងការគាំពារពលរដ្ឋ និងពិសេសដើម្បីទប់ស្កាត់ការផ្តន្ទាទោសជនត្រូវចោទចំពោះអំពីដែលគេពុំបាន ចាត់ទុកថាជាអំពើល្មើសច្បាប់ នៅពេលអំពើទាំងនោះត្រូវបានប្រព្រឹត្ត។ គោលការណ៍ដដែលនេះអាចយកមកអនុវត្តនៅក្នុងច្បាប់អន្តរជាតិ។ ភាពសមហេតុផលរបស់គោលការណ៍នេះគឺភាពចាំបាច់ក្នុងការការពារមនុស្សម្នាក់ៗឱ្យផុតពីការប្រព្រឹត្តតាមអំពើចិត្តរបស់រដ្ឋ ឬតុលាការ...។ សៀវភៅនិពន្ធដោយ ANTONIO CASSESE មានចំណងជើងថា INTERNATIONAL CRIMINAL LAW 48 (ប្រែសម្រួលលើកទី២ បោះពុម្ពដោយ Oxford University Press 2008) ("CASSESE, INTERNATIONAL CRIMINAL LAW 2ND ED.")។

[235] *សូមមើល* ដីកាចោទប្រកាន់ដែលបានចេញនៅក្នុងតុលាការ Nuremberg *មាននៅលើគេហទំព័រ* http://avalon.law.yale.edu/imt/count.asp។ ដីកាចោទប្រកាន់ចេញនៅក្នុងតុលាការយោធាអន្តរជាតិសម្រាប់ចុងបូព៌ា (អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ Tokyo), *មាននៅលើគេហទំព័រ* http://www.trumanlibrary.org/whistlestop/study_collections/nuremberg/index.php?action=search។ ទោះបីក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ពុំមានចោទពីបទអំពើហិង្សាផ្លូវភេទក្តី ក៏ដីកាដែលគេបានចេញសម្រាប់ការជំនុំជម្រះនៅឯតុលាការ Tokyo នេះបានដាក់បញ្ចូលនូវបទរំលោភសេពសន្ថវៈផ្សេងៗ ដែលមាននៅក្នុងឧក្រិដ្ឋកម្មសង្គ្រាមដែលគេបានចោទប្រកាន់នេះ។ *សូមមើល* សេចក្តីបន្ថែម ឃ នៃដីកាចោទប្រកាន់, ផ្នែកទី១, ទី៣ និងទី១២ ទំព័រ iii-iv,vi។ *សូមមើលផងដែរ* ANNE-

ច្បាប់លេខ១០ នៃក្រុមប្រឹក្សាត្រួតពិនិត្យ ពុំបានចាត់ទុកអំពើហិង្សាផ្លូវភេទថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិឡើយ[236] ហើយក៏ពុំដែលមានការកាត់សេចក្ដីណាមួយពីបទឧក្រិដ្ឋកម្មហិង្សាផ្លូវភេទក្រោមច្បាប់នេះដែរ[237]។ ចាប់តាំងពីឆ្នាំ១៩៤៨ មក ក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ[238] គេអាចចាត់ទុកអំពើហិង្សាផ្លូវភេទថាត្រឹមតែជា "អំពើអមនុស្សធម៌ដទៃទៀត" ប៉ុណ្ណោះ។

១០១. ត្រង់កថាខណ្ឌ ១៩៤ ក.ស.ព អះអាងថា "ការដែលថាមានតែតុលាការ SCSL មួយប៉ុណ្ណោះដែលបានទទួលស្គាល់ "ការរៀបការដោយបង្ខំ" ថាជាឧក្រិដ្ឋកម្មមួយនៅឆ្នាំ២០០៨ គឺពុំផ្ទុយទៅនឹងអត្ថិភាពកន្លងមករបស់វាក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិឡើយ"។ ត្រង់កថាខណ្ឌ១៩៥ ក.ស.ព បានលើកយកអនុសញ្ញាបន្ថែមស្ដីពីការលុបបំបាត់ទាសភាព, ការជួញដូរទាសករ, និងទម្លាប់អនុវត្តន៍ស្រដៀងគ្នាទៅនឹងទាសភាព ("អនុសញ្ញាបន្ថែម")[239] មកធ្វើជាភស្តុតាងគាំទ្រអំណះអំណាងដែលថា "ការរៀបការដោយបង្ខំត្រូវបានគេយល់ឃើញថាមានភាពស្រដៀងគ្នាទៅនឹងទាសភាព ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិយ៉ាងពិតប្រាកដ"។ នេះជាឧទាហរណ៍មួយទៀតអំពីការពុំអើពើដែលមានក្នុងចម្លើយតប (និងដីកាដំណោះស្រាយ)[240] ទៅលើទិដ្ឋភាពនៃគោលការណ៍ *គ្មានបទល្មើស បើគ្មានច្បាប់ចែង* ដែលហាមឃាត់មិនឲ្យសំអាងលើសទិសភាពដើម្បីបង្កើតបទល្មើសឧក្រិដ្ឋ[241]។ អនុសញ្ញាបន្ថែមគឺជា

MARIE L.M. DE BROUWER, SUPRANATIONAL CRIMINAL PROSECUTION OF SEXUAL VIOLENCE: THE ICC AND THE PRACTICE OF THE ICTY AND THE ICTR 6-8 (បោះពុម្ពដោយ Intersentia, ឆ្នាំ២០០៥) ("SEXUAL VIOLENCE")។

236 មាត្រា II(1)(គ), ច្បាប់របស់ក្រុមប្រឹក្សាគ្រប់គ្រង លេខ ១០ ។

237 *សូមមើល* ដីកាចោទប្រកាន់ដែលបានចេញនៅក្នុង *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Pohl និងអ្នកផ្សេងទៀត* អនុលោមតាមច្បាប់ក្រុមប្រឹក្សាគ្រប់គ្រង លេខ ១០, *មាននៅ* http://avalon.law.yale.edu/imt/indict4.asp ។ *សូមមើលផងដែរ* អំពើហិង្សាផ្លូវភេទ, ទំព័រ៨។

238 *សូមមើល* បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ២២៥។

239 អនុសញ្ញាបន្ថែមលើការលុបបំបាត់ទាសភាព, ការជួញដូរទាសករ, និងការផ្ដួចផ្ដើម និងទម្លាប់អនុវត្តន៍ស្រដៀងទៅនឹងទាសភាព, 266 UNTS 3, ចូលជាធរមាននៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៥៧ ត្រូវបានទទួលស្គាល់ដោយប្រទេសកម្ពុជានៅខែមិថុនា ឆ្នាំ១៩៥៧។

240 *សូមមើល* បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ១៨៦-៨៧ ។

241 *សូមមើល* លក្ខន្តិកៈតុលាការ ICC មាត្រា២២(២) ដែលចែងក្នុងផ្នែកពាក់ព័ន្ធថា៖ "គេត្រូវបកស្រាយនិយមន័យនៃឧក្រិដ្ឋកម្មណាមួយឲ្យបានល្អិតល្អន់ និងពុំត្រូវពង្រីកឧក្រិដ្ឋកម្មនោះតាមរយៈគោលការណ៍សទិសភាពឡើយ"។ លើសពីនេះ តុលាការជាតិ (ពិសេសក្នុងប្រទេសប្រកាន់ច្បាប់ស៊ីវិល) ព្រមទាំងតុលាការអន្តរជាតិ ជាទូទៅពុំយក [ច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិ] មកអនុវត្តតាមគោលការណ៍សទិសភាពឡើយ។ នៅក្នុងច្បាប់ជាតិ ការហាមឃាត់មិនឲ្យអនុវត្តវិធានចែងពីឧក្រិដ្ឋកម្មតាមរយៈសទិសភាព...មានឫសគល់ក្នុង

លិខិតុបករណ៍សិទ្ធិមនុស្សមួយ ដែលពុំចាត់ទុក "ការរៀបការដោយបង្ខំ" ថាជាឧក្រិដ្ឋកម្ម[242]។ អនុសញ្ញាបន្ថែមនេះចែងច្បាស់ថា "ការបញ្ជូន ឬការប៉ុនប៉ងបញ្ជូនទាសករពីប្រទេសមួយទៅប្រទេសមួយទៀត តាមមធ្យោបាយដឹកជញ្ជូនណាក៏ដោយ ឬក្នុងតួនាទីជាជនសមគំនិត" ដូចជាការជួញដូរទាសករជាដើម "ត្រូវជាបទល្មើសឧក្រិដ្ឋ"[243]។ ទង្វើពាក់ព័ន្ធនឹងការរៀបការក្នុងមាត្រា ១ (គ) ពុំត្រូវបានកំណត់ប្រភេទតាមវិធីដូចគ្នានេះ ដូចជាអំពើឧក្រិដ្ឋកម្មឡើយ។ ការសន្និដ្ឋានថាការរៀបការដោយបង្ខំត្រូវបានកំណត់ជាបទឧក្រិដ្ឋនៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ តាមរយៈអនុសញ្ញាបន្ថែម គឺជាការខុសឆ្គង។ ក.ស.ព បានបកស្រាយអនុសញ្ញាបន្ថែមនេះពុំបានត្រឹមត្រូវ និងរំលោភលើគោលការណ៍ហាមឃាត់សទិសភាព[244]។

១០២. ត្រង់កថាខណ្ឌ ១៩៦ ក.ស.ព ស្នើសុំដាក់និយមន័យការបាត់ខ្លួនដោយបង្ខំ "ចូលទៅក្នុងច្បាប់អន្តរជាតិ" ដែលខ្លួនដកស្រង់និយមន័យនេះចេញពីសេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិឆ្នាំ ២០០៦។ ទីមួយ សេចក្តីសម្រេចទាំងឡាយរបស់មហាសន្និបាតអង្គការសហប្រជាជាតិពុំមានអំណាច ឬសមត្ថកិច្ចក្នុងការប្រកាស ឬ ប្រែក្លាយទស្សនទានណាមួយ ទៅជាច្បាប់ទំនៀមទម្លាប់អន្តរជាតិឡើយ

---

ភាពចាំបាច់ក្នុងការគាំពារពលរដ្ឋ និងពិសេសដើម្បីទប់ស្កាត់ការផ្តន្ទាទោសជនត្រូវចោទចំពោះអំពីដែលគេពុំបានចាត់ទុកថាជាអំពើល្មើសច្បាប់ នៅពេលអំពើទាំងនោះត្រូវបានប្រព្រឹត្ត។ គោលការណ៍ដដែលនេះអាចយកមកអនុវត្តនៅក្នុងច្បាប់អន្តរជាតិ។ ភាពសមហេតុផលរបស់គោលការណ៍នេះគឺភាពចាំបាច់ក្នុងការការពារមនុស្សម្នាក់ៗឱ្យផុតពីការប្រព្រឹត្តតាមអំពើចិត្តរបស់រដ្ឋ ឬតុលាការ..."។ សៀវភៅនិពន្ធដោយ CASSESE មានចំណងជើងថា INTERNATIONAL CRIMINAL LAW 2ND ED, ទំព័រ48។

[242] *សូមមើល* អនុសញ្ញាបន្ថែម, មាត្រា ១(គ) ដែលចែងថា "រដ្ឋភាគីនីមួយៗនៃអនុសញ្ញានេះត្រូវចាត់វិធានការចាំបាច់ជាក់ស្តែងតាមផ្លូវច្បាប់នានា និងវិធានការផ្សេងៗ ដើម្បីនាំមកនូវការលុបបំបាត់ជាបន្តបន្ទាប់ និងទាំងស្រុងតាមដែលអាចធ្វើទៅបាន ឬការបោះបង់នូវគំនិតផ្តួចផ្តើម ឬទម្លាប់អនុវត្តន៍ខាងក្រោមដែលនៅមានអត្ថិភាព ឬដែលពុំទាន់មានចែងក្នុងនិយមន័យនៃទាសភាពក្នុងមាត្រា១នៃអនុសញ្ញាស្តីពីទាសភាព ដែលបានចុះហត្ថលេខានៅទីក្រុងហ្សឺណែវកាលពីថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩២៦៖ ... (គ) គំនិតផ្តួចផ្តើម ឬទម្លាប់អនុវត្តន៍ណាមួយដែល (i) ស្ត្រីដែលគ្មានសិទ្ធិប្រកែក ត្រូវបានគេសន្យា ឬប្រគល់ជាប្រាក់នៅពេលរៀបការ ឬប្រគល់ជាអ្វីផ្សេងទៅឱ្យឪពុកម្តាយ,អាណាព្យាបាល,គ្រួសារ ឬមនុស្ស ឬក្រុមណាមួយផ្សេង ឬ (ii) ប្តីរបស់ស្ត្រីណាម្នាក់, គ្រួសាររបស់ប្តី, ឬបក្សពួកមានសិទ្ធិផ្ទេរស្ត្រីនោះទៅឱ្យមនុស្សម្នាក់ទៀតតាមតម្លៃដែលបានទទួល ឬផ្សេងពីនេះ ឬ (iii) ស្ត្រីគ្រប់រូបនៅពេលប្តីស្លាប់អ្នកផ្សេងអាចស្នងមរតក"។

[243] *ដូចដើងទំព័រខាងលើ* មាត្រា៣(១)។

[244] *សូមមើល យោងខាងលើ* លេខ ២៣៩។

។ ដូច្នេះ សេចក្ដីសម្រេចទាំងអស់នេះពុំចងកាតព្វកិច្ចឡើយ[245]។ ទីពីរ គេពុំគួរផ្ដល់ទម្ងន់ណាមួយដល់អត្ថិភាពនៃសេចក្ដីសម្រេចរបស់មហាសន្និបាតពីឆ្នាំ២០០៦ ថាជាភស្តុតាងបញ្ជាក់ថាវិធាននៃច្បាប់ទំនៀមទម្លាប់អន្តរជាតិបានមានអត្ថិភាពនៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ឡើយ[246]។

១០៣. ត្រង់កថាខណ្ឌ ១៩៧ ក.ស.ព អះអាងថា "អនុសញ្ញាមុនៗដែលបានបង្កើតឱ្យមានច្បាប់សឹក បានផ្ដល់ជាយន្តការដើម្បីទប់ស្កាត់ការបាត់ខ្លួនដោយបង្ខំ"។ ទោះជាយ៉ាងណា ការបង្កើតឱ្យមានយន្តការ នានា ដូចជា "ការិយាល័យផ្ដល់ព័ត៌មានសម្រាប់ឈ្លើយសឹក ... ដើម្បីឆ្លើយតបទៅនឹងចម្ងល់នានារបស់អ្នកទោស"[247] គឺពុំដូចគ្នាទៅនឹងការកំណត់ប្រភេទបទល្មើសមួយដោយឡែក ដែលខុសពីអំពើមនុស្សឃាត, ការនិរទេស ឬការចាប់ដាក់មន្ទីរឃុំឃាំងឡើយ។ ក.ស.ព លើកយកសំណុំរឿង *Justice* មកគាំទ្រអំណះអំណាងដែលថាការបាត់ខ្លួនដោយបង្ខំគឺជាឧក្រិដ្ឋកម្មមួយ ក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩[248]។ ទោះយ៉ាងណា សេចក្ដីសម្រេចមួយនៅពុំគ្រប់គ្រាន់ឡើយ ដើម្បីនឹងបង្កើតឱ្យបានជាទម្លាប់អនុវត្តន៍របស់រដ្ឋ ឬ*ទស្សនៈច្បាប់* "ជាទូទៅ ប្រកបដោយសង្គតិ

---

[245] *សូមមើល* អត្ថបទស្រាវជ្រាវរបស់ Hugh Thirlway មានចំណងជើងថា *The Sources of International Law, នៅក្នុង* INTERNATIONAL LAW ទំព័រ១១៥, ១២៤ (M. Evans, ប្រែសម្រួល, បោះពុម្ពដោយ Oxford University Press, ឆ្នាំ២០០៦), ដោយបានគូសបញ្ជាក់ថាសេចក្ដីសម្រេចរបស់មហាសន្និបាតត្រូវបានចាត់ទុកថាជាភស្តុតាងបញ្ជាក់អំពី *ទស្សនៈច្បាប់* ពុំមែនជាទម្លាប់អនុវត្តន៍ឡើយ។

[246] សេចក្ដីសម្រេចចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៦ បានបញ្ជាក់ថាអនុសញ្ញាអន្តរជាតិសម្រាប់ការពារមនុស្សគ្រប់រូបពីការបាត់ខ្លួនដោយបង្ខំ។ យោងតាមមាត្រា៣៩(១) នៃសេចក្ដីសម្រេចនេះ អនុសញ្ញានេះនឹងចូលជាធរមាននៅពេលមានការផ្ដល់សច្ចាប័នពីសំណាក់រដ្ឋសមាជិកចំនួន២០។ បួនឆ្នាំក្រោយការអនុម័តសេចក្ដីសម្រេចនេះ រដ្ឋទីម្ភៃបានដាក់លិខិតុបករណ៍ស្ដីពីការផ្ដល់សច្ចាប័នរបស់ខ្លួន ជូនអង្គការសហប្រជាជាតិ។ អនុសញ្ញានេះបានចូលជាធរមាននៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១០។ ចាប់តាំងពីពេលនោះ ពុំមានការផ្ដល់សច្ចាប័នណាមួយបន្ថែមទៅលើអនុសញ្ញានេះឡើយ។

[247] អនុសញ្ញាក្រុងឡាអេ (IV) ពាក់ព័ន្ធនឹងច្បាប់ និងទំនៀមទម្លាប់សង្គ្រាមដែនគោក និងឧបសម្ពន្ធរបស់វា៖ នីតិបញ្ញត្តិពាក់ព័ន្ធនឹងច្បាប់ និងទំនៀមទម្លាប់សង្គ្រាម នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ១៩០៧, U.S.T.S. 539, មាត្រា១៤, *ដែលបានលើកយកមកសំអាងនៅក្នុង* ចម្លើយតប, កថាខណ្ឌ១៩៧ លេខ៥០៧។

[248] ចម្លើយតប កថាខណ្ឌ ១៩៧ *ទាញហេតុសំអាង Justice Case*, ច្បាប់ក្រុមប្រឹក្សាគ្រប់គ្រងលេខ១០, *នៅក្នុង* ការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខតុលាការយោធា Nuremberg តាម ច្បាប់ក្រុមប្រឹក្សាគ្រប់គ្រងលេខ១០ (ឆ្នាំ១៩៤៧, ភាគ ៣), ទំព័រ ១០៥៧-៥៨, ១០៦១។

ភាព និងរលូន” ចាំបាច់ដើម្បីចាត់ទុកការបាត់ខ្លួនដោយបង្ខំថាជា “អំពើអមនុស្សធម៌ដទៃទៀត” ដែលបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ[249]។ អាចជាការសមស្របក្នុងការចាត់ទុកការកំណត់ប្រភេទឧក្រិដ្ឋកម្មក្នុងលក្ខន្តិកៈតុលាការ ICC ថាជាពេលដែលវិធានទំនៀមទម្លាប់នេះត្រូវបានកំណត់ច្បាស់លាស់លែង ភ័ន្តច្រឡំ[250]។

១០៤. ត្រង់កថាខណ្ឌ១៩៨ ក.ស.ព អះអាងថា “អៀង សារី ...ពុំបានលើកទឡ្ហីករណ៍ណាមួយដើម្បីឱ្យខុសប្លែកពី” សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង *ឌុច* ដែលថា “អំពើអមនុស្សធម៌ផ្សេងៗបង្កើតបានជាបទល្មើសដែលនៅក្នុងចង្កោមសេសសល់ ដែលនឹងកំណត់ជាបទឧក្រិដ្ឋនូវទង្វើណាដែលបំពេញតាមលក្ខខណ្ឌអប្បបរមានៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ប៉ុន្តែពុំត្រូវនឹងឧក្រិដ្ឋកម្មណាមួយជាក់លាក់ផ្សេងទៀតឡើយ”។ ក.ស.ព ពុំបានឆ្លើយតបទៅនឹងទឡ្ហីករណ៍របស់មេធាវីការពារក្តីដែលថាក្នុងឋានៈជាតុលាការកម្ពុជាដែលប្រើប្រាស់ប្រព័ន្ធច្បាប់ស៊ីវិល អ.វ.ត.ក មានយុត្តាធិការត្រឹមតែទៅលើឧក្រិដ្ឋកម្មណាដែលមានច្បាប់ចែងច្បាស់លាស់ប៉ុណ្ណោះ[251]។ ការខ្វះភាពច្បាស់លាស់ពីធម្មជាតិរបស់ “អំពើអមនុស្សធម៌ដទៃទៀត” មានន័យថាប្រភេទអំពើទាំងនេះរំលោភលក្ខខណ្ឌតម្រូវដែលថាត្រូវមានច្បាប់ចែងច្បាស់អំពីឧក្រិដ្ឋកម្ម។ ដូច្នេះ អ.វ.ត.ក គ្មានយុត្តាធិការលើបទល្មើសនេះឡើយ[252]។

១០៥. ត្រង់កថាខណ្ឌ ១៩៩ ក.ស.ព អះអាងថាដើម្បីឱ្យស្របតាមគោលការណ៍នីត្យានុកូលភាព “ជាការគ្រប់គ្រាន់ដែលថាអំពើទាំងនោះ ត្រូវបានកំណត់ជាបទឧក្រិដ្ឋនៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ទាំងក្នុងច្បាប់ជាតិ ឬអន្តរជាតិ ដោយពុំគិតអំពីការកំណត់ថាអំពើនោះជាឧក្រិដ្ឋកម្មឡើយ”។ ប្រសិនបើអំពើទាំងឡាយត្រូវបានកំណត់ថាជាឧក្រិដ្ឋកម្មនៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ក្នុងច្បាប់ជាតិ ឬអន្តរជាតិ ការអនុវត្តយុត្តាធិការរបស់ អ.វ.ត.ក ត្រូវកំណត់ត្រឹមជាការកាត់សេចក្តីអំពើណាដែល

---

[249] *សូមមើល* សាលដីកា អ.ប.ជ ស្តីពី JCE, កថាខណ្ឌ៥៣ *ទាញហេតុសំអាង* Fisheries Jurisdiction Case (*រឿងក្តី* United Kingdom *តទល់នឹង* Iceland), អង្គសេចក្តី, ១៩៧៤ ICJ Rep. 3, ត្រង់ទំព័រ ៥០ និង លក្ខន្តិកៈឆ្នាំ ១៩៤៦ របស់តុលាការយុត្តិធម៌អន្តរជាតិ មាត្រា៣៨(១)។

[250] *សូមមើល* បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ២៣០-៣១។

[251] មាត្រា ៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ចែងថា “គ្មានបទឧក្រិដ្ឋណាត្រូវផ្តន្ទាទោសតាមរយៈការដាក់ទោសដែលគ្មានចែងក្នុងច្បាប់នៅមុនពេលបទឧក្រិដ្ឋនោះត្រូវបានប្រព្រឹត្តឡើយ” (ការបកប្រែក្រៅផ្លូវការ)។

[252] *សូមមើល* បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ២២០។

មានច្បាប់ចែងក្នុងចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ ការទទួលស្គាល់អំណះអំណាងរបស់ ក.ស.ព គឺជាការរំលោភគោលការណ៍ *គ្មានបទល្មើស បើគ្មានច្បាប់ចែង* ចំនួន ៣ ខ។ ទីមួយ ការទទួលស្គាល់នេះនឹងចាត់ទុកអំពើទាំងឡាយ ថាជាឧក្រិដ្ឋកម្ម ដែលពុំបានមានអត្ថិភាពនៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ (ការរំលោភគោលការណ៍អប្រតិសកម្ម)។ ទីពីរ ការទទួលស្គាល់នេះនឹងអនុញ្ញាតឱ្យមានការចោទប្រកាន់ផ្អែកលើមូលដ្ឋានដែលថាធាតុផ្សំនៃឧក្រិដ្ឋកម្មមួយ ស្រដៀងគ្នាទៅនឹងឧក្រិដ្ឋកម្មនានាដែលបានមានអត្ថិភាពនៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ (ការរំលោភគោលការណ៍ហាមឃាត់សទិសភាព)។ ទីបី ការទទួលស្គាល់នេះនឹងធ្វើឱ្យជនជាប់ចោទពុំអាចដឹងមុននូវកិច្ចដំណើរការនីតិវិធីបច្ចុប្បន្ន នៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ អង្គបុរេជំនុំជម្រះត្រូវបដិសេធសេចក្តីសន្និដ្ឋានរបស់ ក.ស.ព នេះ។

## IX. អ.វ.ត.ក ពុំមានយុត្តាធិការក្នុងការយកអំពើបំពារបំពានធ្ងន់ធ្ងរមកអនុវត្តឡើយ ដោយហេតុថាការធ្វើបែបនេះរំលោភអាជ្ញាយុកាលជាធរមាន

១០៦. ត្រង់កថាខណ្ឌ២០២ ក.ស.ព អះអាងថា “ការកែប្រែពាក្យពេចន៍បន្តិចបន្តួចពុំទាន់គ្រប់គ្រាន់ដើម្បីដាក់អំពើបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ ដែលជាឧក្រិដ្ឋកម្មអន្តរជាតិឱ្យស្ថិតនៅក្រោមអាជ្ញាយុកាលជាតិបានឡើយ”។ វាជាការកែប្រែពាក្យពេចន៍បន្តិចបន្តួចមែន ប៉ុន្តែវាជាបំលាស់ប្តូរធំមួយក្នុងការយកអំពើបំពារបំពានធ្ងន់ធ្ងរមកអនុវត្តនៅ អ.វ.ត.ក។ ដោយហេតុថា អ.វ.ត.ក ជាតុលាការកម្ពុជា ទើប អ.វ.ត.ក ត្រូវយកច្បាប់កម្ពុជាមកអនុវត្ត។ ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ចែងអំពីអាជ្ញាយុកាលរយៈពេល១០ឆ្នាំ សម្រាប់បទល្មើសដែលត្រូវបានប្រព្រឹត្តនៅកម្ពុជា[253]។ ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ បានចាត់ទុកបទល្មើសមួយថាជាបទឧក្រិដ្ឋ ដែលត្រូវផ្តន្ទាទោសជាអប្បបរមាចំនួន៥ឆ្នាំ ដោយតុលាការព្រហ្មទណ្ឌកម្ពុជា[254]។ នៅ អ.វ.ត.ក ដែលជាតុលាការព្រហ្មទណ្ឌកម្ពុជាមួយដែរនោះ

[253] ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ មាត្រា១០៩ ចែងក្នុងផ្នែកពាក់ព័ន្ធ៖ “អ្នកណាប្រព្រឹត្តឧក្រិដ្ឋកម្មកន្លងលើសពីដប់ឆ្នាំ.... អ្នកនោះបានរួចផុតពីទោសហើយ....” (ការបកប្រែក្រៅផ្លូវការ)។

[254] *ដូចដើងទំព័រខាងលើ* មាត្រា២១ ចែងក្នុងផ្នែកពាក់ព័ន្ធ : “ទោសឧក្រិដ្ឋមានបីយ៉ាង :១.សម្លាប់។ ២.បង្ខំឱ្យធ្វើការអស់មួយជីវិត។ ៣.បង្ខំឱ្យធ្វើការជាទម្ងន់ មានកំណត់កាល”។ ទោសសម្លាប់ជាទោសឧក្រិដ្ឋថ្នាក់ទី៣។ ទោសបង្ខំឱ្យធ្វើការជាទម្ងន់អស់មួយជីវិតជាទោសឧក្រិដ្ឋថ្នាក់ទី២។ ទោសបង្ខំឱ្យធ្វើការជាទម្ងន់ មានកំណត់ជាទោសឧក្រិដ្ឋថ្នាក់ទីមួយ។” មាត្រា៣២ ចែងនៅក្នុងផ្នែកពាក់ព័ន្ធ : “ទោសបង្ខំឱ្យធ្វើការជាទម្ងន់ អស់មួយជីវិត ត្រូវសម្រេចជាប់គុកមនុស្សដែលមានទោសនោះអស់មួយជីវិត។”

បទឧក្រិដ្ឋនៃអំពើបំពារបំពានធ្ងន់ធ្ងរត្រូវទទួលការផ្ដន្ទាទោសជាអប្បបរមាចំនួន៥ឆ្នាំ[255]។ ដូចមានចែងក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ គេត្រូវយកអាជ្ញាយុកាលមកអនុវត្តលើ អំពើបំពារបំពានធ្ងន់ធ្ងរ។

១០៧. ត្រង់កថាខណ្ឌ ២០២ ក.ស.ព អះអាងថាពាក្យថា "ដែលគ្មានអាជ្ញាយុកាល" ត្រូវបានយកមកប្រើប្រាស់ក្នុងមាត្រា៤ និងមាត្រា៥ នៃច្បាប់ អ.វ.ត.ក ដើម្បីឱ្យកាន់តែមានភាពច្បាស់លាស់ ប៉ុន្តែពុំបានផ្ដល់ឯកសារសំអាងណាមួយគាំទ្រអំណះអំណាងនេះឡើយ។ ច្បាប់ អ.វ.ត.ក បានលុបចោលយ៉ាងច្បាស់នូវឃ្លា "ដែលគ្មានអាជ្ញាយុកាល" ពាក់ព័ន្ធនឹងអំពើបំពារបំពានធ្ងន់ធ្ងរ។ ប្រសិនបើមានបញ្ហាស្រពេចស្រពិលណាមួយពាក់ព័ន្ធនឹងការបកស្រាយអំពីបញ្ហាអាជ្ញាយុកាលជុំវិញអំពើបំពារបំពានធ្ងន់ធ្ងរ គេត្រូវដោះស្រាយបញ្ហានេះដោយតម្កល់ប្រយោជន៍ជនជាប់ចោទជាធំ។ ចំណុចនេះស្របតាមគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* ដូចមានចែងត្រង់មាត្រា៣៨ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា។

១០៨. ត្រង់កថាខណ្ឌ២០៣ ក.ស.ព អះអាងថាអាជ្ញាយុកាលនៃអំពើបំពារបំពានធ្ងន់ធ្ងរ ត្រូវបានហាមឃាត់ក្រោមកាតព្វកិច្ចអន្តរជាតិរបស់កម្ពុជា។ អំណះអំណាងនេះពុំត្រឹមត្រូវទេ។ "នាពេលបច្ចុប្បន្ន ទាំងទម្លាប់អនុវត្តន៍ និង *ទស្សនៈច្បាប់* ពុំបានហាមឃាត់មិនឱ្យរដ្ឋ យកការអនុវត្តគោលការណ៍នីត្យានុកូលភាពតាមរដ្ឋធម្មនុញ្ញ ឬតាមលក្ខន្តិកៈ មកអនុវត្តខ្លាំង ជាងគោលការណ៍ដែលបានយកមកអនុវត្តក្នុងច្បាប់អន្តរជាតិឡើយ"[256]។ លើសពីនេះ ដើម្បីគាំទ្រអំណះអំណាងរបស់ខ្លួន ក.ស.ព បានលើកយកអនុសញ្ញាក្រុងហ្សឺណែវមកសំអាងដោយពុំត្រឹមត្រូវ។ អនុសញ្ញាក្រុងហ្សឺណែវពុំបានចែងអំពីការហាមឃាត់អាជ្ញាយុកាលឡើយ។ ផ្ទុយទៅវិញ អនុសញ្ញាក្រុងហ្សឺណែវចែងថា "រដ្ឋភាគីត្រូវចាត់វិធានការ

---

មាត្រា៣៣ ចែងនៅក្នុងផ្នែកពាក់ព័ន្ធ : "ទោសបង្ខំឱ្យធ្វើការជាទម្ងន់មានកំណត់ត្រូវសម្រេចដាក់ទោសពី៥ឆ្នាំយ៉ាងតិច ដល់២០ឆ្នាំយ៉ាងច្រើន.... ទោសឧក្រិដ្ឋថ្នាក់ទី១" (ការបកប្រែក្រៅផ្លូវការ)។

[255] ច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក មាត្រា៣៩ ចែងនៅក្នុងផ្នែកពាក់ព័ន្ធ : " ជនទាំងឡាយដែលប្រព្រឹត្តបទឧក្រិដ្ឋណាមួយដូចមានចែងក្នុងមាត្រា ៣ថ្មី, ៤, ៥, ៦ [បំពារពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ], ៧, និងមាត្រា ៨ នៃច្បាប់នេះ ត្រូវផ្ដន្ទាទោសឧក្រិដ្ឋដាក់ពន្ធនាគារពី៥ឆ្នាំ រហូតដល់មួយជីវិត"។

[256] សៀវភៅនិពន្ធដោយ KENNETH S. GALLANT មានចំណងជើងថា THE PRINCIPLE OF LEGALITY IN INTERNATIONAL AND COMPARATIVE CRIMINAL LAW ទំព័រ ៣៩៨ (បោះពុម្ពដោយ Cambrdige University Press, ឆ្នាំ ២០០៩)។

ដើម្បីអនុម័តច្បាប់ចាំបាច់..."[257]។ ដូច្នេះការផ្តន្ទាទោសត្រូវផ្អែកតាមច្បាប់រដ្ឋ ហើយរដ្ឋជាអ្នកយកច្បាប់មកបកស្រាយនិងអនុវត្ត។ ជាក់ស្តែងនៅឆ្នាំ១៩៩២ តុលាការ Hungarian Constitutional Court បានចាត់ទុកជាមោឃៈនូវច្បាប់នានាដែលផ្តួចផ្តើមឲ្យមានភាពគ្មានអាជ្ញា យុកាលលើឧក្រិដ្ឋកម្មមួយចំនួន ដែលត្រូវបានប្រព្រឹត្តនៅចន្លោះថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៤៤ ដល់ថ្ងៃទី២ ខែឧសភា ឆ្នាំ១៩៩០ ផ្អែកតាមការយល់ឃើញថា ការដាក់ឲ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌម្តងទៀតចំពោះបទល្មើស ដែលអស់អាជ្ញាយុកាលទៅហើយនោះ គឺពុំស្របច្បាប់ ពិសេសផ្អែកលើមូលដ្ឋានដែលថា វារំលោភលើសន្តិសុខច្បាប់[258]។ ដូចគ្នានេះតុលាការសហព័ន្ធនៃប្រទេសស្វីស ក៏បានបដិសេធពុំព្រមយកច្បាប់មួយចំនួនដែលចាត់ទុកជាមោឃៈនូវអាជ្ញាយុកាល លើបទល្មើសប្រល័យពូជសាសន៍ និងអំពើបំពារបំពានធ្ងន់ធ្ងរមកអនុវត្តលើឧក្រិដ្ឋកម្ម ដែលត្រូវបានហាមឃាត់ការកាត់សេចក្តីដោយសារការកន្លងផុតទៅនៃពេលវេលា នៅពេលដែលបញ្ញត្តិទាំងនេះបានចូលជាធរមាន[259]។ ដូចតុលាការកម្ពុជាដែរ អ.វ.ត.ក ត្រូវគោរពច្បាប់កម្ពុជា និងអាជ្ញាយុកាលនៃអំពើបំពារបំពានធ្ងន់ធ្ងរផងដែរ។ ដូចនៅតាមបណ្តារដ្ឋជាច្រើន ពិសេសរដ្ឋដែលអនុវត្តប្រព័ន្ធច្បាប់ស៊ីវិល គេត្រូវបកស្រាយច្បាប់នេះឲ្យបានល្អិតល្អន់ម៉ត់ចត់៖ "<u>យើងត្រូវបែងចែកឲ្យដាច់រវាងបុរេលក្ខខណ្ឌនៃគោលការណ៍នីត្យានុកូលភាព ដូចមានចែងក្នុងកម្រិតអន្តរជាតិ និងគោលការណ៍នីត្យានុកូលភាពនៃបទបញ្ញាតតិយុត្តិជាតិ</u>...។ ប្រព័ន្ធតតិយុត្តិជាតិជាច្រើន... តម្រូវឲ្យមានការគោរពតាមគោលការណ៍នីត្យានុកូលភាពមួយដែលតឹងរ៉ឹងជាងនេះ"[260]។ នេះជាការពិតជាក់ស្តែងមួយនៅក្នុងបរិបទកម្ពុជា ដូចមានចែងត្រង់មាត្រា៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦[261]។ ដូច្នេះប្រសិនបើអំពើបំពារបំពានធ្ងន់ធ្ងរត្រូវបានចាត់ទុកថាជាឧក្រិដ្ឋកម្មក្រោមយុត្តាធិការ អ.វ.ត.ក នោះ

---

[257] អនុសញ្ញាទីក្រុងហ្សឺណែវ I មាត្រា៤៩។ អនុសញ្ញាទីក្រុងហ្សឺណែវ II មាត្រា៥០។ អនុសញ្ញាទីក្រុងហ្សឺណែវ III, មាត្រា១២៩។ អនុសញ្ញាទីក្រុងហ្សឺណែវ IV មាត្រា១៤៦។

[258] NAQVI, ត្រង់ទំព័រ ១៩៨, *ទាញហេតុសំអាង* សេចក្តីសម្រេចលេខ ២០៨៦/a/១៩៩១/១៤, ចុះថ្ងៃទី៥ ខែមីនា ឆ្នាំ១៩៩២, បកប្រែជាភាសាអង់គ្លេសនៅក្នុង N. Kritz (ប្រែសម្រួល), *Transitional Justice*, ភាគ III ត្រង់ទំព័រ ៦២៩។

[259] *ដូចដើងទំព័រខាងលើ ទាញសំអាងហេតុ Spring*, Switzerland តុលាការសហព័ន្ធ សាលក្រមចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០០១។

[260] សៀវភៅនិពន្ធដោយ Helmut Kreicker មានចំណងជើងថា *National Prosecution of Genocide from a Comparative Perspective*, 5 INT'L CRIM. L. REV. ទំព័រ ៣១៣, ៣២០ (ឆ្នាំ២០០៥) (គូសបញ្ជាក់បន្ថែម)។

[261] មាត្រា៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ចែងថា "ច្បាប់ព្រហ្មទណ្ឌ គ្មានអនុភាពប្រតិសកម្មទេ គឺបទល្មើសណាបានប្រព្រឹត្តមុនពេលមានបទបញ្ញត្តិរបស់ច្បាប់"។

អាជ្ញាយុកាលបានចប់១០ឆ្នាំ ក្រោយពីពេលនៃការប្រព្រឹត្តិឧក្រិដ្ឋកម្ម។ ឧក្រិដ្ឋកម្មនៃអំពើបំពារបំពានធ្ងន់ធ្ងរត្រូវបានហាមឃាត់ការកាត់សេចក្ដីនៅ អ.វ.ត.ក ដោយការកន្លងផុតទៅនៃពេលវេលា ដូចមានចែងយ៉ាងច្បាស់ និងល្អិតល្អន់ក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦។ ក្នុងនោះ មានហេតុផលនយោបាយផងដែរចំពោះការបកស្រាយដ៏ល្អិតល្អន់បែបនេះ៖

> អាជ្ញាយុកាលត្រូវបានផ្ដល់យុត្តកម្មតាមហេតុផលជាច្រើន។ ហេតុផលចម្បងគឺពាក់ព័ន្ធទៅនឹង ការដែលថាការកន្លងផុតទៅនៃពេលវេលា ធ្វើឲ្យការប្រមែប្រមូលភស្តុតាងចោទប្រកាន់ជនណា ម្នាក់ពីបទឧក្រិដ្ឋទាំងនោះ មានការលំបាកខ្លាំង និងពុំសូវមានភាពគួរឲ្យជឿជាក់ ពិសេសពាក់ព័ន្ធនឹងការស្វែងរកសាក្សីដែលអាចឲ្យគេជឿជាក់បាន។ ការធ្វើឲ្យមានកិច្ចដំណើរការនីតិវិធីឆាប់រហ័សទាន់ពេលវេលា ជួយសម្រាលបានជាអតិបរមានូវហានិភ័យដែលថានឹងមានការក្លែងបន្លំអង្គហេតុ។ ដូច្នេះ អាជ្ញាយុកាលគឺជាមធ្យោបាយចាំបាច់ក្នុងការគាំពារសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការកាត់សេចក្ដីដោយយុត្តិធម៌[262]។

១០៩. ត្រង់កថាខណ្ឌ២០៤ ក.ស.ព អះអាងថាលក្ខន្តិកៈតុលាការ ICTY, តុលាការ ICTR, និងតុលាការ SCSL ពុំមានចែងអំពីអាជ្ញាយុកាលក្នុងការកាត់សេចក្ដីអំពើបំពារបំពានធ្ងន់ធ្ងរឡើយ។ អ.វ.ត.ក ពុំអនុវត្តតាមលក្ខន្តិកៈតុលាការ ICTY, ICTR, ឬ SCSL ដែលជាតុលាការព្រហ្មទណ្ឌអន្តរជាតិ ឬតុលាការព្រហ្មទណ្ឌកូនកាត់ឡើយ។ អ.វ.ត.ក មានច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក របស់ខ្លួន ហើយពុំមែនជាតុលាការព្រហ្មទណ្ឌអន្តរជាតិឡើយ។ អ.វ.ត.ក ជាតុលាការកម្ពុជា។ លក្ខន្តិកៈតុលាការ ICC ត្រូវបានអនុម័តនៅឆ្នាំ១៩៩៨ និងត្រូវបានព្រាងនៅមុនពេលមានច្បាប់បង្កើត អ.វ.ត.ក[263]។ លក្ខន្តិកៈតុលាការ ICC ចែងច្បាស់ថាគ្មានអាជ្ញាយុកាលណាមួយអាចយកមកអនុវត្តបានលើឧក្រិដ្ឋកម្ម ដែលត្រូវបានចោទប្រកាន់នៅតុលាការICCឡើយ[264]។ អ្នកតាក់តែងសេចក្ដីព្រាងច្បាប់ អ.វ.ត.ក ច្បាស់ជា

---

[262] NAQVI, ត្រង់ទំព័រ ១៩០។

[263] នៅលើគេហទំព័រ អ.វ.ត.ក សេចក្ដីយោងទីមួយទៅនឹងសេចក្ដីព្រាងច្បាប់ អ.វ.ត.ក មួយចំនួន នៅខែសីហា ឆ្នាំ១៩៩៩: "នាយករដ្ឋមន្ត្រី ហ៊ុន សែន បានស្នើសុំជំនួយបច្ចេកទេសពី អ.ស.ប ក្នុងការធ្វើសេចក្ដីព្រាងច្បាប់" ដែលអាចរកបាននៅលើគេហទំព័រ http://www.eccc.gov.kh/english/backgroundECCC.aspx ។

[264] លក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិ មាត្រា២៩៖ "ឧក្រិដ្ឋកម្មក្រោមយុត្តាធិការតុលាការនេះពុំត្រូវមានអាជ្ញាយុកាលឡើយ" សាស្ត្រាចារ្យ Schabas បានចាត់ទុកមាត្រា២៩ ថាជា "សញ្ញាបញ្ជាក់យ៉ាងច្បាស់អំពីការចូលរួមរបស់លក្ខន្តិកៈនេះដល់ដំណើរវិវឌ្ឍន៍

បានដឹងអំពីចំណុចមួយចំនួនដូចជាថា បញ្ញត្តិនេះមានចែងក្នុងលក្ខន្តិកៈតុលាការ ICC, ការខ្វះការទទួលស្គាល់ថាជានិយាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ, និងអាជ្ញាយុកាលលើបទឧក្រិដ្ឋដែលអាចផ្តន្ទាទោសបាននៅកម្ពុជាជាដើម។ ការលុបចោលយ៉ាងច្បាស់នូវពាក្យពេចន៍ខាងលើក្នុងមាត្រា៦ សបញ្ជាក់ឱ្យឃើញថាគេត្រូវយកអាជ្ញាយុកាលមកអនុវត្តលើអំពើបំពារបំពានធ្ងន់ធ្ងរ។

១១០. ក.ស.ព អះអាងទៀតថាក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ពុំមានអាជ្ញាយុកាលលើឧក្រិដ្ឋកម្មសង្គ្រាមទេ។ ការអះអាងបែបនេះពុំមានមូលដ្ឋានច្បាស់លាស់ឡើយ៖ "អំណះអំណាងដែលថាមានវិធានទំនៀមទម្លាប់មួយចែងថា អាជ្ញាយុកាលពុំអាចយកមកអនុវត្តលើឧក្រិដ្ឋកម្មអន្តរជាតិ មួយភាគធំគឺជាផ្លែផ្កានៃសកម្មភាពតុលាការ ពោលគឺពុំមែនជាទម្លាប់អនុវត្តន៍របស់រដ្ឋណាមួយ ឬ *ទស្សនៈច្បាប់* ឡើយ...។ ទម្លាប់អនុវត្តន៍របស់រដ្ឋពាក់ព័ន្ធនឹង អាជ្ញាយុកាលលើឧក្រិដ្ឋកម្មអន្តរជាតិ ពុំមានលក្ខណៈជាប់លាប់ខ្ជាប់ខ្ជួន ឬសង្គតិភាពទាល់តែសោះ[265]។ លើសពីនេះ "ទោះបីមានរដ្ឋជាច្រើនដែលមានច្បាប់ [ពាក់ព័ន្ធនឹងការមិនអនុវត្តអាជ្ញាយុកាលលើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ] ប្រហែលពុំមានការឯកភាពគ្នាច្បាស់លាស់ថា <u>ឧក្រិដ្ឋកម្មសង្គ្រាម</u> ពុំត្រូវមានអាជ្ញាយុកាលឡើយ"[266]។ ពុំមានការឯកភាពគ្នាជាទូទៅឡើយ នៅពេលមហាសន្និបាតអង្គការសហប្រជាជាតិបានអនុម័តអនុសញ្ញាស្តីពីការពុំអនុវត្តអាជ្ញាយុកាលលើឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[267]។ ប្រទេសអូទ្រីស, ប្រទេសហូឡង់, ហ្វីលីពីន, ស៊ុយអែត និង ប្រទេសបារាំងដែលជាមូលដ្ឋាននៃប្រព័ន្ធច្បាប់កម្ពុជា បានបង្កើតទស្សនៈថាត្រូវទុកឱ្យរដ្ឋនីមួយៗជាអ្នកសម្រេចលើអាជ្ញាយុកាល[268]។ ការសិក្សាមួយអំពីទម្លាប់អនុវត្តន៍របស់រដ្ឋ និង *ទស្សនៈច្បាប់* ពាក់ព័ន្ធនឹងអាជ្ញាយុកាលលើឧក្រិដ្ឋកម្មអន្តរជាតិ បានសន្និដ្ឋានថា

---

<u>ជាប់ជាហូរហែរ</u>នៃច្បាប់អន្តរជាតិ"។ អត្ថបទរបស់ Schabas, *មាត្រា២៩, នៅក្នុង* TRIFFTERER (ប្រែសម្រួល) មានចំណងជើងថា COMMENTARY ON THE ROME STATUTE: OBSERVERS' NOTES, ARTICLE BY ARTICLE 846 (បោះពុម្ពដោយ Hart Publishing, ឆ្នាំ ២០០៨) (គូសបញ្ជាក់បន្ថែម)។

265 NAQVI, ត្រង់ទំព័រ១៩២-៩៣។

266 *ដូចជើងទំព័រខាងលើ* នៅត្រង់ ១៩៥ (គូសបញ្ជាក់បន្ថែម)។

267 អនុសញ្ញាស្តីពីការមិនអនុវត្តអាជ្ញាយុកាលចំពោះឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ សេចក្តីសម្រេចលេខ ២៣៩១ មហាសន្និបាត អនុម័តថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ១៩៦៨។

268 NAQVI, ជំពូក ៤, លេខ ១៤១។

ពុំមានភស្តុតាងគ្រប់គ្រាន់ដើម្បីបង្ហាញថា វិធានទំនៀមទម្លាប់ដែលហាមឃាត់អាជ្ញាយុកាលលើឧក្រិដ្ឋកម្មអន្តរជាតិ បានមានអត្ថិភាពនៅមុនដំណាច់ទសវត្សរ៍ឆ្នាំ១៩៨០ ឡើយ[269]។ បើគ្មានទម្លាប់អនុវត្តន៍ និង *ទស្សនៈច្បាប់* ចាំបាច់ទេ នោះពុំអាចមានច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលចែងថាអាជ្ញាយុកាលពុំអាចយកមកអនុវត្តបានលើឧក្រិដ្ឋកម្មសង្គ្រាមឡើយ។ យុត្តិសាស្ត្រដែល ក.ស.ព បានលើកយកមកសំអាង ដើម្បីគាំទ្រដល់អំណះអំណាងរបស់ខ្លួនដែលថា តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ អាជ្ញាយុកាលគឺពុំអាចយកមកអនុវត្តបានលើឧក្រិដ្ឋកម្មសង្គ្រាម គឺពុំអាចយកមកអនុវត្តបានក្នុងច្បាប់កម្ពុជា ឬច្បាប់អន្តរជាតិឡើយ។ យុត្តិសាស្ត្រដែល ក.ស.ព បានលើកយកមកសំអាងនោះ គឺជាច្បាប់ជាតិរបស់ប្រទេសអ៊ីតាលី។ យុត្តិសាស្ត្ររបស់រដ្ឋមួយពុំទាន់គ្រប់គ្រាន់ក្នុងការបង្ហាញថា វាជាទម្លាប់អនុវត្តន៍របស់រដ្ឋទូទៅ ប្រកបដោយសង្គតិភាព ដែលមានលក្ខណៈជាប់លាប់ខ្ជាប់ខ្ជួន ឬ ជា *ទស្សនៈច្បាប់* ឡើយ។ តាមគោលការណ៍អធិបតេយ្យភាពនៃរដ្ឋ[270] រដ្ឋនីមួយៗអាចបង្កើតច្បាប់ដើម្បីអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិតាមបំណងរបស់ខ្លួន។ គេពុំអាចយកច្បាប់ទំនៀមទម្លាប់អន្តរជាតិមកអនុវត្តផ្ទាល់នៅ អ.វ.ត.ក បានឡើយ[271]។

១១១. ត្រង់កថាខណ្ឌ ២០៥ ក.ស.ព អះអាងដោយពុំត្រឹមត្រូវថានៅពេលមានការខ្វែងគំនិតគ្នា រវាងកាតព្វកិច្ចរបស់កម្ពុជាក្នុងការកាត់សេចក្តីអំពើបំពារបំពានធ្ងន់ធ្ងរ និងអាជ្ញាយុកាលជាតិ អ.វ.ត.ក គួរកុំអើពើអំពីអាជ្ញាយុកាលជាតិ។ ប្រសិនបើ អ.វ.ត.ក ពុំអើពើលើអាជ្ញា យុកាលជាតិ អ.វ.ត.ក នឹងរំលោភបំពានលើអធិបតេយ្យភាពកម្ពុជាដោយសារការអនុវត្ត *ហួសពីក្របខ័ណ្ឌសិទ្ធិអំណាច* (*ultra vires*)។ នៅពេល អ.វ.ត.ក គ្មានយុត្តាធិការអនុវត្តច្បាប់អន្តរជាតិ អ.វ.ត.ក ពុំអាចយកច្បាប់អន្តរជាតិមកអនុវត្តក្នុងតុលាការកម្ពុជាបាន ឡើយ។

## X. អ.វ.ត.ក ពុំមានយុត្តាធិការលើទំនួលខុសត្រូវរបស់ថ្នាក់លើឡើយ

---

[269] NAQVI, ជំពូក ៤, លេខ ២១០, *ទាញហេតុសំអាង* KOK, STATUTORY LIMITATIONS IN INTERNATIONAL CRIMINAL LAW 375 (បោះពុម្ពដោយ TMC Asser Press, ឆ្នាំ ២០០៧)។

[270] *សូមមើល* ធម្មនុញ្ញអង្គការសហប្រជាជាតិ មាត្រា២(៧)។ សេចក្តីសម្រេច *Kallon* កថាខណ្ឌ ៦៧។ Sadat នៅត្រង់ទំព័រ ១០២៣។

[271] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១២១-២៥។

### ក. ទំនួលខុសត្រូវរបស់ថ្នាក់លើពុំមែនជាទម្រង់នៃទំនួលខុសត្រូវជាធរមាននៅ អ.វ.ត.ក ឡើយ

១១២. ត្រង់កថាខណ្ឌ ២១០ ក.ស.ព អះអាងថាដើម្បីឲ្យទម្រង់នៃទំនួលខុសត្រូវមួយស្ថិតក្រោមយុត្តាធិការ អ.វ.ត.ក ទម្រង់នៃទំនួលខុសត្រូវនោះត្រូវបំពេញតាមបុរេលក្ខខណ្ឌចំនួន៤ គឺ៖ ក. ត្រូវមានចែងច្បាស់លាស់ ឬដោយប្រយោល ក្នុងច្បាប់ [ច្បាប់ អ.វ.ត.ក], ខ. ត្រូវមាន អត្ថិភាពក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងពេលពាក់ព័ន្ធ គ. ច្បាប់ដែលចែងអំពីទម្រង់នៃទំនួលខុសត្រូវ ត្រូវអាចឲ្យបុគ្គលដែលបានប្រព្រឹត្តអំពើបានដឹងគ្រប់គ្រាន់នៅពេលពាក់ព័ន្ធ និង ឃ. ជននោះត្រូវតែអាចដឹងមុនថាខ្លួននឹងត្រូវដាក់ឲ្យស្ថិតក្រោមទំនួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះអំពើរបស់ខ្លួន ប្រសិនបើរកឃើញ[272]។ ទោះបីកន្លងមក អង្គបុរេជំនុំជម្រះ បានទទួលស្គាល់នូវបុរេលក្ខខណ្ឌទាំង៤នេះក្តី ក៏ខ្លួននៅមានកំហុសឆ្គងពាក់ព័ន្ធនឹងបុរេលក្ខខណ្ឌទីពីរ។ តាមហេតុផលរៀបរាប់នៅក្នុងបណ្តឹងឧទ្ធរណ៍[273] ទម្រង់នៃទំនួលខុសត្រូវ ដែលមានចែងត្រឹមតែនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ គឺពុំទាន់គ្រប់គ្រាន់ទេ។ ទម្រង់នៃទំនួលខុសត្រូវក៏ត្រូវមានចែងក្នុងច្បាប់ជាតិកម្ពុជាក្នុងពេលពាក់ព័ន្ធផងដែរ។

#### ១. មិនមែនជាបញ្ហាចោទទេ ទោះបីមាត្រា ២៩ នៃច្បាប់ អ.វ.ត.ក ចែងច្បាស់លាស់ ឬមិនច្បាស់លាស់ អំពីការយកគោលការណ៍ទំនួលខុសត្រូវរបស់ថ្នាក់លើមកអនុវត្ត

១១៣. ត្រង់កថាខណ្ឌ ២១២ និង ២១៣ ក.ស.ព អះអាងថាមាត្រា២៩ នៃច្បាប់ អ.វ.ត.ក ចែងច្បាស់អំពីការយកទំនួលខុសត្រូវរបស់ថ្នាក់លើមកអនុវត្តនៅ អ.វ.ត.ក ហើយនាំឲ្យបុរេលក្ខខណ្ឌទីមួយដែលអង្គបុរេជំនុំជម្រះបានកំណត់ត្រូវបានបំពេញ។ ទោះបីច្បាប់អ.វ.ត.ក ចែងច្បាស់អំពីទំនួលខុសត្រូវរបស់ថ្នាក់លើក្តី ក៏គេពុំអាចសន្និដ្ឋានថាគេអាចយកទំនួលខុសត្រូវរបស់ថ្នាក់លើមកអនុវត្តនៅ អ.វ.ត.ក បានដែរ។ ទំនួលខុសត្រូវរបស់ថ្នាក់លើត្រូវតែបានមានអត្ថិភាពនៅក្នុងច្បាប់កម្ពុជាជាធរមាន នៅចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ១៩៧៩ ដើម្បីឲ្យ អ.វ.ត.ក មានយុត្តាធិការយកទំនួលខុសត្រូវនេះមកអនុវត្ត[274]។ ច្បាប់ អ.វ.ត.ក ពុំអាចបង្កើតច្បាប់ថ្មីណាមួយទៀត ដែលអាចយកមកអនុវត្តជាលក្ខណៈប្រតិសកម្មបាន

---

[272] ចម្លើយតប កថាខណ្ឌ ២១០ *ទាញសំអាងហេតុ* អ.ប.ជ សេចក្តីសម្រេចចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ៤៣។

[273] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១០៤-១៤, ១២១-២៥។

[274] *សូមមើល* បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១០៦-១០។

ឡើយ[275]។ ត្រង់កថាខណ្ឌ ២១៣ ក.ស.ព អះអាងថាមាត្រា២៩ នៃច្បាប់ អ.វ.ត.ក បានយកអត្ថបទដែលគេបានប្រើដើម្បីដាក់ទស្សនទាន នៃទំនួលខុសត្រូវរបស់ថ្នាក់លើបញ្ចូលទៅក្នុងលក្ខន្តិកៈរបស់តុលាការ ICTY និង ICTR ហើយការបង្កើតនូវទំនួលខុសត្រូវរបស់ថ្នាក់លើក្នុងលក្ខន្តិកៈទាំងនេះ ត្រូវបានចាត់ទុកថាជាការទទួលស្គាល់យុត្តាធិការលើឧក្រិដ្ឋកម្មផ្អែកតាមទំនួលខុសត្រូវរបស់ថ្នាក់លើ ដូចច្បាប់ទំនៀមទម្លាប់អន្តរជាតិបានទទួលស្គាល់។ តុលាការ ICTY និងតុលាការ ICTR ខុសពី អ.វ.ត.ក។ តុលាការ ICTY និងតុលាការ ICTR គឺជាតុលាការអន្តរជាតិដែលអាចយកច្បាប់ទំនៀមទម្លាប់អន្តរជាតិមកអនុវត្តផ្ទាល់។ អ.វ.ត.ក គឺជាតុលាការជាតិនៅកម្ពុជាដែលត្រូវអនុវត្តតែច្បាប់ណាដែលបានការទទួលស្គាល់ថាជាច្បាប់ដែលភ្ជាប់កាតព្វកិច្ចនៅកម្ពុជា ពីចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩[276]។ ទោះបី អ.វ.ត.ក អាចគាំទ្រយុត្តាធិការលើទម្រង់នៃទំនួលខុសត្រូវតាមទំនៀមទម្លាប់អន្តរជាតិក៏ពិតមែន ក៏ប៉ុន្តែទំនួលខុសត្រូវរបស់ថ្នាក់លើពុំមែនជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិពីចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ឡើយ។

### ២. ទំនួលខុសត្រូវរបស់ថ្នាក់លើ ពុំមែនជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ឡើយ

១១៤. ត្រង់កថាខណ្ឌ ២១៤ ក.ស.ព អះអាងថាទំនួលខុសត្រូវរបស់ថ្នាក់លើត្រូវបានបង្កើតឡើងយ៉ាងច្បាស់នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅមុនឆ្នាំ១៩៧៥ ហើយមានចង្អុលបង្ហាញតាមរយៈលិខិតុបករណ៍អន្តរជាតិ, ច្បាប់ជាតិ និងសៀវភៅណែនាំយោធា, និងយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទី២។ ត្រង់កថាខណ្ឌ ២១៥ ក.ស.ព អះអាងថាគោលការណ៍បញ្ញាប្រកបដោយទំនួលខុសត្រូវមានអត្ថិភាព ហើយគោលការណ៍នេះមានឫសគល់ប្រវត្តិសាស្ត្រ និងដូចទៅនឹងទំនួលខុសត្រូវរបស់ថ្នាក់លើ។ ត្រង់កថាខណ្ឌនេះ ក.ស.ព ទទួលស្គាល់ថាលិខិតុបករណ៍ ដែលទទួលស្គាល់គោលការណ៍បញ្ញាប្រកបដោយទំនួលខុសត្រូវ ពុំចែងអំពីការអនុវត្តគោលការណ៍នេះ តាមរយៈទំនួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គល។ គោលការណ៍បញ្ញាប្រកបដោយទំនួលខុសត្រូវអាចមានចែងក្នុងច្បាប់នៅមុនឆ្នាំ

[275] *ដូចដើងទំព័រខាងលើ* កថាខណ្ឌ ១០៣-១០។

[276] *ដូចដើងទំព័រខាងលើ* កថាខណ្ឌ ៨-២០, ១១១-១៤, ១២១-២៥។

១៩៧៥ ដល់ឆ្នាំ១៩៧៩ ប៉ុន្តែពុំមានជាភស្តុតាងបញ្ជាក់ថាទំនួលខុសត្រូវរបស់ថ្នាក់លើ ដែលជាទម្រង់នៃទំនួលខុសត្រូវផ្នែកព្រហ្មទណ្ឌមួយ ពិតជាមានចែងក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះទេ (កុំថាឡើយវាមានចែងនៅក្នុងច្បាប់កម្ពុជា) នៅពេលវេលាពាក់ព័ន្ធ។ ការយកគោលការណ៍បញ្ញាប្រកបដោយទំនួលខុសត្រូវ មកសន្និដ្ឋានថាជាទំនួលខុសត្រូវរបស់ថ្នាក់លើដែលមានចែងក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ (កុំថាឡើយវាមានចែងនៅក្នុងច្បាប់កម្ពុជា) នៅពេលវេលាពាក់ព័ន្ធ គឺជាការរំលោភលើគោលការណ៍ហាមឃាត់សទិសភាព[277]។ ច្បាប់ទំនៀមទម្លាប់អន្តរជាតិត្រូវបានបង្កើតឡើងតាមរយៈ ក. ទម្លាប់អនុវត្តន៍របស់រដ្ឋទូទៅប្រកបដោយសង្គតិភាព និង ខ. *ទស្សនៈច្បាប់*[278]។ ទម្លាប់អនុវត្តន៍របស់រដ្ឋគួរមានលក្ខណៈ "ទូលំទូលាយ និងជាប់លាប់ខ្ជាប់ខ្ជួនតាមស្មារតីនៃបញ្ញត្តិដែលបានចែង"[279]។ ចំពោះ *ទស្សនៈច្បាប់* តុលាការ ICJ បានសម្រេចថារដ្ឋ "ត្រូវអនុវត្តឲ្យបានត្រឹមត្រូវដើម្បីឲ្យទង្វើរបស់ខ្លួនជាភស្តុតាងបញ្ជាក់ថា ទម្លាប់អនុវត្តន៍នេះត្រូវបានចាត់ទុកថាជាកាតព្វកិច្ចតាមរយៈអត្ថិភាពនៃវិធាននៃច្បាប់តម្រូវ"[280]។ អង្គបុរេជំនុំជម្រះបានបញ្ជាក់ថា "នៅពេលបញ្ជាក់..."[281]។ ការកំណត់សម្រេចអំពី *ទស្សនៈច្បាប់* មានភាពចាំបាច់ ដូចការកត់សម្គាល់ខាងក្រោមរបស់សាស្ត្រាចារ្យ Shaw៖

> ប្រសិនបើគេទុកនិយមន័យនៃទំនៀមទម្លាប់ជាទម្លាប់អនុវត្តន៍របស់រដ្ឋ ពេលនោះ គេនឹងត្រូវជួបបញ្ហាពាក់ព័ន្ធនឹងបញ្ហាថាតើត្រូវញែកច្បាប់អន្តរជាតិ ចេញពីគោលការណ៍សីលធម៌ ឬអនុវត្តក្នុងសង្គមជាមិនខាន។ នេះមកពីរដ្ឋពុំកំហិតទង្វើរបស់ខ្លួនតាមច្បាប់តម្រូវ។ រដ្ឋអាចអនុវត្តតាមលំនាំនៃទង្វើណាមួយតាមរយៈសុឆន្ទៈសុទ្ធសាធ និងក្នុងក្តីសង្ឃឹមលើផលប្រយោជន៍ទៅវិញទៅមក។...ការដែលថាមានការអនុវត្តដូច្នោះ ពុំមានន័យថាគេត្រូវតែអនុវត្តដូច្នោះឡើយ[282]។

ទំនួលខុសត្រូវរបស់ថ្នាក់លើត្រូវបានចងក្រងជាច្បាប់លើកដំបូងនៅឆ្នាំ១៩៧៧ ហើយនៅ ពេល

---

[277] *សូមមើល យោងខាងលើ* លេខ ២៣៩។

[278] *សូមមើល* បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣០។

[279] *North Sea Continental Shelf Cases*, របាយការណ៍តុលាការយុត្តិធម៌អន្តរជាតិ (១៩៦៩) កថាខណ្ឌ ៧៤។

[280] *រឿងក្តី Nicaragua តទល់នឹង United States of America*, (អង្គសេចក្តី), របាយការណ៍តុលាការយុត្តិធម៌អន្តរជាតិ ឆ្នាំ១៩៨៦ កថាខណ្ឌ ២០៧។

[281] សាលដីកា អ.ប.ជ ស្តីពី JCE កថាខណ្ឌ ៥៣។

[282] MALCOLM N. SHAW, INTERNATIONAL LAW ទំព័រ ៧៤-៧៥ (បោះពុម្ពដោយ Cambridge University Press ឆ្នាំ២០០៨)។

នោះពុំទាន់បានការទទួលស្គាល់ទូលំទូលាយភ្លាមៗនៅឡើយទេ[283]។ ការលើកយក គោលការណ៍បញ្ជាប្រកបដោយទំនួលខុសត្រូវមកធ្វើជាសំអាងកន្លងមក ពុំធ្វើឱ្យចំណុច នេះមានការប្រែប្រួលឡើយ។

១១៥. ត្រង់កថាខណ្ឌ ២១៦ ក.ស.ព អះអាងថា "គំរូដំបូងនាពេលបច្ចុប្បន្នស្តីពីការយកគោលការណ៍ទំនួលខុសត្រូវរបស់ថ្នាក់លើមកអនុវត្ត ត្រូវបានគេប្រទះឃើញនៅក្នុងរបាយការណ៍របស់គណៈ កម្មការអន្តរជាតិស្តីពីទំនួលខុសត្រូវរបស់ស្ថាបនិកសង្គ្រាម និងស្តីពីការពង្រឹងការអនុវត្តទោសទណ្ឌ ដែលត្រូវបានរៀបចំឡើងបន្តពីកេរដំណែលនៃបណ្តាប្រទេសមហាអំណាចសម្ព័ន្ធមិត្ត ក្នុងអំឡុងសន្និសីទសន្តិភាពឆ្នាំ១៩១៩"។ ក.ស.ព អះអាងថារបាយការណ៍នេះបានណែនាំថា គេគួរបង្កើតតុលាការមួយដើម្បីកាត់សេចក្តីអ្នកដែលបាន បញ្ជា ឬពុំបានទប់ស្កាត់ការរំលោភច្បាប់ ឬទំនៀមទម្លាប់សង្គ្រាម។ ការដែលថាមានការពិភាក្សាអំពីការបង្កើតតុលាការក្រោយសង្គ្រាមលោកលើកទី១ ដើម្បីកាត់សេចក្តីមនុស្ស ដែលបានបញ្ជា ឬពុំបានទប់ស្កាត់ឧក្រិដ្ឋកម្មសង្គ្រាម ពុំគាំទ្រអត្ថិភាពនៃទំនួលខុសត្រូវរបស់ថ្នាក់លើ ក្នុងលក្ខណៈជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិឡើយ។ គេពុំដែលបានបង្កើតតុលាការនោះឡើយ។ យើងពុំទាន់អាចសន្មតបានឡើយថាប្រសិនបើតុលាការនោះត្រូវបានបង្កើតឡើងមែន តុលាការនោះអាចបានយកគោលការណ៍ទំនួលខុសត្រូវរបស់ថ្នាក់លើមកអនុវត្តរួចទៅហើយ។

១១៦. ត្រង់កថាខណ្ឌ ២១៧ ក.ស.ព អះអាងថា "ទោះបីសន្ធិសញ្ញាក្រុង Versaille ពុំទទួលស្គាល់ជាក់លាក់នូវគោលការណ៍ដែលថា ថ្នាក់លើអាចស្ថិតក្រោមការដាក់ឱ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គលចំពោះឧក្រិដ្ឋកម្មរបស់មនុស្សក្រោមបង្គាប់ក៏ពិតមែន ក៏ប៉ុន្តែប្រទេសហត្ថលេខីបានទទួលស្គាល់ "សិទ្ធិរបស់ប្រទេសមហាអំណាចសម្ព័ន្ធមិត្ត និងមហាអំណាចពាក់ព័ន្ធ ក្នុងការនាំខ្លួនជនជាប់ចោទពីបទប្រព្រឹត្តអំពើល្មើសច្បាប់ និងទំនៀមទម្លាប់សង្គ្រាម មកកាត់សេចក្តីនៅចំពោះមុខតុលាការយោធា"។ ចំណុចនេះពុំគាំទ្រ អំណះអំណាងមួយដែលថាប្រទេសមហាអំណាចសម្ព័ន្ធមិត្ត និងមហាអំណាចពាក់ព័ន្ធ បានទទួលស្គាល់អត្ថិភាពនៃគោលការណ៍ទំនួលខុសត្រូវរបស់ថ្នាក់លើ នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិឡើយ។ ទម្រង់នៃទំនួលខុសត្រូវតែមួយគត់ដែលបានលើកឡើងនៅក្នុងអត្ថបទសម្រង់

---

[283] *សូមមើល* បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៩៨-៣០២។

ពាក់ព័ន្ធនឹងសន្និសញ្ញានេះគឺ ការប្រព្រឹត្ត។

១១៧. ត្រង់កថាខណ្ឌ ២១៨ ក.ស.ព អះអាងថា ប្រទេសសម្ព័ន្ធមិត្តបានឯកភាពគ្នាថារដ្ឋាភិបាលអាល្លឺម៉ង់នឹងកាត់សេចក្តីជនជាប់ចោទមួយចំនួន ចំពោះមុខតុលាការកំពូលអាល្លឺម៉ង់ដោយ "អនុលោមតាមច្បាប់អន្តរជាតិ"។ ប្រភពដែល ក.ស.ព បានលើកយកមកសំអាង ពុំបានបញ្ជាក់ថាតើចុងចោទនៅឯតុលាការអាល្លឺម៉ង់ បានទទួលការកាត់សេចក្តីត្រឹមត្រូវតាមច្បាប់អន្តរជាតិ ឬច្បាប់អាល្លឺម៉ង់ដែរឬយ៉ាងណានោះឡើយ។ ក.ស.ព យកសំណុំរឿងតែ ១ ករណីប៉ុណ្ណោះមកធ្វើជាសំអាង (ក្នុងចំណោមសំណុំរឿងទាំង១២ ដែលតុលាការកំពូលអាល្លឺម៉ង់បានជំនុំជម្រះ) ដែលក្នុងនោះតុលាការហាក់បីដូចជាបានយកគោលការណ៍ទំនួលខុសត្រូវរបស់ថ្នាក់លើមកអនុវត្ត។ ត្រឹមតែមួយករណីនេះ ពុំអាចគាំទ្ររឹងមាំនូវអត្ថិភាពនៃទម្លាប់អនុវត្តន៍របស់រដ្ឋទូទៅប្រកប ដោយសង្គតិភាព និង *ទស្សនៈច្បាប់* កាលពីពេលនោះបានឡើយ។

១១៨. ត្រង់កថាខណ្ឌ ២១៩ ក.ស.ព អះអាងថាទំនួលខុសត្រូវរបស់ថ្នាក់លើត្រូវបានតុលាការយោធា Nuremberg និងតុលាការចុងបូព៌ា Far East យកមកអនុវត្ត ទោះបីពុំមានចែងក្នុងច្បាប់បង្កើតតុលាការទាំងនេះក្តី។ ត្រង់ជើងទំព័រលេខ ៥៤២ ក.ស.ព គូសបញ្ជាក់ដោយពុំត្រឹមត្រូវថា "សហរដ្ឋអាមេរិកបានស្នើសុំយកគោលការណ៍ទំនួលខុសត្រូវរបស់ថ្នាក់លើ ក្នុងលក្ខណៈជាទម្រង់នៃទំនួលខុសត្រូវមួយ ទៅដាក់បញ្ចូលក្នុងធម្មនុញ្ញតុលាការ IMT"។ តាមការពិត និយមន័យដែលបានស្នើឡើងនោះហាក់ដូចពុំមែនជាសំណើសុំដាក់បញ្ចូលនិយមន័យនោះទៅក្នុងធម្មនុញ្ញតុលាការ IMT ទេ ប៉ុន្តែជាផ្នែកមួយនៃឯកសារមួយ សម្រាប់ផ្សព្វផ្សាយដល់មេបញ្ជាការតំបន់ប្រតិបត្តិការសឹក ដើម្បីឱ្យគេអាចញែកឱ្យដាច់រវាងបទល្មើសរំលោភច្បាប់សង្គ្រាមដែល "ពុំមែនជាបទល្មើសឧក្រិដ្ឋ" (ដូចជា ចារកម្ម) និង បទល្មើស "ឧក្រិដ្ឋ" ដូចជាការប្រព្រឹត្តអំពើយង់ឃ្នងមកលើជនស៊ីវិល"[284]។

១១៩. ត្រង់កថាខណ្ឌ ២២០ ដល់ ២២៥ ក.ស.ព បានលើកឡើងនូវករណីសំណុំរឿងមួយចំនួនក្រោយសង្គ្រាម

[284] អត្ថបទរបស់ Telford Taylor មានចំណងជើងថា *Final Report to the Secretary of the Army on the Nuremberg War Crimes Trials under Control Council Law No. 10,* ថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៤៩ ទំព័រ ១-២។

លោកលើកទី២ ដែលក្នុងនោះតុលាការបានយកទម្រង់នៃទំនួលខុសត្រូវរបស់ថ្នាក់លើមកអនុវត្ត[285]។ នៅពេលតុលាការយកទម្រង់នៃទំនួលខុសត្រូវរបស់ថ្នាក់លើមកអនុវត្តនៅពេលនោះ តុលាការពុំបានយកមកអនុវត្តឱ្យបានជាប់លាប់ខ្ជាប់ខ្ជួនឡើយ ហើយធាតុផ្សំទាំងឡាយនៃទម្រង់នេះនៅតែពុំមានលក្ខណៈច្បាស់លាស់នៅឡើយ ដែលនេះបង្ហាញថាកាលពីពេលនោះ ទម្រង់នេះពុំទាន់ជានិយាមនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅឡើយទេ[286] (ដើម្បីឱ្យក្លាយជានិយាមនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ទម្លាប់អនុវត្តន៍របស់រដ្ឋត្រូវតែ "ស្ទើរតែមានលក្ខណៈជាប់លាប់ខ្ជាប់ខ្ជួន" *ក្នុងចំណោមប្រការផ្សេងៗ* ទៀត")។ ទោះបីតុលាការទាំងនេះបានយកទម្រង់នៃទំនួលខុសត្រូវរបស់ថ្នាក់លើ មកអនុវត្តដោយរលូនក៏ពិតមែន ក៏ប៉ុន្តែរដ្ឋដែលបានអនុវត្តទម្រង់នេះមានចំនួនតិចតួចពុំគ្រប់គ្រាន់នឹងបញ្ជាក់ អំពីអត្ថិភាពនៃទម្លាប់អនុវត្តន៍របស់រដ្ឋទូទៅបានឡើយ។ មេធាវីការពារក្តីធ្លាប់បានបង្ហាញរួចម្តងហើយ អំពីវិការៈនៃសាលក្រម/សាលដីកា នៅក្រោយសម័យសង្គ្រាមលោកលើកទី២[287]។ គេពុំអាចចាត់ទុកសាលក្រម/សាលដីកាទាំងអស់នោះថាមានអាជ្ញាព្រឹត្តិបានឡើយ ដោយហេតុថាវាមានសំអាងហេតុផ្លូវច្បាប់តិចតួច ហើយគេបានចាត់ទុកថាជាសាលក្រម/សាលដីកាដែលតុលាការរបស់រដ្ឋអ្នកឈ្នះបានធ្វើឱ្យមានវិការៈ[288]។

---

[285] ករណីទាំងឡាយដែលបានរៀបរាប់នៅក្នុងកថាខណ្ឌ ២២៥ នឹងទាក់ទងដោយឡែក *ដូចយោងខាងក្រោម* ក្នុងផ្នែកស្តីពីការទទួលខុសត្រូវរបស់ថ្នាក់លើ ចំពោះជនស៊ីវិល។

[286] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៨៧-៩២។

[287] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ២៩១-៩២។

[288] *សូមមើល* RICHARD H. MINEAR, VICTOR'S JUSTICE: THE TOKYO WAR CRIMES TRIAL 16 (1971). "ក្នុងករណីដែលស្ថានភាពច្បាប់អន្តរជាតិបច្ចុប្បន្នពុំមានភាពច្បាស់លាស់ ឬពុំអាចទទួលយកបាន ឧទាហរណ៍ដូចជាពាក់ព័ន្ធនឹងទំនួលខុសត្រូវជាលក្ខណៈបុគ្គលលើអំពើរបស់រដ្ឋ ពេលនោះមហាអំណាចទាំងបួននឹងចងក្រងជាច្បាប់អន្តរជាតិតាមវិធីដែលអំពើរបស់អាល្លឺម៉ង់និងជប៉ុនបានក្លាយជាអំពើឧក្រិដ្ឋ ហើយមេដឹកនាំរបស់ខ្មាំងម្នាក់ៗជាអ្នកទទួលខុសត្រូវ"។ *សូមមើលផងដែរ* Mirjan Damaska, *The Shadow Side of Command Responsibility*, 49 AM. J. COMP. L. 455, 486-87 (២០០១)។ "ពុំចាំបាច់តម្រូវឱ្យមានការសិក្សាអំពីសេចក្តីសម្រេចនានារបស់តុលាការយោធា ក្រោយសម័យសង្គ្រាមលោកលើកទី II ឡើយ ដើម្បីទទួលស្គាល់ថាសេចក្តីសម្រេចទាំងនោះពុំមែនជាប្រភពជាក់ស្តែង ដែលយើងរំពឹងថាចៅក្រមសម័យច្បាប់អន្តរជាតិបច្ចុប្បន្ននឹងបំពេញតាមការចង់បានឡើយ។ ការដែលថាតុលាការទាំងនេះបានប្រឈមនឹងជនដែលមិនអាចអត់ឱនបានដែលជាប់ចោទពីបទឧក្រិដ្ឋគួរឱ្យស្អប់ខ្ពើម ពុំគួរបំបិទភ្នែកយើងមិនឱ្យឃើញការពិតដែលថាបទដ្ឋានគតិយុត្តិដែលពួកគេបានច្នៃប្រឌិតឡើងនេះ (ពិសេសនៅចុងបូព៌ា) មានវិការៈក្នុងក្របខណ្ឌនៃការយល់ដឹងរបស់យើងនាពេលបច្ចុប្បន្នអំពីច្បាប់ឧក្រិដ្ឋកម្ម តាមគោលបំណងមនុស្សធម៌ឡើយ។ ដូចដែលអ្នកស្រាវជ្រាវអន្តរជាតិល្បីឈ្មោះម្នាក់រូបបានកត់សម្គាល់ជាយូរមកហើយគឺថាបទដ្ឋានទាំងនេះគឺដូចជាដើម្បី "ធ្វើឱ្យមេធាវីចង់បំភ្លេចគោលបំណងមនុស្សធម៌ទាំងអស់នេះតាំងពី

១២០. ត្រង់កថាខណ្ឌ ២២៦ ក.ស.ព អះអាងថា ពេលនេះមានរដ្ឋផ្សេងៗដូចជាបារាំងជាដើមបានយកទម្រង់នៃទំនួលខុសត្រូវរបស់ថ្នាក់លើ ទៅដាក់បញ្ចូលក្នុងប្រព័ន្ធច្បាប់ជាតិរបស់ខ្លួន។ ត្រង់កថាខណ្ឌ ២២៧ ក.ស.ព លើកឧទាហរណ៍អំពីប្រទេសចិន, លុចសំបួ, ហូឡង់ និង កាណាដា ដែលពេលនេះបានអនុម័តច្បាប់ទទួលស្គាល់ទំនួលខុសត្រូវរបស់ថ្នាក់លើ ហើយ ក.ស.ព សំអាងលើសៀវភៅណែនាំសម្រាប់សមរភូមិរបស់ទាហានសហរដ្ឋអាមេរិក (United States Army Field Manual) ដែលមានផ្នែកមួយនិយាយពាក់ព័ន្ធនឹងទំនួលខុសត្រូវរបស់ថ្នាក់លើ។ ត្រង់នេះអាចបង្ហាញថាទម្រង់នៃទំនួលខុសត្រូវរបស់ជនសមគំនិត ឬទំនួលខុសត្រូវរបស់ថ្នាក់លើ មួយចំនួន ត្រូវបានចងក្រងជាច្បាប់សម្រាប់ប្រើប្រាស់ក្នុងតុលាការពិសេស ដែលមានយុត្តាធិការលើឧក្រិដ្ឋកម្មសង្គ្រាម។ ទោះជាយ៉ាងនេះក្តី ភស្តុតាងនេះពុំទាន់គ្រប់គ្រាន់ឡើយក្នុងការបញ្ជាក់អំពីទម្លាប់អនុវត្តន៍របស់រដ្ឋទូទៅដែល "ទូលំទូលាយ និងស្ទើរតែជាប់លាប់ខ្ជាប់ខ្ជួន"[289] តាមការតម្រូវ ដើម្បីស្វែងរកអត្ថិភាពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ។

១២១. ត្រង់កថាខណ្ឌ ២២៨ និង ២២៩ ក.ស.ព អះអាងថាគោលការណ៍នៃទំនួលខុសត្រូវរបស់ថ្នាក់លើត្រូវបានចងក្រងក្នុងមាត្រា៨៦ និង៨៧ នៃពិធីសារបន្ថែម I[290] ព្រមទាំងបានដកស្រង់មាត្រាទាំងនេះទៀតផង។ ពិធីសារបន្ថែម I បានត្រឹមតែចងក្រងទំនួលខុសត្រូវរបស់ថ្នាក់លើចំពោះអំពើបំពារបំពានអនុសញ្ញាក្រុងហ្សឺណែវ និងពិធីសារបន្ថែម I តែប៉ុណ្ណោះ ពោលគឺពុំបាននិយាយដល់ទំនួលខុសត្រូវលើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឬឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិឡើយ។

១២២. ត្រង់កថាខណ្ឌ២៣០ ក.ស.ព អះអាងថារដ្ឋមួយចំនួនបានបញ្ចេញទស្សនៈថា ពិធីសារបន្ថែមI បាន

---

ដើមទី"។ អត្ថសញ្ញាណទូទៅនៃបទដ្ឋាននេះដែលពាក់ព័ន្ធនឹងគោលបំណងបច្ចុប្បន្នគឺជាភាពធ្ងន់ធ្ងរជាក់ស្តែង ដែលគេចាត់ទុកយ៉ាងត្រឹមត្រូវថាជាប្រភពចម្បងនៃការពង្រីកវិសាលភាពនៃទំនួលខុសត្រូវ ដែលមានពីធម្មជាតិនៅក្នុងទំនួលខុសត្រូវរបស់ថ្នាក់លើដែលគេបានតាក់តែងឡើងនោះ"។ *សូមមើលផងដែរ* Curt Hessler, *Command Responsibility for War Crimes*, 82 Yale L.J. 1274, 1275 (1972-1973)។ "សេចក្តីសម្រេចភាគច្រើន" គឺជាការចង់បានរបស់តុលាការដើម្បីប្រមែប្រមូលអំណះអំណាងគតិយុត្តិ,ស្មារតី,និងឯកសារភស្តុតាង *ទាំងអស់*ដើម្បីគាំទ្រសេចក្តីសម្រេចរបស់ខ្លួន"។

[289] លក្ខខណ្ឌតម្រូវមួយចំពោះការផ្តល់សំអាងហេតុអំពីអត្ថិភាពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ, យោងតាមតុលាការ ICJ។ *សូមមើល* របាយការណ៍តុលាការ ICJ ដែលមានចំណងជើងថា *North Sea Continental Shelf Cases* (១៩៦៦), កថាខណ្ឌ ៧៤។

[290] ពិធីសាបន្ថែមទៅនឹងសន្ធិសញ្ញាទីក្រុងហ្សឺណែវ ថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ និងទាក់ទងនឹងការការពារជនរងគ្រោះនៃជម្លោះប្រដាប់អាវុធអន្តរជាតិ ("ពិធីសារបន្ថែម I"), ថ្ងៃទី៨ ខែមិថុនា ឆ្នាំ១៩៧៧។

ចងក្រងគោលការណ៍នៃទំនួលខុសត្រូវរបស់ថ្នាក់លើដែលមានពីមុន។ ក.ស.ព បានលើកយកសាលក្រមកាត់សេចក្តី Celebici នៅតុលាការ ICTY មកធ្វើជាអំណះអំណាង។ អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង Celebici ពិតជាបានគូសបញ្ជាក់ថា "ការសិក្សាទៅលើ *ឯកសារការងារត្រៀមរៀបចំ* នៃបញ្ញត្តិទាំងអស់នេះបង្ហាញថា <u>ទោះបីការដាក់បញ្ចូលគោលការណ៍នេះទទួលបានការជំទាស់ ក្នុងអំឡុងពេលតាក់តែងសេចក្តីព្រាងពិធីសារនេះក៏ពិតមែន</u> ក៏ប៉ុន្តែសមាជិកមួយចំនួនបានបញ្ចេញទស្សនៈច្បាស់លាស់ថាគោលការណ៍ដែលបានស្នើឡើងនោះ គឺស្របជាមួយច្បាប់ដែលមានពីមុនស្រាប់"[291]។ ឯកសារសំអាងផ្លូវច្បាប់ដែលអង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី Celebici លើកយកមកធ្វើជាអំណះអំណាងពុំបានគាំទ្រអំណះអំណាងដែលថា "សមាជិកមួយចំនួន" បានសម្តែងទស្សនៈច្បាស់លាស់ថាគោលការណ៍នេះមានចែងនៅក្នុងមាត្រា ៨៦ និង ៨៧ នៃពិធីសារបន្ថែម I គឺស្របជាមួយច្បាប់ដែលមានពីមុនស្រាប់ឡើយ។ អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី Celebici បានលើកយកប្រទេសចំនួន២ប៉ុណ្ណោះគឺយូហ្គោស្លាវី និងស៊ុយអែត មកធ្វើជាសំអាង។ កំណត់ត្រាសង្ខេបស្តីពីការពិចារណាទៅលើពិធីសារបន្ថែម I និង II បង្ហាញថាពុំមានការឯកភាពគ្នាណាមួយដែលថាមាត្រា ៨៦ និងមាត្រា ៨៧ នៃពិធីសារបន្ថែម I បានចងក្រងបង្កើតបានជាច្បាប់ដែលមានស្រាប់ឡើយ[292]។ ក.ស.ព អះអាងទៀតថាអង្គជំនុំជម្រះតុលាការឧទ្ធរណ៍នៃតុលាការ ICTY "បានសន្និដ្ឋានថា

---

[291] សាលក្រមក្នុងរឿងក្តី *Čelebići*, កថាខណ្ឌ៣៤០ (គូសបញ្ជាក់បន្ថែម)។

[292] សូមមើល Official Records of the Diplomatic Conference on the Reaffirmation and Development of International Humanitarian Law Applicable in Armed Conflicts (Swiss Federal Political Department: Bern 1978), CCDH/1/SR.71, Vol. IX. ប្រទេសនីហ្សេរីយ៉ា បានបោះឆ្នោតគាំទ្រមាត្រា៧៦ស្ទួន ដោយហេតុថា "ខ្លួនយល់ឃើញថាជា<u>ការបោះជំហានមួយនៅក្នុងផ្លូវត្រូវ</u>"។ ដើងទំព័រខាងលើ, ត្រង់លេខ ៤០៨, កថាខណ្ឌ ៤៥ (គូសបញ្ជាក់បន្ថែម)។ សមាជិកសភា អ៊ុយក្រែនបានសំដែងការគាំទ្រលើមាត្រា ៧៦ និងបានទាញចំណាប់អារម្មណ៍ទៅលើការដែលថា "នេះជាលើកដំបូងដែលច្បាប់អន្តរជាតិដែលមានលក្ខណៈសុទិដ្ឋិនិយមបានចែងអំពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ជនទាំងឡាយណា ដែលពុំបានចាត់វិធានការណ៍ចាំបាច់ដើម្បីទប់ស្កាត់អំពើបំពារបំពានលើពិធីសារនេះ"។ ដើងទំព័រខាងលើ, ទំព័រ៣៤, កថាខណ្ឌ ៣៩។ ក្រុមអ្នកតំណាងរាស្ត្រឥណ្ឌូនេស៊ីបានគូសបញ្ជាក់ថាគេពុំអាចគាំទ្រមាត្រា ៧៦ ពាក់ព័ន្ធនឹងការពុំបានចាត់វិធានការឡើយ។ "ក្រៅពីការដែលថាក្រមព្រហ្មទណ្ឌប្រទេសនីមួយៗ ខុសគ្នា ច្បាប់ជាតិមួយចំនួនអាចពុំស្របគ្នាជាមួយបញ្ញត្តិនៃមាត្រានោះ។ ប្រសិនបើយ៉ាងដូច្នោះមែន គេអាចចាត់ទុកមាត្រា៧៦ ថាជាការជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់រដ្ឋមួយ"។ ដើងទំព័រខាងលើ, ទំព័រ៤៥, កថាខណ្ឌ ៩។ មាត្រា ៧៦ បានប្រែក្លាយទៅជាមាត្រា៨៦ ហើយមាត្រា៧៦ស្ទួន បានក្លាយជាមាត្រា ៨៧ នៅក្នុងសំណៅចុងក្រោយនៃពិធីសារបន្ថែម I។ សូមមើលដើងទំព័រខាងលើ, វ៉ុល III, ទំព័រ ៣២៨។

គោលការណ៍ទំនួលខុសត្រូវរបស់ថ្នាក់លើគឺជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅមុនពេលមានការអនុម័តិពិធីសារបន្ថែម I ក្នុងឆ្នាំ១៩៧៧ ហើយពិធីសារនេះគ្រាន់តែជាសេចក្តីប្រកាសអំពីឋានៈដែលមានស្រាប់ក្រោមច្បាប់អន្តរជាតិប៉ុណ្ណោះ”[293]។ សេចក្តីសម្រេច និងសាលក្រម /សាលដីការបស់តុលាការ ICTY ពុំចងកាតព្វកិច្ចលើ អ.វ.ត.ក ឡើយ ហើយសេចក្តីសម្រេច និងសាលក្រម/សាលដីកាទាំងអស់នោះ មានកំហុសឆ្គង ដូចដែលយើងបានលើកយកមកពិភាក្សាខាងក្រោម ត្រង់ផ្នែកនិយាយអំពីការយកគោលការណ៍ទំនួលខុសត្រូវរបស់ថ្នាក់លើមកអនុវត្តលើជនស៊ីវិល និងជម្លោះប្រដាប់អាវុធដែលពុំមែនជាជម្លោះប្រដាប់អាវុធអន្តរជាតិ។ ក.ស.ព ក៏បានអះអាងដែរថា មានវិការៈនៅក្នុងអំណះអំណាងរបស់មេធាវីការពារក្តីដែលថា ពិធីសារបន្ថែម I ពុំបានទទួលសច្ចាប័នទូលំទូលាយឡើយ ហើយទើបតែបានទទួលនៅក្រោយពេលពាក់ព័ន្ធប៉ុណ្ណោះ ដែលត្រង់នេះបង្ហាញថាគោលការណ៍ទំនួលខុសត្រូវរបស់ថ្នាក់លើ ពុំមែនជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ឡើយ។ ក.ស.ព អះអាងថាអំណះអំណាងនេះមានវិការៈ ដោយហេតុថារដ្ឋពុំអាចផ្តល់សច្ចាប័នដល់សន្ធិសញ្ញាណាមួយតាមហេតុផល ដែលពុំពាក់ព័ន្ធនឹងបញ្ហាថាតើរដ្ឋទាំងនោះចាត់ទុកថាគោលការណ៍ដែលមាននេះ មានឋានៈជាគោលការណ៍ភ្ជាប់កាតព្វកិច្ចដែរឬយ៉ាងណាឡើយ។ ត្រង់នេះពុំបង្ហាញថាអំណះអំណាងរបស់មេធាវីការពារក្តីមានវិការៈឡើយ។ ការដែលថារដ្ឋជាច្រើនទើបតែបានផ្តល់សច្ចាប័នដល់ពិធីសារបន្ថែម I នៅក្រោយពេលចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ <u>គឺជាភស្តុតាងមួយគាំទ្រដល់ការសន្និដ្ឋានថា រដ្ឋទាំងនេះពុំយល់ឃើញថាខ្លួនជាប់កាតព្វកិច្ចតាមរយៈបញ្ញត្តិដែលមានចែងក្នុងមាត្រាទាំងនេះនៅពេលពាក់ព័ន្ធឡើយ។</u>

### ៣. ការយកគោលការណ៍ទំនួលខុសត្រូវរបស់ថ្នាក់លើមកអនុវត្តនៅ អ.វ.ត.ក ពុំបំពេញតាមលក្ខខណ្ឌតម្រូវឱ្យមានភាពអាចដឹងមុនថាជាបទឧក្រិដ្ឋ និងភាពអាចដឹងថាមានច្បាប់ចែង និងពុំស្របតាមគោលការណ៍នីត្យានុកូលភាពឡើយ

១២៣. ត្រង់កថាខណ្ឌ ២៣៣ ក.ស.ព អះអាងថាការដែលថាឧក្រិដ្ឋកម្ម ឬទម្រង់នៃទំនួលខុសត្រូវណាមួយមានឋានៈជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ “គឺជាសញ្ញាបញ្ជាក់យ៉ាងច្បាស់មុតមាំថាលក្ខខណ្ឌតម្រូវឱ្យមាន

[293] ចម្លើយតប កថាខណ្ឌ ២៣០។

ភាពអាចដឹងមុនថាជាបទឧក្រិដ្ឋ និងភាពអាចដឹងថាមានច្បាប់ចែងត្រូវបានបំពេញ”។ ក.ស.ព លើកយកសាលដីកាមួយរបស់អង្គបុរេជំនុំជម្រះ និងតុលាការ ICTY មកធ្វើជាសំអាងដើម្បីគាំទ្រអំណះអំណាងនេះ។ អង្គបុរេជំនុំជម្រះពុំបានសម្រេចថាប្រសិនបើឧក្រិដ្ឋកម្ម ឬគោលការណ៍នៃទំនួលខុសត្រូវរបស់ថ្នាក់លើណាមួយមានឋានៈជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ នោះលក្ខខណ្ឌតម្រូវឱ្យមានភាពអាចដឹងមុនថាជាបទឧក្រិដ្ឋ និងភាពអាចដឹងថាមានច្បាប់ចែងអាចត្រូវបានបំពេញឡើយ។ អង្គបុរេជំនុំជម្រះគ្រាន់តែបានកត់សម្គាល់ថា “សេចក្តីសម្រេចរបស់តុលាការ ICTY មួយចំនួនហាក់ចង់មានន័យថា ប្រសិនបើទម្រង់នៃទំនួលខុសត្រូវណាមួយមានចែងនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅពេលពាក់ព័ន្ធ នោះគេអាចសន្និដ្ឋានបានអំពីលក្ខខណ្ឌនៃភាពអាចដឹងមុនថាជាបទឧក្រិដ្ឋ និងភាពអាចដឹងថាមានច្បាប់ចែង”[294]។ អង្គបុរេជំនុំជម្រះបានគូសបញ្ជាក់ទៀតថា ខ្លួនបានយល់ឃើញថាជាការច្បាស់លាស់ដែលត្រូវបញ្ជាក់ថាតើជនជាប់ចោទបានដឹងដែរឬទេថាមានច្បាប់ចែងអំពី JCE និងអាចដឹងដែរឬទេមុនថា JCE ជាបទឧក្រិដ្ឋ[295]។ វិធីសាស្ត្រនេះសមស្របសម្រាប់អនុវត្ត នៅពេលណាគេយកភាពអាចដឹងមុនថាជាបទឧក្រិដ្ឋ និងភាពអាចដឹងថាមានច្បាប់ចែងអំពីឧក្រិដ្ឋកម្មអន្តរជាតិ និងទម្រង់នៃទំនួលខុសត្រូវទាំងអស់មកពិចារណា។ ត្រង់ជើងទំព័រ ៥៨១ ក.ស.ព អះអាងថាដោយហេតុថាកម្ពុជាពុំបានជំទាស់ទៅនឹងការយកគោលការណ៍ទំនួលខុសត្រូវរបស់ថ្នាក់លើ មកអនុវត្ត ទើបគេអាចយកគោលការណ៍នេះមកអនុវត្តនៅកម្ពុជាបាន ក្នុងលក្ខណៈជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ ការដែលថាកម្ពុជាពុំបានជំទាស់ទៅនឹងការយកគោលការណ៍ទំនួលខុសត្រូវរបស់ថ្នាក់លើមកអនុវត្ត ពុំបង្ហាញថាគេអាចយកគោលការណ៍នេះមកអនុវត្តនៅកម្ពុជាបានឡើយ។ គោលការណ៍ទំនួលខុសត្រូវរបស់ថ្នាក់លើត្រូវមានចែងក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិជាមុនសិន មុនពេលមានការវាយតម្លៃចាំបាច់ណាមួយអំពីថាតើមានរដ្ឋណាមួយបានជំទាស់គោលការណ៍នេះយ៉ាងដាច់អហង្កា និងដោយចំហរដែរឬទេនោះ។

១២៤. ត្រង់កថាខណ្ឌ ២៣៤ ក.ស.ព អះអាងថាមនុស្សស្គាល់ហេតុផលផងទាំងឡាយដែលស្ថិតក្នុងស្ថានភាពដូចលោក អៀង សារី នឹងអាចយល់ឃើញថាគេអាចចាត់ទុកទង្វើរបស់គាត់ថាជាអំពើឧក្រិដ្ឋ។ ក.ស.ព អះអាងថាការកាត់សេចក្តីទាំងប៉ុន្មាននៅក្រោយសម័យសង្គ្រាមលោកលើកទី២ “គឺជាការបង្ហាញគួរឱ្យ

---

[294] សាលដីកា អ.ប.ជ លើ JCE, កថាខណ្ឌ ៤៥។

[295] *ដូចជើងទំព័រខាងលើ។*

ចាប់អារម្មណ៍" ថាតុលាការអាចយកគោលការណ៍ទំនួលខុសត្រូវរបស់ថ្នាក់លើមកអនុវត្តបាន។ ត្រង់កថាខណ្ឌ ២៣៥ ក.ស.ព បានលើកអំណះអំណាងមួយចំនួន(ដែលមេធាវីការពារក្តីពុំឯកភាព) ដើម្បីគាំទ្រទឡ្ហីករណ៍ដែលថាលោក អៀង សារី អាចបានដឹងមុនថាតុលាការអាចយកគោលការណ៍ទំនួលខុសត្រូវរបស់ថ្នាក់លើមកអនុវត្តលើរូបគាត់។ លោក អៀង សារី ពុំអាចដឹងមុនបានឡើយអំពីគោលការណ៍ទំនួលខុសត្រូវរបស់ថ្នាក់លើ ដោយហេតុថាគោលការណ៍នេះពុំមានចែងនៅក្នុងច្បាប់ជាធរមាននៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ដែលជាពេលពាក់ព័ន្ធ[296]។ លើសពីនេះ មនុស្សដែលពុំមានវិជ្ជាជីវៈជាមេធាវី និងមនុស្សដែលមិនមែនមកពីរដ្ឋណាមួយពាក់ព័ន្ធទៅនឹងសំណុំរឿងក្រោយសង្គ្រាមលោកលើកទីII (កុំថាឡើយមេធាវីឧក្រិដ្ឋកម្មអន្តរជាតិ) ទំនងជាពុំបានដឹងអំពីការយកគោលការណ៍នេះ ទៅប្រើប្រាស់ក្នុងសំណុំរឿងមួយចំនួនតូចកាលក្រោយសង្គ្រាមលោកលើកទី២ឡើយ។ នេះជាការពិតទោះបីលោក អៀង សារី អាចជាមនុស្សចេះដឹង ឬធ្លាប់បានធ្វើដំណើរទៅបរទេសច្រើនក្តី។

១២៥. ត្រង់កថាខណ្ឌ ២៣៦ ក.ស.ព អះអាងថាការបកស្រាយ និងការដុសខាត់ធាតុផ្សំនៃទំនួលខុសត្រូវរបស់ថ្នាក់លើ ពុំរំលោភលើគោលការណ៍នីត្យានុកូលភាពឡើយ។ មានយុត្តិសាស្ត្រមួយដែលកំណត់ថាមិនមែនជាការរំលោភគោលការណ៍នីត្យានុកូលភាពឡើយ ប្រសិនបើ តុលាការបកស្រាយ ឬបញ្ជាក់បំភ្លឺអំពីវិធានណាមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ[297]។ យ៉ាងណាមិញ ការកំណត់បែបនេះគឺជាការទទួលស្គាល់នូវអត្ថិភាពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ នៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ គោលការណ៍ទំនួលខុសត្រូវរបស់ថ្នាក់លើពុំមានចែងក្នុងច្បាប់ទេ។

១២៦. ត្រង់កថាខណ្ឌ ២៣៧ ក.ស.ព អះអាងថា លោក អៀង សារី អាចបានដឹងគ្រប់គ្រាន់ថាមានច្បាប់ដែលចែងអំពីទំនួលខុសត្រូវ តាមគោលការណ៍ទំនួលខុសត្រូវរបស់ថ្នាក់លើ ដោយយោងតាមឋានៈ

---

[296] *សូមមើល* បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៨៣-៣០២។

[297] *សូមមើល រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Vasiljević, IT-98-32-T, សាលក្រម ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០២ កថាខណ្ឌ ១៩៣។ "តាមគំនិតនៃគោលការណ៍ *គ្មានបទល្មើសបើគ្មានច្បាប់ចែង* ជាការដែលមិនអាចទទួលយកបានចំពោះអង្គជំនុំជម្រះសាលាដំបូង ក្នុងការផ្តន្ទាទោសជនជាប់ចោទណាម្នាក់ ដោយផ្អែកតាមការហាមឃាត់ណាមួយដែលពុំមានលក្ខណៈច្បាស់លាស់គ្រប់គ្រាន់ក្នុងការកំណត់ទង្វើណាមួយ និងញែកអំពើឧក្រិដ្ឋចេញពីអំពើដែលអាចច្បាប់អនុញ្ញាត ឬជនជាប់ចោទពុំបានដឹងថាមានច្បាប់ចែងនៅពេលពាក់ព័ន្ធ ដោយលើកយកពិចារណាប្រភេទលក្ខណៈនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងការអនុញ្ញាតឲ្យមានការបញ្ជាក់បំភ្លឺជាបណ្តើរៗនៃវិធាននៃច្បាប់ព្រហ្មទណ្ឌ"។

ជាច្បាប់ទំនៀមទម្លាប់អន្តរជាតិរបស់គោលការណ៍នេះ។ ទោះបីពេលនោះ ច្បាប់ទំនៀមទម្លាប់អន្តរជាតិ មានចែងអំពីគោលការណ៍ទំនួលខុសត្រូវរបស់ថ្នាក់លើក្តី ក៏មិនបានធ្វើឲ្យលោក អៀង សារី ដឹងឡើយ។ នៅទសវត្សរ៍ឆ្នាំ១៩៧០ ពិសេសនៅកម្ពុជាក្រោយសម័យសង្គ្រាមស៊ីវិល គេពុំអាចដឹងព័ត៌មានបាន ងាយស្រួលដូចសព្វថ្ងៃនេះទេ។ ជាការពុំទំនងទាល់តែសោះដែលថាលោក អៀង សារី អាចបានដឹង ច្បាស់ថាទំនួលខុសត្រូវរបស់ថ្នាក់លើ គឺជាទម្រង់នៃទំនួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គល មួយដែលមានសុពលភាពក្នុងច្បាប់កម្ពុជា ឬច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ ជាការពុំសូវទំនង ថែមមួយកម្រិតទៀតដែលថាលោក អៀង សារី បានដឹងថាមានឯកសារមួយចំនួនពាក់ព័ន្ធនឹង ទំនួលខុសត្រូវរបស់ថ្នាក់លើដូចជា ពិធីសារបន្ថែម I[298] ដែលអាចឲ្យគាត់ដឹងថាថ្នាក់លើដែលជា ជនស៊ីវិលក៏អាចត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌផងដែរនោះ។

### ខ. ដីកាដំណោះស្រាយមានកំហុសឆ្គងក្នុងការអះអាងអំពីយុត្តាធិការលើទំនួលខុសត្រូវរបស់ថ្នាក់លើ

#### ១. គោលការណ៍ទំនួលខុសត្រូវរបស់ថ្នាក់លើ ពុំអាចយកមកអនុវត្ត ចំពោះថ្នាក់លើ ដែលជាជនស៊ីវិលនៅចន្លោះឆ្នាំ៩៧៥ ដល់ឆ្នាំ១៩៧៩ បានឡើយ

១២៧. ត្រង់កថាខណ្ឌ ២៣៩ ក.ស.ព អះអាងថា "អនុលោមតាមគោលការណ៍ច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលតុលាការបានយកមកអនុវត្តប្រកបដោយសង្គតិភាពក្នុងយុត្តិសាស្ត្រអន្តរជាតិចាប់តាំងពីទសវត្សរ៍ ឆ្នាំ១៩៥០ តុលាការអាចដាក់ថ្នាក់លើជាយោធា និងថ្នាក់លើជាជនស៊ីវិល ដែលមានសិទ្ធិអំណាច គ្រប់គ្រងប្រកបដោយប្រសិទ្ធភាពលើមនុស្សក្រោមបង្គាប់ ឲ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌពីបទឧក្រិដ្ឋ ដែលមនុស្សក្រោមបង្គាប់របស់ខ្លួនបានប្រព្រឹត្ត"។ អំណះអំណាងនេះពុំត្រឹមត្រូវទេ។ ចាប់តាំងពី ទសវត្សរ៍ឆ្នាំ១៩៥០ តុលាការពុំដែលបានយកគោលការណ៍ទំនួលខុសត្រូវរបស់ថ្នាក់លើ មកអនុវត្តប្រក បដោយសង្គតិភាពទៅលើថ្នាក់លើដែលជាជនស៊ីវិលឡើយ។ ក.ស.ព លើកយកឧទាហរណ៍មួយចំនួន តូចដែលនិយាយអំពីសំណុំរឿងក្រោយសម័យសង្គ្រាមលោកលើកទី២ មកបង្ហាញដែលក្នុងនោះ

---

[298] ទោះបីមាត្រា៨៦ នៃពិធីសារបន្ថែម I តាមរយៈពាក្យពេចន៍របស់វា ពុំបានកំណត់ត្រឹមមេបញ្ជាការយោធាក្តី ក៏មាត្រានេះត្រូវបាន ចាត់ទុកថាអាចយកមកអនុវត្តបានជាចម្បងលើពួកគេដែរ។ Yael Ronen, *Superior Responsibility of Civilians for International Crimes Committed in Civilian Settings*, 43 VAND. J. TRANSNAT'L L. 313, 317 (ឆ្នាំ២០១០) ("Ronen")។

គោលការណ៍នេះត្រូវបានតុលាការយកមកអនុវត្តទៅលើថ្នាក់លើ ដែលជាជនស៊ីវិល[299]។ យោងតាមសំណេររបស់មន្ត្រីពិគ្រោះផ្នែកច្បាប់ជាន់ខ្ពស់មួយរូបនៃការិយាល័យរដ្ឋអាជ្ញានៅតុលាការ ICTY នៅឆ្នាំ ១៩៩៥ “នៅក្នុងសំណេរនេះ គោលការណ៍ទំនួលខុសត្រូវរបស់ថ្នាក់លើ ត្រូវបានចាត់ទុកជាទូទៅថាជាគោលការណ៍ដែលអាចយកមកអនុវត្តបានជាចាំបាច់លើមេបញ្ជាការយោធា និងពាក់ព័ន្ធជាចម្បងទៅនឹងទំនួលខុសត្រូវចំពោះការពុំបានចាត់វិធានការ”[300]។ យោងតាមបណ្ឌិត Yael Ronen នៅក្នុងអត្ថបទមួយដែលគាត់បានសរសេរកាលពីពេលថ្មីៗ សម្រាប់យកអាហាររូបករណ៍ថ្នាក់ក្រោយបណ្ឌិតពាក់ព័ន្ធទៅនឹង “យុត្តិសាស្ត្រក្រោយសម័យសង្គ្រាមលោកលើកទី២ ពាក់ព័ន្ធនឹងថ្នាក់លើក្នុងជួរយោធា”[301] គាត់គូសបញ្ជាក់ថា “ការអះអាងថាច្បាប់ទំនៀមទម្លាប់អន្តរជាតិបានពង្រីកវិសាលភាពពីគោលការណ៍ទំនួលខុសត្រូវរបស់ថ្នាក់លើ ដល់ជនស៊ីវិលដោយពុំគិតពីកាលៈទេសៈស៊ីវិល គឺជាអំណះអំណាងពុំត្រឹមត្រូវទេ។ ក្នុងទម្លាប់អនុវត្តន៍របស់តុលាការ និងក្នុងសេចក្តីសម្រេចរបស់តុលាការនាពេលថ្មីៗ ជនស៊ីវិលកម្រត្រូវបានតុលាការផ្តន្ទាទោសតាមគោលការណ៍នេះណាស់ ទោះបីជនស៊ីវិលនោះមានឋានៈជាមេដឹកនាំអង្គការចាត់តាំងយោធាក្តី។ ហើយទោះនៅពេលមានការផ្តន្ទាទោសជនស៊ីវិលទៀតសោត ក៏ជាទូទៅ ការផ្តន្ទាទោសទាំងនោះពុំសូវមានសារសំខាន់ដល់ទំនួលខុសត្រូវផ្ទាល់របស់ពួកគេឡើយ”[302]។ ត្រង់កថាខណ្ឌ ២២៥ ក.ស.ព រៀបរាប់ និងពិភាក្សាត្រួសៗអំពីសំណុំរឿងមួយចំនួនក្រោយសម័យសង្គ្រាមលោកលើកទី២ ដែលខ្លួនគិតថាជាចំណុចគាំទ្រអំណះអំណាងដែលថាគោលការណ៍ទំនួលខុសត្រូវរបស់ថ្នាក់លើ ត្រូវបានយកមកអនុវត្តចំពោះថ្នាក់លើដែលជាជនស៊ីវិលក្នុងឋានៈជានីតិវិធីមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនាពេលបច្ចុប្បន្ន។ សំណុំរឿងទាំងនេះគាំទ្រតិចតួចដល់អំណះអំណាងនេះ ហើយបានត្រឹមតែបង្ហាញឱ្យកាន់តែច្បាស់ថែមទៀតថាកាលគ្រានោះ តុលាការពុំបានយកទម្រង់នៃទំនួលខុសត្រូវនេះមកអនុវត្តឱ្យបានច្បាស់លាស់ឡើយ។ ពាក់ព័ន្ធនឹងការជំនុំជម្រះនៅ Tokyo៖

ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនៅតុលាការ Tokyo មានបទចោទចំនួន២ ខុសគ្នា ដែលពាក់ព័ន្ធនឹង

---

[299] *សូមមើល* ចម្លើយតប កថាខណ្ឌ ២២៥។

[300] អត្ថបទរបស់ W. J. Fenrick មានចំណងជើងថា *Some International Law Problems Related to Prosecutions before the International Criminal Tribunal for the Former Yugoslavia*, 6 DUKE J. COMP. & INT'L L. ទំព័រ១០៣, ១១០ (ឆ្នាំ១៩៩៥)។

[301] Ronen, ត្រង់ជើងទំព័រលេខ ៣២០។

[302] ត្រង់ជើងទំព័រលេខ ៣១៣។

គោលបំណងបច្ចុប្បន្ន។ បទចោទ ៥៤ ពាក់ព័ន្ធនឹង "ការបញ្ជា, ការចាត់តាំង និងការអនុញ្ញាត" ចំណែកក្នុងបទចោទ ៥៥ ជនជាប់ចោទរងការចោទប្រកាន់ថា "ពុំបានអើពើដោយចេតនា និងដោយការធ្វេសប្រហែស នូវភារកិច្ចផ្លូវច្បាប់របស់ខ្លួនក្នុងការចាត់វិធានការឱ្យបានសមស្របដើម្បីធានាឱ្យមានការគោរពច្បាប់ និងទប់ស្កាត់ការរំលោភច្បាប់សង្គ្រាម។ អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង [Celebici] បានលើកយកការផ្តន្ទាទោសជនជាប់ចោទចំនួន៤រូបនៅតុលាការTokyo មកធ្វើជាសំអាងផ្លូវច្បាប់ចំពោះទំនួលខុសត្រូវរបស់ថ្នាក់លើដែលជាជនស៊ីវិល ក្នុងនោះមានជាអាទិដូចជាការផ្តន្ទាទោសឧត្តមសេនីយ៍ Matsui, នាយករដ្ឋមន្ត្រី Tojo, រដ្ឋមន្ត្រីក្រសួងការបរទេស Hirota និង Shigemitsu។ សម្រាប់ឧត្តមសេនីយ៍ Matsui តាមរយៈតំណែងរបស់គាត់បញ្ជាក់ថាគាត់ជាយោធា។ ...ដូច្នេះ ការផ្តន្ទាទោសរូបគាត់ពុំបង្កើតបានជាយុត្តិសាស្ត្រសម្រាប់គោលការណ៍ទំនួលខុសត្រូវរបស់ថ្នាក់លើដែលជាជនស៊ីវិលឡើយ។ តុលាការបានរកឃើញថានាយករដ្ឋមន្ត្រីTojo មានទោសពីបទឧក្រិដ្ឋកម្មសង្គ្រាមក្នុងបទចោទ៥៤ "ដោយសារគាត់បានណែនាំថាអ្នកទោសណាពុំព្រមធ្វើការ គួរកុំបរិភោគ" ប៉ុន្តែក្នុងបទចោទ ៥៥ វិញ តុលាការពុំបានផ្តល់សំអាងហេតុណាមួយឡើយ។ តុលាការបានរកឃើញថា Tojo ជាអ្នកទទួលខុសត្រូវផ្ទាល់ ជាជាងការទទួលខុសត្រូវចំពោះការពុំបានទប់ស្កាត់មិនឱ្យមនុស្សក្រោមបង្គាប់របស់ខ្លួនប្រព្រឹត្តអំពើល្មើសច្បាប់។ រដ្ឋមន្ត្រីក្រសួងការបរទេស Hirota និង Shigemitsu ត្រូវបានផ្តន្ទាទោសតាមបទចោទ ៥៥ ចំពោះការពុំបានចាត់វិធានការសមស្របនៅពេលមានរបាយការណ៍ស្តីពីឧក្រិដ្ឋកម្មសង្គ្រាម...។ តុលាការនេះ... បានដាក់រដ្ឋមន្ត្រីទាំង២រូប ឱ្យទទួលខុសត្រូវចំពោះការពុំបានជំរុញឱ្យរដ្ឋាភិបាលបំពេញកាតព្វកិច្ចរបស់ខ្លួន ក្នុងការធានាសុខមាលភាពរបស់អ្នកទោស និងជនស៊ីវិលក្រោមការគ្រប់គ្រងរបស់ខ្លួន។ ជាពិសេស ពុំមានសំណុំរឿងណាមួយពាក់ព័ន្ធនឹងអំណះអំណាងថា រដ្ឋមន្ត្រីរូបនេះគឺជាថ្នាក់លើផ្ទាល់ ឬប្រយោល របស់ចារី ឬគាត់អាចបានធ្វើអ្វីមួយប៉ះពាល់ផ្ទាល់ដល់ទង្វើរបស់ចារី។ ទំនួលខុសត្រូវរបស់ចារីក្រោមបទចោទ៥៥ គឺផ្អែកតាមការពុំអើពើនឹងភារកិច្ច ក្នុងឋានៈជាសមាជិកសមូហភាពនៃរដ្ឋាភិបាល។ ចៅក្រម Roling ជាអ្នកជំទាស់លើការផ្តន្ទាទោសនេះ ហើយលើកលែងការចោទប្រកាន់រដ្ឋមន្ត្រីទាំង២រូប។ ចៅក្រមរូបនេះមានភាពស្រពេចស្រពិលជាទូទៅមួយ ចំពោះការសំអាងលើគោលការណ៍នេះ ហើយគាត់បានក្រើនរម្លឹកជាពិសេសអំពីការដាក់ឱ្យមន្ត្រីរដ្ឋាភិបាលដែលជាជនស៊ីវិល ទទួលខុសត្រូវចំពោះទង្វើរបស់កងទ័ព

ក្នុងសមរភូមិ[303]។ ពាក់ព័ន្ធនឹងការជំនុំជម្រះក្នុងរឿងក្តី *Roechling* ដែល ក.ស.ព បានលើកយកមកសំអាង "ផ្អែកតាមការផ្តន្ទាទោសក្នុងសំណុំរឿង Roechling ទំនួលខុសត្រូវរបស់ចុងចោទហាក់ដូចជាផ្អែកតាមការចូលរួមផ្ទាល់របស់ពួកគេតាមរយៈការ "ការគាំទ្រ" ឧក្រិដ្ឋកម្ម។ ការចាត់ទុកការចូលរួមក្នុងឧក្រិដ្ឋកម្មនេះថាជា "ការជួយ និងជំរុញ" គឺជាការមួយសមស្របជាងនេះ[304]។

១២៨. ត្រង់កថាខណ្ឌ ២៤០ ក.ស.ព អះអាងថាយុត្តិសាស្ត្ររបស់តុលាការ ICTY និង ICTR មានប្រយោជន៍ដោយហេតុថាបញ្ញត្តិតាមលក្ខន្តិកៈរបស់វាស្តីពីទំនួលខុសត្រូវរបស់ថ្នាក់លើស្រដៀងទៅនឹងមាត្រា២៩ នៃច្បាប់ អ.វ.ត.ក។ ក.ស.ព អះអាងថាសំអាងហេតុរបស់តុលាការទាំង២ មានសារសំខាន់ដោយហេតុថាទស្សនទាននៃទំនួលខុសត្រូវរបស់ថ្នាក់លើមានការវិវឌ្ឍន៍តិចតួច នៅចន្លោះទសវត្សរ៍ឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៩០។ ដូចអ្វីដែលយើងបានពន្យល់ គឺថាសំណុំរឿងជាច្រើនដែលអង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY ក្នុងសំណុំរឿង Celebici បានលើកយកមកសំអាងក្នុងការសម្រេចអំពីលទ្ធភាពយកគោលការណ៍ទំនួលខុសត្រូវរបស់ថ្នាក់លើមកអនុវត្តលើជនស៊ីវិល ពុំគាំទ្រអំណះអំណាងខាងលើរបស់ ក.ស.ព ឡើយ។ បណ្ឌិត Ronen កត់សម្គាល់ឃើញថា "មាត្រា៦/៧(៣) [បញ្ញត្តិស្តីពីទំនួលខុសត្រូវរបស់ថ្នាក់លើនៃលក្ខន្តិកៈតុលាការ ICTR និង ICTY នីមួយៗ] អាចបានបង្កើតឱ្យមាន ឬយ៉ាងហោចណាស់បានចូលរួមចំណែកដល់ដំណើរវិវឌ្ឍន៍នៃច្បាប់ទំនៀមទម្លាប់អន្តរជាតិលើបញ្ហានេះ"[305]។ គាត់បានកត់សម្គាល់ទៀតថា "ទោះបីទំនួលខុសត្រូវរបស់ថ្នាក់លើដែលជាជនស៊ីវិល គឺជាគោលការណ៍រឹងមាំមួយនៅក្នុងតុលាការមិនអចិន្ត្រៃយ៍ក្តី ក៏យុត្តិសាស្ត្រទូទៅនៃតុលាការ ICTY និង ICTR មុន Nahimana ផ្តល់ជាឧទាហរណ៍អំពីការផ្តន្ទាទោសចំនួន២ប៉ុណ្ណោះ ដោយឈរលើគោលការណ៍ទំនួលខុសត្រូវរបស់ថ្នាក់លើ។ ការផ្តន្ទាទោសទាំង២ ពាក់ព័ន្ធនឹងបុគ្គលដែលជាយោធា ឬជីវពល "[306]។ លើសពីនេះ ដោយពុំបានទទួលស្គាល់ថាតុលាការ ICTY ឬ ICTR មានភាពត្រឹមត្រូវក្នុងការយកគោលការណ៍ទំនួលខុសត្រូវរបស់ថ្នាក់លើមកអនុវត្តលើជនស៊ីវិល ក៏នៅមានការវិវឌ្ឍន៍នានាក្នុង

---

[303] ដូចជើងទំព័រខាងលើ ទំព័រ ៣២១-៣២២ (គូសបញ្ជាក់បន្ថែម)។

[304] ដូចជើងទំព័រខាងលើ ទំព័រ ៣២៣។

[305] ដូចជើងទំព័រខាងលើ ទំព័រ ៣២៤។

[306] *ដូចជើងទំព័រខាងលើ* ត្រង់ទំព័រ ៣២៩។

គោលការណ៍ទំនួលខុសត្រូវរបស់ថ្នាក់លើ ក្នុងអំឡុងរយៈកាលនេះដែរ ដូចជាការចូលជាធរមាននៃពិធីសារបន្ថែម I (ដែលពុំបានចងក្រងជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដូចដែលបានលើកយកមកពន្យល់ខាងដើម) និងការផ្តល់សច្ចាប័នពីសំណាក់រដ្ឋនានា ជាហូរហែ។

១២៩. ត្រង់កថាខណ្ឌ ២៤១ ក.ស.ព បានលើកឡើងអំពីធាតុផ្សំនៃទំនួលខុសត្រូវរបស់ថ្នាក់លើនៅតុលាការ ICTY និង ICTR។ ត្រង់កថាខណ្ឌ ២៤២ ក.ស.ព អះអាងថាយុត្តិសាស្ត្រតុលាការ ICTY និង ICTR បានកំណត់ថាថ្នាក់លើជាអ្នកមាន "អំណាចគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព" លើមនុស្សក្រោមបង្គាប់ ហើយវិធាន*[ការ]*ស្តីពីការគ្រប់គ្រងដោយប្រសិទ្ធភាពនេះ អាចយកមកអនុវត្តបានទៅលើថ្នាក់លើតាម *ព្រឹត្តិន័យ* និង*ជាក់ស្តែង*។ ត្រង់កថាខណ្ឌ ២៤៣ ក.ស.ព អះអាងថា "ក្នុងការវាយតម្លៃអំពីអត្ថិភាពនៃសិទ្ធិអំណាច *ជាក់ស្តែង* តុលាការបានពិចារណាទៅលើកត្តាមួយចំនួន ក្នុងនោះរួមមានថាតើមានការបង្ហាញឱ្យឃើញអំពីការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព តាមរយៈការគ្រប់គ្រងរបស់ថ្នាក់លើទៅលើមនុស្សក្រោមបង្គាប់របស់ខ្លួនដែរ ឬយ៉ាងណា...។ ប៉ុន្តែ នៅមានបញ្ហាមួយ ក្នុងការប្រៀបធៀបការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពទៅនឹងសិទ្ធិអំណាច *ជាក់ស្តែង*។ "កាតព្វកិច្ចដែលផ្អែកផ្ទាល់លើលទ្ធភាពក្នុងការចាត់វិធាន*[ការ]* ប្រកបដោយប្រសិទ្ធភាព បង្កើតបានជាគោលការណ៍ អ្នកគ្មានរបួសត្រូវជួយអ្នករបួសឬអ្នកឈឺ (Good Samaritan) ក្នុងលក្ខណៈជាមូលដ្ឋាននៃទំនួលខុសត្រូវផ្អែកព្រហ្មទណ្ឌអន្តរជាតិ...។ ប្រសិនបើត្រឹមតែឥទ្ធិពលមួយមុខ ទោះតូចក្តីធំក្តី ត្រូវបានទទួលស្គាល់ថាជាមូលដ្ឋានមួយនៃទំនួលខុសត្រូវរបស់ថ្នាក់លើ នោះជនស៊ីវិលណាម្នាក់ឱ្យតែបានទទួលការគោរពពីសង្គមនឹងត្រូវប្រែក្លាយដោយស្វ័យប្រវត្តិទៅជាថ្នាក់លើតែម្តង ដែលនេះនឹងបង្កើនឱកាសឱ្យមានការកាត់សេចក្តីពួកគាត់ចំពោះឧក្រិដ្ឋកម្ម ដែលមនុស្សផ្សេងជាអ្នកប្រព្រឹត្ត"ទៅវិញ[307]។ គេត្រូវបង្កើតនូវលក្ខខណ្ឌតម្រូវឱ្យមានសិទ្ធិអំណាច ក្នុងក្របខ័ណ្ឌឋានានុក្រមចាត់តាំងប្រកបដោយស្មារតីឯករាជ្យ នៅមុនពេលមានការវិភាគណាមួយទៅលើការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព[308]។

១៣០. ត្រង់កថាខណ្ឌ ២៤៤ ក.ស.ព អះអាងថាអង្គជំនុំជម្រះសាលាដំបូងតុលាការ ICTY ក្នុងសំណុំរឿង Celebici និងអង្គជំនុំជម្រះតុលាការឧទ្ធរណ៍នៃតុលាការ ICTR ក្នុងសំណុំ រឿង Kayishema បាន

---

[307] *ដូចជើងទំព័រខាងលើ* ត្រង់ទំព័រ ៣៣៥, ៣៣៩។

[308] *ដូចជើងទំព័រខាងលើ* ត្រង់ទំព័រ ៣៤០។

យល់ឃើញថាខ្លួនអាចយកគោលការណ៍ទំនួលខុសត្រូវរបស់ថ្នាក់លើមកអនុវត្តលើជនស៊ីវិលបាន។ ប៉ុន្តែ ដូចអ្វីដែលបណ្ឌិត Ronen បានពន្យល់ប្រាប់៖

ក្នុងសំណុំរឿង Celebici និង Aleksovski ពួកចុងចោទគឺជាមេបញ្ជាការជាក់ស្តែង នៃជំរំពន្ធនាគារទាំងប៉ុន្មានដែលបានឃុំឃាំងយុទ្ធជន និងជនស៊ីវិល។ ពួកគេជាអ្នកទទួលខុសត្រូវលើស្ថានភាពក្នុងជំរំពន្ធនាគារ ដោយមានសិទ្ធិអំណាចជាក់ស្តែងលើពួកបុគ្គលិក, ឆ្មាំ, និងអ្នកជាប់ឃុំឃាំង។ ក្នុងសំណុំរឿងទាំង ២ តុលាការបានដាក់ឱ្យចុងចោទទទួលខុសត្រូវ លើការពុំបានទប់ស្កាត់ឧក្រិដ្ឋកម្មដែលមនុស្សក្រោមបង្គាប់បានប្រព្រឹត្ត។ ចុងចោទទាំងនោះក៏ត្រូវបានដាក់ឱ្យទទួលខុសត្រូវផ្ទាល់លើឧក្រិដ្ឋកម្មផ្សេងៗទៀតផងដែរ។ ក្នុងសំណុំរឿងទាំង២នេះគ្មានសំណុំរឿងណាមួយ ដែលតុលាការICTY បានផ្តល់សំអាងហេតុច្បាស់លាស់ថាតើចុងចោទជាជនស៊ីវិល ឬពុំមែនឡើយ[309]

អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង Kayishema ហាក់ដូចជាបានប្រព្រឹត្តកំហុសឆ្គង មួយផ្សេងពីនេះ៖

ជាការសំខាន់ដែលយើងត្រូវញែកឱ្យដាច់រវាងអំពើអកម្ម ដែលនាំទៅដល់ទំនួលខុសត្រូវ ផ្ទាល់ និងអំពើអកម្មដែលនាំទៅដល់ទំនួលខុសត្រូវក្នុងនាមជាថ្នាក់លើ។ អំពើអកម្មខាងដើមអាចបង្កើតបានជាកាតព្វកិច្ចនៃលទ្ធផល ចំណែកអំពើអកម្មខាងចុងគឺជាកាតព្វកិច្ចនៃទង្វើ។ ជាទូទៅចេតនាឧក្រិដ្ឋសម្រាប់អំពើអកម្មខាងដើម មានលក្ខណៈខ្លាំងក្លាជាងចេតនាឧក្រិដ្ឋសម្រាប់អំពើអកម្មខាងចុង ហើយមានតែចេតនាឧក្រិដ្ឋសម្រាប់អំពើអកម្មខាងចុង ដែលតម្រូវឱ្យមានការបញ្ជាក់អំពីបណ្តាញ បញ្ជាការ។ ប៉ុន្តែតុលាការ ICTR ហាក់ដូចជាបានយល់ច្រឡំទៅលើអំពើអកម្មទាំង២ប្រភេទនេះ។ ក្នុងសំណុំរឿង Kayishema នៅពេលតុលាការ ICTR ធ្វើការកំណត់ប្រភពនៃកាតព្វកិច្ចក្នុងការគ្រប់គ្រងមនុស្សក្រោមបង្គាប់ដែលមានភារកិច្ចថែរក្សាសណ្តាប់ធ្នាប់សាធារណៈ ខ្លួនបាននិយាយថាបញ្ហានៃទំនួលខុសត្រូវដែលចេញមកពីភារកិច្ចថែរក្សាសណ្តាប់ធ្នាប់សាធារណៈ “និងការពុំបានអនុវត្តភារកិច្ច គឺជាបញ្ហាចោទមួយដែលពាក់ព័ន្ធទាំងស្រុងទៅនឹងបញ្ហាស្តីពីទំនួលខុសត្រូវរបស់ថ្នាក់លើ។ នេះមកពីតាមមាត្រា៦(៣) នៃលក្ខន្តិកៈតុលាការ ICTR បានប្រគល់ភារកិច្ចទៅឱ្យមនុស្សក្នុងជួររដ្ឋអំណាចដែលមានមធ្យោបាយចាំ

[309] *ដូចជើងទំព័រខាងលើ* ត្រង់ទំព័រ ៣២៤។

បាច់ក្នុងដៃដើម្បីទប់ស្កាត់ ឬផ្ដន្ទាទោសការប្រព្រឹត្តឧក្រិដ្ឋកម្ម"។ ប៉ុន្តែ កុំនិយាយ ថា វា ពាក់ព័ន្ធជៀស មិនរួច កាតព្វកិច្ចក្នុងការចាត់វិធានការពុំចាំបាច់ពាក់ព័ន្ធទៅនឹងបញ្ហានៃទំនួលខុសត្រូវ របស់ថ្នាក់លើ ឡើយ។ កាតព្វកិច្ចមួយដែលពុំពាក់ព័ន្ធនឹងតួនាទីរបស់ថ្នាក់លើ គួរពុំនាំឲ្យមានការយកគោលការណ៍ ទំនួលខុសត្រូវរបស់ថ្នាក់លើមកអនុវត្តឡើយ[310]។

ក.ស.ព អះអាងទៀតថាច្បាប់ អ.វ.ត.ក ពុំបានដាក់កំហិតលើលទ្ធភាពក្នុងការយកទំនួលខុសត្រូវ របស់ថ្នាក់លើមកអនុវត្តចំពោះថ្នាក់លើដែលជាយោធាឡើយ។ <u>ច្បាប់បង្កើត អ.វ.ត.ក ពុំបាន បង្កើតច្បាប់ណាដែលត្រូវយកមកអនុវត្តដោយអានុភាពប្រតិសកម្មឡើយ</u>។ ច្បាប់នេះបានត្រឹមតែចែង អំពីឧក្រិដ្ឋកម្ម និងទម្រង់នៃទំនួលខុសត្រូវលើឧក្រិដ្ឋកម្មក្រោមយុត្តាធិការរបស់ អ.វ.ត.ក ប៉ុណ្ណោះ។ អ្វីដែលត្រូវយកមកអនុវត្តនៅទីនេះគឺច្បាប់ដែលបានមានអត្ថិភាពពិតប្រាកដនៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។

### ២. ទំនួលខុសត្រូវរបស់ថ្នាក់លើពុំអាចយកមកអនុវត្តក្នុងជម្លោះប្រដាប់អាវុធអន្តរជាតិនៅ ចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ បានឡើយ

១៣១. ត្រង់កថាខណ្ឌ២៤៧ ក.ស.ព អះអាងថាទំនួលខុសត្រូវរបស់ថ្នាក់លើ "គឺជាផលវិបាកដ៏សមស្របមួយ នៃការដាក់ទំនួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ជាលក្ខណៈបុគ្គលពីបទរំលោភច្បាប់សង្គ្រាម ដែលបុគ្គល ម្នាក់ៗបានអនុវត្តតាមបញ្ជាប្រកបដោយការទទួលខុសត្រូវ"។ ក.ស.ព អះអាងថាអង្គជំនុំជម្រះ តុលាការឧទ្ធរណ៍នៃតុលាការ ICTY ក្នុងសំណុំរឿង *Hadzihasanovic* បានទាញសន្និដ្ឋានដូចខាងលើ នេះ ក្នុងការសម្រេចថាទំនួលខុសត្រូវរបស់ថ្នាក់លើគឺជាគោលការណ៍ជាធរមាន ក្នុងបរិបទនៃជម្លោះ ប្រដាប់អាវុធអន្តរជាតិ។ ត្រង់កថាខណ្ឌ ២៤៨ និង២៤៩ ក.ស.ព បានលើកយក សេចក្ដីសម្រេចក្នុងរឿងក្ដី *Hadzihasanovic* មកពិភាក្សាបន្ថែមទៀត។ ត្រង់កថាខណ្ឌ ២៤៩ ក.ស.ព អះអាងថា អង្គជំនុំជម្រះតុលាការឧទ្ធរណ៍ក្នុងសំណុំរឿង *Hadzihasanovic* បានសម្រេចថាមាត្រា ៣រួម នៃអនុសញ្ញាទីក្រុងហ្សឺណែវ ត្រូវតែមានយន្តការក្នុងការពង្រឹងការអនុវត្តទោសព្រហ្មទណ្ឌទៅលើ

---

[310] *ដូចដើងទំព័រខាងលើ* ត្រង់ទំព័រ ៣៣៣។

ការប្រព្រឹត្តឧក្រិដ្ឋកម្មពាក់ព័ន្ធ។ ក.ស.ព អះអាងថាការពុំមានទម្រង់នៃទំនួលខុសត្រូវមួយពីបទរំលោភច្បាប់ និងទំនៀមទម្លាប់សង្គ្រាមដែលត្រូវបានប្រព្រឹត្តក្នុងបរិបទនៃជម្លោះប្រដាប់អាវុធអន្តរជាតិ គឺពុំស្របទៅនឹងកម្មវត្ថុនិងគោលបំណងនៃអនុ-សញ្ញាក្រុងហ្សឺណែវឡើយ ពិសេសមាត្រា៣រួម។ អំណះអំណាងនេះមានវិការៈ។ ទីមួយ ទំនួលខុសត្រូវមានទម្រង់ផ្សេងៗដូចជា ការប្រព្រឹត្ត ឬការបញ្ជា ដែលគេចាត់ទុកថាអាចយកមកអនុវត្តបានទៅលើជម្លោះប្រដាប់អាវុធពុំមែនអន្តរជាតិ។ យន្តការពង្រឹងការអនុវត្តពុំចាំបាច់ត្រូវជាប់ពាក់ព័ន្ធនឹងទំនួលខុសត្រូវរបស់ថ្នាក់លើឡើយ។ ទីពីរ ចេតនានៃអនុសញ្ញាទីក្រុងហ្សឺណែវគឺចង់ឲ្យគេយកអនុសញ្ញានេះមកអនុវត្ត តាមរយៈច្បាប់ជាតិ[311]។ នៅពេលមានការអនុវត្តអនុសញ្ញានេះ ទម្រង់នៃទំនួលខុសត្រូវជាលក្ខណៈជាតិជាធរមានអាចត្រូវបានយកមកអនុវត្ត។ អង្គជំនុំជម្រះតុលាការឧទ្ធរណ៍នៃតុលាការ ICTY ក្នុងសំណុំរឿង Hadzihasanovic ក្នុងលក្ខណៈជាតុលាការអន្តរជាតិពុំបានពិចារណាទៅលើទំនាក់ទំនងរវាងអនុសញ្ញាទីក្រុងហ្សឺណែវ និងច្បាប់ជាតិឡើយ។

១៣២. ត្រង់កថាខណ្ឌ ២៥០ ក.ស.ព អះអាងថាការដែលថាពិធីសារបន្ថែម II[312] (អាចយកមកអនុវត្តបានចំពោះជម្លោះប្រដាប់អាវុធពុំមែនអន្តរជាតិ) ពុំមានចែងអំពីបញ្ញត្តិស្តីពីទំនួលខុសត្រូវរបស់ថ្នាក់លើនោះពុំមែនជាការជំទាស់ទៅនឹងគោលការណ៍ទំនួលខុសត្រូវរបស់ថ្នាក់លើឡើយ។ ចំពោះអំណះអំណាងនេះ ក.ស.ព ពុំបានលើកយកអ្វីមកគាំទ្រឡើយ ក្រៅពីចង្អុលទៅកាន់សាលដីការបស់អង្គជំនុំជម្រះតុលាការឧទ្ធរណ៍ នៅក្នុងសំណុំរឿង *Hadzihasanovic* ត្រង់កថាខណ្ឌ ២៥១។ នៅក្នុងកថាខណ្ឌនេះ អង្គជំនុំជម្រះតុលាការឧទ្ធរណ៍បានសម្រេចថាគោលការណ៍ទំនួលខុសត្រូវរបស់ថ្នាក់លើ អាចយកមកអនុវត្តបានទៅលើជម្លោះប្រដាប់អាវុធពុំមែនអន្តរជាតិ។ មេធាវីការពារក្តីសូមយោងទៅលើសេចក្តីសន្និដ្ឋាន

---

[311] អនុសញ្ញានីមួយៗក្នុងចំណោមអនុសញ្ញាក្រុងហ្សឺណែវទាំងបួន មានមាត្រា១ដែលតម្រូវឲ្យរដ្ឋត្រូវតែអនុវត្តច្បាប់ជាតិ ដើម្បីផ្តន្ទាទោសព្រហ្មទណ្ឌដល់ជនទាំងឡាយណាដែលបានប្រព្រឹត្តអំពើបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ។ *សូមមើល* អនុសញ្ញាក្រុងហ្សឺណែវ I, មាត្រា ៤៩; អនុសញ្ញាក្រុងហ្សឺណែវ II, មាត្រា ៥០; អនុសញ្ញាក្រុងហ្សឺណែវ III, មាត្រា ២៩, អនុសញ្ញាក្រុងហ្សឺណែវ IV, មាត្រា ១៤៦។ អនុសញ្ញានីមួយៗចែងថា "រដ្ឋភាគីត្រូវចាត់វិធានការអនុវត្តច្បាប់ណាដែលចាំបាច់ដើម្បីផ្តន្ទាទោសព្រហ្មទណ្ឌឲ្យបានមានប្រសិទ្ធភាពចំពោះជនណាដែលបានប្រព្រឹត្ត ឬបញ្ជាឲ្យមានការប្រព្រឹត្តអំពើបំពារបំពានធ្ងន់ធ្ងរណាមួយលើអនុសញ្ញាបច្ចុប្បន្នដែលមានចែងក្នុងមាត្រាខាងក្រោម"។

[312] ពិធីសារបន្ថែមទៅនឹងអនុសញ្ញាទីក្រុងហ្សឺណែវ ថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ និងទាក់ទងនឹងការការពារជនរងគ្រោះដោយសារជម្លោះប្រដាប់អាវុធអន្តរជាតិ ថ្ងៃទី៨ ខែមិថុនា ឆ្នាំ១៩៧៧ ("ពិធីសារបន្ថែម II")។

របស់ខ្លួន នៅក្នុងបណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធនឹងវិការៈក្នុងសេចក្តីវិភាគរបស់អង្គជំនុំជម្រះតុលាការឧទ្ធរណ៍ក្នុងសំណុំរឿង Hadzihasanovic[313]។

### ៣. ទំនួលខុសត្រូវរបស់ថ្នាក់លើតម្រូវឱ្យមានទំនាក់ទំនងធម្មតាមួយរវាងឧក្រិដ្ឋកម្មជាមូលដ្ឋាន និងអំពើរបស់ថ្នាក់លើនៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩

១៣៣. ត្រង់កថាខណ្ឌ ២៥២ ក.ស.ព អះអាងថាតុលាការ ICTY និងតុលាការ ICTR បានយល់ឃើញស្របគ្នាថាគេអាចបញ្ជាក់ឱ្យឃើញអំពីទំនួលខុសត្រូវរបស់ថ្នាក់លើ ដោយពុំចាំបាច់មានភស្តុតាងបង្ហាញអំពីទំនាក់ទំនងធម្មតារវាងអំពើរបស់ជនជាប់ចោទ និងឧក្រិដ្ឋកម្មដែលមនុស្សក្រោមបង្គាប់បានប្រព្រឹត្តឡើយ។ ដូចអ្វីដែលមេធាវីការពារក្តីបានពន្យល់នៅក្នុងបណ្តឹងឧទ្ធរណ៍[314] បន្ទាប់ពីអង្គជំនុំជម្រះតុលាការឧទ្ធរណ៍នៃតុលាការICTY ក្នុងសំណុំរឿង Celebici បានវិភាគជាបឋមទៅលើបញ្ហានេះរួចមក អង្គជំនុំជម្រះក្រោយៗបានទទួលស្គាល់ការបកស្រាយរបស់អង្គជំនុំជម្រះតុលាការឧទ្ធរណ៍ ក្នុងសំណុំរឿង Celebici នេះដោយពុំមានធ្វើវិភាគណាមួយបន្ថែមទៀតទេ។ ខុសពីយុត្តិសាស្ត្ររបស់តុលាការមិនអចិន្ត្រៃយ៍ មាត្រា ២៨ នៃលក្ខន្តិកៈតុលាការ ICC តម្រូវឱ្យមានទំនាក់ទំនងមួយរវាងឧក្រិដ្ឋកម្មជាមូលដ្ឋាន និងអំពើរបស់ថ្នាក់លើនៅពេលពាក់ព័ន្ធ។ មាត្រា ២៨ នេះចែងថា "ថ្នាក់លើត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌលើឧក្រិដ្ឋកម្មទាំងប៉ុន្មាន ... ដែលមនុស្សក្រោមបង្គាប់បានប្រព្រឹត្តក្រោមសិទ្ធិអំណាច និងការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពរបស់ខ្លួន <u>ដោយសារបណ្តាលមកពី</u> ការពុំបានគ្រប់គ្រងឱ្យបានត្រឹមត្រូវលើមនុស្សក្រោមបង្គាប់របស់ខ្លួន..."។ លក្ខខណ្ឌតម្រូវឱ្យមានទំនាក់ទំនង ពិតជាមានចែងក្នុងច្បាប់នៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ប្រាកដមែន។ ប៉ុន្តែ ប្រសិនបើលក្ខខណ្ឌតម្រូវឱ្យមានទំនាក់ទំនងដែលមានក្នុងលក្ខន្តិកៈតុលាការ ICC នេះ គឺជាភស្តុតាងបញ្ជាក់អំពីដំណើរវិវឌ្ឍន៍ល្អប្រសើរក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិមែននោះ គេត្រូវយកច្បាប់ទំនៀមទម្លាប់អន្តរជាតិណាដែលអំណោយផលជាងគេដល់ជនជាប់ចោទ មកអនុវត្តដើម្បីឱ្យស្របតាមគោលការណ៍ *ភាពទន់ភ្លន់នៃច្បាប់ Lex mitior*[315]។

---

[313] *សូមមើល* បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣០៩-១៣។

[314] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ៣១៧។

[315] *ដូចជើងទំព័រខាងលើ*។

### ៤. ទំនួលខុសត្រូវរបស់ថ្នាក់លើ អាចពុំត្រូវបានយកមកអនុវត្តលើឧក្រិដ្ឋកម្មដែលមានចេតនាជាក់លាក់

១៣៤. ត្រង់កថាខណ្ឌ ២៥៥ ក.ស.ព អះអាងថា ក.ស.ច.ស បានអនុវត្តដោយត្រឹមត្រូវនូវគោលការណ៍ទំនួលខុសត្រូវរបស់ថ្នាក់លើចំពោះអំពើប្រល័យពូជសាសន៍ ដោយហេតុថាគេ "បានដឹង ឬមានហេតុផលក្នុងការដឹង" អំពី *ចេតនាឧក្រិដ្ឋ* ពាក់ព័ន្ធសម្រាប់ទំនួលខុសត្រូវរបស់ថ្នាក់លើ។ ក.ស.ព ពុំបញ្ជាក់ច្បាស់ថាតើខ្លួនយល់ឃើញថា ក.ស.ច.ស ពិតជាបានយកគោលការណ៍ទំនួលខុសត្រូវមកអនុវត្តដោយត្រឹមត្រូវ លើឧក្រិដ្ឋកម្មធ្វើទុក្ខបុកម្នេញដែលមានចេតនាជាក់លាក់ ក្នុងប្រភេទជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែរ ឬយ៉ាងណានោះទេ។ ក.ស.ព អះអាងថា ដោយហេតុថាតុលាការមិនអចិន្ត្រៃយ៍បានសម្រេចថាថ្នាក់លើអាចទទួលខុសត្រូវឧក្រិដ្ឋកម្ម ប្រល័យពូជសាសន៍ ដែលមានចេតនាជាក់លាក់ដែលមនុស្សក្រោមបង្គាប់បានប្រព្រឹត្ត ហើយច្បាប់ទំនៀមទម្លាប់អន្តរជាតិពុំមានចែងអំពីវិធានណាមួយខុសពីនេះ ទើបគេអាចយកទំនួលខុសត្រូវរបស់ថ្នាក់លើមកអនុវត្តលើបទប្រល័យពូជសាសន៍នៅ អ.វ.ត.ក។ ក.ស.ព ពុំបានបង្ហាញឯកសារសំអាងផ្លូវច្បាប់ណាមួយដើម្បីគាំទ្រអំណះអំណាងរបស់ខ្លួន ដែលថាច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ពុំបានហាមឃាត់ការយកគោលការណ៍ទំនួលខុសត្រូវរបស់ថ្នាក់លើមកអនុវត្តលើឧក្រិដ្ឋកម្ម ដែលមានចេតនាជាក់លាក់ឡើយ ក្រៅពីការសំអាងតែម្យ៉ាងទៅលើទម្លាប់អនុវត្តន៍របស់តុលាការមិនអចិន្ត្រៃយ៍ក្នុងទសវត្សរ៍ឆ្នាំ១៩៩០។ ការដែលថាទស្សនទានស្ដីពីទំនួលខុសត្រូវរបស់ថ្នាក់លើ ក. កើតចេញពីកាតព្វកិច្ចរបស់មេបញ្ជាការក្នុងការហាមឃាត់មិនឲ្យទ័ពរបស់ខ្លួនរំលោភច្បាប់ និងទំនៀមទម្លាប់សង្គ្រាម និង ខ. ដែលថាការចងក្រងជាច្បាប់របស់គោលការណ៍នេះជាលើកដំបូង គឺពាក់ព័ន្ធទៅនឹងអំពើបំពារបំពានលើអនុសញ្ញាក្រុងហ្សឺណែវ និងពិធីសារបន្ថែមI គាំទ្រដល់ការសន្និដ្ឋានថា ក្នុងលក្ខណៈជាទិដ្ឋភាពមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ គោលការណ៍នេះពុំអាចយកមកអនុវត្តបានឡើយលើឧក្រិដ្ឋកម្មដទៃទៀត ដូចជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដែលមានចេតនាជាក់លាក់ និងការធ្វើទុក្ខបុកម្នេញ ក្នុងប្រភេទជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។

**ហេតុដូច្នេះ** តាមហេតុផលដូចដែលបានរៀបរាប់ខាងលើ និងហេតុផលក្នុងបណ្តឹងឧទ្ធរណ៍ មេធាវីការពារក្តី សូមគោរពស្នើសុំឲ្យអង្គបុរេជំនុំជម្រះមេត្តាទទួលយកបណ្តឹងឧទ្ធរណ៍ និងដោះស្រាយតាមសំណើនានាដែលបាន ស្នើសុំ។

សូមអង្គបុរេជំនុំជម្រះមេត្តាទទួលនូវការគោរពដ៏ស្ម័គ្រស្មោះអំពីយើងខ្ញុំ។

អាង ឧត្តម Michael G. KARNAVAS

សហមេធាវីរបស់លោក អៀង សារី

ធ្វើនៅភ្នំពេញ ថ្ងៃទីxx ខែធ្នូ ឆ្នាំ២០១០